ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# (២០១៤-២០១៨)




រៀបចំដោយ

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេស

លើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ



រាជធានីភ្នំពេញ ខែ មេសា ឆ្នាំ២០១៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# (២០១៤-២០១៨)



**រៀបចំដោយ**

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

**ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេស**

**លើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ**

រាជធានីភ្នំពេញ ខែ មេសា ឆ្នាំ២០១៤

# អារម្ភកថា

សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ត្រូវបានទទួលស្គាល់និងចាត់ទុកជាសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ន។ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អាទិភាពខ្ពស់ និងបានចាត់ទុកវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាបញ្ហាអន្តរវិស័យមួយដ៏មានសារៈសំខាន់ ក្នុងចូលរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ចកម្ពុជា។ ការលើកឡើងនេះ មានគូសបញ្ជាក់នៅក្នុងសន្ទរកថា ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងឱកាសបើកសិក្ខាសាលាជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក្រោមប្រធានបទ “**អាហារូបត្ថម្ភរបស់កុមារ និងមាតា**” ដែលប្រារព្ធធ្វើឡើងកាលពីខែឧសភាឆ្នាំ២០១២។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា÷ ***ដំណោះស្រាយពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មិនត្រឹមតែជាការឆ្លើយតបទៅនឹងគោលនយោបាយ ជាអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញកន្លងមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជន ការដោះស្រាយនូវទុក្ខលំបាក ការលើកស្ទួយកម្រិតជីវភាពរស់នៅ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនទៀតផង។*** ទន្ទឹមនោះ បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានរាជរដ្ឋាភិបាល ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)ផងដែរ។

បញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ គឺជាបញ្ហាអន្តរវិស័យ ដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាល បានដើរតួនាទីសម្របសម្រួលវិស័យនេះ តាំងពីឆ្នាំ១៩៩៩ រហូតមកទល់នឹងបច្ចុប្បន្ន។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ គឺជាប្រធាន **ក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** (TWG-SP&FSN) ដែលត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើង ក្នុងគោលដៅសម្របសម្រួល រៀបចំ និងដឹកនាំអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានា ទាក់ទងទៅនឹងវិស័យគាំពារសង្គមនិងសន្តិសុខស្បៀងអាហារូបត្ថម្ភនិងធ្វើតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តវិស័យទាំងនេះ។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ(២០១៤-២០១៨)** បានកំណត់នូវគោលបំណងចំនួន ៣ ÷ (១).ធានាថាគ្រួសារកម្ពុជា ផលិតបានស្បៀង និងទទួលបានស្បៀងដែលមានអាហារូបត្ថម្ភ តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វដែលមានលក្ខណៈចម្រុះ និងមានផលិតភាពខ្ពស់ជាងមុន, ការប្រើប្រាស់ធនធានជលផលនិងព្រៃឈើប្រកបដោយនិរន្តរភាព, និងការងារក្រៅពីកសិកម្ម ព្រមទាំងឱកាសទទួលបានប្រាក់ចំណូលផ្សេងៗ។ (២).កាត់បន្ថយនូវកង្វះអាហារូបត្ថម្ភរបស់មាតានិងកុមារ តាមរយៈការពង្រីកសេវាកម្មជាក់លាក់សម្រាប់អាហារូបត្ថម្ភ និងការអប់រំអំពីអាហារូបត្ថម្ភ, ការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកស្អាត និងការអនុវត្តន៍អនាម័យនៅក្នុងមូលដ្ឋាន,ការដាក់បញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ, ការលើកកម្ពស់ការមានស្បៀង និងការប្រើប្រាស់ស្បៀងអាហារ ប្រកបដោយអាហារូបត្ថម្ភ និងមានសុវត្ថិភាពនៅកម្រិតសហគមន៍ និងកម្រិតគ្រួសារ ,ការប្រើប្រាស់ឧបករណ៍គាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ ។ (៣).ការ

កែលម្អស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀងក្នុងពេលជួបនឹងវិបត្តិនានា តាមរយៈការប្រើប្រាស់ឧបករណ៍គាំពារសង្គម និងពង្រឹងសមត្ថភាពរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងការឆ្លើយតបទៅនឹងហានិភ័យគ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចឱ្យបាននូវគោលបំណងខាងលើ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ មានកិច្ចការជាច្រើនត្រូវរួមគ្នាអនុវត្ត ជាពិសេសអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព តម្លាភាព និងគណនេយ្យភាព ដើម្បីឈានទៅសម្រេចបាននូវគោលដៅលុបបំបាត់ភាពក្រីក្រ និងអសន្តិសុខស្បៀង, កាត់បន្ថយមរណភាពរបស់កុមារ និងកែលម្អសុខភាពមាតា តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស និងការកៀរគរធនធានហិរញ្ញវត្ថុពីបណ្តាស្ថាប័ននិងដៃគូអភិវឌ្ឍន៍, ការអនុវត្តឱ្យបានសកម្មនូវបណ្តាសកម្មភាពជាអាទិភាពនានា និងការប្រែក្លាយផែនការសកម្មភាពទាំងនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែងនៅមូលដ្ឋាន។

ក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង-ស្ថាប័នពាក់ពន្ធ័ ដៃគូអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិនានា ដែលជាសមាជិកក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលបានរួមចំណែកយ៉ាងសកម្មផ្តល់ធាតុចូលដល់ការរៀបចំ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ(២០១៤-២០១៨)** ដែលធ្វើឱ្យយុទ្ធសាស្ត្រនេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៅកម្ពុជា។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អង្គការស្បៀងអាហារពិភពលោក (WFP) ប្រចាំកម្ពុជា ដែលបានធ្វើការសម្របសម្រួលភាគីដៃគូអភិវឌ្ឍន៍នានា, អង្គការយូនីសេហ្វ (UNICEF) ប្រចាំកម្ពុជា ដែលបានផ្តល់ការគាំទ្រថវិកាមួយចំនួនសម្រាប់បោះពុម្ព និងសូមថ្លែងអំណរគុណផងដែរ ដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់ថវិកាតាមរយៈអង្គការសម្ពន្ធ័សុខភាពកុមារនិងសុខភាពបន្តពូជ (RACHA) សម្រាប់រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រនេះឡើងក្នុងឆ្នាំ២០១៣ និងសូមថ្លែងអំណរគុណដល់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ (FAO) ដែលបានផ្តល់ថវិកាសម្រាប់រៀបចំបញ្ចប់សេចក្តីព្រាងយុទ្ធសាស្ត្រនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**

វេជ្ជបណ្ឌិត **យឹម ឆៃលី**

# មាតិកា


**អារម្ភកថា** ........ I

**មាតិកា** ........ III

**បញ្ជីរាយនាមអក្សរកាត់** ........ V

**បញ្ជីរាយនាមរូបភាព (រាប់បញ្ចូលក្រាហ្វិកតារាង និងផែនទី)** ........ IV

**សេចក្តីសង្ខេប** ........ ១

**១. សេចក្តីផ្តើម** ........ ៧

១.១. សាវតានិងប្រវត្តិនៃការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........ ៧

១.២. ក្របខ័ណ្ឌគោលគំនិតនិងវិសាលភាពនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ........ ៩

១.៣. ដំណើរការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........ ១៤

**២. ស្ថានភាពបច្ចុប្បន្ននៃសន្តិសុខស្បៀងនិង អាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា** ........ ១៥

២.១. ការវាយតម្លៃសន្តិសុខស្បៀងកម្រិតម៉ាក្រូ ........ ១៥

២.២.ការវាយតម្លៃសន្តិសុខស្បៀងកម្រិតគ្រួសារនិងបញ្ហាប្រឈមនាពេលថ្មីៗ ........ ១៧

២.៣. ការវាយតម្លៃអាហារូបត្ថម្ភកុមារនិងមាតា ........ ២៧

២.៤. សេចក្តីសន្និដ្ឋានពីការវិភាគស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ........ ៣៦

**៣. គោលនយោបាយ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការរៀបចំបង្កើតស្ថាប័ន** ........ ៣៩

៣.១. សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងគោលនយោបាយនិងផែនការរួមរបស់កម្ពុជា ........ ៣៩

៣.២. សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយអន្តរវិស័យនានា ........ ៤៣

៣.៣. កម្មវិធីនិងគម្រោងថ្នាក់ជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ........ ៤៧

៣.៤. ការរៀបចំបង្កើតស្ថាប័នសម្រាប់ការសម្របសម្រួលដែលទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ........ ៤៩

**៤. បញ្ហាប្រឈម ចន្លោះប្រហោង និងអាទិភាពកម្មវិធី** ........ ៥២

៤.១. បញ្ហាប្រឈមចម្បងៗនិងចន្លោះប្រហោងដែលមានស្រាប់ទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ........ ៥២

៤.២. អាទិភាពកម្មវិធីរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ២០១៤-២០១៨ ........ ៦២

**៥. យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ២០១៤-២០១៨ ចក្ខុវិស័យ គោលដៅ និងគោលបំណង (ទិដ្ឋភាពទូទៅ)** ........ ៦៥

**៦. គោលបំណង និងសកម្មភាពអាទិភាពរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨** ........ ៧៤

៦.១. គោលបំណងទី១ ៖បង្កើនការមានស្បៀងនិងការទទួលបានស្បៀង........ ៧៤

៦.១.១. លើកកម្ពស់ពិពិធកម្មនិងសមាហរណកម្មទីផ្សារនៃការធ្វើកសិកម្មរបស់កសិករខ្នាតតូច ........ ៧៦

៦.១.២. លើកកម្ពស់ការបែងចែកដីនិងការផ្តល់ប័ណ្ណកម្មសិទ្ធិដីជូនដល់គ្រួសារក្រីក្រ........ ៨១

៦.១.៣. ធ្វើឱ្យប្រសើរឡើងនូវការទទួលបាននិងការប្រើប្រាស់ធនធានជលផលនិងព្រៃឈើប្រកបដោយនិរន្តរភាព ........ ៨២

៦.១.៤. លើកកម្ពស់ឱកាសការងារនិងឱកាសទទួលបានប្រាក់ចំណូលសម្រាប់ជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង........ ៨៥

៦.២. គោលបំណងទី២ ៖ការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់និងការបឺតស្រូបស្បៀងអាហារ ........ ៨៩

៦.២.១. ពង្រីកសេវានិងការអប់រំអំពីអាហារូបត្ថម្ភ ........ ៩២

៦.២.២. ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពក្នុងមូលដ្ឋាន និងការអនុវត្តអនាម័យ........ ៩៦

៦.២.៣. ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ........ ៩៨

៦.២.៤. បង្កើនការមានស្បៀងនិងការប្រើប្រាស់ស្បៀងឱ្យបានសមស្របនៅកម្រិតគ្រួសារ........ ១០០

៦.២.៥. ការប្រើប្រាស់ឧបករណ៍គាំពារសង្គមដើម្បីលើកកម្ពស់អាហារូបត្ថម្ភ........ ១០០

៦.២.៦. អភិវឌ្ឍន៍និងអនុវត្តន៍កម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ ........ ១០១

៦.៣. គោលបំណងទី៣ ៖ការបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង........ ១០៣

៦.៣.១. ពង្រីកសំណាញ់សុវត្ថិភាពសង្គមលើផ្នែកសន្តិសុខស្បៀង ........ ១០៤

៦.៣.២. ធ្វើឱ្យប្រសើរឡើងនូវភាពបន្សាំរបស់គ្រួសារទៅនឹងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ ........ ១០៧

**៧. ការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ**........ ១១៣

៧.១. ការសម្របសម្រួលនិងការឃ្លាំមើលទៅលើគោលនយោបាយសម្រាប់បញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ... ១១៣

៧.២. ការត្រួតពិនិត្យនិងវាយតម្លៃទៅលើយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ........ ១១៧

៧.៣. ការគ្រប់គ្រងចំណេះដឹងនិងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ........ ១២១

៧.៤. ការអភិវឌ្ឍន៍សមត្ថភាព ........ ១២៦

៧.៥. ការជ្រើសរើស និងការកំណត់គោលដៅអ្នកទទួលផល ........ ១២៩

៧.៦. ជំហានបន្តដើម្បីរៀបចំត្រៀមលក្ខណៈសម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ..... ១៣១


**ឧបសម្ព័ន្ធ**


១. ក្របខ័ណ្ឌសូចនាករយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨

២. ទិដ្ឋភាពទូទៅអំពីការវិនិយោគទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា

# បញ្ជីពាក្យអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CAS | ការអង្កេតមនុស្សសាស្ត្រនៅកម្ពុជា (២០០៨) |
| CBHI | ការធានារ៉ាប់រងសុខភាពតាមសហគមន៍ |
| CBNP | កម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ |
| CC | ក្រុមប្រឹក្សាឃុំ |
| CCSP | ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| CCT | ការផ្ទេរសាច់ប្រាក់មានលក្ខខណ្ឌ |
| CCWC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| CDCF | វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CDHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា |
| CDM | យន្តការអភិវឌ្ឍន៍ស្អាត |
| CDP/CIP | ផែនការអភិវឌ្ឍន៍ឃុំ/ផែនការវិនិយោគឃុំ |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CFW | កម្មវិធីសាច់ប្រាក់ពលកម្ម |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CNIP | ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា |
| CPI | សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ |
| CPRs | ធនធានទ្រព្យសម្បត្តិរួម |
| CRC | កាកបាទក្រហមកម្ពុជា |
| CSES | ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា |
| EFAP | គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| EU-FF | មូលដ្ឋានស្បៀងរបស់សហភាពអឺរ៉ុប |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| FDI | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FNPP/FMPP | កម្មវិធីភាពជាដៃគូរវាងអង្គការ FAO និងប្រទេសហូល្លង់/កម្មវិធីភាពជាដៃគូពហុម្ចាស់ជំនួយនៃអង្គការ FAO |
| FFW | កម្មវិធីស្បៀងពលកម្ម |

| | |
|---|---|
| FSN | សន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| FSNIMTF | ក្រុមការងារគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀងអាហារូបត្ថម្ភ |
| FSNIS | ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| GAFSP | កម្មវិធីកសិកម្ម និងសន្តិសុខស្បៀងសកល |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GIZ | អង្គការជីអាយហ្សិត |
| HARVEST | កម្មវិធីជួយដោះស្រាយភាពងាយរងគ្រោះនៅជនបទ និងស្ថេរភាពប្រព័ន្ធអេកូឡូស៊ី |
| HEF | មូលនិធិសមធម៌សុខភាព |
| HKI | អង្គការ Helen Keller International |
| HSSP | កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល |
| ID Poor | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IEC | ព័ត៌មាន ការអប់រំ និងទំនាក់ទំនង |
| IFAD | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម |
| IFPRI | វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ |
| IMCI | សមាហរណកម្មទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ |
| IPC | ការបែងចែកចំណាត់ថ្នាក់ដំណាក់កាលសមាហរណកម្មសន្តិសុខស្បៀង |
| IYCF | ការចិញ្ចឹមទារក និងកុមារតូច |
| LASED | កម្មវិធីបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MDER | តម្រូវការថាមពលអាហារអប្បបរមា |
| M&E | ការត្រួតពិនិត្យ និងវាយតម្លៃ |
| MDG-F JP | មូលនិធិគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ - កម្មវិធីសហការអនុវត្តលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភកុមារ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoE | ក្រសួងបរិស្ថាន |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| | |
|---|---|
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoP | ក្រសួងផែនការ |
| MoSAVYR | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | ក្រសួងកិច្ចការនារី |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAPA | កម្មវិធីសកម្មភាពជាតិបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការងារវិមជ្ឈការ និងវិសហមជ្ឈការ |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCN | ក្រុមប្រឹក្សាជាតិអាហារូបត្ថម្ភ |
| NFSF | វេទិកាជាតិសន្តិសុខស្បៀង |
| NFSTF | ក្រុមការងារថ្នាក់ជាតិទទួលបន្ទុកសន្តិសុខស្បៀង |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NNP | កម្មវិធីជាតិអាហារូបត្ថម្ភ |
| NP-SNDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NSCFF | អនុគណៈកម្មាធិការជាតិទទួលបន្ទុកការងារបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ |
| NSCIDD | អនុគណៈកម្មាធិការជាតិទទួលបន្ទុកវិបត្តិកង្វះជាតិអ៊ីយ៉ូដ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSFSN | យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ |
| FSNDAT | ក្រុមវិភាគទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| FSNIMTF | ក្រុមការងារគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| NSPS | យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា |
| PWP | កម្មវិធី សំណង់សាធារណៈ |
| RACHA | សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ |
| REED | ការកាត់បន្ថយការបំភាយឧស្ម័នពីការបំផ្លាញព្រៃឈើ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS | យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា |
| RWSSHS | យុទ្ធសាស្ត្រផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |
| SAM | កង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ |
| SAW | យុទ្ធសាស្ត្រវិស័យកសិកម្ម និងទឹក ២០០៦-២០១០ |

| | |
|---|---|
| SFFSN | ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SP | គាំពារសង្គម |
| SSN | សំណាញ់សុវត្ថិភាពសង្គម |
| SUN | ការពង្រឹកអាហារូបត្ថម្ភ |
| SRI | ប្រព័ន្ធប្រពលវប្បកម្មស្រូវ |
| ToT | លំក្ខខ័ណ្ឌនៃប្រាក់កម្រៃការងារ |
| TVET | ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| TWG-SP&FSN | ក្រុមការងារបច្ចេកទេសស្តីពី គាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| WASH | កម្មវិធីទឹកសុវត្ថិភាព និងអនាម័យ |
| WB | ធនាគារពិភពលោក |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |

# បញ្ជីរាយនាមរូបភាព


រូបភាពទី១ ៖ គោលគំនិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ.......................................... ៩

រូបភាពទី២ ៖ កម្រិតទាំង៣នៃសន្តិសុខស្បៀង........................................................... ១១

រូបភាពទី៣ ៖ វដ្តនៃភាពក្រីក្រ និងអសន្តិសុខស្បៀង.....................................................១៣

រូបភាពទី៤ ៖ វិសាលភាពនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ........................................................................................ ១៤

រូបភាពទី៥ ៖ និន្នាការនៃអតិរេកផលិតកម្មស្រូវអង្ករជាតិ ពីឆ្នាំ២០០៦-២០១២ ................ ១៦

រូបភាពទី៦ ៖ តារាងតុល្យការស្តីពីស្បៀងអាហារកម្ពុជា ២០១២/២០១៣ គិតជាតោន ....... ១៦

រូបភាពទី៧ ៖ កំណើន GDP ១៩៩៤-២០១៣ (តម្លៃថេរ ២០១០) ................................. ១៨

រូបភាពទី៨ ៖ ការអភិវឌ្ឍន៍អត្រាភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ២០០៧-២០១១ (ប្រើប្រាស់ខ្សែបន្ទាត់ភាពក្រីក្រថ្មី) ......................................................២១

រូបភាពទី៩ ៖ ភាគរយនៃប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ និងខ្សែបន្ទាត់នៃភាពក្រីក្រ ស្បៀងអាហារ ឆ្នាំ២០១១................................២១

រូបភាពទី១០ ៖ ភាគរយនៃការប្រើប្រាស់ស្បៀងអាហារ និង តម្លៃផលធៀបវិសមភាព នៅកម្ពុជា .........................................................២២

រូបភាពទី១១ ៖ ការអភិវឌ្ឍន៍តម្លៃអង្ករចន្លោះពីខែមករា ឆ្នាំ២០០៧ និងខែមេសា ឆ្នាំ២០១៣ ....២២

រូបភាពទី១២ ៖ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ចំពោះតម្លៃសម្រាប់អ្នកប្រើប្រាស់តម្លៃស្បៀង អាហារ និងតម្លៃសម្ភារៈដែលមិនមែនជាស្បៀងអាហារ ចាប់ពីខែមករាឆ្នាំ២០០៧ ដល់ ខែមេសាឆ្នាំ២០១៣................................២៣

រូបភាពទី១៣ ៖ ល័ក្ខខ័ណ្ឌនៃប្រាក់កម្រៃការងារនៅទីជនបទសម្រាប់ពលករគ្មានជំនាញ និងតម្លៃអង្ករលក់រាយនៅទីជនបទ .........................................................២៤

រូបភាពទី១៤ ៖ ភាគរយនៃការទទួលទានថាមពលចំណីអាហារពីម៉ាក្រូជីវជាតិ ដោយយោង ទៅតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក................................២៦

រូបភាពទី១៥ ៖ និន្នាការនៃសូចនាករភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភ (២០០០-២០១១).....២៧

រូបភាពទី១៦ ៖ និន្នាការនៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ ចាប់ពីឆ្នាំ២០០០-២០១០..................................................................២៨

រូបភាពទី១៧ ៖ ផែនទីអំពីអត្រាប្រេវ៉ាឡង់តំបន់ចំពោះបញ្ហាក្រេះគ្រិន និងស្គមស្គាំង ក្នុងចំណោមកុមារអាយុ ក្រោម៥ឆ្នាំ (CDHS ២០១០) ...............................៣០

រូបភាពទី១៨ ៖ កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារបែងចែកទៅតាមទ្រព្យសម្បត្តិការបន្ទោបង់ ពាសវាលពាសកាល ការអប់រំរបស់ម្តាយនិងការបំបៅដោះម្តាយ .................៣២

រូបភាពទី១៩ ៖ សូចនាករដែលទាក់ទងទៅនឹងកង្វះអាហារូបត្ថម្ភកុមារ នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០, ២០០៥, ២០១០ (គិតជាភាគរយ)........................................ ៣៣
រូបភាពទី២០ ៖ អត្រាមរណៈរបស់ទារក និងកុមារអាយុក្រោម៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០ , ២០០៥, ២០១០ ........................................................... ៣៤
រូបភាពទី២១ ៖ និន្នាការនៃសូចនាករកង្វះអាហារូបត្ថម្ភរបស់ស្ត្រី(១៥-៤៩ឆ្នាំ) ពីឆ្នាំ២០០០-២០១០ ......................................................................... ៣៥
រូបភាពទី២២ ៖ ភាពស្លេកស្លាំងនៅក្នុងចំណោមស្ត្រី បែងចែកទៅតាមក្រុមសមធម៌ ............. ៣៥
រូបភាពទី២៣ ៖ ការប្រៀបធៀបរវាងតំបន់ចំពោះអត្រាកង្វះអាហារូបត្ថម្ភ និងអត្រាមរណៈរបស់កុមារ................................................................. ៣៦
រូបភាពទី២៤ ៖ ការភ្ជាប់ FSNទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ....................... ៤០
រូបភាពទី២៥ ៖ ទិដ្ឋភាពទូទៅអំពីគោលនយោបាយយុទ្ធសាស្ត្រនិងផែនការជាតិចម្បងៗ ដែលទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ............................... ៤៥
រូបភាពទី២៦ ៖ ការតម្រឹមយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅនឹងយុទ្ធសាស្ត្រ និងផែនការដែលមានស្រាប់ដទៃទៀត ......................... ៤៦
រូបភាពទី២៧ ៖ ទិដ្ឋភាពរួមរបស់ស្ថាប័នចំពោះបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា ....................................................................... ៥១
រូបភាពទី២៨ ៖ ទិដ្ឋភាពទូទៅអំពីបញ្ហាប្រឈម វឌ្ឍនភាពដែលសម្រេចបាន និងចន្លោះប្រហោងដែលនៅសេសសល់.................................................៥៣
រូបភាពទី២៩ ៖ អាទិភាពកម្មវិធីរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ..៦៣
រូបភាពទី៣០ ៖ គោលបំណង អាទិភាពកម្មវិធី និងសកម្មភាពអាទិភាពរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ.............................................៦៧
រូបភាពទី៣១ ៖ ការផលិតស្រូវ និងទិន្នផល ឆ្នាំ២០០០-២០១២ ...................................... ៧៧
រូបភាពទី៣២ ៖ វិស័យអាទិភាពសម្រាប់គោលបំណងទី២ ................................................ ៩២
រូបភាពទី៣៣ ៖ ស្ថេរភាពនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ យុទ្ធសាស្ត្រអន្តរាគមន៍ ដើម្បីកាត់បន្ថយហានិភ័យ ................................................................ ១០៣
រូបភាពទី៣៤ ៖ តំបន់ស្រូវវស្សា ដែលត្រូវបានបំផ្លាញដោយ ទឹកជំនន់ និងគ្រោះរាំងស្ងួត ២០០១-២០១១......................................................................... ១០៨
រូបភាពទី៣៥ ៖ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការត្រួតពិនិត្យ និងវាយតម្លៃ និងអភិក្រមផែនការពង្រីក ........................... ១២១

# សេចក្តីសង្ខេប

សិក្ខាសាលាថ្នាក់ជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អាណត្តិការងារក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ឱ្យធ្វើការសម្របសម្រួលដល់ការរៀបចំយុទ្ធសាស្រ្តសន្តិសុខស្បៀងមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចយកមកអនុវត្តបាននៅប្រទេសកម្ពុជា។ **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ២០១៤-២០១៨** ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា។ **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នឹងបំពេញបន្ថែមទៅលើក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០០៨-២០១៣ និងលទ្ធផលនៃការត្រួតពិនិត្យឡើងវិញទៅលើក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ ក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២។

ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភមានការពាក់ព័ន្ធចំពោះការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ហើយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាអាទិភាពមួយដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានលើកឡើងនៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រដ្ឋាភិបាល ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP 2014-2018) និងត្រូវបានទទួលស្គាល់ថាជាអាទិភាពនៅក្នុងគោលនយោបាយ និង ផែនការតាមវិស័យជាច្រើន។

**យុទ្ធសាស្រ្តស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** តម្រូវឱ្យមានអភិក្រមពហុវិស័យ និងសមាហរណកម្មមួយ ដែលគ្របដណ្តប់ទៅលើប្រធានបទអភិវឌ្ឍន៍ដ៏ទូលំទូលាយ។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ យុទ្ធសាស្រ្តគោលនយោបាយ និងការវិនិយោគនៅក្នុងវិស័យៈ កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ការគ្រប់គ្រងធនធានទឹក សុខភាព ទឹកនិងអនាម័យ អប់រំ និងកិច្ចគាំពារសង្គម សុទ្ធសឹងតែមានសារសំខាន់។ **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ត្រូវបានរៀបចំឡើង ដើម្បីបំពេញបន្ថែមដល់យុទ្ធសាស្រ្ត និង ផែនការតាមវិស័យដែលមានស្រាប់ សំដៅបំពេញចន្លោះប្រហោងនានា និងជាមូលដ្ឋានមួយសម្រាប់ការធ្វើសកម្មភាពអន្តរវិស័យរួមគ្នា ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ វិសាលភាពរបស់ **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** មានភាពទូលំទូលាយ ដោយរួមមានសកម្មភាពជាអាទិភាពដែលគ្របដណ្តប់ទៅលើរាល់ទិដ្ឋភាពទាំង៤របស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺៈ (ការមានស្បៀង ការទទួលបានស្បៀង ការប្រើប្រាស់ស្បៀង និងការបឺតស្រូបស្បៀង ព្រមទាំងស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង)។ **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** កំណត់កម្មវិធីអាទិភាព និងសកម្មភាពអាទិភាព ដោយផ្អែកលើការវិភាគទៅលើស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅកម្រិតថ្នាក់ជាតិ គ្រួសារ និងបុគ្គល ព្រមទាំងរៀបចំពង្រឹងស្ថាប័នដែលចាំបាច់ ដើម្បីធ្វើឱ្យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានភាពប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេល ៥ឆ្នាំបន្ទាប់ (២០១៤-២០១៨)។

ការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា បានបង្ហាញឱ្យឃើញអំពីការសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងទសវត្សរ៍ចុងក្រោយនេះ។ ប្រទេសកម្ពុជា គឺជាប្រទេសដែលផលិតស្រូវអង្ករដោយខ្លួនឯងបានគ្រប់គ្រាន់ ព្រមជាមួយនឹងអតិរេកអង្ករចំនួនជាង ៣លានតោន ក្នុងឆ្នាំ២០១៣ ហើយកំពុងក្លាយខ្លួនទៅជាប្រទេសដែលនាំចេញអង្ករដ៏សំខាន់នៅក្នុងតំបន់។ ស្បៀងអាហារមាននៅទូទាំងប្រទេស ហើយទីផ្សារត្រូវបានធ្វើសមាហរណកម្មយ៉ាងល្អប្រសើរ។ ដូច្នេះនៅកម្រិតថ្នាក់ជាតិ ប្រទេសកម្ពុជាសម្រេចបានសមិទ្ធផលគួជាទីមោទនៈនិងមានសន្តិសុខស្បៀង (ភាពដែលមាន)គ្រប់គ្រាន់ និងលើសសេចក្តីត្រូវការ។

ផ្អែកលើអត្រាកាត់បន្ថយភាពក្រីក្រដ៏គួរឱ្យចាប់អារម្មណ៍ ដែលមានកម្រិត៤៧,៨% ក្នុងឆ្នាំ២០០៧ មកត្រឹម១៨,៨% ក្នុងឆ្នាំ២០១៣ និងការកាត់បន្ថយអសមធម៌នៃការទទួលទានអាហារលទ្ធភាពក្នុងការទទួលបានស្បៀងអាហាររបស់គ្រួសារ និងការទទួលទានអាហារជាទូទៅ បានមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បើទោះបីជាបន្តមានភាពខុសគ្នានៅតាមតំបន់ និងក្រុមសង្គមមួយចំនួនក៏ដោយ។ ប្រជាពលរដ្ឋកម្ពុជានៅតែប្រឈមមុខទៅនឹងឧបសគ្គ ជាច្រើន ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើសន្តិសុខស្បៀងរបស់គ្រួសារ ដូចជាៈ ផលិតភាព និង ពិពិធកម្មកសិកម្មនៅមានកម្រិតទាប ការទទួលបាន និងការប្រើប្រាស់ធនធានព្រៃឈើ និងជលផលនៅមានកម្រិត និងគ្មាននិរន្តរភាព ប្រជាពលរដ្ឋជនបទភាគច្រើនគ្មានដី និងកង្វះការងារ ព្រមទាំងឱកាសទទួលបានប្រាក់ចំណូល ជាពិសេសនៅតំបន់ជនបទ។ ដូចស្តែងឱ្យឃើញតាមរយៈវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចលើកចុងក្រោយ ស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀងអាហារសម្រាប់ជនក្រីក្រ និងជនដែលរស់នៅក្បែរខ្សែបន្ទាត់ភាពក្រីក្រ ងាយទទួលរងនូវវិបត្តិផ្ទាល់ខ្លួន និងវិបត្តិពីខាងក្រៅមួយចំនួនដែលទាក់ទងទៅនឹងកត្តាសង្គមសេដ្ឋកិច្ច និងគ្រោះមហន្តរាយធម្មជាតិ។ ការបង្កើនសមត្ថភាពរបស់ក្រុមងាយរងគ្រោះសម្រាប់ដោះស្រាយបញ្ហា តាមរយៈការពង្រីកសំណាញ់សុវត្ថិភាពសង្គម និងការធ្វើឱ្យប្រសើរឡើងនូវយន្តការត្រៀមទប់ទល់ និងកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះមហន្តរាយ (រាប់បញ្ចូល ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ) នៅតែបន្តជាបញ្ហាប្រឈមមួយនៅពេលអនាគត។

ភាពប្រសើរឡើងនៃការទទួលទានអាហារ ពុំមានន័យជាស្វ័យប្រវត្តិថាៈ មានភាពប្រសើរឡើងចំពោះ អាហារូបត្ថម្ភកុមារ និងមាតាឡើយ អាស្រ័យដោយរបបអាហារចម្រុះ និងគុណភាពនៃអាហារ ការបែងចែកអាហារនៅក្នុងគ្រួសារ ការប្រព្រឹត្តដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ សមត្ថភាពរបស់អ្នកថែទាំកុមារ ទឹកមានសុវត្ថិភាព អនាម័យ ព្រមទាំងការទទួលបានសេវាសុខភាព សុទ្ធសឹងតែជាកត្តាដែលបង្កឱ្យប៉ះពាល់ដល់ស្ថានភាពអាហារូបត្ថម្ភ។ អត្រាមរណៈរបស់កុមារ និងមាតា ព្រមទាំងសូចនាករមួយចំនួនដែលទាក់ទងទៅនឹងអាហារូបត្ថម្ភរបស់កុមារ និងមាតា មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់នៅចន្លោះ ឆ្នាំ២០០០ និង ២០១០។ បើទោះជាដូច្នេះក្តី កង្វះអាហារូបត្ថម្ភជាទូទៅរបស់កុមារ និងមាតា ពុំបានធ្លាក់ចុះឡើយ ចាប់តាំងពីឆ្នាំ២០០៥មក។ ក្នុងឆ្នាំ២០១០ កុមារអាយុក្រោម៥ឆ្នាំប្រមាណជិត ៤០% មានបញ្ហាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃនិងស្ត្រីប្រមាណ ២០% ខ្វះអាហារូបត្ថម្ភដែលនេះ គឺជាកម្រិតមួយដ៏ខ្ពស់ដែលមិនអាចទទួលយកបាន។ កង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ

និងមាតា មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ទៅតាមតំបន់ និងក្រុមសង្គម។ ប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទ ជនក្រីក្រ និងជនដែលពុំបានទទួលការអប់រំ មានឱកាសខ្ពស់ជាង ក្នុងការប្រឈមទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភ បើធៀបទៅនឹងប្រជាពលរដ្ឋដែលរស់នៅតំបន់ទីក្រុង អ្នកមាន និងអ្នកដែលមានការអប់រំ ដែលចំណុចនេះ ទាមទារឱ្យមាន អន្តរាគមន៍ដែលកំណត់គោលដៅ និងធ្វើសមាហរណកម្មឱ្យបានល្អប្រសើរ។ កង្វះអាហារូបត្ថម្ភពេលដែលកុមារនៅតូច បង្កឱ្យមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់កុមារនោះអស់មួយជីវិត អាស្រ័យដោយកត្តាកង្វះអាហារូបត្ថម្ភ នាំឱ្យកុមារចុះខ្សោយនូវការអភិវឌ្ឍបញ្ញាញាណ និងជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សា ដែលចំណុចទាំងនេះបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ការបង្កើតមូលធនមនុស្ស ផលិតភាព និងកំណើនសេដ្ឋកិច្ចរបស់ប្រទេស។ ថ្លៃចំណាយផ្នែកសង្គម និងសេដ្ឋកិច្ចចំពោះបញ្ហាកង្វះអាហារូបត្ថម្ភមានតម្លៃខ្ពស់ ដោយឡែកការវិនិយោគ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្ហាញឱ្យឃើញថាផ្តល់នូវផលតបស្នងខ្ពស់[១] ដូច្នេះ **យុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានផ្តោតយកចិត្តទុកដាក់យ៉ាងច្បាស់លាស់ ទៅលើការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ និងមាតា ក្នុងរយៈពេល៥ឆ្នាំបន្ទាប់។

ផ្អែកលើការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការវិភាគទៅលើវិសាលភាព និងការគ្របដណ្តប់នៃអន្តរាគមន៍ដែលមានស្រាប់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨ ធ្វើការដោះស្រាយនូវវិស័យអាទិភាពកម្មវិធីចំនួន៣ដូចខាងក្រោម ៖




[១] ផ្អែកលើការសិក្សាថ្មីមួយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ អង្គការមូលនិធិសហប្រជាជាតិដើម្បីកុមារ និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក បានប៉ាន់ប្រមាណថា៖ប្រទេសកម្ពុជាបាត់បង់ប្រាក់ប្រមាណជា ៤០០ លាន ដុល្លារសហរដ្ឋអាមេរិកលើផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដោយសារតែកង្វះអាហារូបត្ថម្ភនៅទូទាំងវដ្តជីវិតនិងកង្វះមីក្រូសារជាតិគឺជាបន្ទុករបស់ជាតិជាង ២០០ លានដុល្លារជារៀងរាល់ឆ្នាំ។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨** រួមមានៈ ចក្ខុវិស័យរយៈពេលវែងមួយ គោលដៅមួយ និងគោលបំណងចំនួន៣។

ស្របគ្នាទៅនឹងនិយមន័យអន្តរជាតិដែលបានកំណត់ទៅលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ **ចក្ខុវិស័យរយៈពេលវែង** របស់រាជរដ្ឋាភិបាលកម្ពុជាគឺជាការសម្រេចឱ្យបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា ដោយចាត់ទុកថាជាល័ក្ខខ័ណ្ឌមួយដ៏សំខាន់សម្រាប់ធានាឱ្យមាននូវការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ចក្នុងកម្រិតមួយខ្ពស់ ភាពចម្រុងចម្រើន និងសមធម៌សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។

*"ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាពផ្នែករូបវ័ន្តសង្គម និងសេដ្ឋកិច្ចប្រសើរជាងមុន ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់"* ៕

**គោលដៅរួម** ផ្តោតទៅលើ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ សំដៅឆ្ពោះទៅសម្រេចឱ្យបាននូវទស្សនៈវិស័យនេះ ដែលគេអាចធ្វើការវាស់ស្ទង់បាន តាមរយៈភាពរីកចម្រើនគួរឱ្យកត់សម្គាល់ចំពោះការទទួលទានអាហាររបស់គ្រួសារ (សូចនាករៈកង្វះអាហារូបត្ថម្ភ) និង កង្វះអាហារូបត្ថម្ភរបស់កុមារ (សូចនាករ ៖ ភាពក្រិះក្រិន) រហូតដល់ឆ្នាំ ២០១៨។

*"ត្រឹមឆ្នាំ២០១៨ប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពផ្នែករូបវ័ន្តសង្គមនិងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សម្គាល់ ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាពនិងប្រកបដោយអាហារូបត្ថម្ភដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារនិងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេ មានសុខភាពល្អ និងមានផលិតភាពខ្ពស់ "* ៕

ផ្អែកលើការវិភាគមួយទៅលើចន្លោះប្រហោង និងជម្រើសយុទ្ធសាស្ត្រ ព្រមទាំងដំណើរការពិគ្រោះយោបល់ក្នុង ឆ្នាំ២០១៣ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានកំណត់រកឃើញ**គោលបំណងចំនួន៣** ព្រមទាំងអន្តរាគមន៍គន្លឹះជាអាទិភាព និងឧបករណ៍មួយចំនួន ដើម្បីសម្រេចឱ្យបាននូវគោលបំណងទាំងនោះ។

**គោលបំណងទី១** ៖ បង្កើនការមានស្បៀង និងការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វដែលកាន់តែមានភាពចម្រុះនិងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើ ប្រកបដោយនិរន្តរភាព ព្រមទាំងពីការងារដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។

**គោលបំណងទី២** ៖ ធ្វើឱ្យមានភាពប្រសើរឡើងនូវការប្រើប្រាស់ និង ការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ដល់ការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។

**គោលបំណងទី៣៖** ការធ្វើឱ្យប្រសើរឡើងប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងវិបត្តិនានា ដើម្បីបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង សម្រាប់គ្រួសារដែលមានបញ្ហាសន្តិសុខស្បៀង។

ប្រទេសកម្ពុជា បានរៀបចំរួចជាស្រេចនូវស្ថាប័នសម្រាប់សម្របសម្រួលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ហើយមានការរៀបចំបែបនេះជាច្រើនឆ្នាំមកហើយ។ ប្រទេសកម្ពុជា បានសម្រេចបាននូវវឌ្ឍនភាពមួយចំនួន ជាពិសេសតាមរយៈការរៀបចំបង្កើត **ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** (TWG-FSN) និងលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសនេះ នៅឆ្នាំ២០០៤។ នៅដើមឆ្នាំ២០១៤ អង្គភាពសម្របសម្រួលវិស័យគាំពារសង្គមត្រូវបានបញ្ចូលជាមួយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅជា **ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** (TWG-SP&FSN) ថ្មីមួយ ដែលដឹកនាំដោយប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណុចរួមគ្នារវាងបញ្ហាសំខាន់ដែលមានលក្ខណៈប្រទាក់ក្រឡាទាំងពីរនេះ។ ភាពប្រសើរឡើងនៃការសម្របសម្រួលអន្តរក្រសួងសម្រាប់ការគ្រប់គ្រងព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បាននាំឱ្យមានកិច្ចសហការផលិតព្រឹត្តបត្រព័ត៌មានប្រចាំត្រីមាស ហើយតាមរយៈក្រុមគ្រូបង្គោលបណ្តុះបណ្តាល ដែលមានសមាសភាពចម្រុះ មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ នាំឱ្យសមត្ថភាពក្នុងការបញ្ជ្រាបអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានលើកកម្ពស់។ បើទោះជាដូច្នេះក្តី ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព និងមានភាពសក្តិសិទ្ធិចំពោះអាទិភាពដែលមានគូសបញ្ជាក់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ដែលត្រូវធ្វើ ដើម្បីពង្រឹងបន្ថែមទៅលើសមិទ្ធផលទាំងនេះ និងបន្តលើកកម្ពស់ការសម្របសម្រួល និងការធ្វើសមាហរណកម្មនូវចំណាត់ការនានា ត្រូវការឱ្យមាននូវការត្រួតពិនិត្យ និងវាយតម្លៃ ដែលមានមូលដ្ឋានផ្អែកលើលទ្ធផលទៅលើកិច្ចអន្តរាគមន៍នានា និងពង្រីកកិច្ចខិតខំ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពជាតិ សំដៅធ្វើយ៉ាងណាឱ្យមានដំណោះស្រាយប្រកបដោយនិរន្តរភាពសម្រាប់លប់បំបាត់បញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

ដូច្នេះ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ក៏ធ្វើការដោះស្រាយផងដែរ ទៅលើបរិយាកាសផ្នែកស្ថាប័ន និងគោលនយោបាយ ដើម្បីអនុវត្តយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ព្រមទាំងគូសបញ្ជាក់អំពីគោលការណ៍ណែនាំ និងសកម្មភាពជាអាទិភាពមួយចំនួន ដើម្បីធ្វើឱ្យប្រសើរឡើង និងបន្តអភិវឌ្ឍន៍៖

(១). ការសម្របសម្រួល និងការឃ្លាំមើលគោលនយោបាយ សម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

(២). ត្រួតពិនិត្យ និងវាយតម្លៃ

(៣). ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

(៤). ការកសាងសមត្ថភាពលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

(៥). ការជ្រើសរើសអ្នកទទួលផល និងការកំណត់គោលដៅអន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ការបន្តដាក់ឱ្យដំណើរការនូវ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨** តាមរយៈកម្មវិធី និងគម្រោងថ្នាក់ជាតិ ដោយផ្អែកលើដំណើរការមួយដែលមានការចូលរួម និងមានភាពជាម្ចាស់ រៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការពិគ្រោះយោបល់ជាមួយ**ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** និងមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិលនានា។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងសម្របសម្រួលការពិភាក្សាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា អំពីជំហានបន្ទាប់ និងធនធានដែលត្រូវការ ដើម្បីពង្រីកកម្មវិធីដែលមានស្រាប់ ឬ ចាប់ផ្តើមកម្មវិធីថ្មី ព្រមទាំងអនុវត្តសកម្មភាពជាអាទិភាព ដូចមានគូសបញ្ជាក់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ**។ ស្របពេលជាមួយគ្នានេះដែរ គោលការណ៍ណែនាំសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលការត្រួតពិនិត្យ និងវាយតម្លៃ និងការគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងការកសាងសមត្ថភាព នឹងត្រូវបានបញ្ជាក់ឱ្យបានជាក់លាក់ជាងនេះបន្ថែមទៀត និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃនៃយុទ្ធសាស្ត្រដែលបានបញ្ចប់[២] ។ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍នៅក្នុងសិក្ខាសាលាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងខែឧសភា ឆ្នាំ២០១២ ថា៖ ត្រូវរៀបចំផែនការសកម្មភាព និងផែនការវិនិយោគស្តីពីអាហារូបត្ថម្ភមួយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភរបស់កុមារ និងមាតានៅគ្រប់វិស័យទាំងអស់ ដើម្បីបន្តដាក់ឱ្យដំណើរការនូវសកម្មភាពជាអាទិភាពដែលមានគូសបញ្ជាក់នៅក្នុងគោលបំណងទី២នៃយុទ្ធសាស្ត្រនេះ។

---

[២] សូចនាករ និងគោលដៅទាំងអស់នឹងត្រូវបានតម្រឹមជាមួយក្របខ័ណ្ឌលទ្ធផលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។

# ១. សេចក្ដីផ្ដើម

## ១.១. សាវតា និងប្រវត្តិនៃការរៀបចំយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាអាទិភាពនៃការអភិវឌ្ឍន៍មួយដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ហើយមានភាពពាក់ព័ន្ធចំពោះការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(CMDGs)។ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបញ្ចូលនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល២០១៤-២០១៨និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP២០១៤-២០១៨)។ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបន្តទទួលស្គាល់ថាជាសិទ្ធិមនុស្សមូលដ្ឋានមួយ ក្រោមសេចក្ដីថ្លែការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិការអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌ដែលលិខិតុបករណ៍ទាំងពីរនេះសុទ្ធសឹងតែត្រូវបានផ្ដល់សច្ចាប័នដោយរាជរដ្ឋាភិបាលកម្ពុជា។

ការគ្រប់គ្រងក្រោមអំណាចផ្ដាច់ការរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ បាននាំឱ្យប្រជាជនកម្ពុជាមានបញ្ហាកង្វះអាហារូបត្ថម្ភ និងភាពក្រីក្រយ៉ាងធ្ងន់ធ្ងរ។ រហូតដល់មានការបង្កើតរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៣ ទើបក្របខ័ណ្ឌគោលនយោបាយថ្មីៗ ត្រូវបានរៀបចំឡើងជាបណ្ដើរៗ។ ប្រធានបទមួយដែលមានសង្គតភាពនៅក្នុងរាល់ក្របខ័ណ្ឌគោលនយោបាយរបស់រដ្ឋាភិបាលថ្នាក់ជាតិទាំងអស់ គឺជាអាទិភាពដែលផ្ដោតទៅលើការកាត់បន្ថយភាពក្រីក្រ ក្នុងនោះរាប់បញ្ចូលភាពអត់ឃ្លានផងដែរ។ កម្មវិធីធំៗ ជាច្រើនដែលមានសមាសធាតុ និងសកម្មភាពទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានអនុវត្តចាប់ពីឆ្នាំ១៩៩៦ មក[៣]។ បើទោះជាដូច្នេះក្ដី កម្មវិធីទាំងនេះ នៅខ្វះកិច្ចគាំទ្រពីក្របខ័ណ្ឌគោលនយោបាយយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដែល**យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានផ្ដល់ជូនកន្លងមក។

អាស្រ័យដោយថ្លៃចំណាយផ្នែកសង្គម និងសេដ្ឋកិច្ចទៅលើបញ្ហាកង្វះអាហារូបត្ថម្ភ សម្រាប់ប្រជាជនកម្ពុជា មានតម្លៃខ្ពស់គួរឱ្យកត់សម្គាល់ ហើយការវិនិយោគទៅលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានបង្ហាញឱ្យឃើញថាផ្ដល់នូវផលតបស្នង និងប្រយោជន៍ខ្ពស់ត្រឡប់មកវិញសម្រាប់ការអភិវឌ្ឍន៍ជាតិនិងសង្គម រាជរដ្ឋាភិបាលបានធ្វើការគូសបញ្ជាក់អំពីសេចក្ដីណែនាំគោលនយោបាយស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៨។ "**ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ**"(SFFSN 2008-2012) ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅក្នុងដំណើរការពិគ្រោះយោបល់មួយដ៏ទូលំទូលាយ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ក្នុងឆ្នាំ២០០៧ និងបានបញ្ជាក់នៅក្នុងគោលដៅរបស់ខ្លួនថា៖ នៅត្រឹមឆ្នាំ២០១២ ប្រជាជនកម្ពុជាដែលក្រីក្រ និងមាន

[៣] កម្មវិធីទាំងនេះរួមមាន កម្មវិធីអភិវឌ្ឍន៍ជនបទដែលមានវិសាលភាពទូលំទូលាយ រាប់បញ្ចូលការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខ ស្បៀង នៅក្នុងគោលបំណង ឬ សកម្មភាពរបស់កម្មវិធីទាំងនោះ។

បញ្ហាអសន្តិសុខស្បៀង មានលទ្ធភាពផ្នែករូបវន្ត និងសេដ្ឋកិច្ចប្រសើរជាងមុន គួរឱ្យកត់សម្គាល់ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ ព្រមទាំងចំណង់ចំណូលចិត្ត ក្នុងការទទួលទានអាហាររបស់ពួកគេ ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេ មានភាពសកម្ម និងមានសុខភាពល្អ។

ដោយសារតែមានប្រវត្តិនៃបញ្ហាប្រឈម ដែលបង្កឡើងដោយតម្លៃស្បៀងអាហារ និងវិបត្តិសេដ្ឋកិច្ចពិភពលោក ក្នុងឆ្នាំ២០០៨-២០០៩ ការប្រែប្រួលនៅក្នុងបរិបទគោលនយោបាយ និងស្ថាប័ន ព្រមទាំងយុទ្ធសាស្ត្រ និងកម្មវិធីថ្មីៗ ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានរៀបចំធ្វើការត្រួតពិនិត្យឡើងវិញមួយ ទៅលើ**ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នៅចុងឆ្នាំ២០១១និងដើមឆ្នាំ២០១២ ដើម្បីវាយតម្លៃទៅលើវឌ្ឍនភាពដែលសម្រេចបាន និងដើម្បីធានាថា ឯកសារនេះ នៅតែបន្តជាក្របខ័ណ្ឌឯកសារយោងមួយដ៏មានតម្លៃ សម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា[៩]។

លទ្ធផលនៃការត្រួតពិនិត្យឡើងវិញនេះ បានបង្ហាញឱ្យដឹងថា៖ **ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** គឺជាឯកសារមួយដ៏មានសារៈប្រយោជន៍ សម្រាប់បង្កើតការយល់ដឹង និងបានគាំទ្រ ដល់ការបញ្ជ្រាបខ្លឹមសារនៃបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រថ្មីៗ មួយចំនួនដូចជា៖ យុទ្ធសាស្ត្រស្តីពីកសិកម្មនិងទឹក យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា យុទ្ធសាស្ត្រជាតិស្តីពីអាហារូបត្ថម្ភ កម្មវិធីធំៗ ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការពង្រឹងកិច្ចសម្របសម្រួលអន្តរក្រសួង ការធ្វើឱ្យប្រសើរឡើងចំពោះការត្រួតពិនិត្យ និងវាយតម្លៃ និងការអភិវឌ្ឍន៍សមត្ថភាពទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងការបង្កើនការយកចិត្តទុកដាក់ និងការផ្តល់អាទិភាពចំពោះកិច្ចអន្តរាគមន៍នានាសុទ្ធសឹងតែជាអនុសាសន៍សំខាន់ៗ ដែលទទួលបានពីការត្រួតពិនិត្យឡើងវិញ ដើម្បីរៀបចំឯកសារយុទ្ធសាស្ត្រថ្នាក់ជាតិថ្មី ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨** បានធ្វើការកំណត់ទៅលើជម្រើសយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាព ដោយផ្អែកលើការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភមួយ ដែលត្រូវបានធ្វើបច្ចុប្បន្នភាព និងរៀបចំមាតិកាមួយ ដើម្បីពង្រឹងការរៀបចំស្ថាប័នដែលចាំបាច់ ដើម្បីធ្វើឱ្យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានភាពប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេល៥ឆ្នាំបន្ទាប់។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នឹងផ្តល់នូវមូលដ្ឋានមួយសម្រាប់ការសម្របសម្រួល និងត្រួតពិនិត្យលើគ្រប់វិស័យ ដែលគេអាចពង្រឹងបន្ថែមនូវសកម្មភាពប្រតិបត្តិការ និងផែនការវិនិយោគច្រើនជាងនេះបន្ថែមទៀត ទៅលើវិស័យទាំងនោះ។

[៩] សូមមើលរបាយការណ៍បូកសរុបក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា ខែធ្នូ ឆ្នាំ២០១១

## ១.២. ក្របខ័ណ្ឌគោលគំនិត និងវិសាលភាពនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានកំណត់ជ្រើសរើសយកនិយមន័យនៃសន្តិសុខស្បៀងដែលត្រូវបានទទួលយកជាសកល ថា៖ នៅពេលដែលមនុស្សគ្រប់រូប នៅគ្រប់ពេលវេលាទាំងអស់ មានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ច ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ ព្រមទាំងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានភាពសកម្ម និងមានសុខភាពល្អ ។ កង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង គឺបណ្តាលមកពីអន្តរកម្មដ៏ស្មុគស្មាញមួយនៃកត្តានានា ដូច្នេះ ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង គឺជាបញ្ហាប្រឈមមួយ ដែលមានលក្ខណៈពហុវិស័យ។

ដើម្បីជួយដោះស្រាយភាពស្មុគស្មាញនេះ គោលគំនិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ [៥] បានកំណត់រកឃើញទិដ្ឋភាពមូលដ្ឋានចំនួន៤ នៃសន្តិសុខស្បៀង៖

(១).ការមានស្បៀង

(២). ការទទួលបានស្បៀង

(៣). ការប្រើប្រាស់ និងការបឺតស្រូបស្បៀង

(៤). ស្ថេរភាពស្បៀង។

<u>រូបភាពទី១</u>៖ គោលគំនិតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ




**១.ការមានស្បៀង**៖ភាគច្រើនទាក់ទងទៅនឹងលទ្ធភាពក្នុងការផលិតស្បៀងអាហារឱ្យបានគ្រប់គ្រាន់ដោយផ្ទាល់ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការអាហារូបត្ថម្ភតាមរយៈកិច្ចខិតខំផ្ទាល់ខ្លួននៅក្នុងផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វ និងតាមរយៈការប្រមូលពីធនធានទ្រព្យ

[៥] នៅក្នុងនិយមន័យទូលំទូលាយរបស់អង្គការ FAOពាក្យថា "សន្តិសុខស្បៀង" ក៏បង្កប់អត្ថន័យអាហារូបត្ថម្ភនៅក្នុងនោះផងដែរ។ នៅក្នុងយុទ្ធសាស្ត្រនេះ ពាក្យ "សន្តិសុខស្បៀង និងអាហារូបត្ថម្ភ" ត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយដើម្បីសង្កត់ធ្ងន់ថា សន្តិសុខស្បៀង មិនអាចត្រូវបានកាត់បន្ថយមកត្រឹមការផលិតស្បៀង និងលទ្ធភាពផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវការឱ្យមាននូវការប្រើប្រាស់ និងការទទួលទានស្បៀងអាហារឱ្យបានគ្រប់គ្រាន់ផងដែរ។

សម្បត្តិរួម រាប់បញ្ចូលធនធានព្រៃឈើ និងជលផល។

**២.ការទទួលបានស្បៀង** ៖ ទាក់ទងទៅនឹងប្រាក់ចំណូល និងលទ្ធភាពក្នុងការទិញរបស់មនុស្ស ដើម្បីទទួលបានស្បៀងអាហារគ្រប់គ្រាន់តាមរយៈទីផ្សារ។ ទីផ្សារអាចខ្វះហេដ្ឋារចនាសម្ព័ន្ធ សេវា និងមូលធនសម្រាប់ផ្តល់ការរក្សាទុកស្បៀងឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការស្បៀងអាហារអប្បបរមា។ ក្រៅពីប្រាក់ចំណូលផ្ទាល់ខ្លួន ការកំណត់គោលដៅសង្គហទានសង្គម (សំណាញ់សុវត្ថិភាព) អាចផ្តល់លទ្ធភាពក្នុងការទិញស្បៀងអាហារជូនដល់ជនក្រីក្រ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការស្បៀងអាហាររបស់ពួកគេ។

**៣. ការប្រើប្រាស់ និងការបឺតស្រូបស្បៀង** ៖ទាក់ទងទៅនឹងអាហារូបត្ថម្ភគ្រប់គ្រាន់ (ការអនុវត្តអាហារូបត្ថម្ភ) និងសុខភាព។ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូនអាចខ្វះអាហារូបត្ថម្ភ ដែលនាំឱ្យបរិមាណអាហារូបត្ថម្ភ ដែលមានសម្រាប់ចិញ្ចឹមកូនរបស់ពួកគេមានកម្រិត។ ការអនុវត្តរបស់ម្តាយក្នុងការថែទាំកូន អាចពុំមានភាពសមស្របសម្រាប់សុខភាព និងអាហារូបត្ថម្ភរបស់កូន។ឧបទ្ទវហេតុខ្ពស់នៃការឆ្លងជំងឺមួយចំនួនដូចជា៖ ជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវ ជំងឺរាគរូស និងកង្វះសេវាសុខភាពមាតា និងទារក នឹងបណ្តាលឱ្យសុខភាព និងអាហារូបត្ថម្ភរបស់មាតា និងទារកមានការធ្លាក់ចុះ។ កង្វះលទ្ធភាពក្នុងការទទួលបានទឹកទទួលទានមានសុវត្ថិភាព និងអនាម័យ នឹងបង្កើនអត្រាឈឺ និងឆ្លងជំងឺ ព្រមទាំងធ្វើឱ្យស្ថានភាពសុខភាព និងអាហារូបត្ថម្ភមានការធ្លាក់ចុះ។

**៤. ស្ថេរភាពស្បៀង**៖ អស្ថេរភាពនៃការផ្គត់ផ្គង់ឱ្យបានទៀងទាត់នូវស្បៀងអាហារ និងទឹកស្អាតគ្រប់គ្រាន់ បង្កឱ្យមាននូវកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង។ មូលហេតុនៃអស្ថេរភាពបែបនេះ អាចរួមមានផលប៉ះពាល់បណ្តាលមកពីទឹកជំនន់ និងគ្រោះរាំងស្ងួតទៅលើវិស័យកសិកម្ម ភាពវិចវិលនៃ បរិស្ថាន ឬ ការប្រែប្រួលក្នុងការទទួលបានធនធានទ្រព្យសម្បត្តិរួម ការផ្លាស់ប្តូរនៃលទ្ធភាពក្នុងការទិញស្បៀង និងអស្ថេរភាពនយោបាយ រាប់បញ្ចូលសង្គ្រាម និង ជម្លោះនានា។ ប្រជាពលរដ្ឋអាចជួបប្រទះបញ្ហាអស្ថេរភាពធ្ងន់ធ្ងរ (ឬ អស្ថេរភាពស្បៀងបណ្តោះអាសន្ន) នៅពេលណាមួយ (វិបត្តិ) ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះចំពោះផលប៉ះពាល់ ពីបញ្ហាអស្ថេរភាពដទៃទៀតនៅពេលអនាគត។

ក្រៅពីទិដ្ឋភាពមូលដ្ឋានទាំងនេះ ការវិភាគក៏ត្រូវធ្វើទៅលើសន្តិសុខស្បៀងនៅកម្រិតផ្សេងៗគ្នាផងដែរ៖ នៅកម្រិតសកល និងកម្រិតថ្នាក់ជាតិ (សន្តិសុខស្បៀងកម្រិតម៉ាក្រូ) នៅកម្រិតគ្រួសារ និងកម្រិតបុគ្គល (សន្តិសុខស្បៀងនៅកម្រិតគ្រួសារ)[៦]។

[៦] ជួនកាល នៅចន្លោះកម្រិតម៉ាក្រូនិងកម្រិតមីក្រូ(កម្រិតគ្រួសារ និងកម្រិតបុគ្គល) មានកម្រិតមួយទៀតដែលស្ថិតនៅចន្លោះនោះ ("កម្រិតមេសូ") ដើម្បីសង្កត់បញ្ជាក់ថាអាចមានភាពខុសគ្នាពាក់ព័ន្ធមួយចំនួននៅកម្រិតតំបន់ ឬ កម្រិតមូលដ្ឋានក្នុងប្រទេសមួយ ទាក់ទងទៅនឹង ការមានស្បៀង ការទទួលបានស្បៀង ការប្រើប្រាស់ និងការបឺតស្រូបស្បៀងអាហារ។

រូបភាពទី២ ៖ កម្រិតទាំង៣នៃសន្តិសុខស្បៀង




- *សន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ (កម្រិតម៉ាក្រូ)* ពុំមានអត្ថន័យស្មើគ្នាទៅនឹងការផលិតស្បៀងឱ្យបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅក្នុងប្រទេសឡើយ ប៉ុន្តែប្រសើរបំផុត យើងគួរយល់ថាជាស្ថានភាពមួយដែលការមានស្បៀងនៅកម្រិតថ្នាក់ជាតិ យ៉ាងហោចណាស់មានចំនួនស្មើទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅពេលណាមួយ (អាចមានប្រភពមកពីការផលិតស្បៀងអាហារដោយខ្លួនឯង ឬ ការនាំចូលស្បៀងអាហារ ឬការច្របាច់បញ្ចូលគ្នានៃកត្តាទាំងពីរនេះ)។ ប្រទេសកម្ពុជាសម្រេចបានសន្តិសុខស្បៀងនៅកម្រិតម៉ាក្រូ អស់រយៈពេលជាច្រើនឆ្នាំមកហើយ អាស្រ័យដោយប្រទេសកម្ពុជាផលិតបាននូវអតិរេកផលស្រូវជាច្រើន ដែលជាស្បៀងអាហារចម្បងរបស់ប្រទេស ហើយកម្ពុជាកំពុងក្លាយខ្លួនជាប្រទេសនាំចេញអង្ករមួយដ៏សំខាន់នៅក្នុងតំបន់។ កម្ពុជាត្រូវការនាំចូលនូវប្រភេទស្បៀងអាហារសំខាន់ៗ ជាច្រើនទៀត ប៉ុន្តែកម្ពុជាអាចធានានូវការផ្គត់ផ្គង់ និងការមានស្បៀងអាហារទាំងនេះ តាមរយៈការធ្វើពាណិជ្ជកម្មនៅក្នុងទីផ្សារតំបន់ និងសកលលោក។ អាស្រ័យដោយសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ ពុំមែនជាការព្រួយបារម្ភសម្រាប់ប្រទេសកម្ពុជា **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** កំពុងផ្តោតយកចិត្តទុកដាក់ជាចម្បង ទៅលើសន្តិសុខស្បៀងនៅកម្រិតគ្រួសារ និងបុគ្គល។

- *សន្តិសុខស្បៀងនៅកម្រិតគ្រួសារ* សម្រេចទៅបាននៅពេលដែលគ្រួសារមួយ មានលទ្ធភាពទទួលបានស្បៀងអាហារ ដែលចាំបាច់សម្រាប់សមាជិកគ្រួសារទាំងអស់ ដើម្បីរស់នៅបានប្រកបដោយសុខភាពល្អ (មានភាពគ្រប់គ្រាន់ចំពោះគុណភាព បរិមាណសុវត្ថិភាព និងអាចទទួលយកបានទៅតាមលក្ខណៈវប្បធម៌) និងនៅពេលដែលមានស្ថេរភាពចំពោះលទ្ធភាពក្នុងការទទួលបានស្បៀងអាហារ និងពុំមានហានិភ័យខ្ពស់។ សន្តិសុខស្បៀង នៅកម្រិតគ្រួសារពឹងផ្អែកយ៉ាងខ្លាំងទៅលើលទ្ធភាពរបស់គ្រួសារក្នុងការទទួលបានស្បៀងអាហារពីការផលិត

ស្បៀងដោយខ្លួនឯង តាមរយៈការទិញស្បៀងអាហារពីប្រភពចំណូលផ្ទាល់ខ្លួន ឬ ការផ្ទេរស្បៀង និង សាច់ប្រាក់។

- *សន្តិសុខស្បៀងកម្រិតបុគ្គល* អាស្រ័យទៅលើការបែងចែកស្បៀងអាហារសមស្របនៅក្នុងគ្រួសារ ព្រមទាំងទិដ្ឋភាពផ្នែកអាហារូបត្ថម្ភដែលពឹងផ្អែកទៅលើការប្រើប្រាស់ស្បៀងអាហារឱ្យបានត្រឹមត្រូវ ស្ថានភាពសុខភាពរបស់បុគ្គល និងអន្តរកម្មសរីរាង្គ រវាងការស្រូបយកអាហារូបត្ថម្ភ និងជំងឺ។ អាស្រ័យដោយកុមារមានតួនាទី ពិសេសនៅក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅពេលអនាគត ហើយពួកគេមានភាពងាយរងគ្រោះខ្ពស់ ដូច្នេះ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ផ្តោតការយកចិត្តទុកដាក់ពិសេសចំពោះស្ថានភាពអាហារូបត្ថម្ភ និងសុខភាពរបស់កុមារ និងមាតា។

ការមានសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ ពុំបញ្ជាក់ថាមានសន្តិសុខស្បៀងនៅកម្រិតគ្រួសារ ឬ កម្រិតបុគ្គលឡើយ។ ដូច្នេះ ដើម្បីវាស់ស្ទង់ទៅលើលទ្ធផលសរុបនៃសន្តិសុខស្បៀងនៅគ្រប់កម្រិត **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានប្រើប្រាស់ការបឺតស្រូបស្បៀងអាហារនៅកម្រិតគ្រួសារ និងវិធានការចំនួន៣ ដែលពិនិត្យទៅលើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ។ លុះត្រាណាតែពុំមានវត្តមាននៃកង្វះអាហារូបត្ថម្ភកុមារ ទើបយើងអាចចាត់ទុកថាប្រទេសមួយសម្រេចបាននូវសន្តិសុខស្បៀងទាំងស្រុង។

អាស្រ័យទៅតាមរយៈពេល យើងអាចធ្វើការពណ៌នាបន្ថែមទៀត ទៅលើបញ្ហាអសន្តិសុខស្បៀង ថាមានលក្ខណៈរ៉ាំរ៉ៃ ឬ បណ្តោះអាសន្ន៖ អសន្តិសុខស្បៀងរ៉ាំរ៉ៃមានន័យថា មនុស្សមិនអាចមានលទ្ធភាពទទួលបានសេចក្តីត្រូវការស្បៀងអាហារអប្បបរមារបស់ពួកគេក្នុងរយៈពេលវែង ដោយសារតែភាពក្រីក្រ ការដែលពុំមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលបានធនធានសម្រាប់ផលិត ឬ ធនធានហិរញ្ញវត្ថុ។ អសន្តិសុខស្បៀងបណ្តោះអាសន្ន ជាញឹកញាប់ មានទំនាក់ទំនងទៅនឹងវិបត្តិផ្នែកសង្គមនិងសេដ្ឋកិច្ច (ដូចជា ការកើនឡើងនូវតម្លៃស្បៀងអាហារពិភពលោក ឬ ឱនភាពសេដ្ឋកិច្ច) គ្រោះមហន្តរាយធម្មជាតិ (ដូចជា ៖ទឹកជំនន់ និងគ្រោះរាំងស្ងួត) និងជម្លោះនានា ដែលអាចប៉ះពាល់ដល់សន្តិសុខស្បៀងនៅកម្រិតទាំង៣នេះ។ បន្ថែមពីនេះទៀត ផលប៉ះពាល់ នៃការប្រែប្រួលរយៈពេលវែង ចំពោះល័ក្ខខ័ណ្ឌធម្មជាតិ (ការប្រែប្រួលអាកាសធាតុ) អាចប៉ះពាល់ដល់សន្តិសុខស្បៀង[៧]។ ការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ និងសំណាញ់សុវត្ថិភាពសង្គម អាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃហេតុការណ៍ទាំងនេះ ទៅលើសន្តិសុខស្បៀង និងជួយដល់ប្រជាពលរដ្ឋ ដាកចេញពីការប្រើប្រាស់យន្តការដោះស្រាយបញ្ហាបែបអវិជ្ជមាន ដូចជា ការលក់ទ្រព្យសម្បត្តិសម្រាប់បង្កបង្កើនផល ដែលធ្វើឱ្យពួកគេប្រឈមទៅ នឹងអសន្តិសុខស្បៀងរ៉ាំរ៉ៃ។

[៧] គោលគំនិតនៃអសន្តិសុខស្បៀងតាមរដូវកាល ស្ថិតនៅចន្លោះអសន្តិសុខស្បៀងរ៉ាំរ៉ៃ និង បណ្តោះអាសន្ន។ អសន្តិសុខស្បៀងតាមរដូវកាល រមែងតែងកើតឡើងនៅក្នុងរដូវកាលដែលមិនសូវមានការងារកសិកម្ម និង មានទម្រង់ជាអសន្តិសុខស្បៀងបណ្តោះអាសន្នដែលកើតឡើងដដែលៗ។

បើទោះបីជាភាពក្រីក្រពុំមែនជាមូលហេតុតែម៉្យាងក៏ដោយប៉ុន្តែ**ភាពក្រីក្រគឺជាបុព្វហេតុចម្បងមួយដែលនាំឱ្យមានបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ** ហើយភាពក្រីក្រ និងអសន្តិសុខស្បៀងមានអន្តរទំនាក់ទំនងយ៉ាងជ្រាលជ្រៅ និងជាញឹកញាប់ គឺជាបាតុភូតមួយដែលបន្តពីជំនាន់មួយទៅជំនាន់មួយទៀត។ ជាទូទៅ ជនក្រីក្រ រមែងតែងទទួលទានអាហារតិចតួច ឬ មិនសូវមានគុណភាព និងសមត្ថភាពថែទាំកូនរបស់ពួកគេមានកម្រិត ដែលកត្តាទាំងនេះ នាំឱ្យលទ្ធផលនៃការអភិវឌ្ឍន៍មនុស្សមានភាពទន់ខ្សោយ ទទួលបានប្រាក់ចំណូលទាប និងបណ្តាលឱ្យមានភាពក្រីក្របន្តទៀត នៅជំនាន់ក្រោយ។

<u>រូបភាពទី៣៖</u> វដ្តនៃភាពក្រីក្រ និងអសន្តិសុខស្បៀង




យុទ្ធសាស្ត្រសន្តិសុខស្បៀងមួយ ទាមទារឱ្យមានអភិក្រមពហុវិស័យដែលគ្របដណ្តប់ទៅលើវិស័យជាច្រើន។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង យុទ្ធសាស្ត្រ គោលនយោបាយ និងការវិនិយោគនៅក្នុងវិស័យ៖ កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ការគ្រប់គ្រងធនធានទឹក សុខភាពសាធារណៈអាហារូបត្ថម្ភទឹកនិងអនាម័យការអប់រំនិងកិច្ចគាំពារសង្គមសុទ្ធសឹងតែមានសារៈសំខាន់។ ដូច្នេះ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** សង្កត់ធ្ងន់ទៅលើកិច្ចខិតខំរួមគ្នាពីរាល់ បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលនានា។

វិសាលភាពរបស់**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** មានភាពទូលំទូលាយ ដោយរួមមានសកម្មភាពជាអាទិភាព ដែលគ្របដណ្តប់ទៅលើរាល់ទិដ្ឋភាពទាំង៤ របស់

សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងកំណត់គោលការណ៍មួយចំនួន ទាក់ទងទៅនឹងការរៀបចំស្ថាប័ន សម្រាប់អនុវត្ត និងត្រួតពិនិត្យវាយតម្លៃទៅលើយុទ្ធសាស្ត្រ។

<u>រូបភាពទី៤</u>៖ វិសាលភាពនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨




**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** គឺជាឯកសារគ្រប់ជ្រុងជ្រោយមួយ ប៉ុន្តែ ឯកសារនេះ បន្តផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាព និងសកម្មភាពសំខាន់ៗនៅក្នុងរាល់គ្រប់វិស័យពាក់ព័ន្ធទាំងអស់។ ឯកសារនេះ ពុំចាំបាច់ត្រូវសំដៅចំពោះរាល់គ្រប់ទិដ្ឋភាពទាំងអស់ដែលទាក់ទងទៅនឹងបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាឡើយ។

## ១.៣. ដំណើរការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ក្នុងឆ្នាំ២០១២ និង ឆ្នាំ២០១៣ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានរៀបចំកិច្ចប្រជុំអ្នកពាក់ព័ន្ធ និងសិក្ខាសាលាពិគ្រោះយោបល់មួយចំនួន ដើម្បីផ្តល់ឱកាសជូនដល់ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ធ្វើការសម្រេចចិត្តទៅលើវិសាលភាព និងចរិតលក្ខណៈនៃយុទ្ធសាស្ត្រនេះ ពិនិត្យស្វែងរកឱកាសយុទ្ធសាស្ត្រ និង ដើម្បីពិភាក្សា ព្រមទាំងកំណត់វិស័យអាទិភាព និងអន្តរាគមន៍ឱ្យបានស៊ីជម្រៅ។ បន្ទាប់មក ក្រុមការងារមួយរួមមានសមាសភាពពីភាគីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដែលបានភ្ជាប់ទំនាក់ទំនងជាមួយ**ក្រុមការងារបច្ចេកទេស សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** (TWG-SFN) ត្រូវបានរៀបចំឡើង ជាយន្តការមួយដើម្បីផ្តល់ធាតុចូល និងមតិយោបល់ជាប្រចាំជូនដល់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងអំឡុងពេលនៃដំណើរការរៀបចំបង្កើតយុទ្ធសាស្ត្រ។ ជាពិសេស ព្រឹត្តិការណ៍ខាងក្រោមនេះ ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃការរៀបចំបង្កើតយុទ្ធសាស្ត្រ ៖

- *ការពិភាក្សាអំពីលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ ទៅលើក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនិងវិសាលភាពនៃ NSFSN ថ្មី ក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងខែមីនារហូតដល់ខែមិថុនាឆ្នាំ២០១២។*
- *កិច្ចប្រជុំលើកដំបូង សម្រាប់រៀបចំបង្កើត NSFSN ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ និងការបង្កើតក្រុមការងារស្នូល អន្តរវិស័យ សម្រាប់ផ្តល់ធាតុចូល និងមតិយោបល់ ក្នុងអំឡុងពេលនៃដំណើរការរៀបចំបង្កើតយុទ្ធសាស្ត្រ។*
- *សិក្ខាសាលាពិគ្រោះយោបល់លើកទី១ ស្តីពីការរៀបចំបង្កើត NSFSN ក្នុងខែមេសា ឆ្នាំ២០១៣ ជាមួយបណ្តាក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីវិស័យអាទិភាព គោលបំណង និងសកម្មភាពអាទិភាព។*
- *ការចងក្រងសេចក្តីព្រាងដំបូងនៃ NSFSN នៅចុងខែមិថុនា ឆ្នាំ២០១៣។*
- *ការផ្សព្វផ្សាយសេចក្តីព្រាងទី១ នៃNSFSNជូនដល់បណ្តាក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីផ្តល់មតិយោបល់ក្នុងខែធ្នូឆ្នាំ២០១៣និងខែមករា ឆ្នាំ២០១៤*
- *ការពិនិត្យឡើងវិញនៃសេចក្តីព្រាងលើកទី១ផ្អែកលើមតិយោបល់និងធាតុចូលពីភាគីពាក់ព័ន្ធ*
- *សិក្ខាសាលាពិគ្រោះយោបល់លើកទី២ ដើម្បីបង្ហាញ និងពិភាក្សាទៅលើសេចក្តីព្រាងចុងក្រោយនៃ NSFSN នៅថ្ងៃទី២៤ខែកុម្ភៈ ឆ្នាំ២០១៤ និងបញ្ចប់ឯកសារនេះនៅកំឡុងខែមេសា ឆ្នាំ២០១៤។*
- *អនុម័តលើ NSFSN ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។*
- *ការផ្សព្វផ្សាយអំពី NSFSN នៅថ្នាក់ជាតិ និងក្រោមជាតិ។*

# ២. ស្ថានភាពបច្ចុប្បន្ននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា

## ២.១. ការវាយតម្លៃសន្តិសុខស្បៀងកម្រិតម៉ាក្រូ

សន្តិសុខស្បៀងកម្រិតម៉ាក្រូ (ថ្នាក់ជាតិ) ត្រូវបានកំណត់ទៅតាមកម្រិតនៃការផលិតស្បៀងអាហារ កម្រិតនៃការរក្សាទុកស្បៀងអាហារក្នុងស្តុក និងការធ្វើពាណិជ្ជកម្មរបស់ប្រទេសមួយ។ ប្រទេសកម្ពុជាសម្រេចបាននូវសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ ហើយប្រទេសនេះ មានផលស្រូវដែលជាអាហារចម្បងរបស់ប្រទេស សម្រាប់ផ្គត់ផ្គង់ខ្លួនឯងបានគ្រប់គ្រាន់ ចាប់តាំងពីឆ្នាំ១៩៩៥/១៩៩៦ ព្រមទាំងបានក្លាយខ្លួនជាអ្នកនាំចេញអង្ករមួយដ៏សំខាន់ [៨]។ រូបភាពទី៥ បង្ហាញអំពីអតិរេកស្រូវអង្ករដែលបន្តកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ក្នុងប្រទេសកម្ពុជា។

[៨] បើទោះជាដូច្នេះក្តី ស្រូវភាគច្រើនត្រូវបានលក់ដោយកសិករក្នុងតម្លៃទាបភ្លាមៗក្រោយពេលប្រមូលផល និងត្រូវបាននាំចេញតាមរយៈច្រកព្រំដែនមិនផ្លូវការទៅកាន់ប្រទេសវៀតណាម ឬ ប្រទេសថៃ ដើម្បីនាំចូលមកវិញជាអង្ករនៅពេលក្រោយក្នុងតម្លៃខ្ពស់ជាងមុន។ ការធ្វើឱ្យប្រសើរឡើងនូវខ្សែសង្វាក់តម្លៃស្រូវ ត្រូវបានផ្តល់ដំណោះស្រាយជាក់លាក់ ដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលនយោបាយស្តីពីផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំ២០១០។

## រូបភាពទី៥៖ និន្នាការនៃអតិរេកផលិតកម្មស្រូវអង្ករជាតិ ២០០៦-២០១២




| | 2006 | 2007 | 2008 | 2009 | 20010 | 2011 | 2012 |
|---|---|---|---|---|---|---|---|
| អតិរេកស្រូវគិតជាតោន | 2240438 | 2577562 | 3164114 | 3507185 | 3932425 | 4344263 | 4735964 |
| អតិរេកអង្ករគិតជាតោន | 1433880 | 1649640 | 2025033 | 2244598 | 2516752 | 2780328 | 3031017 |

ប្រភព ៖MAFF

## រូបភាពទី៦៖ តារាងតុល្យការស្តីពីស្បៀងអាហារកម្ពុជា ២០១២/២០១៣ គិតជាតោន

| | រដូវស្រូវវស្សា | រដូវស្រូវប្រាំង | សរុប |
|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត) | 2,512,038 | 495,507 | 3,007,545 |
| ផ្ទៃដីខូចខាត (ហ.ត) | 36,025 | 42 | 36,067 |
| ផ្ទៃដីដាំដុះឡើងវិញ (ហ.ត) | 8,819 | | 8,819 |
| ផ្ទៃដីប្រមូលផល (ហ.ត) | 2,484,832 | 495,465 | 2,980,297 |
| ទិន្នផល (តោន/ហ.ត) | 2.872 | 4.349 | 3.117 |
| ផលិតកម្មស្រូវ (តោន) | **7,136,139** | **2,154,801** | **9,290,940** |
| តម្រូវការគ្រាប់ពូជ និងការបាត់បង់ក្រោយពេលប្រមូលផល (១៣%) (តោន) | | | 1,207,822 |
| ស្រូវដែលនៅសេសសល់សម្រាប់ទទួលទាន (តោន) | | | 8,083,118 |
| ស្រូវដែលមានសម្រាប់ទទួលទាន នៅពេលដែលកិនទៅជាអង្ករ (៦៤%) | | | 5,173,195 |
| តម្រូវការស្បៀងអាហារក្នុងមួយឆ្នាំ (តោន) | | | 2,142,178 |
| អតិរេកបរិមាណអង្ករនៅក្នុងប្រទេស (តោន) | | | **3,031,017** |

ប្រភព ៖ MAFF

ផលិតកម្មស្រូវមានភាពខុសគ្នាតាមតំបន់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែក្នុងឆ្នាំ២០១២/២០១៣ រាជធានី-ខេត្តទាំង២៤ ភាគច្រើនបានបង្ហាញឱ្យឃើញនូវតុល្យភាពផលស្រូវមួយជាវិជ្ជមាន លើកលែងតែរាជធានីភ្នំពេញ ខេត្តកោះកុង និងខេត្តព្រះសីហនុប៉ុណ្ណោះ ដែលផលិតកម្មស្រូវអង្ករ មិនបានឆ្លើយ

តបតាមតម្រូវការប្រើប្រាស់នៅក្នុងរាជធានី/ខេត្តនោះ។

ប្រទេសកម្ពុជា នៅតែធ្វើការនាំចូលស្បៀងអាហារជាច្រើនប្រភេទ ហើយប្រទេសនេះ កំពុងអនុវត្តគោលនយោបាយធ្វើពិពិធកម្មផលិតកម្មកសិកម្ម សម្រាប់ទីផ្សារក្នុងស្រុក ព្រមទាំងដើម្បីទាញប្រយោជន៍ពីគុណសម្បត្តិប្រហាក់ប្រហែលគ្នាមួយចំនួនសម្រាប់ការនាំចេញ។ បើទោះជាដូច្នេះក្តី ទីផ្សារស្បៀងអាហារនៅក្នុងប្រទេសកម្ពុជា រមែង តែងមានសមាហរណកម្មល្អប្រសើរទៅនឹងការប្រែប្រួលបន្តិចបន្តួចនៃតម្លៃក្នុងតំបន់ ហើយការធានាឱ្យមានស្បៀង ដទៃទៀតក្នុងស្រុក (ក្រៅពីស្រូវអង្ករ) ពុំមែនជាការព្រួយបារម្ភឡើយ។ ទោះបីជាក្នុងឆ្នាំ២០១១/២០១២ ប្រទេសកម្ពុជាជួបប្រទះគ្រោះទឹកជំនន់ នៅក្នុងខេត្តចំនួន១៨ ក៏ដោយ ក៏ប្រទេសកម្ពុជាសម្រេចបាននូវអតិរេកផលស្រូវក្នុងស្រុក ដោយបានបង្កើនផលស្រូវក្នុងប្រទេសរបស់ខ្លួន រហូតដល់ជាង ២,៧លានតោន។

បើទោះបីជាមានការសម្រេចបាននូវសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិក៏ដោយ ការទទួលបានស្បៀងអាហារពីផលិតកម្មផ្ទាល់ខ្លួននៅក្នុងចំណោមគ្រួសារកសិករក្រីក្រ រមែងតែងមានបរិមាណ និងគុណភាពមិនគ្រប់គ្រាន់ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការស្បៀងអាហាររបស់ពួកគេ ហើយអនាម័យ និងបទដ្ឋានភូតគាម-អនាម័យ (SPS) មិនត្រូវបានអនុវត្តពេញលេញនៅឡើយ។

សកម្មភាពជាអាទិភាពដើម្បីធ្វើឱ្យប្រសើរឡើង នូវការមានស្បៀងអាហារនៅកម្រិតគ្រួសារ តាមរយៈការធ្វើប្រពលវប្បកម្ម និងពិពិធកម្មប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវទ្រព្យសម្បត្តិធនធានរួម ដូចជា៖ ជលផល និងព្រៃឈើ ត្រូវបានកំណត់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ក្រោមចំណុច ៦.៣.១។

## ២.២.ការវាយតម្លៃសន្តិសុខស្បៀងកម្រិតគ្រួសារ និងបញ្ហាប្រឈមនាពេលថ្មីៗ

លទ្ធភាពក្នុងការទទួលបានស្បៀងនៅកម្រិតគ្រួសារ ពឹងផ្អែកទៅលើការផលិតស្បៀងអាហារផ្ទាល់ខ្លួន និងការទទួលបានពីការទិញស្បៀងអាហារពីទីផ្សារ។ លទ្ធភាពក្នុងការទិញស្បៀងអាហារត្រូវបានកំណត់តាមរយៈការងារ និងប្រាក់ចំណូល (រាប់បញ្ចូល ការផ្ទេរប្រាក់ចំណូល) ប៉ុន្តែ ក៏ត្រូវបានកំណត់តាមរយៈតម្លៃស្បៀងអាហារផងដែរ។ អត្រាភាពក្រីក្រ និងអត្រាភាពក្រីក្រផ្នែកស្បៀងអាហារ ព្រមទាំងអត្រាប្រជាពលរដ្ឋដែលខ្វះអាហារូបត្ថម្ភ រមែងតែងត្រូវបានប្រើប្រាស់ទូទៅជាសូចនាករតំណាងឱ្យសន្តិសុខស្បៀងរបស់គ្រួសារ។ ការវិភាគខាងក្រោមទៅលើសន្តិសុខស្បៀងកម្រិតគ្រួសារ ផ្តោតទៅលើកំណើនសេដ្ឋកិច្ច ភាពក្រីក្រ តម្លៃស្បៀងអាហារ បៀវត្សរ៍ពិតប្រាកដ និងការទទួលទានអាហាររបស់គ្រួសារ។ ការប្រែប្រួលនៃសន្តិសុខស្បៀងរបស់គ្រួសារ ក្នុងអំឡុងពេលនៃវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចលើកចុងក្រោយ ត្រូវបានលើកយកមកពិភាក្សាជាមេរៀនបទពិសោធន៍ជាក់ស្តែង។

### កំណើនសេដ្ឋកិច្ច និងតម្លៃស្បៀងអាហារ ព្រមទាំងវិបត្តិសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៨/២០០៩

កំណើនសេដ្ឋកិច្ច គឺជាលក្ខខ័ណ្ឌមួយដ៏ចាំបាច់ ប៉ុន្តែលក្ខខ័ណ្ឌនេះ ពុំទាន់គ្រប់គ្រាន់ឡើយ សម្រាប់កាត់បន្ថយភាពក្រីក្រ។ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់ឆ្នាំ២០០៧ ប្រទេសកម្ពុជាទទួលបាននូវកំណើនសេដ្ឋកិច្ចមួយដ៏ខ្ពស់។ កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ បានធ្វើ

ឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទិញស្បៀងអាហារ តាមរយៈការបង្កើនប្រាក់ចំណូលក្នុងមួយនាក់ រហូតដល់ជិត៣ដង ចាប់ពី ២៤៨ដុល្លាសហរដ្ឋអាមេរិក ក្នុងឆ្នាំ១៩៩៤ រហូតដល់ ៧៣៩ដុល្លាសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៨[៨]។

**<u>រូបភាពទី៧</u> ៖ កំណើន GDP ១៩៩៤-២០១៣ (តម្លៃថេរ ២០១០)**




ប្រភព ៖MoP/NIS

កំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ធ្វើដំណើរស្របគ្នាទៅនឹងការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវសុខភាព និងការអប់រំ។ រាជរដ្ឋាភិបាលសម្រេចបាននូវកំណើនលទ្ធផលសន្តិសុខស្បៀងជារួម ក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ ហើយអត្រាកង្វះអាហារូបត្ថម្ភកុមារបានធ្លាក់ចុះជាបន្តបន្ទាប់ ព្រមជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់រវាងឆ្នាំ២០០០-២០០៥។ យ៉ាងណាមិញ វិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសកលលោកក្នុងឆ្នាំ២០០៧និងឆ្នាំ២០០៨ក៏បានបង្កឱ្យមានផលប៉ះពាល់ទៅលើសេដ្ឋកិច្ចកម្ពុជា ហើយកំណើនសេដ្ឋកិច្ច បានធ្លាក់ចុះជាបណ្តោះអាសន្នក្នុងឆ្នាំ២០០៩។

ការសិក្សាបានបង្ហាញឱ្យដឹងថា តម្លៃស្បៀងអាហារខ្ពស់ក្នុងឆ្នាំ២០០៨ បានរួមចំណែកឱ្យមាននូវការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាបែបអវិជ្ជមានមួយចំនួន ដូចជា៖ការផ្លាស់ប្តូរទៅទទួលទានអាហារដែលមានតម្លៃទាបជាងមុន[១០] ដែលនាំឱ្យមានការប៉ះពាល់ជាពិសេសចំពោះជនក្រីក្រនៅតំបន់ទីក្រុង[១១] ។ ម្យ៉ាងវិញទៀត អ្នកផលិតកសិផលដែលផ្សារភ្ជាប់ទៅនឹងទីផ្សារ ទទួលបានប្រយោជន៍ពីតម្លៃលក់កសិផលពីស្រែចម្ការ ក្នុងកម្រិតខ្ពស់ជាងមុន ហើយប្រាក់កម្រៃសម្រាប់ពលកម្មគ្មានជំនាញ

[៨] បើទោះជាដូច្នេះក្តី កំណើនសេដ្ឋកិច្ចមានមូលដ្ឋានចង្អៀត និងភាគច្រើនទទួលបានការជំរុញពីឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់។ ការវិនិយោគដោយផ្ទាល់ពីបរទេស (FDI)បានដើរតួនាទីសំខាន់ ជាពិសេសនៅក្នុងរយៈពេលមុនវិបត្តិដែលបានកើតឡើងលើកចុងក្រោយ (និងបានកើនឡើងពី ១២១លានដុល្លាសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៤ ទៅ ៨៦៨លានដុល្លាសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៧)។

[១០] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)ផលប៉ះពាល់នៃតម្លៃស្បៀងអាហារខ្ពស់នៅក្នុងប្រទេសកម្ពុជា ខែសីហា ឆ្នាំ២០០៨។

[១១] ចំណុចនេះ អាចពន្យល់អំពីកំណើនខ្ពស់នៃអត្រាស្គមស្គាំងរបស់កុមារនៅតំបន់ទីក្រុង ដូចមានផ្តល់សេចក្តីរាយការណ៍ដោយ CAS ក្នុងឆ្នាំ២០០៨

នៅក្នុងវិស័យកសិកម្ម បានមានការកើនឡើង ព្រមជាមួយនឹងកំណើនតម្លៃស្បៀងអាហារចម្បង (អត្រាភាពក្រីក្របានធ្លាក់ចុះ ក្នុងឆ្នាំ២០០៨ ជាពិសេស ចំពោះក្រុមដែលមានប្រាក់ចំណូលទាបជាងគេ)[១២]។ ស្ថានភាពនេះ បានមានការប្រែប្រួលក្នុងឆ្នាំ២០០៩ នៅពេលឱនភាពសេដ្ឋកិច្ចសកលលោក បានបង្កផលប៉ះពាល់អវិជ្ជមានទៅលើការងារ និងបៀវត្សរ៍នៅក្នុងឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ហើយការកាត់បន្ថយភាពក្រីក្រ ដែលបានកើនឡើងពីឆ្នាំ២០០៨ បានធ្លាក់ចុះទៅវិញបន្តិច។ ប្រជាពលរដ្ឋជាពិសេសស្ត្រីបានព្យាយាមសម្របទៅនឹងស្ថានភាពនេះដោយស្វែងរកការងារថ្មី ឬធ្វើការងារបន្ទាប់បន្សំបន្ថែមទៀត ជាពិសេសនៅក្នុងវិស័យកសិកម្ម។

រាជរដ្ឋាភិបាលកម្ពុជា បានឆ្លើយតបទៅនឹងវិបត្តិតម្លៃស្បៀងអាហារ និងសេដ្ឋកិច្ចដែលមានការធ្លាក់ចុះក្នុងឆ្នាំ២០០៩ ដោយចាត់វិធានការភ្លាមៗ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃតម្លៃស្បៀងអាហារ និងធាតុចូលកសិកម្មដែលមានកម្រិតខ្ពស់[១៣] និងវិធានការរយៈពេលខ្លី ដើម្បីលើកកម្ពស់កសិកម្មខ្នាតតូច និងបង្កើនការគ្របដណ្តប់នៃសំណាញ់សុវត្ថិភាពសង្គម (SSN)។ ស្របពេលជាមួយគ្នានោះដែរ ចំណុចខ្សោយផ្នែករចនាសម្ព័ន្ធ និងស្ថាប័ន ត្រូវបានដោះស្រាយតាមរយៈការអភិវឌ្ឍន៍គោលនយោបាយ ដើម្បីលើកកម្ពស់ប្រពលវប្បកម្ម ពិពិធកម្មកសិកម្ម និងកិច្ចគាំពារសង្គម ដើម្បីឱ្យមានការត្រៀមលក្ខណៈប្រសើរជាងមុន សម្រាប់វិបត្តិសង្គមសេដ្ឋកិច្ច និងប្រព័ន្ធបម្រុងស្បៀងអាហារជាតិ (គ្រាប់ពូជ) ត្រូវបានបង្កើតឡើង ដើម្បីរៀបចំសម្រាប់វិបត្តិនាពេលអនាគត។

### មេរៀនបទពិសោធន៍ពីវិបត្តិដែលបានកើតឡើងកន្លងមក៖

- អាស្រ័យដោយគ្រួសារភាគច្រើននៅតំបន់ទីក្រុង និងតំបន់ជនបទ សុទ្ធសឹងតែអ្នកទិញស្បៀងអាហារសម្រាប់ប្រើប្រាស់ ដូច្នេះ ការកើនឡើងនូវតម្លៃស្បៀងអាហារ ទំនងនឹងនាំឱ្យសុខុមាលភាពរបស់គ្រួសារមានការធ្លាក់ចុះ ជាពិសេសសម្រាប់ជនក្រីក្រ។
- អ្នកផលិតកសិផលបានឆ្លើយតបជាវិជ្ជមានទៅនឹងការលើកទឹកចិត្ត តាមរយៈការលក់កសិផលដោយផ្ទាល់ពីស្រែចម្ការរបស់ពួកគេក្នុងតម្លៃខ្ពស់ជាងមុន ប៉ុន្តែ ជាញឹកញាប់ ពួកគេតែងទទួលរងនូវអារម្មណ៍តានតឹង ដោយសារតែអស្ថេរភាពនៃតម្លៃកសិផលដែលកើតឡើងនៅពេលក្រោយ។
- ការប្រែប្រួលក្នុងទំហំតូចល្មមចំពោះប្រាក់ចំណូល និងលទ្ធភាពក្នុងការទិញស្បៀងអាហារ (ដោយសារតែតម្លៃខ្ពស់ជាងមុន ឬការបាត់បង់ការងារ) អាចធ្វើឱ្យគ្រួសារមួយចំនួន នៅក្នុងប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងភាពក្រីក្រ ដែលកត្តានេះ បណ្តាលឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់។

---

[១២] ធនាគារពិភពលោក ភាពក្រីក្រ និងផលប៉ះពាល់ទៅលើសង្គមនៃវិបត្តិសេដ្ឋកិច្ចសកល ខែមេសា ឆ្នាំ២០១១

[១៣] ក្រៅពីអន្តរាគមន៍ទីផ្សាររយៈពេលខ្លី ដើម្បីធ្វើឱ្យមានស្ថេរភាពនូវតម្លៃអង្ករ ចំណុចនេះផ្តោតយកចិត្តទុកដាក់ភាគច្រើនទៅលើគោលនយោបាយរូបិយប័ណ្ណ (បង្កើនទុនបម្រុងដែលត្រូវរក្សានៅធនាគារជាតិកម្ពុជា បង្កើនល័ក្ខខ័ណ្ឌតម្រូវចំពោះមូលធនអប្បបរមាសម្រាប់ធនាគារពាណិជ្ជ កម្ចីរយៈពេលខ្លីរបស់ធនាគារជាតិកម្ពុជា សម្រាប់ធនាគារក្នុងស្រុក។ល។) ឥណទានពិសេសសម្រាប់រោងម៉ាស៊ីនកិនស្រូវ ការលើកលែងពន្ធ និងការកាត់បន្ថយពន្ធទៅលើការវិនិយោគវិស័យកសិកម្ម និងឧស្សាហកម្ម អាហារូបករណ៍ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លីជូនដល់អតីតកម្មករ-កម្មការីរោងចក្រកាត់ដេរ និងយុវជនគ្មានការងារធ្វើ ព្រមទាំងកម្ចីខ្នាតតូចសម្រាប់ចាប់ផ្តើមធ្វើអាជីវកម្ម។

- ដើម្បីដោះស្រាយទៅនឹងផលប៉ះពាល់នៃវិបត្តិនេះ គ្រួសារបានឆ្លើយតប តាមរយៈការធ្វើការងារថ្មី (ជាញឹកញាប់ ជាការងារបណ្ដោះអាសន្ន) ជាពិសេសនៅក្នុងវិស័យកសិកម្ម។ បើទោះជាដូច្នេះក្ដី ពុំសូវមានឱកាសការងារដទៃទៀត (ក្រៅពីវិស័យកសិកម្ម) ដែលផ្ដល់ប្រាក់ចំណូលគ្រប់គ្រាន់ ក្នុងអំឡុងពេលនៃវិបត្តិឡើយ។
- សមត្ថភាពក្នុងការសន្សំប្រាក់ និងផ្ដល់កម្ចីរបស់គ្រួសារជាច្រើន បានធ្លាក់ចុះក្នុងអំឡុងពេលនៃវិបត្តិទាំងពីរ និងបង្កឱ្យមានផលប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយទៅនឹងវិបត្តិចម្បងៗ នៅពេលអនាគត។
- ប្រទេសកម្ពុជាអាចត្រូវធ្វើការកែសម្រួលជាថ្មីម្ដងទៀត ទៅនឹងសេដ្ឋកិច្ចសកលលោក ដែលកំពុងមានការរីកចម្រើនយឺតយ៉ាវ (បណ្ដាលមកពីស្ថានភាពវិបត្តិជំពាក់បំណុលបច្ចុប្បន្ននៅអឺរ៉ុប និងសហរដ្ឋ អាមេរិក) ដូច្នេះ រាជរដ្ឋាភិបាលត្រូវបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច លើកកម្ពស់ផលិតភាពកសិកម្ម និងបង្កើតឱកាសការងារនៅតំបន់ជនបទ។
- ប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គមមួយប្រកបដោយប្រសិទ្ធភាព (ដែលអាចឆ្លើយតបភ្លាមៗទៅនឹងវិបត្តិ) មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនៅពេលអនាគត និងលើកកម្ពស់សមត្ថភាពក្នុងការឆ្លើយតបទៅនឹងវិបត្តិ ព្រមទាំងមូលធនសហគមន៍របស់ជនក្រីក្រ និងជនដែលមានបញ្ហាអសន្តិសុខស្បៀង។

អាស្រ័យដោយកំណើននៃការនាំចេញសម្លៀកបំពាក់ដ៏ខ្លាំងក្លា ព្រមទាំងជាមួយនឹងភាពធូរស្រាលឡើងវិញនៅក្នុងវិស័យសំណង់ និងទេសចរណ៍ និងកំណើននៃការនាំចេញផលិតផលកសិកម្ម ឥឡូវនេះ សេដ្ឋកិច្ចរបស់កម្ពុជា បានវិលត្រឡប់មកកាន់ដំណាក់កាលរីកចម្រើនដូចកាលមុនពេលមានវិបត្តិ។ ជាមួយនឹងការប៉ាន់ប្រមាណទៅលើ អត្រាកំណើនសេដ្ឋកិច្ចប្រមាណ ៦,៥% និង GDP ចំនួន ៩៣១ ដុល្លាសហរដ្ឋអាមេរិកក្នុងមួយនាក់ នៅក្នុង ឆ្នាំ២០១២ GDPរបស់ប្រទេសអាចកើនឡើងលើស ១.០០០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយនាក់ ត្រឹមឆ្នាំ២០១៤។

## *អត្រាភាពក្រីក្រ និងវិសមភាព*

ព្រមជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ រាជរដ្ឋាភិបាលក៏សម្រេចបានផងដែរនូវវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ផ្អែកលើអត្រាភាពក្រីក្រដែលបានកំណត់និយមន័យថ្មី និងសម្រួលទៅតាមកម្រិតអតិផរណា[១៩] ភាពក្រីក្រត្រូវបានកាត់បន្ថយជាងពាក់កណ្ដាល ក្នុងរយៈពេលត្រឹមតែ៤ឆ្នាំប៉ុណ្ណោះ ដោយបានធ្លាក់ចុះពី ៤៧,៨% ក្នុងឆ្នាំ២០០៧ មកត្រឹមការប៉ាន់ប្រមាណចំនួន ១៨,៨% ក្នុងឆ្នាំ២០១៣។ បើទោះជាដូច្នេះក្ដី មានប្រជាពលរដ្ឋជាច្រើនដែលរស់នៅក្បែរខ្សែបន្ទាត់នៃភាពក្រីក្រ ហើយពួកគេ អាចធ្លាក់ទៅក្នុងភាពក្រីក្រវិញយ៉ាងងាយនៅពេលមានវិបត្តិ។

---

[១៩] ក្រសួងផែនការ ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា - អភិក្រមថ្មី (ការកំណត់និយមន័យឡើងវិញទៅលើខ្សែបន្ទាត់ភាពក្រីក្រ) ខែមេសា ឆ្នាំ២០១៣។ ខ្សែបន្ទាត់ភាពក្រីក្រថ្មី ត្រូវបានគណនាផ្អែកលើកញ្ចប់ស្បៀងអាហារយោងមួយ ក្នុងកម្រិត ២.២០០ គីឡូកាល់ឡូរី ដែលទទួលទានដោយគ្រួសារដែលស្ថិតនៅកម្រិតទាបជាងគេចន្លោះពី ៥% ទៅ ៣០% បូករួមនឹងសម្ភារៈមួយចំនួនដែលមិនមែនជាស្បៀង ព្រមទាំងការផ្ដល់ទឹកស្អាតសម្រាប់ទទួលទាន។

## រូបភាពទី៨ ៖ ការអភិវឌ្ឍន៍អត្រាភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ២០០៧-២០១១ (ប្រើប្រាស់ខ្សែបន្ទាត់ភាពក្រីក្រថ្មី)




ការប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០១១ ផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រថ្មី បង្ហាញឱ្យឃើញថា ភាពក្រីក្រសរុបមានចំនួន ២០,៥% និងភាពក្រីក្រផ្នែកស្បៀងអាហារមានចំនួនប្រមាណ ៣,៨% សម្រាប់ប្រទេសកម្ពុជា (ធៀបទៅនឹងឆ្នាំ ២០០៤ ដែលភាពក្រីក្រសរុបមានចំនួន ៦៣,២% និង ភាពក្រីក្រផ្នែកស្បៀងអាហារមានចំនួន ១៩,៧%)[១៥]។ បើទោះជាដូច្នេះក្តី ភាពក្រីក្រទូទៅ និងភាពក្រីក្រផ្នែកស្បៀងអាហារមានកម្រិតខ្ពស់ជាងនៅតំបន់ជនបទ ដែលជនក្រីក្រចំនួនប្រមាណ ៩១% រស់នៅទីនោះ។

## រូបភាពទី៩ ៖ ភាគរយនៃប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ និង ខ្សែបន្ទាត់នៃភាពក្រីក្រ ស្បៀងអាហារ ឆ្នាំ២០១១

| តំបន់ | អត្រាភាពក្រីក្រស្បៀងអាហារគិតជា% | អត្រាភាពក្រីក្រគិតជា% |
|---|---|---|
| ភ្នំពេញ[១៦] | 0.00 | 1.53 |
| តំបន់ទីក្រុងដទៃទៀត | 3.75 | 16.10 |
| តំបន់ជនបទ | 4.38 | 23.72 |
| ប្រទេសកម្ពុជា (គិតជាមធ្យម) | 3.80 | 20.50 |

ប្រភព ៖ ការប៉ាន់ប្រមាណរបស់ធនាគារពិភពលោក

អត្រាភាពក្រីក្ររវាងបណ្តាខេត្តផ្សេងៗគ្នា និងនៅក្នុងខេត្តផ្សេងៗគ្នា នៅតែបន្តមានភាពខុសគ្នាគួរឱ្យកត់សម្គាល់។ ការប៉ាន់ប្រមាណនៅកម្រិតថ្នាក់ស្រុក (ទទួលបានពីការប៉ាន់ប្រមាណភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភពីតំបន់តូចៗ ផ្អែកលើទិន្នន័យអង្កេតសង្គមសេដ្ឋកិច្ចនៅកម្ពុជា (CSES)

[១៥] តួលេខសម្រាប់ឆ្នាំ២០០៤ មានមូលដ្ឋានផ្អែកលើរបាយការណ៍ពីធនាគារពិភពលោក ដោយប្រើប្រាស់វិធីសាស្ត្រថ្មីនៃការគណនាខ្សែបន្ទាត់ភាពក្រីក្រ។

[១៦] បើទោះបីជាភាពក្រីក្រនៅតំបន់ទីក្រុងមានកម្រិតទាប បើធៀបទៅនឹងអត្រាកំណើននៅតំបន់ទីក្រុង ដែលត្រូវបានកំណត់ថាបន្តមានមានការកើនឡើន (២,២១% ពីឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០៨) សមាមាត្រនៃជនក្រីក្រងាយរងគ្រោះនៅតំបន់ទីក្រុងអាចកើនឡើង ជាពិសេស នៅតំបន់តាំងទីលំនៅរបស់ជនក្រីក្រជុំវិញរាជធានីភ្នំពេញ។

២០០៩)[១៧] បង្ហាញឱ្យឃើញអំពីឧប្បទ្ទវហេតុនៃភាពក្រីក្រមួយដែលស្ថិតនៅចន្លោះពី ៦,៥% ទៅ ៥០,៩% ជាមួយនឹងគំរូទូទៅមួយដែលភាពក្រីក្រមានកម្រិតទាប គួរឱ្យកត់សម្គាល់នៅក្នុងរាជធានីភ្នំពេញ មានកម្រិតខ្ពស់បន្តិចនៅតំបន់ទំនាប ជ្រលងទន្លេ និងមាត់ច្រាំងជុំវិញ បឹងទន្លេសាប ប៉ុន្តែភាពក្រីក្រមានកម្រិតខ្ពស់នៅតំបន់ខ្ពង់រាបភាគឦសាន។

ការវិភាគទិន្នន័យ CSES បង្ហាញឱ្យឃើញថា វិសមភាពនៃប្រាក់ចំណូល ក្រោយពេលមានការកើនឡើងជាបណ្ដោះអាសន្នក្នុងឆ្នាំ២០០៧ បានធ្លាក់ចុះក្នុងប្រទេសកម្ពុជា នៅតំបន់ទីក្រុង និងតំបន់ជនបទ ដែលកត្តានេះ បានរួមចំណែកគួរឱ្យកត់សម្គាល់ដល់ការកាត់បន្ថយអត្រាភាពក្រីក្រយ៉ាងគំហុក។

## រូបភាពទី១០ ៖ ភាគរយនៃការប្រើប្រាស់ស្បៀងអាហារ និងតម្លៃផលធៀបវិសមភាពនៅកម្ពុជា

| សូចនាករសមធម៌ប្រាក់ចំណូល | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|
| ការប្រើប្រាស់ស្បៀងអាហាររបស់ជនក្រីក្របំផុត ចំនួន២០% (គិតជា%) | 6.85 | 7.46 | 8.00 | 8.34 | 8.98 |
| កម្រិតវិសមភាព (GINI Coefficient) | 0.411 | 0.381 | 0.343 | 0.341 | 0.313 |

ប្រភព៖ របាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣ ក្រសួងផែនការ

ប្រសិនបើនិន្នាការនេះនៅតែបន្ត គោលដៅចំនួន២សម្រាប់សូចនាករCMDGs(អត្រាភាពក្រីក្រចំនួន១៩% និងការប្រើប្រាស់ស្បៀងអាហាររបស់ក្រុមប្រជាជនចំនួន២០%ដែលក្រីក្របំផុតមានចំនួនមិនតិចជាង ១០% នៃការប្រើប្រាស់ស្បៀងអាហារសរុប) ទំនងនឹងសម្រេចបាននៅចុងឆ្នាំ២០១៥។

### តម្លៃស្បៀង ៖

នៅដើមឆ្នាំ២០០៨ស្បៀងអាហារជាពិសេសគឺតម្លៃអង្ករបានកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជា ស្របតាមនិន្នាការសកលលោក។ លទ្ធភាពក្នុងការទិញស្បៀងអាហាររបស់គ្រួសារក្រីក្របានធ្លាក់ចុះជាបណ្ដោះអាសន្ន ដែលនាំឱ្យប៉ះពាល់ដល់គំរូនៃការប្រើប្រាស់ស្បៀងអាហារ និងអាចប៉ះពាល់ដល់ស្ថានភាពអាហារូបត្ថម្ភ និងសុខភាព។ តម្លៃស្បៀងអាហារ និងតម្លៃអង្ករបានធ្លាក់ចុះក្នុងឆ្នាំ២០០៩ ហើយក្រោយមក មានការកើនឡើងរយៈពេលខ្លីក្នុងឆ្នាំ២០១១និងបច្ចុប្បន្ន កំពុងមានស្ថេរភាព។

## រូបភាពទី១១៖ ការអភិវឌ្ឍន៍តម្លៃអង្ករចន្លោះពីខែមករាឆ្នាំ២០០៧ និងខែមេសាឆ្នាំ២០១៣




ប្រភព ៖ MAFF (តម្លៃលក់ដុំ) , WFP (តម្លៃលក់រាយ)

[១៧] សូមមើល MoP/WFP ការប៉ាន់ប្រមាណភាពក្រីក្រនិងកង្វះអាហារូបត្ថម្ភនៅតាមតំបន់តូចៗក្នុងប្រទេសកម្ពុជា ខែឧសភា ឆ្នាំ២០១៣។

បើទោះបីជាតម្លៃអង្ករបានធ្លាក់ចុះយ៉ាងគំហុក ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៨ ក៏ដោយ ប៉ុន្តែបានបង្ហាញឱ្យឃើញនូវនិន្នាការកើនឡើងរហូតដល់ឆ្នាំ២០១៣ ហើយកំពុងស្ថិតនៅកម្រិតមួយដែលខ្ពស់ជាងតម្លៃមុនពេលមានវិបត្តិនៅដើមឆ្នាំ២០០៧។ ផលធៀបនៃតម្លៃស្បៀងអាហារធៀបទៅនឹងតម្លៃសម្ភារៈដែលមិនមែនស្បៀងអាហារ ដែលជាសូចនាករមួយសម្រាប់វាស់ស្ទង់ទៅលើលទ្ធភាពទិញស្បៀងអាហាររបស់គ្រួសារ នៅចុងឆ្នាំ២០១១ នៅតែមានកម្រិតខ្ពស់ជាងចំនួន២២% បើធៀបទៅនឹងពេលដែលវិបត្តិតម្លៃស្បៀងអាហារ បានចាប់ផ្តើមកើតមានឡើងនៅដើមឆ្នាំ២០០៨[១៨]។

**រូបភាពទី១២ ៖ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ចំពោះតម្លៃសម្រាប់អ្នកប្រើប្រាស់ តម្លៃស្បៀងអាហារ និងតម្លៃសម្ភារៈដែលមិនមែនជាស្បៀងអាហារ ចាប់ពីខែមករា ឆ្នាំ២០០៧ ដល់ ខែមេសាឆ្នាំ២០១៣**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS)

អត្រាអតិផរណា ឆ្នាំ២០១៣ ធៀបនឹងឆ្នាំមុន សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ (CPI) ក៏ដូចជាសន្ទស្សន៍តម្លៃស្បៀងអាហារ(FPI) ដែលវាស់ពីថ្លៃម្ហូបអាហារច្រើនមុខលើថ្លៃទំនិញប្រើប្រាស់មួយកញ្ចប់ គឺ៤,៧% និង៦,២% ដែលចំនួននេះមានកម្រិតតិចតួចនៅឡើយ។

ការបាត់បង់លទ្ធភាពទិញស្បៀងអាហារ លទ្ធភាពក្នុងការទទួលបានស្បៀងអាហារមានកម្រិតកើតឡើងតែនៅពេលដែលពុំមានការផ្តល់សំណងតាមរយៈការបង្កើនបៀវត្សរ៍ជាក់ស្តែង សម្រាប់ទប់ទល់ទៅនឹងតម្លៃស្បៀងអាហារ ដែលកើនឡើងខ្ពស់ជាងមុន។ ក្រាហ្វិកខាងក្រោមបង្ហាញថាល័ក្ខខ័ណ្ឌនៃប្រាក់កម្រៃការងារ (ToT) សម្រាប់អត្រាប្រាក់ឈ្នួលពលកម្មប្រចាំថ្ងៃសម្រាប់ពលករគ្មានជំនាញ និងតម្លៃជាមធ្យមសម្រាប់អង្ករនៅជនបទ គុណភាពទាបបំផុត ចាប់ពីខែមករា ឆ្នាំ២០០៩ រហូតដល់ខែមីនា ឆ្នាំ២០១៣។ ថ្មីៗនេះ ល័ក្ខខ័ណ្ឌនៃប្រាក់កម្រៃការងារកំពុងមានភាពប្រសើរឡើង អាស្រ័យដោយអតិផរណាស្បៀងអាហារមានកម្រិតទាប ហើយថ្លៃឈ្នួលពលកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ ធៀបទៅនឹងសេចក្តីត្រូវការកម្លាំងពលកម្មដ៏ខ្លាំងក្លានៅក្នុងវិស័យកាត់ដេរ សំណង់ និងកសិកម្ម។

[១៨] វិទ្យាស្ថានជាតិស្ថិតិ ៖ សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ទូទៅ (CPI) ដែលប្រមូលដោយវិទ្យាស្ថានជាតិស្ថិតិ វាស់ស្ទង់ទៅលើតម្លៃកញ្ចប់ស្បៀងអាហារសម្រាប់ទទួលទាន ចំនួន ២៥៩ប្រភេទ។

**រូបភាពទី១៣ ៖លក្ខខ័ណ្ឌនៃប្រាក់កម្រៃការងារនៅទីជនបទសម្រាប់ពលករគ្មានជំនាញ និងតម្លៃអង្ករលក់រាយ នៅទីជនបទ**




| | | | | | |
|---|---|---|---|---|---|
| អត្រាប្រាក់កម្រៃសម្រាប់ពលករគ្មានជំនាញ(ជាមធ្យមក្នុងមួយឆ្នាំ)រៀល/ថ្ងៃ | 10.070 (2009) | 11.138 (2010) | 12.988 (2011) | 14.616 (2012) | 16.439 (2013) |

ប្រភព ៖ មូលដ្ឋានទិន្នន័យតម្លៃរបស់WFP

បើទោះបី ជាមានការអភិវឌ្ឍន៍ជាវិជ្ជមាន ទាក់ទងទៅនឹងលទ្ធភាពទិញស្បៀងអាហាររបស់គ្រួសាររយៈពេល២ឆ្នាំចុងក្រោយ ជនក្រីក្រនៅតែបន្តមានភាពងាយរងគ្រោះខ្ពស់ទៅនឹងតម្លៃទំនិញដែលគ្មានស្ថេរភាពនៅក្នុងប្រទេសកម្ពុជា ដែលចំណូលមួយភាគធំរបស់គ្រួសារ ត្រូវបានចំណាយទៅលើស្បៀងអាហារ។ ភាគរយជាមធ្យមនៃស្បៀងអាហារនៅក្នុងចំណាយសរុបរបស់គ្រួសារ បានធ្លាក់ចុះ ដោយសារតែប្រាក់ចំណូលខ្ពស់ជាងមុន និងលក្ខខ័ណ្ឌសង្គម សេដ្ឋកិច្ចប្រសើរជាងមុន អាស្រ័យដោយមធ្យមភាគចំណាយមានចំនួន៦៨% ក្នុងឆ្នាំ១៩៩៣ មកត្រឹម៥៥% ក្នុងឆ្នាំ២០០៤ និង៥១% ក្នុងឆ្នាំ២០១១[១៩]។ ប៉ុន្តែ គ្រួសារដែលស្ថិតនៅក្នុងក្រុមក្រីក្រជាងគេបំផុត នៅតែចំណាយថវិកាគ្រួសាររបស់ពួកគេជាងពីរភាគបីទៅលើស្បៀងអាហារ។ សូម្បីតែនៅតំបន់ជនបទ គ្រួសារជាច្រើន គឺជាអ្នកទិញស្បៀងអាហារទាំងស្រុង[២០] ហើយពួកគេពុំទទួលបានប្រយោជន៍ពីការកើនឡើងនូវតម្លៃស្រូវ អង្ករ និងប្រភេទអាហារចម្បងៗដទៃទៀត ដែលលក់នៅឯស្រែចម្ការឡើយ។

## ការបរិភោគស្រូបស្បៀង ៖

យោងតាមការវិភាគនិន្នាការសន្តិសុខស្បៀង[២១] ដោយផ្អែកលើទិន្នន័យចំណាយលើស្បៀងអាហារ ដែលទទួលបានពីការអង្កេត CSES ឆ្នាំ២០០៤ និង២០០៩ ការបរិភោគស្រូបស្បៀងអាហារជាទូទៅ បានមានភាពប្រសើរឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលនេះ៖ ប្រជាពលរដ្ឋកម្ពុជាចំនួន ៣៣%

---

[១៩] សូមមើលឯកសារធនាគារពិភពលោកប្រចាំប្រទេសកម្ពុជាខែធ្នូឆ្នាំ២០០៩៖ លទ្ធផលនៃភាពក្រីក្រដោយប្រើវិធីសាស្ត្រថ្មីឆ្នាំ២០១១

[២០] សូមមើល ៖ ការប៉ាន់ប្រមាណឆាប់រហ័សនៃផលប៉ះពាល់របស់កំណើនតម្លៃស្បៀងអាហារទៅលើជនក្រីក្រ និងជនងាយរងគ្រោះ និង ការឆ្លើយតបគោលនយោបាយនៅក្នុងប្រទេសកម្ពុជា CDRIខែមិថុនា ឆ្នាំ២០១២។ នៅក្នុងបរិបទនេះ គេត្រូវពិចារណាថា ប្រមាណ២៥% នៃគ្រួសារជនបទ ពុំមានដីធ្លី ហើយប្រមាណ ២០-២៥% ទៀត មានដីកសិកម្មតិចជាង ០,៥ ហិកតា។

[២១] សូមមើលរបាយការណ៍វិភាគនិន្នាការសន្តិសុខស្បៀងCSES 2004 និង2009, NIS/FAO ខែមេសា ឆ្នាំ២០០១។

ក្នុងឆ្នាំ២០០៩ ខ្វះអាហារូបត្ថម្ភ (ខ្វះស្បៀង) ទទួលទានតិចជាងតម្រូវការថាមពលប្រចាំថ្ងៃអប្បបរមា បើប្រៀបធៀបទៅនឹងឆ្នាំ២០០៤ដែលមានចំនួន៣៧%[២២]។ បើទោះជាដូច្នេះក្តី កង្វះអាហារូបត្ថម្ភមានកម្រិតខ្ពស់ជាងគួរឱ្យកត់សម្គាល់ ក្នុងឆ្នាំ២០០៩ (៥៩%) នៅក្នុងចំណោមក្រុមប្រជាពលរដ្ឋដែលមិនសូវមានទ្រព្យសម្បត្តិ។

ថ្លៃចំណាយសម្រាប់ទិញ ១.០០០ kcal គិតជារៀល (តម្លៃឯកតាថាមពលអាហារ) បានកើនឡើងទ្វេដងពីតម្លៃ ៧០០ រៀល ក្នុងឆ្នាំ២០០៤ រហូតដល់ ១.៤០០ រៀល ក្នុងឆ្នាំ២០០៩ ដែលបណ្តាលមកពីតម្លៃស្បៀងអាហារកើនឡើងខ្ពស់ក្នុងឆ្នាំ២០០៨។ ក្នុងឆ្នាំ២០០៩ គ្រួសារនៅក្នុងប្រទេសកម្ពុជាបានទិញស្បៀងអាហាររបស់ពួកគេជាមធ្យម ចំនួន៤៩% ពីទីផ្សារ ហើយសូម្បីតែនៅតំបន់ជនបទក៏ដោយ ស្បៀងអាហារដែលគេប្រើប្រាស់ចំនួន ៤៣% ត្រូវបានទិញពីទីផ្សារ (បើធៀបទៅនឹងតម្លៃស្បៀងអាហារដែលមានកម្រិតខ្ពស់ប្រជាជនដែលរស់នៅតំបន់ជនបទបានកាត់បន្ថយការទិញស្បៀងអាហារបន្តិចបន្តួច និងបានបង្កើនការប្រើប្រាស់ស្បៀងអាហារដែលពួកគេផលិតខ្លួនឯង)។

ស្របគ្នាទៅនឹងនិន្នាការសកលលោក ការប្រើប្រាស់កាបូអ៊ីដ្រាត បានធ្លាក់ចុះនៅក្នុងប្រទេសកម្ពុជា ដោយឡែក ការប្រើប្រាស់ខ្លាញ់ និងប្រូតេអ៊ីន បានកើនឡើងនៅចន្លោះឆ្នាំ២០០៤ និង ២០០៩ ដែលបង្ហាញឱ្យឃើញអំពីការទទួលទានអាហារដែលមានគុណភាពម៉ាក្រូជីវជាតិប្រសើរជាងមុន។ សម្រាប់ម៉ាក្រូជីវជាតិទាំង៣ ការទទួលទានជាមធ្យមរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងឆ្នាំ២០០៩ ស្ថិតនៅក្នុងចន្លោះអប្បបរមា/អតិបរមា ដែលអង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍។ បន្ថែមពីនេះទៀត ពិពិធភាពអាហារបានផ្លាស់ប្តូរនៅក្នុងចំណោម ប្រជាពលរដ្ឋកម្ពុជា ដោយពួកគេទទួលទានត្រី សាច់ ស៊ុត និង សណ្តែកច្រើនជាងមុន ប៉ុន្តែ ពួកគេកាត់បន្ថយការទទួលទានបាយ និងបន្លែ ក្នុងឆ្នាំ២០០៩ បើធៀបទៅនឹងរយៈពេលកាលពី៥ឆ្នាំមុន[២៣]។ ជារួម គំហើញដែលទទួលបានពីការវិភាគបានបង្ហាញឱ្យដឹងថា ការទទួលទានអាហារសម្រាប់ប្រជាពលរដ្ឋទាំងអស់បានកើនឡើង និងមានគុណភាព និងពិពិធភាពប្រសើរជាងមុន ក្នុងឆ្នាំ២០០៩ បើធៀបទៅនឹងឆ្នាំ២០០៤ បើទោះបីជាមានផលប៉ះពាល់អវិជ្ជមាននៃវិបត្តិតម្លៃស្បៀងអាហារក៏ដោយ[២៤]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការធ្វើឱ្យប្រសើរទូទៅទាក់ទងទៅនឹងការទទួលទានម្ហូបអាហារសម្រាប់ប្រជាពលរដ្ឋកម្ពុជាជាច្រើនក្នុងរបបអាហារប្រចាំថ្ងៃ នៅតែមិនបានផ្តល់មីក្រូសារជាតិគ្រប់គ្រាន់។

---

២២ សូមមើលរបាយការណ៍វិភាគនិន្នាការសន្តិសុខស្បៀង ។ MDERគឺជាមធ្យមភាគនៃតម្រូវការថាមពលអប្បបរមា ដោយពិចារណា ទៅលើរចនាសម្ព័ន្ធភេទ និងអាយុរបស់ក្រុមប្រជាជនមួយ។ សម្រាប់ឆ្នាំ២០០៩ គេបានធ្វើការប៉ាន់ប្រមាណថា MDERមានចំនួន ១៧៦២kcal/ក្នុង១នាក់/ក្នុង១ថ្ងៃ ក្នុងប្រទេសកម្ពុជា។ គោលគំនិតនៃកង្វះអាហារូបត្ថម្ភមានភាពខុសគ្នាពីភាពក្រីក្រផ្នែកស្បៀងអាហារ ហើយតួលេខសម្រាប់សូចនាករទាំងពីរនេះ មិនអាចយកមកធ្វើការប្រៀបធៀបគ្នាបានឡើយ។

២៣ សម្រាប់គ្រប់ទិន្នន័យទាំងអស់ សូមមើលរបាយការណ៍វិភាគទិន្នន័យសន្តិសុខស្បៀង របស់ NIS/FAOឆ្នាំ២០១១។

២៤ បើទោះជាដូច្នេះក្តី ពុំមានភស្តុតាងបញ្ជាក់ថាជនក្រីក្របានធ្វើឱ្យការទទួលទានមីក្រូជីវជាតិរបស់ពួកគេមានភាពប្រសើរឡើងឡើយ។ អាស្រ័យដោយការអង្កេត CSESត្រូវបានអនុវត្តពេញមួយឆ្នាំក្នុងឆ្នាំ២០០៩ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ប្រហែលជាមិនត្រូវបានឆ្លុះបញ្ចាំងពេញលេញនៅក្នុងទិន្នន័យនេះឡើយ។

## រូបភាពទី១៤ ៖ ភាគរយនៃការទទួលទានថាមពលចំណីអាហារពីម៉ាក្រូជីវជាតិ ដោយយោងទៅតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក




ប្រភព ៖ NIS, របាយការណ៍វិភាគនិន្នាការសន្តិសុខស្បៀង

ភាពប្រសើរឡើងនៃការទទួលទានអាហារនៅក្នុងគ្រួសារ ពុំមានន័យថាមានភាពប្រសើរឡើងចំពោះអាហារូបត្ថម្ភរបស់កុមារឡើយ។របបអាហារចម្រុះនិងគុណភាពអាហារការបែងចែកអាហារនៅក្នុងគ្រួសារ និងការប្រព្រឹត្តដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ ព្រមទាំងសមត្ថភាពរបស់អ្នកថែទាំកុមារ និងលទ្ធភាពក្នុងការទទួលបានសេវាសុខភាព អនាម័យ និងទឹកស្អាត សុទ្ធសឹងតែជាកត្តាដែលបង្កការប៉ះពាល់ទៅលើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ។ ការកើនឡើងនូវតម្លៃស្បៀងអាហារ និងវិបត្តិសេដ្ឋកិច្ចសកលលោកក្នុងឆ្នាំ២០០៨/២០០៩ហាក់បីដូចជាបានបង្កផលប៉ះពាល់ទៅលើនិន្នាការរយៈពេលវែងក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសន្តិសុខស្បៀង និងអាហារូបត្ថម្ភជារួម (អាហារូបត្ថម្ភកុមារ) ព្រមជាមួយនឹងការកាត់បន្ថយភាពក្រីក្រ។ ខណៈពេលដែលបរិមាណគំរូការប្រើប្រាស់អាហាររបស់គ្រួសារនីមួយៗ បានមានភាពប្រសើរឡើង មូលហេតុភាគច្រើនទំនងដោយសារការប្រើប្រាស់និងការបើតស្រូបអាហារមានការកើនឡើងដែរ។

ស្រូប

រូបភាពទី១៥ ៖ និន្នាការនៃសូចនាករភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភ (២០០០-២០១១)




ប្រភព ៖ CDHS 2000, 2005, 2010, CSES 2004, 2009/របាយការណ៍នៃការវិភាគនិន្នាការសន្តិសុខស្បៀង របស់វិទ្យាស្ថានជាតិស្ថិតិ (NIS)

## ២.៣. ការវាយតម្លៃអាហារូបត្ថម្ភកុមារ និងមាតា

### អាហារូបត្ថម្ភកុមារ ៖

ស្ថានភាពអាហារូបត្ថម្ភកុមារអាយុក្រោម៥ឆ្នាំ គឺជាសូចនាករលទ្ធផលសរុបសម្រាប់ស្ថានភាពអសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ ឬ ថ្នាក់មូលដ្ឋាន [២៥]។

កង្វះអាហារូបត្ថម្ភនៅក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ ត្រូវបានវាស់ស្ទង់តាមរយៈសូចនាករចំនួន៣ ៖

(១). អត្រានៃភាពក្រេះក្រិន (កម្ពស់ទាបធៀបនឹងអាយុ) ចង្អុលបង្ហាញអំពីសមាមាត្រនៃកុមារដែលប្រឈមទៅនឹងកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃឬរយៈពេលវែង

(២). អត្រាកុមារមិនគ្រប់ទម្ងន់ (ទម្ងន់ទាបធៀបនឹងអាយុ) ចង្អុលបង្ហាញ អំពីសមាមាត្រនៃកុមារដែលប្រឈមទៅនឹងការច្របាច់បញ្ចូលនៃកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃនិងស្រួចស្រាវ

[២៥] អាស្រ័យដោយកុមារកង្វះអាហារូបត្ថម្ភមានការប្រឈមខ្ពស់ទៅនឹងការឆ្លងរោគជំងឺ និងការស្លាប់ ៥៤%នៃគ្រប់ករណីទាំងអស់នៃមរណភាពកុមារអាយុក្រោម៥ឆ្នាំក្នុងប្រទេសកម្ពុជា មានទំនាក់ទំនងទៅនឹងកង្វះអាហារូបត្ថម្ភ។ កង្វះអាហារូបត្ថម្ភ ក៏មានផល ប៉ះពាល់អវិជ្ជមានទៅលើការរីកចម្រើន និងការអភិវឌ្ឍន៍ផ្នែករាងកាយ និងខួរក្បាលរបស់កុមារផងដែរ ដែលនាំឱ្យមានផលប៉ះពាល់បន្តទៀតទៅលើសក្ដានុពលរបស់ពួកគេ។

(៣). អត្រានៃភាពស្គមស្គាំង (ទម្ងន់ទាបធៀបនឹងកម្ពស់) ចង្អុលបង្ហាញអំពីសមាមាត្រនៃកុមារ ដែលមានបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS) ចំនួន៣ ឆ្នាំ២០០០, ២០០៥, ២០១០ និងការអង្កេតមនុស្សសាស្ត្រនៅកម្ពុជាចំនួន១ (ឆ្នាំ២០០៨) ផ្តល់នូវនិន្នាការអំពីកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ (អាយុក្រោម៥ឆ្នាំ) ចន្លោះពីឆ្នាំ២០០០ ទៅ ឆ្នាំ២០១០ (សូមមើលរូបភាពទី១៦)។

ការវិភាគនិន្នាការមួយ ទៅលើកត្តាមនុស្សសាស្ត្ររបស់កុមារ បានបង្ហាញឱ្យដឹងថាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ចំពោះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ នៅចន្លោះឆ្នាំ ២០០០ និង២០០៥ ប៉ុន្តែ ចាប់តាំងពីពេលនោះមក ក៏លែងមានការរីកចម្រើន។ កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ នៅក្នុងចំណោមកុមារ (ក្រេះក្រិន) ដែលពុំមានការឆ្លើយតបចំពោះការផ្លាស់ប្តូររយៈពេលខ្លី បានធ្លាក់ចុះនៅចន្លោះឆ្នាំ២០០៥ និង២០០៨ (ឆ្នាំដែលមានវិបត្តិតម្លៃស្បៀងអាហារ) ពី៤៣,២៝ មកត្រឹម ៣៩,៥% និងមានសភាពថេរហូតដល់ឆ្នាំ២០១០ (៣៩,៩%)។ វឌ្ឍនភាព ចំពោះភាពមិនគ្រប់ទម្ងន់នៅក្នុងចំណោមកុមារក៏មានភាពថេរផងដែរ ក្នុងអំឡុងឆ្នាំ២០០៥ និងឆ្នាំ២០១០ (២៨,២% និង ២៨,៣%)។ សម្រាប់ កង្វះអាហារូបត្ថម្ភស្រួចស្រាវ(ស្គមស្គាំង) និន្នាការបានមានភាពបញ្ច្រាសត្រឡប់ទៅវិញ ហើយប្រេវ៉ាឡង់របស់វាបានកើនឡើងនៅក្នុងប្រទេសកម្ពុជាពី ៨,៤% (២០០៥) ទៅ ៨,៩% (២០០៨) រហូតដល់១០,៩% (២០១០) ហើយបច្ចុប្បន្ននេះ មានការប៉ាន់ប្រមាណថាមានករណីកុមារស្គមស្គាំងធ្ងន់ធ្ងរចំនួន ៦៦.០០០ ទៅ ៨៣.០០០នាក់ នៅក្នុងប្រទេសជារៀងរាល់ឆ្នាំ។

រូបភាពទី១៦៖ និន្នាការនៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ ចាប់ពីឆ្នាំ២០០០-២០១០




ប្រភព៖ CDHS 2000, 2005, 2010, ការអង្កេតមនុស្សសាស្ត្រនៅកម្ពុជា ២០០៨

- **គម្លាតរវាងតំបន់ជនបទ និងតំបន់ទីក្រុង** កំពុងតែធំឡើងជាលំដាប់។ ក្នុងឆ្នាំ២០១០ កុមារចំនួន ៤២,២% ខ្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ(ក្រេះក្រិន) និង ៣០% មិនគ្រប់ទម្ងន់នៅតំបន់ជនបទ បើធៀបទៅនឹងតំបន់ទីក្រុង ដែលអត្រាកុមារក្រេះក្រិនមានចំនួន ២៧,៥% និងមិនគ្រប់

ទម្ងន់ចំនួន ១៨,៤% [២៦]។ បើទោះបីជាវិសាលភាពនៃកង្វះអាហារូបត្ថម្ភរបស់កុមារមានអត្រាខ្ពស់នៅតាមតំបន់ជនបទ ក៏បញ្ហាអសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅតាមទីក្រុងនៅតែមានក្នុងប្រទេសកម្ពុជា ជាពិសេសនៅតំបន់ក្រីក្រ និងតំបន់ជុំវិញរាជធានីភ្នំពេញ [២៧]។

- ចរិកលក្ខណៈមួយដ៏សំខាន់នៃប្រេវ៉ាឡង់របស់កង្វះអាហារូបត្ថម្ភកុមារ នៅប្រទេសកម្ពុជា គឺត្រង់ថាវាមានភាព **ខុសប្លែកគ្នាយ៉ាងសម្បើម ដោយយោងទៅតាមតំបន់ភូមិសាស្ត្រនិងក្រុមសង្គម**។ ចំណុចនេះ គូសបញ្ជាក់អំពីសេចក្តីត្រូវការដ៏សំខាន់ក្នុងការកំណត់អត្តសញ្ញាណ និងកំណត់គោលដៅគ្រួសារដែលខ្វះអាហារូបត្ថម្ភ និងជួបប្រទះបញ្ហាអសន្តិសុខស្បៀងទៅតាមតំបន់និងក្រុមសង្គមដើម្បីផ្តល់អន្តរាគមន៍ដែលមានប្រសិទ្ធភាពបំផុត។ភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយទៀត ចំពោះកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ(គ្រេះក្រិន) និង កង្វះ អាហារូបត្ថម្ភស្រួចស្រាវ (ស្គមស្គាំង) មានបង្ហាញនៅក្នុងផែនទីចំនួន២ នៅក្នុងរូបភាពទី១៧។ នៅក្នុងខេត្តចំនួន ១៥ កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃក្នុងចំណោមកុមារកំពុងស្ថិតនៅកម្រិតមួយដ៏ធ្ងន់ធ្ងរ។

[២៦] ក្នុងឆ្នាំ២០០៥ ទាំងតំបន់ទីក្រុង និងតំបន់ជនបទ មានអត្រាកុមារមិនគ្រប់ទម្ងន់ចំនួន ២៨%។ ក្នុងឆ្នាំ២០១០ អត្រានេះមានភាពខុសគ្នាជាង១០%អាស្រ័យដោយកម្រិតនៃភាពមិនគ្រប់ទម្ងន់នៅតំបន់ទីក្រុងមានចំនួន១៨,៩%និងនៅតំបន់ជនបទមានចំនួន ២៨,៣%។

[២៧] វិបត្តិតម្លៃស្បៀងអាហារ និងការធ្វើអង្កេតមនុស្សសាស្ត្រក្នុងឆ្នាំ២០០៨កន្លងមកបង្ហាញពីអត្រាកង្វះអាហារូបត្ថម្ភ (ស្គមស្គាំង) ស្រួចស្រាវកម្រិតខ្ពស់គួរឱ្យព្រួយបារម្ភក្នុងតំបន់ក្រីក្រមួយចំនួននៃរាជធានីភ្នំពេញ(១៦%) និងការស្ទង់មតិមូលដ្ឋាននាពេលថ្មីៗនេះបានបង្ហាញពីអត្រាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃកម្រិតខ្ពស់ក្នុងខណ្ឌចំនួន២នៃរាជធានីភ្នំពេញ (FAO,ការវាយតម្លៃជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅតំបន់ទីក្រុង, ខែមិថុនា ឆ្នាំ២០១២)។

## រូបភាពទី១៧ ៖ ផែនទីអំពីអត្រាប្រេវ៉ាឡង់តំបន់ចំពោះបញ្ហាក្រេះក្រិន និងស្គមស្គាំង ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ (CDHS២០១០) [២៨]







ប្រភព ៖ ផែនទីទាំងពីរទទួលបានពីWFP

[២៨] ឧទាហរណ៍ អត្រាក្រេះក្រិននៅកម្រិតថ្នាក់ជាតិ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ ក្នុងឆ្នាំ២០១០ មានចំនួន ៣៩,៩% ទូទាំងប្រទេស ដោយឡែក វាមានកម្រិតត្រឹម ២៥,១% ក្នុងរាជធានីភ្នំពេញ ២៦,៥% ក្នុងខេត្តបាត់ដំបង/ប៉ៃលិន (ខេត្តដែលមានកម្រិតទាបជាងគេបំផុត) ប៉ុន្តែក្នុងខេត្តសៀមរាប វាមានកម្រិតរហូតដល់ ៥០,៣% មណ្ឌលគិរី/រតនៈគិរី ៥៤,៩% និង ព្រះវិហារ/ស្ទឹងត្រែង ចំនួន ៥៦,៨%។ បន្ថែមពីនេះទៀត វាមានភាពខុសគ្នាយ៉ាងទូលំទូលាយ ចំពោះអត្រាក្រេះក្រិននៅកម្រិតថ្នាក់ឃុំ (ចាប់ពី ១៨% ទៅ ៦២%) និងអត្រា មិនគ្រប់ទម្ងន់ (ចាប់ពី ១០% ទៅ ៥០%)។ សូមមើលការប៉ាន់ប្រមាណភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភ នៅតាមតំបន់តូចៗក្នុងប្រទេសកម្ពុជា របស់ MoP/WFPឆ្នាំ២០១៣។

ការវិភាគមួយដែលលម្អិតជាងនេះ ទៅលើទិន្នន័យទទួលបានពីការអង្កេត CDHS ឆ្នាំ២០១០ [២៩] បង្ហាញឱ្យដឹងថា ៖

- កូនរបស់ម្តាយដែលគ្មានការអប់រំ មានអត្រាកង្វះអាហារូបត្ថម្ភខ្ពស់ជាងកូនរបស់ម្តាយដែលមានការអប់រំ។ ចំណុចនេះបង្ហាញអំពី**សារៈសំខាន់នៃការអប់រំស្ត្រី** ដើម្បីឱ្យពួកគេមានការអនុវត្តន៍អាហារូបត្ថម្ភ និងការថែទាំ កូនឱ្យបានសមស្រប [៣០]។
- កុមារទំនងនឹងមិនគ្រប់ទម្ងន់ ឬ មានភាពក្រេះក្រិន ប្រសិនបើគ្រួសាររបស់ពួកគេអនុវត្តការបន្ទោបង់ពាសវាលពាសកាល។ ចំណុចនេះ គូសបញ្ជាក់អំពី**សារៈសំខាន់នៃការអនុវត្តអនាម័យល្អ** ដើម្បីអាហារូបត្ថម្ភកុមារ។
- កុមារដែលបានទទួល**ការបំបៅដោះម្តាយ**មិនសូវមានភាពក្រេះក្រិន ឬ មិនគ្រប់ទម្ងន់ឡើយ បើធៀបទៅនឹងកុមារ ដែលមិនបានទទួលការបំបៅដោះម្តាយ។
- **ភាពក្រេះក្រិននិងមិនគ្រប់ទម្ងន់មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងស្ថានភាពក្រីក្រ**របស់គ្រួសារ [៣១]។ នៅក្នុងចំណោមក្រុមដែលមានភាពក្រីក្រជាងគេ ក្នុងឆ្នាំ២០១០ មានកុមារក្រេះក្រិនច្រើនជាងក្រុមដែលមានទ្រព្យធនខ្ពស់ជាងគេរហូតដល់ពីរដង (៥១,១% ធៀបទៅនឹង ២៣,១%) ដោយឡែក កង្វះអាហារូបត្ថម្ភស្រួចស្រាវ (ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពសុខភាពរបស់កុមារ) ហាក់បីដូចជាពុំមានទំនាក់ទំនងទៅនឹងស្ថានភាពក្រីក្រឡើយ។ បើទោះជាដូច្នេះក្តី ភាពក្រីក្រពុំមែនជាមូលហេតុតែម្យ៉ាងដែលបណ្តាលឱ្យកុមារខ្វះអាហារូបត្ថម្ភឡើយ អាស្រ័យដោយសូម្បីតែនៅក្នុងចំណោមក្រុមដែលមានទ្រព្យធនខ្ពស់ ក៏មានកុមារម្នាក់ក្នុងចំណោម ៥នាក់ មិនគ្រប់ទម្ងន់ផងដែរ។

---

[២៩] ផ្អែកលើការវិភាគទំនាក់ទំនងដែលអថេរសំខាន់ៗមួយចំនួនត្រូវបានបញ្ចូល (អនុវត្តដោយអង្គការយូនីសេហ្វ និងធនាគារពិភពលោក ក្នុងឆ្នាំ២០១៣)។

[៣០] បើទោះជាដូច្នេះក្តី ពុំមានទំនាក់ទំនងដាច់ខាតឡើយ។ ម្តាយដែលគ្មានការអប់រំក៏អាចមានកូនដែលទទួលបានអាហារូបត្ថម្ភល្អប្រសើរផងដែរ។ សូមមើល N. Ikeda, Y. Irieb & K. Shibuya. កត្តាកំណត់នៃការកាត់បន្ថយភាពក្រិនរបស់កុមារនៅក្នុងប្រទេសកម្ពុជា: ការវិភាគទិន្នន័យដែលបានពីការវាស់ស្ទង់ ប្រជាសាស្ត្រនិងសុខភាពចំនួនបី។

[៣១] ចំណុចនេះ មិនត្រឹមតែមានទំនាក់ទំនងទៅនឹងលទ្ធភាពមានកម្រិតរបស់គ្រួសារក្រីក្រក្នុងការទិញស្បៀងអាហារ ដែលនាំឱ្យកូនរបស់ពួកគេទទួលទានចំណីអាហារតិចជាងមុន (ឬ គុណភាពទាបជាងមុន) ប៉ុណ្ណោះទេ ប៉ុន្តែសមត្ថភាពថែទាំរបស់ម្តាយក្រីក្រ (ជាទូទៅ) ក៏ធ្លាក់ចុះផងដែរ (ការអប់រំទាប មិនសូវមានពេលវេលា) ដែលកត្តាទាំងនេះ រារាំងពួកគេក្នុងការផ្តល់អាហារដល់កូនឱ្យបានសមស្រប។ ប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ និងមីក្រូសារជាតិនៅក្នុងចំណោមម្តាយក្រីក្រ ព្រមទាំងលទ្ធភាពមានកម្រិតរបស់គ្រួសារក្រីក្រក្នុងការទទួលបានទឹកស្អាត និងអនាម័យ គឺជាកត្តាដទៃទៀត ដែលពន្យល់អំពីទំនាក់ទំនងរវាងស្ថានភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភកុមារ។

## រូបភាពទី១៨ ៖ កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារបែងចែកទៅតាមទ្រព្យសម្បត្តិ ការបន្ទោបង់ពាសវាលពាសកាល ការអប់រំរបស់ម្តាយ និងការបំបៅដោះម្តាយ




ប្រភព ៖CDHS 2010 ( **ការវិភាគរបស់ធនាគារពិភពលោក** )

ការផ្តល់អាហារបន្ថែមមិនគ្រប់គ្រាន់ក្រោយពេលដែលកុមារអាយុបាន៦ខែ រួមចំណែកគួរឱ្យកត់សម្គាល់ចំពោះអត្រាកង្វះអាហារូបត្ថម្ភកុមារដែលបន្តមានកម្រិតខ្ពស់។កំនើនយ៉ាងខ្ពស់នៃការធ្លាក់ចុះកំណើននៃបញ្ហាកង្វះអាហារូបត្ថម្ភ ចាប់ផ្តើមតាមរយៈការណែនាំការផ្តល់អាហារបំពេញបន្ថែមនេះ។ ក្នុងឆ្នាំ២០១០ មានកុមារ ២៤% ប៉ុណ្ណោះ ដែលមានល័ក្ខខ័ណ្ឌស្របទៅតាមបទដ្ឋានអប្បបរមាទាក់ទងទៅនឹងការអនុវត្តទាំង៣ នៃគោលនយោបាយចិញ្ចឹមទារក និងកុមារតូច (IYCF)[៣២]។ ដូច្នេះការផ្តល់អាហារបន្ថែមព្រមទាំងឥរិយាបថ និងការទទួលបានអាហារដែលមានបញ្ចូលមីក្រូសារជាតិ គឺជាបញ្ហាមួយសំខាន់បំផុតក្នុងចំណោមបញ្ហាដទៃទៀតទាក់ទងទៅនឹងអាហារូបត្ថម្ភកុមារក្នុងប្រទេសកម្ពុជា។

បើទោះបីជាពុំមានភាពរីកចម្រើន ទាក់ទងទៅនឹងការកាត់បន្ថយជាទូទៅ ចំពោះបញ្ហាកង្វះអាហារូបត្ថម្ភកុមារ នៅចន្លោះឆ្នាំ២០០៥ និងឆ្នាំ២០១០ ក៏ដោយ លទ្ធផលអាហារូបត្ថម្ភដទៃទៀត និងសូចនាករអំពីការប្រព្រឹត្ត និងសេវាអាហារូបត្ថម្ភសំខាន់ៗ បានមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។

[៣២] ៨៣% បានទទួលទឹកដោះម្តាយ ឬ ផលិតផលទឹកដោះដទៃទៀត , ៧០% បានទទួលអាហារ ក្នុងកម្រិតចំនួនដងអប្បបរមា ប៉ុន្តែ មានតែ ៣៧% ប៉ុណ្ណោះ បានទទួលអាហារពីចំនួនអប្បបរមានៃក្រុមអាហារដែលគេបានផ្តល់អនុសាសន៍ (CDHS 2010)។

**រូបភាពទី១៩ ៖ សូចនាករដែលទាក់ទងទៅនឹងកង្វះអាហាររូបត្ថម្ភកុមារ នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០, ២០០៥, ២០១០ (គិតជាភាគរយ)**

| សូចនាករ | CDHS 2000 | CDHS 2005 | CDHS 2010 | គោលដៅCMDG 2015 (%) |
|---|---|---|---|---|
| **កុមារអាយុ ៦-៥៩ខែ មានភាពស្លេកស្លាំង** | 63 | 62 | 55 | **42 (គោលដៅNNS)** |
| **កុមារអាយុ ពី១-៥ឆ្នាំ ដែលបានទទួលគ្រាប់ថ្នាំ វីតាមីន A** | 28,5 | 34,5 | 70,9 | 90 |
| **ការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់** | 11,4 | 60 | 73,5 | **49 (MDG) 70 (NNP)** |
| **ការបំបៅកូនដោយទឹកដោះម្ដាយក្នុងអំឡុងពេល១ម៉ោងដំបូងបន្ទាប់ពីសម្រាល** | 11 | 35,1 | 65,2 | **62 (MDG)** |
| **គ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ** | **12** | **73** | **83** | **90** |

ប្រភព ៖CDHS 2000, 2005, 2010, CMDG

រូបភាពទី១៩ បង្ហាញថា មានភាពរីកចម្រើនយ៉ាងខ្លាំងក្នុងការប្រើប្រាស់អំបិលអ៊ីយ៉ូដ ការគ្របដណ្ដប់នៃការផ្ដល់បន្ថែមគ្រាប់ថ្នាំវីតាមីន A បន្ថែម និងការបំបៅដោះកូនតែមួយមុខគត់ចាប់ពីកើតរហូតដល់អាយុ៦ខែ ព្រមទាំងការផ្ដួចផ្ដើមឱ្យឆាប់បំបៅដោះកូនក្នុងអំឡុងម៉ោងដំបូងបន្ទាប់ពីសម្រាល។ បើទោះជាដូច្នេះក្ដី ក្នុងចំណោមកុមារកម្ពុជាដែលមានអាយុចន្លោះពី ៦-៥៩ខែ មានកុមារចំនួន ៥៥% ដែលនៅមានភាពស្លេកស្លាំង។ ប្រេវ៉ាឡង់នៃភាពស្លេកស្លាំងបន្តស្ថិតនៅកម្រិតដូចគ្នាទៅនឹងឆ្នាំ២០០០ ហើយអត្រាប្រេវ៉ាឡង់បច្ចុប្បន្ន គឺជាបញ្ហាសុខភាពសាធារណៈមួយដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា។

ស្របពេលជាមួយគ្នានោះដែរ CDHS ឆ្នាំ២០១០ បានបង្ហាញឱ្យឃើញអំពីវឌ្ឍនភាពដ៏សំខាន់ក្នុងការកាត់បន្ថយអត្រាមរណៈរបស់ទារក និងកុមារអាយុក្រោម៥ឆ្នាំ។ អត្រានេះបានធ្លាក់ចុះជាង ៣០% នៅចន្លោះឆ្នាំ២០០៥ និង ឆ្នាំ២០១០។ បើទោះបីជាមានសមិទ្ធផលគួរឱ្យកត់សម្គាល់យ៉ាងដូច្នេះក៏ដោយ មានកុមារកម្ពុជាជិតមួយនាក់ ក្នុងចំណោមកុមារចំនួន ២០នាក់ ស្លាប់មុនពេលដែលពួកគេមានអាយុបាន៥ឆ្នាំ (២០០៥-២០១០)។

រូបភាពទី២០៖ អត្រាមរណៈរបស់ទារក និងកុមារអាយុក្រោម៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០, ២០០៥, ២០១០

| សូចនាករ | CDHS 2000 | CDHS 2005 | CDHS 2010 | គោលដៅ CMDG 2015 |
|---|---|---|---|---|
| អត្រាមរណៈរបស់ទារក- IMR(ក្នុង១.០០០ កំណើតរស់ រហូតដល់អាយុ ១១ខែ) | 95 | 66 | 45 | **50** |
| អត្រាមរណៈក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ- U5MR(ក្នុង១.០០០ កំណើតរស់រហូតដល់ អាយុ ៥៩ខែ) | 124 | 83 | 54 | 65 |

ប្រភព ៖CDHS 2000, 2005, 2010, របាយការណ៍ CMDG

*អាហារូបត្ថម្ភមាតា ៖*

ប្រេវ៉ាឡង់ខ្ពស់នៃសន្ទស្សន៍ម៉ាស់រាងកាយស្ត្រីដែលមានកម្ពស់ទាប ពុំមានការប្រែប្រួលច្រើនឡើយនៅចន្លោះឆ្នាំ២០០០និងឆ្នាំ២០១០ អាស្រ័យដោយស្ត្រីម្នាក់ក្នុងចំណោមស្ត្រី៥នាក់ខ្វះអាហារូបត្ថម្ភ និងស្ត្រី ៦% មានកម្ពស់ទាបជាង ១៤៥សង្ទីម៉ែត្រ ដែលបង្ហាញឱ្យដឹងថាពួកគេខ្វះអាហារូបត្ថម្ភនៅពេលដែលពួកគេនៅតូច។ កង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រីមានទំនាក់ទំនងទៅនឹងមរណភាពរបស់មាតា ការសម្រាលកូនមុនពេលកំណត់ កូនកើតមកមានទម្ងន់ មិនគ្រប់គីឡូ និងកង្វះអាហារូបត្ថម្ភកុមារ។ បើទោះជាដូច្នេះក្តី មានការកើនឡើងគួរឱ្យកត់សម្គាល់ ចំពោះការលើសអាហារូបត្ថម្ភក្នុងចំណោមស្ត្រី ចាប់ពី ៦% (ឆ្នាំ២០០០) រហូតដល់ ១១% (ឆ្នាំ២០១០)[៣៣] គួបទៅនឹងការធ្វើទំនើបកម្ម និងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ម្ហូបអាហារ និងរបបអាហារជាគំរូលើការលើសអាហារូបត្ថម្ភ និងជំងឺធាត់ (ក៏ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការកើនឡើងនៃអត្រាស្លាប់របស់ទារក និងមាតា) ទំនងនឹងក្លាយជាការព្រួយបារម្ភមួយ ជាពិសេសសម្រាប់ ជនវណ្ណៈកណ្តាលដែលរស់នៅតំបន់ទីក្រុង។

**ភាពស្លេកស្លាំងនៅក្នុងចំណោមស្ត្រី** គឺជាមូលហេតុឬសគល់នៃមរណភាពមាតា និងការសម្រាលកូនមានទម្ងន់មិនគ្រប់គីឡូ (ដែលភាពស្លេកស្លាំងនេះ គឺជាកត្តារួមចំណែក) ហើយបញ្ហានេះបានធ្លាក់ចុះបន្តិចបន្តួចប៉ុណ្ណោះ ពី ៤៦,៦% ក្នុងឆ្នាំ២០០៥ មក ៤៤,១% ក្នុងឆ្នាំ២០១០។ ភាពស្លេកស្លាំងក្នុងចំណោមស្ត្រីមានផ្ទៃពោះ បានធ្លាក់ចុះចំនួន ៤% នៅក្នុងរយៈពេលដូចគ្នានេះ ប៉ុន្តែ អត្រា ៥៣% នៅតែខ្ពស់ជាងគោលដៅរបស់ CMDGs ដែលបានកំណត់ ៣៩% សម្រាប់ឆ្នាំ២០១០។ អត្រាទារកកើតមិនគ្រប់ទម្ងន់(៨% ក្នុងឆ្នាំ២០១០) ពុំមានការផ្លាស់ប្តូរច្រើនឡើយ ចាប់តាំងពីឆ្នាំ២០០៥។

[៣៣] ស្ត្រីមានបញ្ហាលើសអាហារូបត្ថម្ភនៅតំបន់ទីក្រុង(១៦%) មានកម្រិតខ្ពស់ជាងតំបន់ជនបទ(៥%) ហើយចំពោះក្រុមមានទ្រព្យធនខ្ពស់បំផុត(១៧%) មានកម្រិតខ្ពស់ជាង៣ដងធៀបនឹងក្រុមមានទ្រព្យធនតិចបំផុត(៥%)។ មើល CDHS 2010។

## រូបភាពទី២១៖ និន្នាការនៃសូចនាករកង្វះអាហារូបត្ថម្ភរបស់ស្ត្រី( ១៥-៤៩ឆ្នាំ) ឆ្នាំ ២០០០-២០១០




ប្រភព ៖CDHS 2000, 2005, 2010,

កង្វះអាហារូបត្ថម្ភមាតា ក៏មានទំនាក់ទំនងខ្ពស់ទៅនឹងភាពក្រីក្រផងដែរ ប៉ុន្តែ ការលុបបំបាត់ភាពក្រីក្រពុំគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភមាតាទាំងស្រុងឡើយ អាស្រ័យដោយ ១៦% នៃក្រុមដែលមានទ្រព្យធនខ្ពស់បំផុត មានសន្ទស្សន៍ម៉ាស់រាងកាយទាប ហើយស្ត្រីម្នាក់ក្នុងចំណោមស្ត្រី៣នាក់នៅក្នុងក្រុមនេះមានភាពស្លេកស្លាំងក្នុងឆ្នាំ២០១០។លទ្ធផលនៃការវិភាគសមធម៌មួយទៅលើប្រេវ៉ាឡង់នៃភាពស្លេកស្លាំងរបស់មាតាទៅតាមក្រុម ទ្រព្យសម្បត្តិ មានលក្ខណៈស្របគ្នាទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភកុមារទៅតាមការបែងចែកសង្គមទូទៅ និងនៅតំបន់ជនបទ ៖ ជនក្រីក្រ និងប្រជាពលរដ្ឋដែលរស់គ្មានការអប់រំ មានកម្រិតខ្វះអាហារូបត្ថម្ភខ្ពស់ជាង អ្នកមានទ្រព្យធនប្រជាពលរដ្ឋដែលរស់នៅតំបន់ទីក្រុង និងអ្នកដែលមានការអប់រំ។

## រូបភាពទី២២ ៖ ភាពស្លេកស្លាំងនៅក្នុងចំណោមស្ត្រី បែងចែកទៅតាមក្រុមសមធម៌




ប្រភព ៖CDHS 2000, 2005, 2010 ( ការវិភាគរបស់អង្គការយូនីសេហ្វ )

អត្រាកង្វះអាហារូបត្ថម្ភ និងអត្រាមរណៈរបស់កុមារ ក្នុងឆ្នាំ២០១០ នៅតែបន្តមានកម្រិតខ្ពស់ជាងអត្រារបស់ប្រទេសជិតខាងជាច្រើនរបស់កម្ពុជា លើកលែងតែប្រទេសឡាវ និងភូមា ដូចមានបញ្ជាក់នៅក្នុងតារាងរូបភាពខាងក្រោម ៖

<u>រូបភាពទី២៣</u> ការប្រៀបធៀបរវាងតំបន់ចំពោះអត្រាកង្វះអាហារូបត្ថម្ភ និងអត្រាមរណៈរបស់កុមារ

| ប្រទេស | អត្រាក្រេះក្រិន (%) | អត្រាស្គមស្គាំង (%) | អត្រាមិនគ្រប់ទម្ងន់ (%) | អត្រាទារកកើតមកមានទម្ងន់មិនគ្រប់គីឡូ (%) | អត្រាមរណៈរបស់កុមារអាយុក្រោម ៥ឆ្នាំ ក្នុង១.០០០ កំណើតរស់ |
|---|---|---|---|---|---|
| **ចិន** | 10 | 3 | 4 | 3 | **15** |
| **ថៃ** | 16 | 5 | 7 | 7 | **12** |
| **ម៉ាឡេស៊ី** | 17 | - | 13 | 11 | **7** |
| **វៀតណាម** | 23 | 4 | 12 | 5 | **22** |
| **ហ្វីលីពីន** | 32 | 7 | 22 | 21 | **25** |
| **ភូមា** | 35 | 8 | 23 | 9 | **62** |
| **កម្ពុជា** | 40 | 11 | 28 | 11 | **54** |
| **ឡាវ** | **48** | **7** | **31** | **11** | **42** |

Low-birth weight: ទារកកើតមិនគ្រប់ទម្ងន់ ឬ ទារកកើតមកមានទម្ងន់មិនគ្រប់គីឡូ

ប្រភព ៖ អង្គការយូនីសេហ្វការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ២០១៣ (អត្រាសម្រាប់ប្រទេសដទៃទៀតក្រៅពីប្រទេសកម្ពុជាគឺជាអត្រាចុងក្រោយបំផុតដែលមាននៅចន្លោះឆ្នាំ២០០៧-២០១១)

## ២.៤. សេចក្តីសន្និដ្ឋានពីការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ឆ្លងតាមរយៈការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា និងនិន្នាការនាពេលថ្មីៗ យើងអាចទាញសេចក្តីសន្និដ្ឋានដូចតទៅ ៖

### សន្តិសុខស្បៀងកម្រិតម៉ាក្រូ ៖

- ប្រទេសកម្ពុជាបាននិងកំពុងផលិតអតិរេកផលស្រូវជាច្រើន ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ព្រមទាំងបានធ្វើសមាហរណកម្មទីផ្សារស្បៀងអាហារបានយ៉ាងល្អប្រសើរ។ ដូច្នេះកម្ពុជាអាចសម្រេចបានភាគច្រើននូវសន្តិសុខស្បៀងនៅកម្រិតម៉ាក្រូ និង ពុំមានការព្រួយបារម្ភជាក់លាក់ណាមួយសម្រាប់ប្រទេសកម្ពុជាឡើយ នាពេលបច្ចុប្បន្ននេះ។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**មិនចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ជាក់លាក់ទៅលើសន្តិសុខស្បៀង នៅកម្រិតថ្នាក់ជាតិឡើយ ប៉ុន្តែគេត្រូវផ្តោតយកចិត្តទុកដាក់នៅកម្រិតគ្រួសារ និងកម្រិតបុគ្គល (អាហារូបត្ថម្ភ)។

### សន្តិសុខស្បៀងកម្រិតគ្រួសារ ៖

- ស្បៀងអាហារជាច្រើនដែលគ្រួសារនៅក្នុងប្រទេសកម្ពុជាប្រើប្រាស់ដើម្បីទទួលទាន គឺទទួលបានពីការផលិតដោយខ្លួនឯង។ ដូច្នេះ ការបង្កើនស្បៀងអាហារប្រកបដោយអាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់នៅកម្រិតគ្រួសារ តាមរយៈការធ្វើពិពិធកម្មមានសារៈសំខាន់ខ្លាំង ដើម្បីលើកកម្ពស់ការទទួលទានស្បៀងអាហារជាទូទៅនៅកម្រិតគ្រួសារ។
- អាស្រ័យដោយអសន្តិសុខស្បៀងកើតឡើងភាគច្រើន នៅក្នុងចំណោមក្រុមប្រជាជនក្រីក្រដែលរស់នៅតាមទីជនបទ ដូច្នេះ ការអភិវឌ្ឍប្រាក់ចំណូលប្រកបដោយនិរន្តរភាព តាមរយៈសមាហរណកម្មទីផ្សាររបស់កសិករខ្នាតតូច ព្រមទាំងការបែងចែកដីកសិកម្មជូនដល់ជនដែលគ្មានដី និងជនដែលខ្វះខាតដីមានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ។
- អាស្រ័យដោយនៅតំបន់ជនបទ ស្បៀងអាហារចំនួនពាក់កណ្តាលនៅកម្រិតគ្រួសារ ពុំមានប្រភពមកពីការផលិតដោយខ្លួនឯងឡើយ ដូច្នេះ ការអភិវឌ្ឍឱកាសការងារកសិកម្ម និងការបង្កើតឱកាសការងារដទៃទៀត ព្រមទាំងប្រាក់ចំណូលសម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀងនៅតំបន់ជនបទ និងតំបន់ទីក្រុង នៅតែបន្តជាបញ្ហាប្រឈមមួយដ៏សំខាន់ក្នុងការធានាឱ្យទទួលបានស្បៀងអាហារគ្រប់គ្រាន់គ្រប់ពេលវេលា[៣៩]។
- ទ្រព្យសម្បត្តិរួមដូចជាធនធានជលផល និងព្រៃឈើ គឺជាប្រភពស្បៀងអាហារ និងប្រាក់ចំណូលដ៏សំខាន់សម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ហើយទ្រព្យសម្បត្តិទាំងនេះ ត្រូវការពារ និងគ្រប់គ្រងប្រកបដោយនិរន្តរភាព។
- ថវិកាមួយភាគធំដែលប្រជាពលរដ្ឋកម្ពុជាចំណាយទៅលើស្បៀងអាហារ (ពីថវិកាគ្រួសាររបស់ពួកគេ) និងការដែលគ្រួសារជនបទភាគច្រើនគឺជាអ្នកទិញស្បៀងអាហារសុទ្ធសាធ ធ្វើឱ្យពួកគេមានភាពងាយរងគ្រោះ ទៅនឹងតម្លៃស្បៀងអាហារដែលគ្មានស្ថេរភាព។ ដូច្នេះ គេត្រូវធ្វើការត្រួតពិនិត្យឱ្យបានដិតដល់ទៅលើផលប៉ះពាល់នៃតម្លៃស្បៀងអាហារដែល កើនឡើងខ្ពស់ទៅលើជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ព្រមទាំងត្រូវពិចារណាស្វែងរកអន្តរាគមន៍រយៈពេលខ្លី ដើម្បីកាត់បន្ថយការបាត់បង់លទ្ធភាពទិញ ស្បៀងអាហាររបស់ពួកគេ។
- នៅកម្រិតគ្រួសារ ការទទួលទានស្បៀងអាហារបានមានភាពប្រសើរឡើង គួរឱ្យកត់សម្គាល់ ប៉ុន្តែអសមធម៌ តាមតំបន់ និងនៅក្នុងសង្គម នៅតែបន្តកើតមាន ដែលបញ្ហានេះត្រូវដោះស្រាយតាមរយៈអន្តរាគមន៍ដែលកំណត់គោលដៅឱ្យបានល្អប្រសើរ។
- ដូចដែលវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចលើកចុងក្រោយ បានបង្ហាញឱ្យឃើញថា លទ្ធភាពក្នុងការទទួលបានស្បៀងអាហាររបស់ជនក្រីក្រ និងជនដែលរស់នៅក្បែរខ្សែបន្ទាត់នៃភាពក្រីក្រ អាចទទួលរងផលប៉ះពាល់យ៉ាងងាយពីវិបត្តិខាងក្រៅ ដែលទាក់ទងទៅនឹងកត្តាសង្គមសេដ្ឋកិច្ច និងគ្រោះមហន្តរាយធម្មជាតិ។ ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពក្នុងការដោះស្រាយបញ្ហារបស់ក្រុមងាយរងគ្រោះ តាមរយៈការពង្រីកសំណាញ់សុវត្ថិភាពសង្គម និងការធ្វើឱ្យប្រសើរឡើងនូវយន្តការត្រៀមលក្ខណៈ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅតែបន្តជាបញ្ហាប្រឈមមួយសម្រាប់អនាគត។

---

[៣៩] ចំណុចនេះ រាប់បញ្ចូលពិពិធកម្មនៃវិស័យឧស្សាហកម្មដែលមានមូលដ្ឋានចង្អៀត ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម និងការធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ដែលស្រូបយកកម្លាំងពលកម្មជាច្រើនរបស់កម្ពុជា)។

## សន្តិសុខស្បៀងនៅកម្រិតបុគ្គល (អាហារូបត្ថម្ភ)

- បើទោះបីជាមានការកាត់បន្ថយភាពក្រីក្រជាទូទៅ និងភាពក្រីក្រផ្នែកស្បៀងអាហារគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ អាហារូបត្ថម្ភកុមារ និងមាតា ពុំមានភាពប្រសើរឡើងទ្បើយនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០០៥។ ដោយសារតែអត្រាប្រេវ៉ាឡង់នៃបញ្ហាកង្វះអាហារូបត្ថម្ភកុមារពុំរ៉ែមានចំនួនជិត ៤០% ដូច្នេះ ត្រូវដោះស្រាយបញ្ហានេះជាបន្ទាន់ក្នុងលក្ខណៈជាអាទិភាពអភិវឌ្ឍន៍មួយនៅក្នុងប្រទេសកម្ពុជា។ កង្វះអាហារូបត្ថម្ភកុមារក្នុងកម្រិតខ្ពស់បែបនេះ មិនត្រឹមតែជាបញ្ហាសុខភាពសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាឧបសគ្គទូទៅមួយ ដែលរាំងស្ទះដល់ការអភិវឌ្ឍមូលដ្ឋានធនធានមនុស្ស និងភាពរីកចម្រើនផ្នែកសង្គមសេដ្ឋកិច្ចបន្ថែមទៀតរបស់ប្រទេសកម្ពុជា។ ការសិក្សាថ្មីមួយលើផលវិបាកនៃកង្វះអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា បានប៉ាន់ប្រមាណថាបញ្ហាកង្វះអាហារូបត្ថម្ភ ជាបន្ទុកមួយដ៏ធំចំពោះសេដ្ឋកិច្ចជាតិ ពោលគឺចំណាយ ៤១៩ លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ឬប្រហែល ២,៦% នៃផលិតផលក្នុងស្រុកសរុប[៣៥]។
- កម្ពុជាសម្រេចបាននូវភាពរីកចម្រើនគួរឱ្យកត់សម្គាល់ នៅក្នុងការផ្តល់សេវាមួយចំនួនដែលទាក់ទងទៅនឹងអាហារូបត្ថម្ភកុមារ និងមាតា ( ដូចជា ការទៅទទួលសេវាពិនិត្យផ្ទៃពោះមុនពេលសម្រាល ) និងសូចនាករផ្លាស់ប្តូរការប្រព្រឹត្តមួយចំនួន ( ដូចជា ការផ្តួចផ្តើមឱ្យឆាប់បំបៅដោះកូន និងការបំបៅដោះកូនតែមួយមុខគត់ )។ ដូច្នេះ កម្ពុជាត្រូវការពារចំពោះវឌ្ឍនភាពបែបនេះ ព្រមទាំងត្រូវពង្រីកកិច្ចអន្តរាគមន៍បន្ថែមទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រព្រឹត្តដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ ដូចជាការផ្តល់អាហារបន្ថែមសមស្រប។
- ការវិភាគបង្ហាញឱ្យដឹងថាកង្វះអាហារូបត្ថម្ភកុមារនិងមាតាមិនត្រឹមតែទាក់ទងទៅនឹងស្ថានភាពទ្រព្យសម្បត្តិរបស់គ្រួសារប៉ុណ្ណោះទេ ប៉ុន្តែ ក៏ទាក់ទងទៅនឹងអនាម័យ ព្រមទាំងកម្រិតនៃការអប់រំរបស់ម្តាយផងដែរ។ ជាពិសេស ការអប់រំមូលដ្ឋានអំពីចំណេះដឹងរបៀបរបបរស់នៅមានអនាម័យហូបស្អាតរស់នៅស្អាត និងចេះច្នៃប្រឌិតម្ហូបអាហារសាមញ្ញៗ មានប្រយោជន៍ដោយប្រើប្រាស់ធនធាន ដែលងាយរកបាន ឬធ្វើបាននៅក្នុងភូមិស្ថាន ឬជុំវិញលំនៅស្ថានរបស់ខ្លួន។ ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនៅកម្រិតបុគ្គលក្នុងប្រទេសកម្ពុជា ក៏ទាមទារឱ្យមានមិនត្រឹមតែអន្តរាគមន៍ជាក់ស្តែង ដែលផ្តោតការយកចិត្តទុកដាក់ទៅលើអាហារូបត្ថម្ភ ព្រមទាំងត្រូវការឱ្យមានសកម្មភាពលើការសម្របសម្រួលរឹងមាំ រវាងវិស័យនានាផងដែរ។
- ម្យ៉ាងវិញទៀត បញ្ហាកង្វះអាហារូបត្ថម្ភ និងជំងឺធាត់ក្នុងចំណោមស្ត្រីនិងកុមារកំពុងកើនឡើងយ៉ាងឆាប់រហ័ស ហើយ “បន្ទុកទ្វេដងនៃបញ្ហាកង្វះអាហារូបត្ថម្ភ” នៅកម្ពុជាចាំបាច់ត្រូវដោះស្រាយនៅដំណាក់កាលដំបូង ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ស្ថានភាពសុខភាព និងការចំណាយលើសុវត្ថិភាពសង្គម និងសេដ្ឋកិច្ច។

---

[៣៥] តួលេខនេះត្រូវបានរួមមាន ១) តម្លៃបច្ចុប្បន្នសុទ្ធ (NPV) នៃការបាត់បង់កម្លាំងពលកម្ម ជាលទ្ធផលពី (ពាក់ព័ន្ធបញ្ហាកង្វះអាហារូបត្ថម្ភ) ការស្លាប់របស់កុមារ ២) NPV នៃការបាត់បង់ផលិតភាពនាពេលអនាគត ដោយសារតែយល់ដឹងនិងឱនភាពផ្សេងទៀតពីភាពស្លកសាំង និងភាពក្រិនរបស់កុមារ, ៣) ការខាតបង់ប្រចាំឆ្នាំ នាពេលបច្ចុប្បន្នដោយសារតែឱនភាពការធ្វើការងារ នៅក្នុងចំណោមមនុស្សពេញវ័យដែលមានភាពស្លកសាំងពាក់ព័ន្ធនឹងការងារធ្វើដោយដៃ ៤) ក៏ដូចជាការចំណាយសម្រាប់ការចំណាយដើម្បីព្យាបាលសុខភាព (ទាក់ទងនឹងបញ្ហាកង្វះអាហារូបត្ថម្ភ) ករណីលើសនៃជំងឺរាគរូសជំងឺដង្ហើមនិងមានទម្ងន់មិនគ្រប់គីឡូ។ សូមមើល: អង្គការ UNICEF, ផលវិបាកនៃកង្វះអាហារូបត្ថម្ភនៅប្រទេសកម្ពុជា ១១/២០១៣

## ៣. គោលនយោបាយ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ និងការរៀបចំបង្កើតស្ថាប័ន

ផ្នែកនេះ ពិនិត្យមើលទៅលើគោលនយោបាយបច្ចុប្បន្ន និងបរិបទស្ថាប័ននៃបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា។ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានកំណត់ម្តងហើយម្តងទៀតថាៈជាអាទិភាពមួយដ៏សំខាន់ក្រោមក្របខ័ណ្ឌគោលនយោបាយជាតិដែលមានស្រាប់ និងគោលនយោបាយតាមវិស័យ។ បន្ថែមពីនេះទៀត កម្មវិធីអភិវឌ្ឍន៍ជាច្រើនក្នុងប្រទេសកម្ពុជា បានកំណត់យកការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និង អាហារូបត្ថម្ភ (ឬ ទិដ្ឋភាពមូលដ្ឋានរបស់វា) ជាគោលបំណងរបស់ខ្លួន។ លើសពីនេះទៀត អស់រយៈពេលជាច្រើនឆ្នាំហើយ ដែលរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់ប្រធានបទសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីគាំទ្រដល់ក្រសួង-ស្ថាប័ននានា ក្នុងការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង-ស្ថាប័នទាំងនោះ។

### ៣.១. សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងគោលនយោបាយ និងផែនការរួមរបស់កម្ពុជា

ក្នុងលក្ខណៈជាបញ្ហាមួយដែលមានភាពប្រទាក់ក្រឡាគ្នាដ៏សំខាន់ សន្តិសុខស្បៀង និង អាហារូបត្ថម្ភត្រូវបានលើកយកមកធ្វើការដោះស្រាយនៅក្នុងរាល់គោលនយោបាយរួម និងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៤-២០១៨)របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព បានកំណត់ទិសដៅគោលនយោបាយទូលំទូលាយសម្រាប់ធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងកំណត់អាទិភាពដើម្បីលើកកម្ពស់ការមានស្បៀង ការទទួលបានស្បៀង ការបឺតស្រូបស្បៀង និងស្ថេរភាពស្បៀង ជាពិសេសនៅក្នុងអនុចតុកោណដែលផ្តោតទៅលើប្រពលវប្បកម្ម និងពិពិធកម្មវិស័យកសិកម្ម កំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ និងការបង្កើតបទប្បញ្ញត្តិស្តីពីសំណាញ់សុវត្ថិភាពសង្គម។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** មានសង្គតភាពទាំងស្រុងទៅនឹងឯកសារគោលនយោបាយនេះ។

សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ជាបញ្ហាដ៏សំខាន់មានលក្ខណៈប្រទាក់ក្រឡានេះ ត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ជាគោលនយោបាយអាទិភាពមួយដ៏សំខាន់ និងសកម្មភាពពាក់ព័ន្ធជាច្រើនទៀតដើម្បីបង្កើន ភាពមានស្បៀង លទ្ធភាពទទួលបានស្បៀង ការប្រើប្រាស់និងការបឺតស្រូបស្បៀង និងស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀងអាហារបានរៀបរាប់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ត្រូវបានរួមបញ្ចូលនៅក្នុងជំពូកទី ៤ នៃផែនការគ្រប់គ្រងការអភិវឌ្ឍសម្រាប់កម្ពុជា។ សកម្មភាពដើម្បីធ្វើឱ្យប្រសើរឡើង នូវបរិយាកាសនយោបាយ និងគោលនយោបាយសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករសំខាន់លើសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដូចជា

សូចនាករកង្វះអាហារូបត្ថម្ភកុមារ ត្រូវបានរួមបញ្ចូលជាសូចនាករស្នូលនៅក្នុងក្របខ័ណ្ឌតាមដានផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានតម្រឹមយ៉ាងពេញលេញជាមួយនឹងគោលដៅ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិនេះ។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** មានទំនាក់ទំនង និងរួមចំណែកដល់ការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs)។ CMDG 1 គឺ "លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ"។ បើទោះជាដូច្នេះក្តី ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏ដើរតួនាទីសំខាន់ផងដែរ ក្នុងការសម្រេចឱ្យបាននូវគោលដៅជាច្រើន ក្នុងចំណោម CMDGs ទាំង៨ដទៃទៀត។

**រូបភាពទី២៤ ៖ ការភ្ជាប់ FSNទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា**

| CMDG | តួនាទីក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សំដៅសម្រេចឱ្យបាននូវ CMDGs |
|---|---|
| ១ ៖លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ | ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ គឺជាមូលដ្ឋានគ្រឹះ ក្នុងការលុបបំបាត់ភាពអត់ឃ្លាន និងក៏ជាទិដ្ឋភាពចម្បងមួយនៃការលុបបំបាត់ភាពក្រីក្រផងដែរ។អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ ធ្វើឱ្យបាត់បង់មូលធនមនុស្ស កាត់បន្ថយភាពធន់ទ្រាំទៅនឹងវិបត្តិនានា ព្រមទាំងធ្វើឱ្យធ្លាក់ចុះនូវផលិតភាពកម្លាំងពលកម្ម។ |
| ២ ៖សម្រេចឱ្យបានជាទូទៅ ការអប់រំមូលដ្ឋាន រយៈពេល៩ឆ្នាំ | ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងរួមចំណែក បង្កើនវត្តមាន និងការបន្តការសិក្សានៅឯសាលារៀន និងនាំឱ្យមានអត្រា បោះបង់ការសិក្សាទាបជាងមុន ព្រមទាំងនឹងជួយធ្វើឱ្យប្រសើរឡើងនូវការសិក្សារៀនសូត្ររបស់កុមារ។ |
| ៣ ៖លើកតម្កើងសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | កុមារី និងស្ត្រីដែលមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភល្អប្រសើរ នឹងទទួលបានសុខភាពល្អ ព្រមទាំងទទួលបានប្រយោជន៍កាន់តែប្រសើរពីការអប់រំសុខុមាលភាព សេដ្ឋកិច្ច ជម្រើសក្នុងការបន្តពូជ ការអនុវត្តន៍ចិញ្ចឹមកូន ព្រមទាំងការចូលរួមនៅក្នុងអភិបាលកិច្ចរបស់សង្គមស៊ីវិល។ |
| ៤ ៖ កាត់បន្ថយមរណភាពកុមារ | កុមារកម្ពុជាអាយុក្រោម៥ឆ្នាំ ជាង៤០% ដែលបានស្លាប់ គឺជាកុមារដែលខ្វះអាហារូបត្ថម្ភ។ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ និងសន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ នឹងកាត់បន្ថយមរណភាពកុមារដោយផ្ទាល់។ |

| | |
|---|---|
| ៥ ៖លើកកម្ពស់ សុខភាពមាតា | អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ មានទំនាក់ទំនងទៅនឹងកត្តា ហានិភ័យចម្បងៗជាច្រើនដែលបណ្តាលឱ្យមានមរណភាពមាតា។ ស្ត្រីកម្ពុជា និងម្តាយទទួលរងគ្រោះពីអត្រាកង្វះអាហារូបត្ថម្ភខ្ពស់ ដែលបណ្តាលឱ្យមានជំងឺបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព របស់ម្តាយ និងកុមារតូច។ |
| ៦ ៖ ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃទៀត | អសន្តិសុខស្បៀងជំរុញឱ្យមានយន្តការដោះស្រាយបញ្ហាមួយចំនួនដូចជា ចំណាកស្រុក ដើម្បីស្វែងរកការងារ និង/ឬ ពេស្យាកម្មដែលបង្កើនល្បឿននៃការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។ អាហារូបត្ថម្ភ និង សន្តិសុខស្បៀងគ្រប់គ្រាន់ គឺជាកត្តាមួយដ៏សំខាន់ ដើម្បីពន្យារអាយុជីវិតរបស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និង កាត់បន្ថយអត្រាស្លាប់ពីជំងឺគ្រុនចាញ់ និងជំងឺដទៃទៀត។ |
| ៧ ៖ធានាចីរភាពបរិស្ថាន | អសន្តិសុខស្បៀង គឺជាមូលហេតុមួយនៃការប្រើប្រាស់ដីព្រៃ និងធនធាន ព្រៃឈើ ដោយពុំមាននិរន្តរភាព។ ប្រជាពលរដ្ឋដែលជួបប្រទះបញ្ហា អសន្តិសុខស្បៀង និងក្រីក្រខ្លាំង រមែងតែងពឹងផ្អែកទៅលើព្រៃឈើ និង ជលផលជាប្រភពផ្គត់ផ្គង់ចំណីអាហារ និងសម្រាប់សេចក្តីត្រូវការជីវភាព រស់នៅរបស់ពួកគេ។ ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និង អាហារូបត្ថម្ភ គឺជាទិដ្ឋភាពមួយដ៏សំខាន់នៃការសម្រេចឱ្យបាននូវនិរន្តរភាពបរិស្ថាន។ |
| ៨ ៖បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍ | ភាពជាដៃគូទាំងនេះ ត្រូវបញ្ចូលដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារអន្តរជាតិ ដែលមានជំនាញឯកទេស ក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ |
| ៩ ៖ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនិងការសង្គ្រោះជនរងគ្រោះ | ប្រជាពលរដ្ឋដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង និងក្រីក្រខ្លាំងទទួល រងផលប៉ះពាល់ ជាពិសេស ព្រមទាំងងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះអាស្រ័យដោយពួកគេពឹងផ្អែកខ្លាំងទៅលើព្រៃឈើ និងជលផលជាប្រភពផ្គត់ផ្គង់ស្បៀងអាហារ និងសម្រាប់សេចក្តីត្រូវការជីវភាពរស់នៅរបស់ពួកគេ។ |

រាជរដ្ឋាភិបាលកម្ពុជា គឺជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិមួយចំនួន ដែលផ្តល់ក្របខ័ណ្ឌច្បាប់ ដើម្បីទទួលស្គាល់បញ្ហាសន្តិសុខស្បៀងថាជាសិទ្ធិមនុស្សមូលដ្ឋានមួយ ក្រោមច្បាប់អន្តរជាតិ ជាពិសេសអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) និងប្រកាន់ខ្ជាប់ទៅនឹង«សេចក្តីណែនាំស្ម័គ្រចិត្តដើម្បីគាំទ្រដល់ការយល់ដឹងកាន់តែច្រើនពីសិទ្ធិទទួលបានអាហារគ្រប់គ្រាន់នៅក្នុងបរិបទនៃសន្តិសុខស្បៀងថ្នាក់ជាតិ» អនុម័តដោយរដ្ឋជាសមាជិក អង្គការ FAO ចំនួន១៨៧ កាលពីខែ វិច្ឆិកា ឆ្នាំ ២០០៤ ។

លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តជ្រើសរើសយក **ក្របខ័ណ្ឌសមាហរណកម្ម សន្តិសុខស្បៀងអាស៊ាន** និងផែនការសកម្មភាពនៃក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀង (២០០៩-២០១៣) ដែលត្រូវបានអភិវឌ្ឍន៍ និងអនុម័ត ក្នុងឆ្នាំ២០០៨ ដើម្បីប្រើប្រាស់សម្រាប់ឆ្លើយតបទៅនឹងវិបត្តិស្បៀងអាហារ។ ឯកសារទាំងនេះ ផ្តល់នូវវិសាលភាពសម្រាប់អភិក្រមជាក់ស្តែងរួមគ្នាសម្រាប់កិច្ចសហប្រតិបត្តិការ ក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន ក្នុងការដោះស្រាយបញ្ហាសន្តិសុខស្បៀងនៅក្នុងតំបន់។ ផែនការសកម្មភាពយុទ្ធសាស្ត្រដាក់ចេញសកម្មភាពអាទិភាព នៅក្រោមសមាសភាគបួន[៣៦] ជាមួយនឹងគោលបំណង ដើម្បីបង្កើនការផលិតស្បៀងអាហារដើម្បីកាត់បន្ថយការខាតបង់ក្រោយការប្រមូលផល ដើម្បីលើកកម្ពស់វិជ្ជាជីវៈទីផ្សារ និងពាណិជ្ជកម្មសម្រាប់ទំនិញកសិកម្ម និងធនធាន ដើម្បីធានាបាននូវស្ថេរភាពស្បៀងអាហារ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបាននូវធនធានកសិកម្ម និងដើម្បីប្រតិបត្តិការរៀបចំជំនួយសង្គ្រោះបន្ទាន់ជាម្ហូបអាហារក្នុងតំបន់។ ការផ្តល់យោបល់កម្រិតខ្ពស់ក្នុងចំណោមរដ្ឋសមាជិក ដើម្បីបញ្ចូលអាហារូបត្ថម្ភទៅក្នុងក្របខ័ណ្ឌសមាហរណកម្មសន្តិសុខស្បៀងអាស៊ាន (AIFS) និងផែនការសកម្មភាពយុទ្ធសាស្ត្ររបស់ខ្លួន។

រាជរដ្ឋាភិបាលកម្ពុជា កំពុងបន្តគាំទ្រ និងរៀបចំសមាជិកភាពរបស់ខ្លួន ដើម្បីចូលរួមនៅក្នុង **ចលនាពង្រីកអាហារូបត្ថម្ភអន្តរជាតិ** ដែលត្រូវបានដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១០ ក្នុងគោលបំណងបង្កើតឱ្យមាននូវបរិយាកាសអំណោយផលផ្នែកនយោបាយមួយ បង្កើតការអនុវត្តន៍ល្អ ដាក់បញ្ចូលសកម្មភាព និងបង្កើន ធនធានដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតា។

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ជាថ្មីឡើងវិញអំពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ថាជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ជាពិសេសនៅក្នុងសិក្ខាសាលាថ្នាក់ជាតិលើកទី៣ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទសំណាញ់សុវត្ថិភាពសង្គម ដែលបានប្រព្រឹត្តធ្វើឡើងនៅក្នុងខែកក្កដា ឆ្នាំ២០០៩ និងនៅក្នុងសិក្ខាសាលាថ្នាក់ជាតិ លើកទី៤ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្រោមប្រធានបទអាហារូបត្ថម្ភកុមារ និងមាតា ដែលបានប្រព្រឹត្តធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១២[៣៧]។ ព្រឹត្តិការណ៍ទាំងពីរនេះ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះទៀត ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវបានផ្តល់អាណត្តិការងារនៅក្នុងសិក្ខាសាលាថ្នាក់ជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ "ដើម្បីរៀបចំឱ្យមាននូវយុទ្ធសាស្ត្រជាតិគ្រប់ជ្រុងជ្រោយមួយ ដែលអាចយកមកអនុវត្តបានសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងផែនការសកម្មភាពការងារ និងផែនការវិនិយោគ ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ"។

[៣៦] ១. សន្តិសុខស្បៀង និង ជំនួយសង្គ្រោះបន្ទាន់ ២. ការអភិវឌ្ឍពាណិជ្ជកម្មម្ហូបអាហារ ប្រកបដោយនិរន្តរភាព ៣. ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងដែលបានធ្វើសមាហរណកម្ម ៤. បច្ចេកទេសកសិកម្ម,សូមមើល ក្របខ័ណ្ឌសមាហរណកម្ម សន្តិសុខស្បៀងអាស៊ាន (AIFS) និងផែនការយុទ្ធសាស្ត្រសកម្មភាពស្តីពីសន្តិសុខស្បៀងក្នុងតំបន់អាស៊ាន (SPA- FS) ។

[៣៧] សិក្ខាសាលាជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភត្រូវបានរៀបចំរួចហើយពីមុនដោយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ១៩៩៩ និងឆ្នាំ ២០០៣។

## ៣.២. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយអន្តរវិស័យនានា

ក្រសួងជាច្រើនបានដាក់ឱ្យដំណើរការនូវយុទ្ធសាស្ត្រជាតិតាមវិស័យ ដែលដោះស្រាយស្ថានភាពសន្តិសុខស្បៀងដោយផ្ទាល់ ឬ ប្រយោល។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ត្រូវបានរៀបចំឡើងដើម្បីបំពេញន្ថែមចំពោះយុទ្ធសាស្ត្រ និងផែនការតាមវិស័យដែលមានស្រាប់ទាំងនេះ ព្រមទាំងបំពេញចន្លោះប្រហោងដែលមានស្រាប់ និងប្រើប្រាស់ជាមូលដ្ឋានមួយសម្រាប់សកម្មភាពអន្តរវិស័យរួមគ្នា ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ រូបភាពទី២៥ ផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីយុទ្ធសាស្ត្រពាក់ព័ន្ធ និងផែនការដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ទិដ្ឋភាពនីមួយៗ នៃទិដ្ឋភាពទាំង៤របស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យុទ្ធសាស្ត្រខាងក្រោមមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគោលបំណងដែលត្រូវបានគូសបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។

**យុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក** (SAW 2006-2010) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម** ២០០៩-២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្លុះបញ្ចាំងអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងចក្ខុវិស័យ និងគោលបំណងរួម។ សសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំង៦ នៃឯកសាររៀបចំកម្មវិធីសម្រាប់ SAW[៣៨] ផ្តោតការយកចិត្តទុកដាក់ជាក់លាក់ទៅលើគ្រួសារជនបទដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។ សសរស្តម្ភនេះ មានសមាសភាគចំនួនពីរ៖

(១). សហគមន៍ពឹងផ្អែកលើខ្លួនឯងដើម្បីទទួលបានសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើប្រពលវប្បកម្ម និងពិពិធកម្ម ប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច

(២). ការលើកកម្ពស់ក្របខ័ណ្ឌ ស្ថាប័ន និងក្របខ័ណ្ឌគោលនយោបាយសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព័ត៌មាន។ បើទោះជាដូច្នេះក្តី SAW មិនត្រូវបានអនុវត្តតាមរយៈអភិក្រមដែលមានមូលដ្ឋានផ្អែកលើកម្មវិធី ទៅតាមការគ្រោងទុកពីដំបូងឡើយដោយឡែកអន្តរាគមន៍ដែលទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់កម្មវិធីចម្បងៗ ពង្រឹងបន្ថែមទៅលើ SAW និងជាពិសេស គឺសសរស្តម្ភផ្នែកសន្តិសុខស្បៀង[៣៩]។

**យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ**(NNS2009-2015) ដែលត្រូវបានរៀបចំ ក្នុងឆ្នាំ២០០៩ ដោយកម្មវិធីជាតិអាហារូបត្ថម្ភ នៃក្រសួងសុខាភិបាល កំពុងផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពនៅក្នុងវិស័យសុខាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពកង្វះអាហារូបត្ថម្ភរបស់មាតា

---

[៣៨] ជំហានបន្តទៀត ដើម្បីដាក់យុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក ឱ្យមានប្រតិបត្តិការ ត្រូវបានគូសបញ្ជាក់នៅក្នុងឯកសាររៀបចំកម្មវិធី (២០១០-២០១៣) សម្រាប់យុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក ខែមេសា ឆ្នាំ២០១០។

[៣៩] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានរៀបចំផងដែរនូវកម្មវិធីជាតិសម្រាប់សន្តិសុខស្បៀងគ្រួសារ និងការ «កាត់បន្ថយភាពក្រីក្រក្នុងឆ្នាំ ២០០៦»(មុនយុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក)។ សំណើកម្មវិធីសកល ស្តីពីកសិកម្ម និងសន្តិសុខស្បៀង (GAFSP) របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបច្ចុប្បន្នត្រូវបានអនុវត្តតាមរយៈគម្រោងជំនួយស្បៀងសង្គ្រោះបន្ទាន់ ដំណាក់កាលទី២ (EFAP) កំពុងពង្រឹងបន្ថែមទៅលើអ្វីដែលបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រនេះ និងកម្មវិធីសន្តិសុខស្បៀងរបស់យុទ្ធសាស្ត្រស្តីពីកសិកម្មនិងទឹក។

និងកុមារតូច ប៉ុន្តែ យុទ្ធសាស្ត្រក៏បានគូសបញ្ជាក់ផងដែរថា ចាំបាច់ត្រូវមានអភិក្រមពហុវិស័យមួយដើម្បីដោះស្រាយមូលហេតុដែលបណ្តាលឱ្យមានបញ្ហាកង្វះអាហារូបត្ថម្ភប្រកបដោយជោគជ័យ។ គោលបំណង សូចនាករ និងគោលដៅព្រមទាំងអន្តរាគមន៍ជាអាទិភាពរបស់NNSមានសង្គតភាពទាំងស្រុងទៅនឹង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**[៤០]។ក្នុងពេលថ្មីៗនេះ ក្រសួងសុខាភិបាល/កម្មវិធីជាតិអាហារូបត្ថម្ភ កំពុងចាប់ផ្តើមធ្វើប្រតិបត្តិការ យុទ្ធសាស្ត្រ NNS និងដាក់ចេញនូវ "**ផែនទីបង្ហាញផ្លូវដើម្បីធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ ២០១៤-២០២០**" ដើម្បីបន្តពង្រីកភស្តុតាង ផ្អែកលើអន្តរាគមន៍អាហារូបត្ថម្ភក្នុងវិស័យសុខភិបាល។

**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា** (NSPS 2009-2013) ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) ដោយមានកិច្ចសហការជាមួយក្រសួងតាមវិស័យ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១១។ គោលដៅចម្បងនៃ NSPS គឺ "ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងងាយរងគ្រោះនឹងទទួលបានកិច្ចការពារកាន់តែច្រើនឡើងជាលំដាប់ ពីភាពក្រីក្ររ៉ាំរ៉ៃ និងភាពអត់ឃ្លាន វិបត្តិនានា ទុក្ខវេទនា និងការផាត់ចេញពីសង្គម ព្រមទាំងទទួលបានប្រយោជន៍ពីការវិនិយោគនៅក្នុងមូលធនមនុស្សរបស់ពួកគេ"។ អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភកុមារភាគច្រើនត្រូវបានឆ្លុះបញ្ចាំងថាជាប្រភពចម្បងនៃភាពងាយរងគ្រោះ និងត្រូវបានដោះស្រាយនៅក្នុងយុទ្ធសាស្ត្រនេះ។

**ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ**ត្រូវបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការយ៉ាងឱឡារិកកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ក្រោមទស្សនៈ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសនាំចេញអង្ករមួយដ៏សំខាន់ ដែលទទួលបានប្រយោជន៍ពីតម្រូវការ និងតម្លៃស្បៀងអាហារពិភពលោក ដែលមានការកើនឡើង។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថានៅត្រឹមឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជានឹងសម្រេចបានអតិរេកផលស្រូវចំនួនជាង ៤លានតោន និងការនាំចេញអង្ករយ៉ាងហោចណាស់ចំនួន ១លានតោន។ គោលនយោបាយនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយធ្វើសមាហរណកម្មទៅលើវិស័យផ្សេងៗគ្នា និងឆ្លុះបញ្ចាំងអំពីហានិភ័យប្រកបដោយសក្តានុពលចំពោះសន្តិសុខស្បៀងគ្រួសារ។

[៤០] បច្ចុប្បន្ន កម្មវិធីជាតិអាហារូបត្ថម្ភកំពុងចាប់ផ្តើមដាក់ឱ្យយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភមានប្រតិបត្តិការ ដោយរៀបចំបង្កើតជាផែនការសកម្មភាពអាហារូបត្ថម្ភ ដើម្បីបន្តពង្រីកអន្តរាគមន៍អាហារូបត្ថម្ភដែលមានមូលដ្ឋានផ្អែកលើភស្តុតាង។

## រូបភាពទី២៥៖ ទិដ្ឋភាពទូទៅអំពីគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិចម្បងៗ ដែលទាក់ទងទៅនឹង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

| ទិដ្ឋភាពនៃ [៤១] FSN | យុទ្ធសាស្ត្រ និងផែនការ | ក្រសួងដឹកនាំធ្វើ | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| **១. ការមានស្បៀង និងការទទួលបានស្បៀង** | ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យកសិកម្ម<br>យុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក (SAW)<br>ឯកសាររៀបចំកម្មវិធីពាក់ព័ន្ធ | MAFF<br>MAFF/<br>MOWRAM | 2009-2013<br>2006-2010<br>2010-2013 |
| | ឯកសារគោល នយោបាយស្តីពីការជំរុញ ផលិតកម្មស្រូវ និង ការនាំចេញអង្ករ (គោលនយោបាយស្រូវអង្ករ) | MEF MAFF | 2010 |
| | ក្របខ័ណ្ឌផែនការ យុទ្ធសាស្ត្រសម្រាប់ សត្វពាហនៈ | MAFF | 2011 – 2020 |
| | ផែនការអាទិភាពសុខភាពសត្វរយៈពេលមធ្យម | MAFF | 2011 -2015 |
| | ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល | MAFF | 2010 – 2019 |
| | កម្មវិធីព្រៃឈើជាតិ | MAFF | 2010 – 2029 |
| | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ស្តីពីធនធានទឹក និងឧតុនិយម | MOWRAM | 2009-2013 |
| | ផែនការយុទ្ធសាស្ត្រអប់រំ | MoEYS | 2009-2013 |
| | ក្របខ័ណ្ឌគោលនយោបាយដីធ្លី<br>ច្បាប់ភូមិបាល ២០០១ | MLMUPC | 2002<br>2001 |
| | ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និង វិសហមជ្ឈការព្រម ទាំងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) | MoI | 2010-2019 |
| **២. ការទទួលទានស្បៀង** | ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល(HSSP II) | MoH | 2008-2015 |
| | យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ (NNS) និង ផែនទីបង្ហាញផ្លូវដើម្បីធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ | MoH | 2009-2015 |
| | យុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | MRD | 2011-2025 |
| | គោលនយោបាយស្តីពីសុវត្ថិភាពស្បៀងអាហារ | | |

[៤១] យុទ្ធសាស្ត្រមួយចំនួន កំពុងធ្វើការដោះស្រាយទៅលើទិដ្ឋភាពជាច្រើននៃបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភស្របពេលជាមួយគ្នា ហើយនៅក្នុងតារាងនេះ សន្តិសុខស្បៀងមានទំនាក់ទំនងទៅនឹងទិដ្ឋភាពដែលផលប៉ះពាល់របស់សន្តិសុខស្បៀងទំនងនឹងមានកម្រិតខ្ពស់បំផុត។

| | | | |
|---|---|---|---|
| ៣.ស្ថេរភាព ស្បៀង | យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា (NSPS) | CARD | 2009-2013 |
| | ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ<br>ផែនការសកម្មភាពជាតិ (SNAP) ស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ | NCDM<br>NCDM | 2008-2013 |
| | អនុក្រឹត្យស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា | NCDM | 2006 |
| | កម្មវិធីសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | MoE | 2006 |
| | យុទ្ធសាស្ត្រឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | MAFF | 2014-2018 |
| | ផែនការយុទ្ធសាស្ត្រកម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុ | MoE | |

**យុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ** (RWSSHS 2011-2025) ដែលត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងឆ្នាំ២០១២ គូសបញ្ជាក់អំពីអតិក្រម រយៈពេលវែងមួយក្នុងគោលបំណងដែលបានកំណត់ថាត្រឹមឆ្នាំ២០១៥ - ៥០% (២០២៥ - ១០០%) នៃប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទ ទទួលបានការផ្គត់ផ្គង់ទឹកដែលមានលក្ខណៈប្រសើរជាងមុន និង ៣០% (២០២៥ - ១០០%) ទទួលបានអនាម័យ ប្រសើរជាងមុន និងអនុវត្តការប្រព្រឹត្តអនាម័យមូលដ្ឋានប្រកបដោយសុវត្ថិភាព។ យុទ្ធសាស្ត្រនេះ មិនត្រឹមតែផ្តោតយកចិត្តទុកដាក់ទៅលើការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែ យុទ្ធសាស្ត្រក៏ផ្តោតការយកចិត្តទុកដាក់ផងដែរ ទៅលើការផ្លាស់ប្តូរការប្រព្រឹត្ត និងយន្តការពាក់ព័ន្ធនានាដែលលើកកម្ពស់ភាពជាម្ចាស់ និងនាំឱ្យឈានទៅរកការប្រើប្រាស់ប្រតិបត្តិការ និងការថែទាំឧបករណ៍ទាំងនោះឱ្យបានសមស្រប។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**នឹងមិនជំនួស ឬ ប្រកួតប្រជែងជាមួយយុទ្ធសាស្ត្រទាំងនេះឡើយ ទោះក្នុងរូបភាពណាក៏ដោយ ដោយឡែកយុទ្ធសាស្ត្រនេះផ្តល់នូវឧបករណ៍មួយដើម្បីស្វែងរកការគាំទ្រឱ្យមាន ការផ្តល់មូលនិធិបន្ថែម និងលើកកម្ពស់ការធ្វើសកម្មភាពរួមគ្នាដោយមានការសម្របសម្រួល សំដៅធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និង អាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា។

__រូបភាពទី២៦__ ៖ ការតម្រឹមយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅនឹងយុទ្ធសាស្ត្រ និងផែនការដែលមានស្រាប់ដទៃទៀត



## ៣.៣. កម្មវិធី និងគម្រោងថ្នាក់ជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

កម្មវិធី និងគម្រោងនានាដែលមានបំណងលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភកម្រិតគ្រួសារ ពុំមែនជាកម្មវិធី ឬ គម្រោងថ្មីឡើយ អាស្រ័យដោយកម្មវិធី និងគម្រោងបែបនេះ ត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ តាមរយៈបណ្តាក្រសួងនានា (MAFF, MRD, MWORAM, MoH, MEF) ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសហប្រជាជាតិ។ កម្មវិធីទាំងនេះភាគច្រើន មិនត្រូវបានរៀបចំជាក់លាក់ ដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងលក្ខណៈជាបញ្ហាដែលមានភាពប្រទាក់ក្រឡាគ្នាឡើយ ប៉ុន្តែកម្មវិធី និងគម្រោងទាំងនោះត្រូវបានរៀបចំឡើងក្នុងទម្រង់ជាគម្រោងអភិវឌ្ឍន៍ជនបទ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ តាមរយៈការគាំទ្រដល់ប្រព័ន្ធផលិតកម្មកសិកម្មរបស់កសិករខ្នាតតូច [៤២] កម្មវិធីសម្រាប់គាំទ្រដល់កំណើនសេដ្ឋកិច្ចគ្រួសារប្រកបដោយនិរន្តរភាព សំដៅកាត់បន្ថយភាពក្រីក្រ និងការទទួលបានស្មើភាពគ្នានូវធនធានធម្មជាតិ [៤៣] ឬដើម្បីលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភសហគមន៍ [៤៤]។ សំណាញ់សុវត្ថិភាពសង្គមសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (កម្មវិធីផ្តល់អាហារនៅឯសាលារៀន អាហារូបករណ៍សម្រាប់ជនក្រីក្រ កម្មវិធីអាហាររូបត្ថម្ភដែលរួមមានផលិតផលម្ហូបអាហារមានជីវជាតិពិសេសសម្រាប់កុមារតូច និង ការចែកចាយស្បៀងអាហារបានកំណត់គោលដៅសម្រាប់គ្រួសារដែលទទួលរងផលប៉ះពាល់ពីគ្រោះមហន្តរាយនិងកម្មវិធីស្បៀងពលកម្ម សាច់ប្រាក់ពលកម្មត្រូវបានអនុវត្តតាមរយៈកម្មវិធីស្បៀងអាហារពិភពលោក ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាល។ អន្តរាគមន៍ដែលផ្តោតយកចិត្តទុកដាក់ទៅលើអាហារូបត្ថម្ភវិស័យសុខាភិបាល ត្រូវបានសម្របសម្រួល និងអនុវត្តតាមរយៈកម្មវិធីជាតិអាហារូបត្ថម្ភរបស់ក្រសួងសុខាភិបាលនិងក្រសួងផែនការ ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម និង អង្គការមិនមែនរដ្ឋាភិបាល បានសម្របសម្រួលដល់ការអនុវត្តន៍កម្មវិធី ដើម្បីលើកកម្ពស់ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារអស់រយៈពេលជាច្រើនឆ្នាំ។

---

[៤២] ឧទាហរណ៍ចម្បងៗសម្រាប់គម្រោង និងកម្មវិធីទាំងនេះ រួមមាន EU-PRASAC និងECOSORN (ការផ្សព្វផ្សាយឡើងវិញអំពីកត្តា សេដ្ឋកិច្ច និងសង្គមនៃបណ្តាខេត្តដែលស្ថិតនៅភាគឦសាន ប្រទេសកម្ពុជា) គម្រោងអភិវឌ្ឍន៍ជនបទ/កសិកម្មនៅទសវត្សរ៍ចុងក្រោយ។ "គម្រោងជួយដោះស្រាយភាពងាយរងគ្រោះនៅជនបទ និងស្ថេរភាពប្រព័ន្ធអេកូឡូស៊ី" HARVEST) ដែលផ្តល់ហិរញ្ញប្បទានគាំទ្រដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ កំពុងត្រូវបានអនុវត្តនៅក្នុងបណ្តាខេត្តជុំវិញបឹងទន្លេសាប ដែលមានកម្រិតអសន្តិសុខស្បៀងខ្ពស់ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូល និងអាហារូបត្ថម្ភសម្រាប់គ្រួសារដែលរស់នៅតំបន់ជនបទ ចំនួន ៧០.០០០គ្រួសារ (ផ្តោតលើវិស័យកសិកម្ម វារីវប្បកម្ម និងជលផល ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ការបញ្ចូលក្នុងសង្គម និងការអភិវឌ្ឍន៍សមត្ថភាព)។

[៤៣] ឧទាហរណ៍នៃចំណុចទាំងនេះ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងគម្រោងដែលទទួលបានការគាំទ្រទាំងស្រុងពី IFAD នៅក្នុងការផ្តួចផ្តើមតំបន់បឹងទន្លេសាប ដូចជាគម្រោងគាំទ្រជីវភាពរស់នៅប្រកបដោយនិរន្តរភាពនៅតំបន់បឹងទន្លេសាប (TSSLP) និងគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិករខ្នាតតូច នៅទំបន់បឹងទន្លេសាប។

[៤៤] ក្នុងចំណោមកម្មវិធីដទៃទៀត កម្មវិធី "សិទ្ធិកុមារ" ដែលគាំទ្រដោយអង្គការយូនីសេហ្វ ផ្តោតយកចិត្តទុកដាក់ទៅលើបញ្ហាអាហារូបត្ថម្ភ និងអនាម័យ (បានអនុវត្តកាលពីទសវត្សរ៍មុន) និង MDG-F "កម្មវិធីរួមគ្នាសម្រាប់កុមារ សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា" ផ្តោតយកចិត្តទុកដាក់ទៅលើការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ (តាមរយៈការពង្រឹងការសម្របសម្រួលអន្តរាគមន៍ អាហារូបត្ថម្ភទូទាំងបណ្តាក្រសួងពាក់ព័ន្ធ និងអង្គការសហប្រជាជាតិ)។

ក្នុងលក្ខណៈជាការឆ្លើយតបទៅនឹងតម្លៃស្បៀងអាហារ និងធាតុចូលកសិកម្ម ដែលបានកើនឡើងខ្ពស់ក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំកម្មវិធីសន្តិសុខស្បៀងដែលមានទ្រង់ទ្រាយធំជាងមុន ដើម្បីជួយដល់ជនក្រីក្រ និងជនដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង ដើម្បីដោះស្រាយផលប៉ះពាល់នៃវិបត្តិនេះ ក្នុងនោះរួមមានគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ (EFAP) [៩៥] មូលដ្ឋានស្បៀងរបស់សហភាពអឺរ៉ុប (EU-FF) និងហិរញ្ញប្បទានកម្មវិធីឆ្លើយតបទៅនឹងវិបត្តិស្បៀងអាហារសកលរបស់ធនាគារពិភពលោក(WB)។ កម្មវិធីទាំងនេះ មានចរិកលក្ខណៈជាការឆ្លើយតបទៅនឹងគ្រោះអាសន្ន និងផ្តោតយកចិត្តទុកដាក់ទៅលើការផ្តល់កិច្ចគាំទ្រភ្លាមៗជូនដល់ជនក្រីក្រ និងជនងាយរងគ្រោះ តាមរយៈការចែកស្បៀងអាហារ និងធាតុចូលកសិកម្ម ការបង្កើតឱកាសទទួលបានប្រាក់ចំណូលបណ្តោះអាសន្ន និងការពង្រឹងសមត្ថភាពឆ្លើយតបទៅនឹងគ្រោះអាសន្ន។ អន្តរាគមន៍ទាំងនេះ គឺជាអន្តរាគមន៍រយៈពេលខ្លី និងមានការអភិវឌ្ឍន៍ដោយមិនពឹងផ្អែកគ្នាទៅវិញទៅមក។

បន្ថែមពីនេះទៀត កម្មវិធីលើកកម្ពស់សមត្ថភាពស្ថាប័ន និងបរិយាកាសគោលនយោបាយសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (រាប់បញ្ចូលការត្រួតពិនិត្យ និងការគ្រប់គ្រងព័ត៌មាន) ត្រូវបានអនុវត្តក្នុងលក្ខណៈជាធាតុផ្សំនៃអន្តរាគមន៍ដែលមានទ្រង់ទ្រាយធំជាងនេះ ឬ តាមរយៈគម្រោងតូចៗ ដែលមានមូលដ្ឋាននៅក្នុងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា (MAFF, MoP, CARD, NCDM, MEF) នៅក្នុងទសវត្សរ៍ចុងក្រោយនេះ [៩៦]។

<u>ឧបសម្ព័ន្ធ២</u> នៃ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីរាល់កម្មវិធី និងគម្រោងចម្បងៗដែលកំពុងដំណើរការ (ឬ កំពុងត្រូវបានគ្រោងរៀបចំឡើង) ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្របខ័ណ្ឌពេលវេលា និងក្រុមគោលដៅរបស់កម្មវិធី និងគម្រោងទាំងនោះ។

---

៩៥ គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ (EFAP) ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានអនុវត្តពីឆ្នាំ២០០៨-២០១១ ក្នុងលក្ខណៈ ជាគម្រោងកម្ចី និងជំនួយឥតសំណងទ្រង់ទ្រាយធំមួយ ដែលមានសមាសធាតុចំនួន៣ ៖ កិច្ចគាំទ្រស្បៀងអាហារ (ការចែកស្បៀង - FFW) ការលើកកម្ពស់ផលិតភាព (ភាគច្រើនផ្តោតលើការផ្តល់គ្រាប់ពូជ និងជីក្នុងតម្លៃឧបត្ថម្ភធន)និងការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការឆ្លើយតបទៅនឹងគ្រោះអាសន្ន។ នៅថ្នាក់ភូមិភាគ គម្រោងបានផ្តោតយកចិត្តទុកដាក់ទៅលើបណ្តាខេត្តដែលស្ថិតនៅជុំវិញបឹងទន្លេសាប។ គម្រោងនេះបានផ្តល់ជំនួយដល់ការធ្វើប្រតិបត្តិការនៃស្បៀងបម្រុងរបស់កម្ពុជា។ ដំណាក់កាលបន្ត (EFAP-AF) នឹងត្រូវ អនុវត្តនៅចន្លោះ ឆ្នាំ២០១៣-២០១៥ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានមូលនិធិគាំទ្រពី GAFSPក្នុងខេត្តគោលដៅចំនួន១០ ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដើម្បីដោះស្រាយបញ្ហារចនាសម្ព័ន្ធដែលទាក់ទងទៅនឹងអសន្តិសុខស្បៀង តាមរយៈការបង្កើនភាពមានស្បៀងដែលប្រកបដោយអាហារូបត្ថម្ភ និងការយល់ដឹងអំពីស្បៀងដែលប្រកបដោយអាហារូបត្ថម្ភ និងអនាម័យ ការទទួលបានធាតុចូល និងបច្ចេកទេសកសិកម្មប្រសើរជាងមុន។ គម្រោង EFAPមានបំណងបន្តធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព ក្នុងការបញ្ជ្រាបអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនភាពធន់ទ្រាំរបស់ជនក្រីក្រ និងជនងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយ។

៩៦ អង្គការ GIZ បានគាំទ្រគម្រោងគាំទ្រគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភមួយ ដែលផ្តល់ជំនួយបច្ចេកទេសជូនដល់ក្រសួងផែនការ និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (2003-2010)។ អង្គការ FAOបានជួយដល់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ លើការកសាងសមត្ថភាពដើម្បីបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយអង្គការ FAO និង WFPបានកសាងសមត្ថភាពគ្រប់គ្រងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ ក្នុងរយៈពេល២ឆ្នាំចុងក្រោយ។ គម្រោង EFAPដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការអភិវឌ្ឍន៍សំណើសម្រាប់ការត្រៀមលក្ខណៈនិងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ព្រមទាំងការត្រួតពិនិត្យទៅលើសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

## ៣.៤. ការរៀបចំបង្កើតស្ថាប័នសម្រាប់ការសម្របសម្រួលដែលទាក់ទងនៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ដើម្បីទទួលបានផលប៉ះពាល់ និងលទ្ធផលជាអតិបរមា ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា តម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពខ្ពស់ពីបណ្ដាក្រសួងពាក់ព័ន្ធ អ្នកពាក់ព័ន្ធពីស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យបានទូលំទូលាយ ដើម្បីឱ្យពួកគេ អាចកំណត់អាទិភាព និងធ្វើសកម្មភាពរួមគ្នាបាន។ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំបង្កើតរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់វិស័យសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដើម្បីគាំទ្រដល់បណ្ដាក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងការកសាងសមត្ថភាពទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

រដ្ឋាភិបាលកម្ពុជាបានប្រគល់ភារកិច្ច ក្នុងការដឹកនាំសម្របសម្រួលអភិវឌ្ឍន៍គោលនយោបាយទាក់ទងទៅនឹងបញ្ហាសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដែលជាប្រធានបទមានលក្ខណៈប្រទាក់ក្រឡាគ្នា ទៅឱ្យក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ [៤៧] ។ ក្នុងឆ្នាំ២០០៣ វេទិកាជាតិស្ដីពីសន្តិសុខស្បៀង(NFSF) ត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវចែករំលែកព័ត៌មាន ចំណេះដឹង បទពិសោធន៍ និងការអនុវត្តន៍ល្អ ក្នុងចំណោមក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៤ ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (TWG-FSN) ដែលរួមមានសមាសភាពពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល ការធ្វើសុខដុមនីយកម្ម និងការតម្រឹមទៅលើកិច្ចខិតខំអភិវឌ្ឍន៍ ហើយលេខាធិការដ្ឋានមួយនៃក្រុមការងារបច្ចេកទេសសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធាន ត្រូវបានបង្កើតឡើង។

ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនជន និងក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្របសម្រួល ដល់ការបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ SFFSN 2008-2013 និង NSFSN 2014-2018) និងកិច្ចគាំពារសង្គម (NSPS) ព្រមទាំងត្រូវរៀបចំធ្វើការត្រួតពិនិត្យ និងវាយតម្លៃឱ្យមានប្រសិទ្ធភាព។ នៅដើមឆ្នាំ ២០១៤ អង្គភាពសម្របសម្រួលវិស័យគាំពារសង្គម ត្រូវបានបញ្ចូលជាមួយក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅជាក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ថ្មីមួយ ដែលដឹកនាំដោយប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណុចរួមរវាងបញ្ហាសំខាន់ ដែលមានលក្ខណៈប្រទាក់ក្រឡាទាំងពីរនេះ បង្កើនការត្រួតពិនិត្យគោលនយោបាយនិងសមត្ថភាពនៃការប្រើប្រាស់ដ៏ល្អបំផុត នៅក្នុងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ[៤៨]។

[៤៧] អាណត្តិការងារនេះត្រូវបានគូសបញ្ជាក់នៅក្នុងព្រះរាជក្រឹត្យ ឆ្នាំ១៩៩៨ និងបញ្ជាក់កាន់តែជាក់លាក់នៅក្នុងអនុក្រឹត្យ (លេខ៧៩ អនក្រ/បក) ហើយថ្មីៗនេះ ត្រូវបានបញ្ជាក់ឡើងវិញដោយសម្ដេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងសិក្ខាសាលាថ្នាក់ជាតិលើកទី៤ ស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលប្រព្រឹត្តិឡើងក្នុងខែឧសភា ឆ្នាំ២០១២។

[៤៨] សូមមើល សេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារបច្ចេកទេស គាំពារស ង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤របស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

ចាប់តាំងពីឆ្នាំ២០០៤ ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSNIS) នៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានក្លាយជាច្រកស្វែងរកប្រភពព័ត៌មានតាមអ៊ិនធឺណែតនៅកម្រិតថ្នាក់ជាតិ សម្រាប់ព័ត៌មានទាំងឡាយណាដែលទាក់ទងទៅនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០០៦ **ក្រុមការងារគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភមួយ** (FSNIMTF) ត្រូវបានបង្កើតឡើង ក្នុងលក្ខណៈជាអនុរចនាសម្ព័ន្ធរបស់ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីសម្របសម្រួលដល់ការគ្រប់គ្រងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០១០ ក្រុមវិភាគទិន្នន័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភមួយ (FSNDAT) ដែលរួមមានសមាសភាពចូលរួមមកពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនជន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងផែនការ ក្រសួងសុខាភិបាល និងគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ ត្រូវបានបង្កើតឡើងដើម្បីធ្វើការវិភាគទៅលើស្ថានភាពសន្តិសុខស្បៀងដោយផ្អែកលើព័ត៌មានដែលមានស្រាប់ ដែលទទួលបានពីស្ថានីយ៍អាកាសធាតុ ស្ថិតិរដ្ឋបាល និងទិន្នន័យពីការអង្កេតថ្នាក់ជាតិ។ **ព្រឹត្តិបត្រព័ត៌មានស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រចាំត្រីមាស** ត្រូវបានផលិតដើម្បីផ្តល់នូវទិដ្ឋភាពទូទៅមួយជាទៀងទាត់ អំពីនិន្នាការ និងការគំរាមកំហែងដែលកំពុងកើតឡើងថ្មីៗ ទាក់ទងទៅនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា សម្រាប់ធ្វើការរៀបចំគោលនយោបាយ និងអន្តរាគមន៍នានា ព្រមទាំងការឆ្លើយតបទៅនឹងវិបត្តិ។ ចាប់តាំងពីឆ្នាំ ២០០៤ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ដោយមានកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាល បានរៀបចំធ្វើការកសាងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ដើម្បីលើកកម្ពស់ការបញ្ជ្រាបអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងយុទ្ធសាស្ត្រជាតិ និងដំណើរការរៀបចំផែនការវិមជ្ឈការ ហើយ**ក្រុមគ្រូបង្គោលថ្នាក់ជាតិសម្រាប់បណ្តុះបណ្តាលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ត្រូវបានរៀបចំបង្កើតជាផ្លូវការក្នុងខែធ្នូ ឆ្នាំ២០០៩។

បន្ថែមពីនេះទៀត រចនាសម្ព័ន្ធសម្របសម្រួលជាច្រើនផ្សេងៗគ្នាសម្រាប់បញ្ហាដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្កើតឡើង និងមានបណ្តាក្រសួងពាក់ព័ន្ធនានាធ្វើជាប្រធាន។ ក្រុមការងារសន្តិសុខស្បៀង ត្រូវបានបង្កើតឡើងនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោយពេលដែលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើកចុងក្រោយ ដើម្បីសម្របសម្រួលដល់ការអភិវឌ្ឍ និងការអនុវត្តន៍ប្រតិបត្តិការសន្តិសុខស្បៀងសង្គ្រោះបន្ទាន់របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបានក្លាយជារចនាសម្ព័ន្ធមួយដែលកាន់តែមានភាពអចិន្ត្រៃយ៍ សម្រាប់ឃ្លាំមើលទៅលើការអនុវត្តន៍គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ (EFAP) និងការបង្កើតអង្ករ និងគ្រាប់ពូជបម្រុងជាតិ។ ក្រុមការងារអាហារូបត្ថម្ភ (NWG) នៃកម្មវិធីជាតិអាហារូបត្ថម្ភ (NNP) ក្នុងក្រសួងសុខាភិបាល សម្របសម្រួលដល់អន្តរាគមន៍វិស័យសុខាភិបាល ដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតា។ អនុគណៈកម្មាធិការជាតិទទួលបន្ទុកវិបត្តិកង្វះជាតិអ៊ីយ៉ូដ (NSCIDD) និង **អនុគណៈកម្មាធិការជាតិទទួលបន្ទុកការងារបញ្ចូល**

**មីក្រូសារជាតិទៅក្នុងចំណីអាហារ** (NSCFF) ដែលមានក្រសួងផែនការជាប្រធាន និងមានទំនាក់ទំនងទៅនឹង**ក្រុមប្រឹក្សាជាតិអាហារូបត្ថម្ភ** (NCN)[៤៩] កំពុងរៀបចំបង្កើតផែនការ និងគោលការណ៍ណែនាំជាតិ ព្រមទាំងសម្របសម្រួលដល់ដំណើរការលើកកម្ពស់ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ នៅក្នុងប្រទេសកម្ពុជា។ រចនាសម្ព័ន្ធទាំងនេះ កំពុងសម្របសម្រួលការងាររបស់ពួកគេយ៉ាងជិតស្និទ្ធ ជាមួយ**ក្រុមការងារបច្ចេកទេស គាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។

**រូបភាពទី២៧៖ ទិដ្ឋភាពរួមរបស់ស្ថាប័ន ចំពោះបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា**




ការរៀបចំស្ថាប័នសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្កើតឡើងយ៉ាងល្អប្រសើរក្នុងប្រទេសកម្ពុជា ប៉ុន្តែ គេត្រូវការឱ្យមាននូវការបន្តលើកកម្ពស់សមត្ថភាព ការបញ្ជាក់អំពីតួនាទី និងមុខងារ និងការចូលរួមកាន់តែច្រើនបន្ថែមទៀតពីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យមាននូវការអនុវត្តន៍**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ប្រកបដោយប្រសិទ្ធភាព។ អាទិភាពសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល ការត្រួតពិនិត្យ និងការគ្រប់គ្រងព័ត៌មាន ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេល៥ឆ្នាំបន្ទាប់ នឹងត្រូវកំណត់នៅក្នុងជំពូកទី៧ នៃឯកសារនេះ។

[៤៩] ស្ថិតក្រោមក្រុមប្រឹក្សាជាតិអាហារូបត្ថម្ភ និងគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងនៃក្រុមប្រឹក្សានេះ ផែនការវិនិយោគអាហា រូបត្ថម្ភនៅកម្ពុជាមួយ (CNIP 2002-2008)ត្រូវបានអភិវឌ្ឍន៍ឡើង។

# ៤. បញ្ហាប្រឈម ចន្លោះប្រហោង និងអាទិភាពកម្មវិធី

ដើម្បីធ្វើឱ្យ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** កាន់តែមានភាពជាក់លាក់ ជំពូកនេះ កំណត់អំពីវិស័យអាទិភាពកម្មវិធី ដើម្បីសម្រេចឱ្យបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ចំពោះបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្រិតគ្រួសារ ក្នុងរយៈពេល៥ឆ្នាំបន្ទាប់ក្នុងប្រទេសកម្ពុជា។ បើទោះបីជាវិស័យ និងបញ្ហាប្រទាក់ក្រឡាគ្នាជាច្រើនមានទំនាក់ទំនងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក៏ដោយ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ** ព្យាយាមផ្តោតយកចិត្តទុកដាក់ទៅលើវិស័យទាំងឡាយណា ដែលបច្ចុប្បន្នកំពុងមានភាពពាក់ព័ន្ធបំផុតនៅក្នុងបរិបទប្រទេសកម្ពុជា។

## ៤.១. បញ្ហាប្រឈមចម្បងៗ និងចន្លោះប្រហោងដែលមានស្រាប់ទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

រូបភាពទី២៨ សង្ខេបអំពីបញ្ហាចម្បងៗ និងការប្រឈមដែលក្រុមផ្សេងៗគ្នា កំពុងជួបប្រទះនាពេលបច្ចុប្បន្ន ទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា វឌ្ឍនភាពដែលសម្រេចបានតាមរយៈអន្តរាគមន៍កន្លងមក ឬ អន្តរាគមន៍បច្ចុប្បន្ន ព្រមទាំងចន្លោះប្រហោងដែលនៅសេសសល់សំខាន់ៗបំផុត។បញ្ហាប្រឈមនិងចន្លោះប្រហោងនានា[៥០] សុទ្ធសឹងតែមានវត្តមាននៅក្នុងទិដ្ឋភាពទាំង៤ នៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ សកម្មភាពជាក់លាក់ (សកម្មភាពអាទិភាព) ដើម្បីលុបបំបាត់ចន្លោះប្រហោងទាំងនេះ ក្នុងគោលបំណងលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ រហូតដល់ឆ្នាំ២០១៨ នឹងត្រូវបានគូសបញ្ជាក់ក្រោមគោលបំណងនីមួយៗនៅក្នុងជំពូកទី៦នៃឯកសារនេះ។

[៥០] ចន្លោះប្រហោងអាចកើតមាននៅកម្រិតផ្សេងៗគ្នា (ចំណេះដឹង/ការយល់ដឹង ការអនុវត្តន៍ ឬ ការប្តេជ្ញាចិត្ត។ល។)។ សម្រាប់អន្តរាគមន៍ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ភាពសមស្របផ្នែកបច្ចេកទេសនៃដំណោះស្រាយរបស់អន្តរាគមន៍ទាំងនោះ និងការកំណត់គោលដៅឱ្យបានសមស្រប (ចំពោះតំបន់គ្រួសារ និងក្រុមដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង) មានសារៈសំខាន់ខ្លាំងណាស់។

រូបភាពទី២៨ ៖ ទិដ្ឋភាពទូទៅអំពីបញ្ហាប្រឈម វឌ្ឍនភាពដែលសម្រេចបាន និង ចន្លោះប្រហោងដែលនៅសេសសល់

| ការប្រឈម/បញ្ហា | ក្រុមពាក់ព័ន្ធ | វឌ្ឍនភាពសម្រេចបាន | ចន្លោះប្រហោង និងបញ្ហាប្រឈម ដែលនៅសេសសល់ |
|---|---|---|---|
| **១. ការមានស្បៀង និងការទទួលបានស្បៀង** | | | |
| ផលិតភាពទាប និងហានិភ័យខ្ពស់នៃប្រព័ន្ធកសិកម្មដែលមានមូលដ្ឋានផ្អែកលើស្រូវ - ភាពមានកម្រិតក្នុងការទទួលបានធាតុចូលប្រកបដោយគុណភាព (គ្រាប់ពូជ និងជី) និងសេវាគាំទ្រវិស័យកសិកម្ម (សេវាផ្សព្វផ្សាយ ការរក្សាទុក និងទីផ្សារ)។ | កសិករខ្នាតតូចដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង | ការកើនឡើងនូវទិន្នផលស្រូវ គួរឱ្យកត់សម្គាល់ ក្នុងរយៈពេលទសវត្សរ៍ចុងក្រោយ។ អសន្តិសុខស្បៀងត្រូវបានដោះស្រាយជាក់លាក់នៅក្នុងកម្មវិធី ដោយផ្អែកលើ SAW (កម្មវិធីគាំទ្រសន្តិសុខស្បៀង) និងតាមរយៈ គម្រោងជាច្រើន របស់អង្គការមិនមែនរដ្ឋាភិបាល និងគម្រោងផ្សេងៗ ដែលប្រើប្រាស់ថវិការដ្ឋ។ | • ភាពមានកម្រិតនៃវិសាលភាពនៃកម្មវិធី ប្រពលវប្បកម្មស្រូវ ដែលផ្តោតយកចិត្តទុកដាក់ទៅលើកសិករខ្នាតតូច<br>• ការលំបាក ទាក់ទងទៅនឹងការ រក្សាទុក និងទីផ្សារស្រូវនៅតែបន្តកើតមាន (សម្រាប់កសិករដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង)។<br>• កង្វះទុនសម្រាប់ការងារស្រាវជ្រាវរកពូជ និងបច្ចេកទេសល្អៗ និងខ្វះថវិកាក្នុងការបណ្តុះបណ្តាលកសិករ អំពីបច្ចេកទេសផលិតកម្ម និង ក្រោយពេលប្រមូលផល និងការធ្វើស្រែបង្ហាញដល់កសិករ។ |
| កង្វះពិពិធកម្ម និងសមាហរណកម្មទីផ្សារនៃប្រព័ន្ធកសិកម្ម ធ្វើឱ្យមានកម្រិតក្នុងការទទួលបានធាតុចូលប្រកបដោយគុណភាព (គ្រាប់ពូជ និងជី) និងសេវាគាំទ្រ វិស័យកសិកម្ម (សេវាផ្សព្វផ្សាយ ការរក្សាទុក និងទីផ្សារ)។ | កសិករខ្នាតតូចដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង | បង្កើនពិពិធកម្ម (ការច្របាច់បញ្ចូលគ្នានូវការផលិតបន្លែ ការចិញ្ចឹមសត្វខ្នាតតូច វារីវប្បកម្ម ដំណាំ កសិផលសម្រាប់លក់) តាមរយៈអន្តរាគមន៍ នានាដែលត្រូវបាន អនុវត្តនៅក្នុង ក្របខ័ណ្ឌនៃ | • វិសាលភាពមានកម្រិត និងការសម្របសម្រួលមិនគ្រប់គ្រាន់ និងការត្រួតពិនិត្យទៅលើកម្មវិធីពិពិធកម្មរបស់កសិករខ្នាតតូចនៅមានកម្រិត<br>• មានអង្គការកសិករ/សហករតិចតួច សម្រាប់ធ្វើទីផ្សារ និង ផ្គត់ផ្គង់ធាតុចូល<br>• យន្តការសម្រាប់ការរៀបចំធ្វើកសិកម្មតាមកិច្ចសន្យា |

| | | | |
|---|---|---|---|
| | | SAW (កម្មវិធីគាំទ្រសន្តិសុខស្បៀង) និងតាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងគម្រោងផ្សេងៗ ដែលប្រើប្រាស់ថវិការដ្ឋ។ | មិនទាន់ ត្រូវបានបង្កើត។<br>• កង្វះការចូលរួមពីវិស័យឯកជន ក្នុងការវិនិយោគវិស័យកែច្នៃក្នុង ស្រុក (Agro processing) ហើយ ឧបត្ថម្ភទុនពីរាជរដ្ឋាភិបាលនៅ មានកម្រិតទាប។ |
| លទ្ធភាពរបស់កសិករខ្នាតតូចនៅមានកម្រិតក្នុងការទទួលបាន ប្រព័ន្ធធារាសាស្ត្រ | កសិករខ្នាតតូចដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង | ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រខ្នាតធំ កំពុងត្រូវ បានអនុវត្ត។ | • កសិករខ្នាតតូចដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀងទទួល បានប្រយោជន៍តិចតួចពីការវិនិយោគទៅលើប្រព័ន្ធធារាសាស្ត្រខ្នាតធំ។ |
| លទ្ធភាពក្នុងការទទួលបានដីកសិកម្មនៅមានកម្រិតនិងពុំមានស្ថេរភាព | គ្រួសារជួបប្រទះបញ្ហាអសន្តិសុខស្បៀងដែលខ្វះខាតដីនិងគ្មានដី | លទ្ធភាពរបស់ជនក្រីក្រក្នុងការទទួលបានដីធ្លី និងសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី កំពុងមានភាពប្រសើរឡើង(ការផ្តល់ប្លង់ដីក្នុងលក្ខណៈជាប្រព័ន្ធសម្បទានដីសង្គមកិច្ច និងការអនុវត្តន៍ សារាចរណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ចាប់ពីថ្ងៃទី១ ខែ ឧសភា ឆ្នាំ ២០១២ ក្នុងគោលបំណង ធានាឱ្យបាននូវ សិទ្ធិដីធ្លីរបស់គ្រួសារក្រីក្រចំនួន ៤៧.០០០ គ្រួសារ)។ | • សិទ្ធិសមូហភាពក្នុងការទទួលបានដីធ្លីនៅក្នុងសហគមន៍ជនជាតិភាគតិចពុំទទួលបានការធានា<br>• សម្ពាធដីធ្លី និងកង្វះដីធ្លីនៅតំបន់ទំនាប (គ្មានដីសម្រាប់ចែកជូន)<br>• ពុំមានការភ្ជាប់ទំនាក់ទំនងគ្រប់គ្រាន់ (សម្បទានដីសង្គមកិច្ច/ សេវាកសិកម្ម)<br>• ការបាត់បង់ទំនាក់ទំនង រវាងសម្បទានដី សេដ្ឋកិច្ច និងប្រព័ន្ធផលិតកម្មរបស់កសិករខ្នាតតូច។<br>• ពុំមានក្របខ័ណ្ឌគតិយុត្តដើម្បី គ្រប់គ្រងប្រើប្រាស់ និងអភិរក្ស ធនធានដីកសិកម្ម។ |

| | | | |
|---|---|---|---|
| ភាពរិចរិល និងភាពមានកម្រិតក្នុងការទទួលបានធនធានទ្រព្យសម្បត្តិរួមពីវិស័យជលផល និង ព្រៃឈើ | គ្រួសារក្រីក្រដែល យ៉ាងហោចណាស់មានការពឹងផ្អែកមួយផ្នែកទៅលើ ធនធានជលផល និងព្រៃឈើ | គោលនយោបាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់គ្រួសារដែល ជួបប្រទះបញ្ហា អសន្តិសុខស្បៀង ក្នុងការទទួលបាន ធនធានជលផល (ការបិទឡូតិ៍ នេសាទឯកជន) និងកិច្ចខិតខំ ដើម្បី ជំរុញឱ្យមានការចូលរួមពីសហគមន៍ នៅក្នុងការគ្រប់គ្រង ធនធានជលផល និងព្រៃឈើប្រកប ដោយនិរន្តរភាព។ | • វិសាលភាពនៃកិច្ចសហការគ្រប់គ្រងរបស់សហគមន៍ទៅ លើធនធានជលផល និង ព្រៃឈើ នៅមិនទាន់មានភាព គ្រប់គ្រាន់<br>• ការរំលោភនៃសម្បទានដីសេដ្ឋកិច្ច (ELC) ទៅលើធនធានទ្រព្យសម្បត្តិរួម<br>• ការគំរាមកំហែងពីគម្រោងវារី-អគ្គិសនីទៅលើការបំលាស់ទីរបស់ត្រី និងការអនុវត្តន៍ នេសាទដែលបង្កឱ្យមាននូវគ្រោះថ្នាក់។ |
| ការងារ (ក្រៅពីស្រែចម្ការ) និងឱកាសបង្កើតប្រាក់ចំណូលនៅតំបន់ជនបទមានកម្រិត( ការធ្វើពលកម្មដើម្បីទទួលបានប្រាក់កម្រៃ នៅក្នុងវិស័យសេដ្ឋកិច្ច ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ) | ជាពិសេស គឺ គ្រួសារ និងយុវជន ជួបប្រទះ បញ្ហាអសន្តិសុខស្បៀងដែលគ្មានដី និងខ្វះខាតដី | តម្រូវការកម្លាំងពលកម្មមានការកើនឡើងជាលំដាប់ (វិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ប៉ុន្តែ កំណើននេះ ក៏បណ្តាលមកពីការធ្វើពាណិជ្ជកម្ម ទៅលើ វិស័យកសិកម្មផងដែរ) ។ TVET ដើម្បីបង្កើន ជំនាញ (កំណត់ គោលដៅទៅលើ ជនក្រីក្រ) ការភ្ជាប់ទំនាក់ទំនងរវាង តំបន់ទីក្រុងនិងតំបន់ជនបទ មានការកើនឡើង។ | • គ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ខ្វះជំនាញដើម្បីឱ្យស្របទៅនឹងល័ក្ខខ័ណ្ឌ តម្រូវសម្រាប់ទទួលបានការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ<br>• ការស្រូបយកកម្លាំងការងារនៅតំបន់ជនបទ តាមរយៈកសិធុរកិច្ច/សម្បទានដីសេដ្ឋកិច្ច ខ្នាតធំនៅមានកម្រិត<br>• ល័ក្ខខ័ណ្ឌការងារដែលមិនត្រូវបានធ្វើនិយ័តកម្មចំពោះពលកម្ម ទទួលបានប្រាក់កម្រៃក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធបង្កឱ្យមានផលប៉ះពាល់ជាពិសេសទៅលើស្ត្រី។ |

| | | | |
|---|---|---|---|
| សហគ្រាសខ្នាតតូចបំផុត និងសហគ្រាសខ្នាតតូច និងមធ្យម ដែលផ្តល់ការងារ និងប្រាក់ចំណូល (និងដែលផ្តល់នូវស្ថេរភាពចំពោះលទ្ធភាពក្នុង ការទិញស្បៀងអាហារ របស់គ្រួសារដែលជួប ប្រទះបញ្ហាអសន្តិសុខ ស្បៀងពីមួយឆ្នាំទៅមួយឆ្នាំ) ខ្វះការទទួលស្គាល់និងការគាំទ្រ។ | ជាពិសេស គឺគ្រួសារជួបប្រទះ បញ្ហាអសន្តិសុខស្បៀងដែលគ្មានដី និងខ្វះខាតដី | វិស័យសហគ្រាសខ្នាតតូច និងមធ្យមកំពុងមានការរីកចម្រើន ហើយនិយ័តកម្ម និងគោលនយោបាយនានា កំពុងត្រូវបានបង្កើត។ ការគ្របដណ្តប់នៃស្ថាប័នមីក្រូឥណទានកំពុងមានការរីកចម្រើន។ គម្រោងដែលគាំទ្រដល់ការអភិវឌ្ឍន៍សិប្បកម្ម ជនបទ និងអាជីវកម្មខ្នាតតូច កំពុងត្រូវបានអនុវត្ត។ | • ឧបសគ្គសម្រាប់សហគ្រាសខ្នាតតូចបំផុត ក្នុងការទទួលបានហិរញ្ញវត្ថុ និងទីផ្សារ (អត្រាការប្រាក់ខ្ពស់)<br>• ក្របខ័ណ្ឌច្បាប់/និយ័តកម្មសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយលទ្ធភាពក្នុងការទទួលបានបច្ចេកវិទ្យា ឥណទាន និងទីផ្សារនៅមានកម្រិត<br>• វិសាលភាពនៃកិច្ចគាំទ្រចំពោះសហគ្រាស/ អាជីវកម្មខ្នាតតូចបំផុត នៅពុំទាន់មានភាព គ្រប់គ្រាន់។ |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងទីផ្សារ នៅមិនទាន់មានភាពគ្រប់គ្រាន់ ដែលកត្តានេះ គឺជាឧបសគ្គមួយដែលរាំងស្ទះដល់ការបង្កើតការងារ និង ទីផ្សារ ជាពិសេសនៅ តំបន់ដាច់ស្រយាល។ | ជាពិសេស គឺគ្រួសារជួបប្រទះ បញ្ហាអសន្តិសុខស្បៀងដែលគ្មានដី និងខ្វះខាតដី | បណ្តាញផ្លូវថ្នល់ ទូទៅ (សំដៅចំពោះ តំបន់ជនបទផងដែរ) កំពុងមានភាពប្រសើរឡើង គួរឱ្យកត់ សម្គាល់ | • តំបន់ដាច់ស្រយាល (ដែលមាន ការប្រឈមខ្ពស់ទៅនឹងបញ្ហា អសន្តិសុខស្បៀង) នៅខ្វះការ ភ្ជាប់ទំនាក់ទំនងឱ្យបានគ្រប់គ្រាន់<br>• ការថែទាំបណ្តាញផ្លូវថ្នល់ជនបទចម្បងៗ មិនទាន់មានប្រសិទ្ធភាព។ |
| **២. ការប្រើប្រាស់ និងការបឺតស្រូបស្បៀង** | | | |
| <u>ជារួម</u> ៖ ពុំមានភាពរីកចម្រើនចំពោះកង្វះអាហារូបត្ថម្ភកុមារ និងមាតា ឡើយ នៅចន្លោះឆ្នាំ២០០៥ និង ២០១០ ព្រមទាំងមានឧប្បត្តិហេតុ ខ្ពស់នៃបញ្ហាកង្វះអាហារូបត្ថម្ភ(ជាពិសេសនៅតំបន់ជនបទ) - ភាពគ្រេះគ្រិនក្នុងចំណោមកុមារ អាយុក្រោម៥ឆ្នាំ = | កុមារ និងម្តាយ (ជាពិសេសកុមារ និងម្តាយនៃគ្រួសារក្រីក្រ និងគ្រួសារដែលរស់នៅតំបន់ជនបទ) | ការបំបៅដោះកូនមានភាពរីកចម្រើន ហើយអនុក្រឹត្យ ជាធរមាន ស្តីពីការធ្វើនិយ័តកម្មទឹកដោះម្តាយ រួមចំណែកដល់ ៖<br>-មានការកើនឡើងចំពោះការទទួលបានសេវាពិនិត្យ ផ្ទៃពោះ | • ការកើនឡើងនៃការបំបៅកូនដោយទឹកដោះសិប្បនិម្មិត<br>• ការផ្តល់មីក្រូសារជាតិចម្រុះបន្ថែម មិនទាន់មានភាពទូលំទូលាយ<br>• នៅបន្តមានការអនុវត្តន៍ផ្តល់អាហារ បន្ថែមមិនសមស្រប (កុមារ ៧៦%)<br>• កង្វះអាហារូបត្ថម្ភកុមារ |

| | | | |
|---|---|---|---|
| ៣៩,៨% កង្វះ អាហារូបត្ថម្ភក្នុងចំណោមស្ត្រី = ១៩,៨% ព្រមទាំងមានប្រេវ៉ាឡង់ខ្ពស់ចំពោះភាពស្លេកស្លាំង (ស្ត្រី <5: )។ អន្តរាគមន៍ (មួយចំនួន) ទៅលើបញ្ហាអាហារូបត្ថម្ភ នៅក្នុងវិស័យសុខាភិបាល(ផ្តោតទៅលើ ១.000ថ្ងៃដំបូង) មិនទាន់មានភាពទូលំទូលាយ។ ការអប់រំ អំពីអាហារូបត្ថម្ភ មិនទាន់ត្រូវបានបញ្ជ្រាបឱ្យបានគ្រប់គ្រាន់។ | | មុនសម្រាល និងការគ្របដណ្តប់នៃការផ្តល់វីតាមីន A និងការទម្លាក់ព្រូន។ -មាគ៌ាដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតា នៅក្នុងប្រទេសកម្ពុជាទូទាំងវិស័យនានាត្រូវបានកំណត់ (អនុសាសន៍ពីNSFSN លើកទី៤ ដែលប្រារព្ធធ្វើឡើងក្នុង ខែឧសភា ឆ្នាំ២០១២)។ | ធ្ងន់ធ្ងរ រមែងតែងមិនត្រូវបានកំណត់រកឃើញ និងព្យាបាល (ការព្យាបាលជំងឺរាគរូស ដោយប្រើប្រាស់ ជាតិស័ង្កសីនៅមិនទាន់គ្រប់គ្រាន់)<br>• សមត្ថភាពមិនទាន់គ្រប់គ្រាន់សម្រាប់បញ្ហាអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាល (គុណភាពនៃសេវា)<br>• ការភ្ជាប់ទំនាក់ទំនងនៅក្នុងវិស័យសុខាភិបាល ជាមួយវិស័យដទៃទៀត នៅមិនទាន់មានភាពគ្រប់គ្រាន់ ហើយថវិកាសម្រាប់លើកកម្ពស់អាហារូបត្ថម្ភ នៅមានកម្រិត។ |
| លទ្ធភាពក្នុងការទទួលបានអនាម័យ នៅមានកម្រិតទាប និងខ្វះការអនុវត្តន៍អនាម័យមូលដ្ឋាន ពិសេសនៅតំបន់ជនបទ (->ប្រេវ៉ាឡង់នៃ ជំងឺរាគរូស មានកម្រិតខ្ពស់)។ | គ្រួសារក្រីក្រនៅជនបទ | មានយុទ្ធសាស្ត្របច្ចុប្បន្នភាព ស្តីពី RWSSH និងមាន ការកើនឡើងនូវការយល់ដឹងអំពី សារៈសំខាន់នៃការធ្វើឱ្យអនាម័យមានភាពប្រសើរឡើងនៅកម្រិតគោលនយោបាយ។ | • កម្មវិធីសំដៅធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍អនាម័យមិនទាន់មានភាពទូលំទូលាយ<br>• មានការយល់ដឹងតិចតួចអំពីសារៈសំខាន់ នៃ WASH ក្នុងចំណោមសាធារណជន និងមានការលើកទឹកចិត្តតិចតួច<br>• ពុំមានការភ្ជាប់ទំនាក់ទំនងគ្រប់គ្រាន់ រវាងកម្មវិធី WASH និងអាហារូបត្ថម្ភ។ |
| ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារមូលដ្ឋានចម្បងៗ និងគ្រឿងផ្សំនានា (ជាវិធីដែលមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច ខ្ពស់បំផុតក្នុងការលុបបំបាត់កង្វះមីក្រូសារជាតិ) នៅមានកម្រិតនៅឡើយក្នុងប្រទេសកម្ពុជា។ | គ្រប់គ្រួសារទាំងអស់ | ការបញ្ចូលសារជាតិ (អ៊ីយ៉ូដ) ទៅក្នុងអំបិលត្រូវបានកំណត់ថាជាកាតព្វកិច្ច និងមានវិសាលភាពទូលំទូលាយ។ ទទួលបានបទពិសោធន៍មួយចំនួនពីការសាកល្បងបញ្ចូលជាតិដែកទៅ | • ខ្វះគោលនយោបាយ និងគោលការណ៍ណែនាំជាតិគ្រប់ជ្រុងជ្រោយ ស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារមូលដ្ឋាន<br>• ការបញ្ចូលជាតិដែកទៅក្នុងទឹកត្រី/ទឹកស៊ីអ៊ីវ មិនទាន់មានភាពទូលំទូលាយ (ពុំមានលក្ខណៈជាការកំណត់ |

| | | | |
|---|---|---|---|
| ការអនុវត្តច្បាប់និងទិន្នន័យនៃការអនុលោមតាមច្បាប់នៃឧស្សាហកម្មមិនគ្រប់គ្រាន់ | | ក្នុងទឹកត្រី/ ទឹក ស៊ីអ៊ីវ។ មានរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ។ | កាតព្វកិច្ច ដូចជាអនុក្រឹត្យនិងមានសិប្បកម្ម តូចៗ ជាច្រើន)<br>• ការចូលរួមរបស់វិស័យឯកជននៅក្នុងការបញ្ចូលមីក្រូសារជាតិ ទៅក្នុងចំណីអាហារនៅមានកម្រិត (សាធារណជនមានការយល់ដឹងទាបអំពីប្រយោជន៍នៃអាហារដែលបានបញ្ចូលមីក្រូសារជាតិ)។<br>• ការចូលរួមពីស្ថាប័នរដ្ឋនិងដៃគូអភិវឌ្ឍន៍ នៅមានកម្រិត ។<br>• ថវិកានៅមានកម្រិត។ |
| អភិក្រមដែលមានមូលដ្ឋានផ្អែកលើសហគមន៍សំដៅធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ មានភាពបែកខ្ញែក និងពុំមានភាពទូលំទូលាយ។ | កុមារ និងម្តាយ (ជាពិសេសកុមារ និងម្តាយនៃគ្រួសារក្រីក្រ និងគ្រួសារដែលរស់នៅតំបន់ជនបទ) | មានបទពិសោធន៍ជាមួយ (សមាហរណកម្ម) កម្មវិធីអាហារូបត្ថម្ភ ដែលមានមូលដ្ឋានផ្អែកលើសហគមន៍ (CBNP) (នៅក្នុងតំបន់ និងប្រទេសកម្ពុជា)។ មានរចនាសម្ព័ន្ធអនុវត្តន៍នៅថ្នាក់ក្រោមជាតិ។ ការប្តេជ្ញាចិត្ត (ពីសិក្ខាសាលា NSFSN លើកទី៤)។ | • ពុំមានការសម្របសម្រួលគ្រប់គ្រាន់ទូទាំងវិស័យនានា<br>• កម្មវិធីអាហារូបត្ថម្ភដែលមានការចូលរួមពីសហគមន៍មួយនៅកម្រិតថ្នាក់ជាតិដែល មានទ្រង់ទ្រាយធំ មិនត្រូវបាន បង្កើតឡើង<br>• សមត្ថភាពខ្សោយនៅថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តន៍អភិក្រមដែលមានការចូលរួមពីសហគមន៍។ |
| លទ្ធភាពក្នុងការទទួលបាន (និង តម្រូវការ) សេវាអាហារូបត្ថម្ភ របស់គ្រួសារក្រីក្រនៅមានកម្រិត។ | | ការរៀបចំកម្មវិធី CCT ដើម្បីលើកកម្ពស់តម្រូវការ។ មូលនិធិសមធម៌សុខភាពកំពុងត្រូវបានបើកដើម្បី គ្របដណ្តប់ទៅលើសេវាអាហារូបត្ថម្ភ | • CCT ត្រូវបានគូសបញ្ជាក់ ប៉ុន្តែមិនត្រូវបានអនុវត្ត<br>• ការភ្ជាប់ទំនាក់ទំនងរវាងកម្មវិធី អាហារូបត្ថម្ភ (វិស័យសុខាភិបាល) និងកម្មវិធីគាំពារសង្គម មិនទាន់ មានភាពគ្រប់គ្រាន់នៅឡើយ។ |

| ៣. ស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង | | | |
|---|---|---|---|
| គ្រួសារងាយរងគ្រោះ ឆ្លើយតប ដោយប្រើប្រាស់យន្តការដោះស្រាយបញ្ហាបែបអវិជ្ជមាន ចំពោះគ្រោះមហន្តរាយធម្មជាតិ វិបត្តិសេដ្ឋកិច្ច ឬ វិបត្តិផ្ទាល់ខ្លួន ហើយជាញឹកញាប់ ពួកគេបានក្លាយខ្លួនទៅជាគ្រួសារដែលមានបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ និងខ្វះអាហារូបត្ថម្ភ។ ការអន្តរាគមន៍សន្តិសុខស្បៀងអាហារដែលទាក់ទងនឹង ការគាំពារសង្គម ជាញឹកញាប់ រមែង តែងមានលក្ខណៈ ជាគម្រោង មានលក្ខណៈបណ្ដោះអាសន្ន និងពុំមានភាពទូលំទូលាយឡើយ។ | គ្រួសារដែលជួបប្រទះ (ឬ ស្ទើរតែជួបប្រទះ) បញ្ហាអសន្តិសុខស្បៀង | មានការកំណត់គោលដៅ សម្រាប់ចែកស្បៀងអាហារ ជូនដល់ក្រុមជនក្រីក្រ និងជនងាយរងគ្រោះ ព្រមទាំង FFW/CFW។ NSPS គូសបញ្ជាក់អំពីមាគ៌ា សម្រាប់ធ្វើសុខដុមនីយកម្ម និង កែលម្អ FS-SSN; ប្រព័ន្ធកំណត់គោលដៅគ្រួសារប្រកបដោយប្រសិទ្ធភាព (អត្តសញ្ញាណកម្មគ្រួសារ ក្រីក្រ) , អនុវត្តសាកល្បង ទៅលើសមាហរណកម្ម SSN ដែលមានភាពប្រសើរជាងមុន។ | • ការគ្របដណ្ដប់របស់សំណាញ់សុវត្ថិភាពសង្គមទៅលើគ្រួសារ និងក្រុមដែលជួប ប្រទះបញ្ហាអសន្តិសុខស្បៀង នៅមានកម្រិតនៅឡើយ<br>• ពុំមានឱកាសប្រាក់ចំណូលដែលអាចព្យាករណ៍ទុកជាមុនបាន (PWP) ដើម្បីការពារអសន្តិសុខស្បៀងបណ្ដោះអាសន្ន ឬ រ៉ាំរ៉ៃ<br>• ការសម្របសម្រួលនិងសមាហរណកម្ម កម្មវិធី FS-SSN នៅមានភាពទន់ខ្សោយ។<br>• ការកាត់បន្ថយហានិភ័យរបស់ វិស័យឯកជន (ការធានារ៉ាប់រងទៅលើកសិផល) មិនទាន់ត្រូវបានអភិវឌ្ឍន៍ ហើយការទទួលបានឥណទានសមស្របនៅមានកម្រិត។ |
| ប្រទេសកម្ពុជាមានការប្រឈមទៅនឹងវិបត្តិធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច ដែលនាំឱ្យមានផលប៉ះពាល់ទៅ លើស្ថេរភាពនៃការ ផ្គត់ផ្គង់ និង អាហារូបត្ថម្ភ - សមត្ថភាព និងយន្តការសម្រាប់ទប់ស្កាត់/ ត្រៀមលក្ខណៈទប់ទល់ និង ឆ្លើយតបទៅ | គ្រួសារដែលជួបប្រទះ (ឬ ស្ទើរតែជួបប្រទះ) បញ្ហាអសន្តិសុខស្បៀង | មានផែនការសម្រាប់ការកាត់ បន្ថយគ្រោះភ័យនៃគ្រោះ មហន្តរាយ (SNAP) និង រចនាសម្ព័ន្ធ ស្ថាប័នសម្រាប់ គ្រប់គ្រងទៅលើការត្រៀមលក្ខណៈ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ (NCDM | • សមត្ថភាពគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ/វិបត្តិនានានៅមានកម្រិត ហើយការសម្របសម្រួលនៅមិនទាន់មានភាពគ្រប់គ្រាន់<br>• ការភ្ជាប់ទំនាក់ទំនងរវាងការផ្តួចផ្តើមផ្តល់ជំនួយសង្គ្រោះបន្ទាន់ និងការអភិវឌ្ឍន៍ |

| | | | |
|---|---|---|---|
| នឹងវិបត្តិនៅមានភាពទន់ខ្សោយនៅឡើយ។ | | និងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ)។ ស្រូវអង្ករ បម្រុងនៅកម្រិតថ្នាក់ជាតិកំពុងត្រូវបានកសាងឡើង។ | រយៈពេលវែង មិនទាន់មានភាពគ្រប់គ្រាន់<br>• នីតិវិធីដើម្បីដោះស្រាយទៅនឹងវិបត្តិតម្លៃស្បៀងអាហារ និងវិបត្តិសេដ្ឋកិច្ច មិនទាន់ត្រូវបានអភិវឌ្ឍន៍ឱ្យបានពេញលេញ<br>• ប្រព័ន្ធព័ត៌មានអំពីគ្រោះអាសន្ន មិនទាន់ត្រូវបានធ្វើសមាហរណកម្ម និងប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ដើម្បីជំរុញឱ្យមាននូវការធ្វើសកម្មភាពនៅឡើយ។ |
| ការប្រែប្រួលអាកាសធាតុនឹងបង្កឱ្យមានផលប៉ះពាល់ ទៅលើសន្តិសុខស្បៀងគ្រួសារគ្រប់ពេលវេលា (ធ្វើឱ្យទិន្នផលធ្លាក់ចុះ និងនាំឱ្យមានទឹកជំនន់ និងគ្រោះរាំងស្ងួត កាន់តែច្រើន ព្រមទាំងបរាជ័យចំពោះកសិផលពាក់ព័ន្ធ ។ល។) | កសិករដែលជួប ប្រទះបញ្ហាអសន្តិសុខស្បៀង ជាពិសេសនៅក្នុងតំបន់ដែលប្រឈមទៅនឹងគ្រោះរាំងស្ងួត | មានយុទ្ធសាស្ត្រ (NAPA) និង ផែនការ (CCCSP) សម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបន្សាំ ទៅនឹងការប្រែប្រួល អាកាសធាតុត្រូវបានរៀបចំ និងមានការរៀបចំស្ថាប័នដើម្បីធ្វើការសម្របសម្រួល ។ បញ្ហានេះទទួលបាន ការយកចិត្តទុកដាក់ខ្ពស់ពីកម្រិត នយោបាយ។ | • សមត្ថភាពក្នុងការដោះស្រាយបញ្ហាការបន្សាំទៅនឹងការប្រែ ប្រួលអាកាសធាតុនៅមានកម្រិត<br>• ការបញ្ជ្រាបអំពីការធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈវិស័យនានាមិនទាន់មានភាពគ្រប់គ្រាន់<br>• សមាហរណកម្មនៃកិច្ចខិតខំដើម្បីលើកកម្ពស់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀងប្រកបដោយនិរន្តរភាពមិនទាន់មានភាពគ្រប់គ្រាន់។ |

បន្ថែមពីលើចន្លោះប្រហោង និង បញ្ហាប្រឈមទាំងនេះ គេអាចកំណត់រកចន្លោះប្រហោង និងឧបសគ្គរាំងស្ទះសំខាន់ៗដែលទាក់ទងទៅនឹងស្ថាប័ន និងការអនុវត្តន៍ក្នុងលក្ខណៈទូទៅជាងនេះ ដូចខាងក្រោម៖

- អន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រមែងតែងឆ្លុះបញ្ចាំងអំពីអាទិភាពភ្លាមៗ (ឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិវិបត្តិតម្លៃស្បៀងអាហារ។ល។) ជាជាងការអនុវត្តន៍តាមចក្ខុវិស័យរយៈពេលវែងអំពីវិធីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងលក្ខណៈមួយប្រកបដោយនិរន្តរភាព។
- គំនិតយល់ដឹង និងសមត្ថភាពក្នុងការដោះស្រាយបញ្ហា សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលជាបញ្ហាប្រទាក់ក្រឡានៅតែមានកម្រិត។ ការបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ផ្តល់ជូនក្នុងពេលកន្លងមកមិនបានគ្របដណ្តប់គ្រប់គ្រាន់និងអាស្រ័យលើការឧបត្ថម្ភពីខាងក្រៅ
- វិសាលភាព និងការគ្របដណ្តប់ភូមិសាស្ត្រនៃអន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានស្រាប់ជាច្រើន នៅមានកម្រិត។
- អន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រមែងតែងត្រូវបានអនុវត្តក្រោមអភិក្រមដែលមានមូលដ្ឋានផ្អែកលើគម្រោង (ស្របគ្នាទៅនឹងរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា) ដែលនាំឱ្យមានថ្លៃចំណាយប្រតិបត្តិការខ្ពស់ និងខកខានក្នុងការកសាងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន។ អភិក្រមដែលមានមូលដ្ឋានផ្អែកលើកម្មវិធី (លើគ្រប់វិស័យនានា) សម្រាប់ប្រធានបទសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ឬសម្រាប់វិស័យអាទិភាពជាក់លាក់ មិនទាន់ត្រូវ បានរៀបចំនៅឡើយ។
- ការសម្របសម្រួលនៅមានកម្រិតចំពោះអន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ត្រូវបានអនុវត្តតាមរយៈស្ថាប័នផ្សេងៗគ្នា របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា) នាំឱ្យមានភាពត្រួតស៊ីគ្នាទៅលើកិច្ចខិតខំកាត់បន្ថយនិរន្តរភាព និងផលប៉ះពាល់ជាទូទៅនៃអន្តរាគមន៍ទាំងនោះ។
- រចនាសម្ព័ន្ធសម្របសម្រួលរបស់រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ដូចជាក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មិនត្រូវបានប្រើប្រាស់ក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីអភិវឌ្ឍន៍ឱ្យមាននូវអន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យមានភាពសុខដុមរមនា និងត្រួតពិនិត្យទៅលើវឌ្ឍនភាពនៃរចនាសម្ព័ន្ធទាំងនោះតាមវិស័យនានា។
- ការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំបង្កើត និងការអនុវត្តន៍ ព្រមទាំង ការត្រួតពិនិត្យទៅលើអន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានចាប់ផ្តើមព្រមជាមួយនឹងការកសាងសមត្ថភាពនៃរចនាសម្ព័ន្ធទាំងនេះ ប៉ុន្តែ កំពុងស្ថិតនៅដំណាក់កាលបឋមនៅឡើយ។

- **ការកំណត់គោលដៅគ្រួសារ និង ការកំណត់គោលដៅតំបន់របស់អន្តរាគមន៍លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ (ការប្រើប្រាស់បញ្ជីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ បើទោះជាដូច្នេះក្តី កម្មវិធីមួយចំនួននៅតែពឹងផ្អែកទៅលើនីតិវិធីកំណត់គោលដៅបណ្តោះអាសន្ន ហើយតំបន់ដែលជាគោលដៅនៃអន្តរាគមន៍ មិនទាន់ត្រូវបានសម្របសម្រួលឱ្យមានប្រសិទ្ធភាពខ្ពស់នៅឡើយ។
- **ការគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នៅក្នុងប្រទេសកម្ពុជា បានមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ (ក្រុមការងារព័ត៌មានសន្តិសុខស្បៀង និង អាហារូបត្ថម្ភ, FSNIS , ព្រឹត្តិបត្រព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រចាំត្រីមាស) ប៉ុន្តែនៅតែពឹងផ្អែកយ៉ាងខ្លាំងទៅលើធាតុចូលពីខាងក្រៅ និងមិនពង្រីកទៅកម្រិតថ្នាក់ក្រោមជាតិនៅឡើយ។
- **ការត្រួតពិនិត្យ និង វាយតម្លៃ** ទៅលើក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (SFFSN) មិនទាន់មានភាពគ្រប់គ្រាន់នៅឡើយ។ សូចនាករមែងតែងពុំមានភាពជាក់លាក់ និងមានសង្គតភាពទៅនឹងក្របខ័ណ្ឌសូចនាករដែលមានស្រាប់ ព្រមទាំងត្រូវបានកំណត់ស្របទៅតាមខ្សែសង្វាក់លទ្ធផល (ផលប៉ះពាល់) ដើម្បីអនុញ្ញាតឱ្យមាននូវសកម្មភាពកែតម្រូវ។ នីតិវិធី និងការទទួលខុសត្រូវសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ មិនត្រូវបានកំណត់ច្បាស់លាស់ ហើយការត្រួតពិនិត្យទៅលើគម្រោង និងកម្មវិធីដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រមែងតែងផ្តោតយកចិត្តទុកដាក់ទៅលើធាតុចូល និងធាតុចេញប៉ុណ្ណោះដែលចំណុចនេះ នាំឱ្យមានការធ្លាក់ចុះនូវប្រសិទ្ធភាព និងផលប៉ះពាល់ជាទូទៅនៃអន្តរាគមន៍។
- **ថវិកាជារួមសម្រាប់អន្តរាគមន៍អាទិភាពលើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ដូចជា ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ និងមាតា នៅតែបន្តមានកម្រិតទាប ដោយថវិកាភាគច្រើនត្រូវបានផ្តល់ជូនពីដៃគូអភិវឌ្ឍន៍ និង កំណត់ឱ្យមានអន្តរាគមន៍ដែលរមែងតែងត្រូវបានអនុវត្តស្របគ្នាទៅនឹងប្រព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ៤.២. អាទិភាពកម្មវិធីរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨

សន្តិសុខស្បៀងនិងអាហារូបត្ថម្ភគឺជាបញ្ហាស្មុគស្មាញដែលទាមទារឱ្យមានចំណាត់ការពីវិស័យនានាជាច្រើន ដើម្បីពង្រឹងការមានស្បៀង ការទទួលបានស្បៀង និងការប្រើប្រាស់/ការបឺតស្រូបស្បៀង។ អាស្រ័យដោយរាជរដ្ឋាភិបាលសម្រេច បាននូវការមានស្បៀងជារួមនៅកម្រិតថ្នាក់ជាតិ អន្តរាគមន៍នឹងផ្តោតយកចិត្តទុកដាក់ទៅលើកម្រិតគ្រួសារ និងកម្រិតបុគ្គល។ ផ្អែកលើការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ជំពូកទី២) និងការវិភាគវិសាលភាព និងការគ្របដណ្តប់នៃអន្តរាគមន៍ដែលមានស្រាប់ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ជំពូកទី៣) **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨** បានធ្វើការដោះស្រាយ

វិស័យអាទិភាពកម្មវិធីចំនួន៣ដូចខាងក្រោម ដែលត្រូវបានកំណត់រកឃើញតាមរយៈដំណើរការពិគ្រោះយោបល់ក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣[៥១]៖

១. ធ្វើឱ្យប្រសើរឡើងនូវការមានស្បៀងអាហារ និងលទ្ធភាពទទួលបានស្បៀងអាហារនៅកម្រិតគ្រួសារ (ពិសេសនៅ តាមតំបន់ជនបទ)។

២. លើកកម្ពស់ការប្រើប្រាស់ និងបឺតស្រូបស្បៀងអាហារ ដែលនាំឱ្យមានភាពប្រសើរឡើងចំពោះអាហារូបត្ថម្ភកុមារ និងមាតា(ផ្តោតយកចិត្តទុកដាក់ទៅលើរយៈពេល ១០០០ថ្ងៃដំបូង)។

៣. ធ្វើឱ្យប្រសើរឡើងនូវស្ថេរភាពផ្គត់ផ្គង់ស្បៀងអាហារ តាមរយៈការការពារក្រុមជនងាយរងគ្រោះពីហានិភ័យនានា។

<u>រូបភាពទី២៩</u> ៖ អាទិភាពកម្មវិធីរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ




[៥១] បើទោះជាដូច្នេះក្តី ការជ្រើសរើសតំបន់អាទិភាព (ព្រមទាំងសកម្មភាពជាក់លាក់នៅក្នុងវិស័យទាំងនេះ) ពុំមែនមានមូលដ្ឋានផ្អែកលើនីតិវិធីបែបវិទ្យាសាស្ត្រ (គំរូសង្គមសេដ្ឋកិច្ច និងអាហារូបត្ថម្ភ) និងពុំមានការអនុវត្តន៍ធ្វើការវិភាគទៅលើថ្លៃចំណាយ និង ផលចំណេញឡើយ បើទោះបីជាព័ត៌មានដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ឬ ភស្តុតាងទទួលបានពីប្រទេសដទៃទៀតដែលអាចយកមកធ្វើការប្រៀបធៀបគ្នាបាន ត្រូវបានយកមកប្រើប្រាស់ក៏ដោយ។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ**ពង្រឹងបន្ថែមទៅលើយុទ្ធសាស្ត្រ និងផែនការដែលមានស្រាប់ (ជំពូកទី៣) និងធ្វើសមាហរណកម្មធាតុផ្សំនៃយុទ្ធសាស្ត្រទាំងនេះនៅក្នុងក្របខ័ណ្ឌមួយ ដើម្បីលើកកម្ពស់សមាហរណកម្ម និងការរួមកម្លាំងគ្នា និងសំដៅទទួលបានលទ្ធផលជាអតិបរមា ទាក់ទងទៅនឹងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាជនកម្ពុជា។ យុទ្ធសាស្ត្រកសិកម្មនិងទឹក, យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា និងយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភមានភាពពាក់ព័ន្ធជាក់លាក់នៅក្នុងការងារនេះ។

វិធានការណ៍ដើម្បីលើកកម្ពស់ការរៀបចំស្ថាប័ន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការស្វែងរកការគាំទ្រ និងការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការកសាងសមត្ថភាព (ដែលចំណុចនេះ នឹងមានគូសបញ្ជាក់បន្ថែមទៀតនៅក្នុងជំពូកទី៧) មានសារៈសំខាន់ ដើម្បីធានាឱ្យការអនុវត្តន៍ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ប្រកបដោយប្រសិទ្ធភាព។

បន្ថែមទៅលើកម្មវិធីវិស័យអាទិភាព ដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រនេះនឹងត្រូវបានប្រសើរឡើងដោយការពិចារណាពីអភិបាលកិច្ចលើសន្តិសុខស្បៀង ដែលជាស្រទាប់បញ្ហាប្រទាក់ក្រឡា។ ការធ្វើឱ្យប្រសើរឡើង នូវរបៀបដែលការសម្រេចចិត្ត ត្រូវបានធ្វើឡើងដែលមានឥទ្ធិពលលើសកម្មភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ(រួមបញ្ចូលទាំងការធ្វើឱ្យប្រសើរនៃក្របខ័ណ្ឌច្បាប់និងស្ថាប័ន) ក៏ដូចជា ការចូលរួមកាន់តែច្រើនពីសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានក្នុងការតាក់តែង ការអនុវត្ត និងការត្រួតពិនិត្យសកម្មភាពសន្តិសុខស្បៀងនឹងត្រូវបានយកមកពិចារណា។

## ៥. យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ចក្ខុវិស័យ គោលដៅ និងគោលបំណង (ទិដ្ឋភាពទូទៅ)

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨** ធ្វើបច្ចុប្បន្នភាពទៅលើក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ(SFFSN 2008-2012)។ យុទ្ធសាស្ត្រនេះមានសង្គតភាព ព្រមទាំងបន្តធ្វើប្រតិបត្តិការទៅលើអាទិភាពដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ (២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ព្រមទាំងបំពេញបន្ថែមទៅលើយុទ្ធសាស្ត្រ និងផែនការតាមវិស័យដទៃទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត និង មានទំនាក់ទំនងដោយផ្ទាល់ ឬ ប្រយោលទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (សូមមើលជំពូកទី៣)។

### ចក្ខុវិស័យនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាការសម្រេចឱ្យបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឱ្យបានគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា។ នេះគឺជាល័ក្ខខ័ណ្ឌមួយដ៏សំខាន់ដើម្បីធានាឱ្យមាននូវការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ចក្នុងកម្រិតមួយខ្ពស់ វិបុលភាព និងសមធម៌សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ ចក្ខុវិស័យនេះ ក៏មានសង្គតភាពទាំងស្រុងទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាផងដែរ ៖

*ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុន ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់ស្បៀងអាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់។*

យុទ្ធសាស្ត្រមួយ ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឱ្យមាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភមានគោលបំណង៖

(១). ធ្វើឱ្យប្រសើរឡើងនូវការមានស្បៀងអាហារប្រកបដោយអាហារូបត្ថម្ភ និងផ្តល់ផលល្អចំពោះសុខភាព សម្រាប់គ្រួសារកម្ពុជា ក្នុងលក្ខណៈមួយប្រកបដោយនិរន្តរភាព

(២). ការទទួលបានស្បៀងអាហារគ្រប់គ្រាន់ និងមានស្ថេរភាព តាមរយៈការកាត់បន្ថយភាពក្រីក្រ និង ភាពងាយរងគ្រោះរបស់គ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង

(៣). ការប្រើប្រាស់និងការបឺតស្រូបស្បៀងអាហារឱ្យបានប្រសើរបំផុតដើម្បីនាំឱ្យមានភាពប្រសើរឡើងនូវអាហារូបត្ថម្ភកុមារនិងមាតា។

## គោលដៅនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

*ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សម្គាល់ ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និង ចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់ស្បៀងអាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់។*

សមិទ្ធផលនៃគោលដៅ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ត្រូវវាស់ស្ទង់ដោយសូចនាកររួមដែលមានកម្រិតខ្ពស់ជាង ចំពោះសន្តិសុខស្បៀងនៅកម្រិតគ្រួសារ និងកង្វះអាហារូបត្ថម្ភកុមារ ដោយប្រចាប់បញ្ចូលគ្នា ជាមួយការសម្រេចបាននូវគោលបំណងទាំង៣ របស់ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** និងឆ្លុះបញ្ចាំងអំពីលទ្ធផលនៃគោលនយោបាយ និងសកម្មភាពទូទាំងវិស័យជាច្រើន[៥២]។

- កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រេះក្រិន) ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ នឹងត្រូវកាត់បន្ថយពី ៣៩,៩% ក្នុងឆ្នាំ២០១០ មកត្រឹម ២៥% ក្នុងឆ្នាំ២០១៨។
- កង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រី (BMI <18.5kg/sq.meter) នឹងត្រូវកាត់បន្ថយពី ១៩,១% (២០១០) មកត្រឹម ៨% ក្នុងឆ្នាំ២០១៥ និង ៦% ក្នុងឆ្នាំ២០១៨។
- ការទទួលទានស្បៀងអាហារជាមធ្យម (kcal/ក្នុងមួយនាក់/ក្នុងមួយថ្ងៃ) ក្នុងចំណោមក្រុមដែលក្រីក្របំផុត នឹងកើនឡើងពី ១៦៩០ kcal ក្នុងឆ្នាំ២០០៩ ទៅ ១៨៨៦ kcal ក្នុងឆ្នាំ២០១៥ និង ២០៦០ kcal ក្នុងឆ្នាំ២០១៨។

ផ្អែកលើការវិភាគមួយទៅលើចន្លោះប្រហោង និងជម្រើសយុទ្ធសាស្ត្រ ព្រមទាំងដំណើរការពិគ្រោះយោបល់ក្នុង ឆ្នាំ២០១៣ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** កំណត់រកឃើញគោលបំណងចំនួន៣ ព្រមទាំងបានផ្តោត អាទិភាពទៅលើអន្តរាគមន៍ និង ឧបករណ៍សំខាន់ៗមួយចំនួន ដើម្បីសម្រេចឱ្យបាននូវគោលបំណងទាំងនោះ។ អន្តរាគមន៍ទាំងនេះ ភាគច្រើនត្រូវបានផ្តល់អនុសាសន៍រួចទៅហើយនៅក្នុង SFFSN ២០០៨-២០១៣ ប៉ុន្តែ អន្តរាគមន៍ទាំងនោះនឹងត្រូវពង្រីកបន្ថែម ហើយការអនុវត្តន៍នឹងត្រូវបានកំណត់គោលដៅសម្របសម្រួល និងត្រួតពិនិត្យបានកាន់តែប្រសើរជាងមុន ដើម្បីបង្កើនផលប៉ះពាល់។ សកម្មភាពកម្មវិធីដទៃទៀតដែលថ្មីចំពោះប្រទេសកម្ពុជា នឹងត្រូវអនុវត្តសាកល្បង វាយតម្លៃ និងពង្រីក ដោយផ្អែកទៅលើប្រសិទ្ធភាពដែលបង្ហាញឱ្យឃើញ។ រូបភាពទី៣០ នៅទំព័របន្ទាប់ គូសបញ្ជាក់អំពីគោលបំណងទាំង៣ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងសង្ខេបអំពីអាទិភាពកម្មវិធីរយៈពេលមធ្យម ព្រមទាំងសកម្មភាពសំខាន់ៗ។ គោលបំណងមួយចំនួនមានអន្តរទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ហើយអន្តរាគមន៍ដូចគ្នានេះ អាចរួមចំណែកដល់ការសម្រេចឱ្យបាននូវគោលបំណងជាច្រើន។ សូចនាករសម្រាប់តាមដានវឌ្ឍនភាព ធៀបទៅនឹងគោលបំណង ត្រូវបានសង្ខេបនៅក្នុងក្របខ័ណ្ឌសូចនាករ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ក្នុងឧបសម្ព័ន្ធ១ នៃឯកសារនេះ។

[៥២] សូចនាករទាំង៣នេះ នឹងត្រូវយកមកប្រើប្រាស់ដើម្បីធ្វើការប៉ាន់ប្រមាណទៅលើការសម្រេចបានជារួមនៃគោលដៅរបស់យុទ្ធសាស្ត្រ ប៉ុន្តែក៏មានសូចនាករមនុស្សសាស្ត្រ និងសូចនាករអំពីការទទួលទានស្បៀងអាហារដទៃទៀត ដែលត្រូវបានបញ្ចូលនៅក្នុងក្របខ័ណ្ឌត្រួត ពិនិត្យ និងវាយតម្លៃផងដែរ។

<u>រូបភាពទី៣០</u>៖ គោលបំណង អាទិភាពកម្មវិធីនិងសកម្មភាព របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ

| គោលបំណងទី១៖ បង្កើនការមានស្បៀង និងការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វដែលកាន់តែមានភាពចម្រុះនិងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើ ប្រកបដោយនិរន្តរភាព ព្រមទាំងពីការងារដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។ | |
|---|---|
| អាទិភាពកម្មវិធី | សកម្មភាពអាទិភាព (សកម្មភាពសំខាន់ៗ និងឧបករណ៍) |
| **ធ្វើប្រពលវប្បកម្ម និងធ្វើពិពិធកម្ម ប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូចព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការភ្ជាប់ទំនាក់ទំនងទីផ្សារ** | • លើកកម្ពស់លទ្ធភាពរបស់កសិករដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀងឱ្យទទួលបានបច្ចេកទេសសមស្របអាចយកទៅអនុវត្តបានដែលមានតម្លៃទាប អាចយកមកធ្វើការកែសម្រួលបាន និង អាចចម្លងយកទៅប្រើប្រាស់នៅកន្លែងដទៃទៀត សម្រាប់ដំណាំស្រូវ និងកសិផល ដទៃទៀត វារីវប្បកម្ម ផលិតកម្មសត្វពាហនៈ និងបន្លែខ្នាតតូច ព្រមទាំងការរក្សាទុក និងការកែច្នៃកសិផល។<br>• ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់កសិករ ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ក្នុងការទទួលបានប្រព័ន្ធធារាសាស្ត្រខ្នាតតូច ជាពិសេសនៅក្នុងតំបន់ដែលប្រឈមទៅនឹងគ្រោះរាំងស្ងួត។<br>• ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់សមស្របចំពោះធាតុចូលកសិកម្មប្រកបដោយគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពសម្រាប់កសិករខ្នាតតូចដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង (ព្រមទាំងលើកកម្ពស់សេវាពាក់ព័ន្ធ តាមរយៈវិស័យឯកជន)។<br>• លើកកម្ពស់លទ្ធភាពក្នុងការទទួលបានឥណទាន និងការសន្សំប្រាក់សម្រាប់កសិករខ្នាតតូច (មីក្រូហិរញ្ញវត្ថុ)។<br>• លើកកម្ពស់យន្តការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូច ឱ្យបានកាន់តែប្រសើរទៅនឹងទីផ្សារ (សមាគមកសិករ/សហករ ការធ្វើកសិកម្មតាមកិច្ចសន្យា ព័ត៌មាន ទីផ្សារ) និងអភិវឌ្ឍន៍ឱ្យមាននូវខ្សែសង្វាក់តម្លៃដែលជាប្រយោជន៍ដល់កសិករ។<br>• ជួយគាំទ្រការកសាង និងអភិវឌ្ឍន៍សហគមន៍កសិកម្ម សហករណ៍កសិកម្ម ដើម្បីលើកកម្ពស់លទ្ធភាពអភិវឌ្ឍន៍ផលិតកម្មស្បៀង និងចំណូលគ្រួសារ។ |

| | |
|---|---|
| **លើកកម្ពស់និរន្តរភាព និងធានា នូវការទទួលបានដីធ្លីសម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង** | • ពង្រីកការបែងចែកដីសង្គមកិច្ចជូនដល់ជនក្រីក្រ និងជនដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង ព្រមទាំងផ្តល់ប្លង់ដីសហគមន៍ជូនដល់ក្រុមជនជាតិដើមភាគតិច។<br>• ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់កសិករក្រីក្រដែលទទួលបានប្លង់ដីក្នុងការទទួលបានសេវាគាំទ្រចំពោះវិស័យកសិកម្មនិងទីផ្សារ។ |
| **ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវ ធនធានជលផល និងព្រៃឈើដែលជាទ្រព្យសម្បត្តិរួម** | • ពង្រឹងប្រព័ន្ធគ្រប់គ្រងការងារជលផល និងព្រៃឈើសហគមន៍។<br>• អភិវឌ្ឍន៍ប្រព័ន្ធប្រើប្រាស់ដីធ្លីសហគមន៍។<br>• លើកកម្ពស់ទំនាក់ទំនងរវាងទីផ្សារទេសចរណ៍នៅក្នុងតំបន់ទីក្រុង និងអ្នកភូមិដែលពឹងផ្អែកលើព្រៃឈើជាមួយនឹងសហគ្រាសខ្នាតតូចនិងសិប្បកម្ម<br>• បន្តការអភិវឌ្ឍនិងការអនុវត្តការកាត់បន្ថយការបំភាយឧស្ម័នពីការបំផ្លាញព្រៃឈើ<br>• រក្សាតុល្យភាពរវាងប្រយោជន៍សេដ្ឋកិច្ច និងថ្លៃចំណាយផ្នែកសង្គម និងបរិស្ថានរបស់ គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ (វារីអគ្គិសនី) និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។ |
| **លើកកម្ពស់ការងារ និងឱកាស ប្រាក់ចំណូលសម្រាប់ជនដែល ជួបប្រទះបញ្ហាអសន្តិសុខស្បៀង** | • លើកកម្ពស់ការបណ្តុះបណ្តាលបច្ចេកទេស និង ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង នៅតំបន់ជនបទ និងតំបន់ទីក្រុង ដើម្បីបង្កើនជំនាញ និងលទ្ធភាពក្នុងការទទួលបានការងារ។<br>• ជាពិសេស លើកកម្ពស់ជំនាញការងារដែលចាំបាច់ សម្រាប់សហគ្រាសកែច្នៃកសិកម្ម សម្បទានកសិសេដ្ឋកិច្ច (និងកិច្ចសន្យាកសិធុរកិច្ច) សម្រាប់បង្កើតឱកាសការងារ និងបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារជនបទដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។<br>• លើកកម្ពស់កិច្ចគាំពារសង្គមនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធជាពិសេសសម្រាប់ស្ត្រី។<br>• លើកកម្ពស់ (ជាពិសេស) សហគ្រិនជាស្ត្រីដែលចូលរួមនៅក្នុងសហគ្រាសខ្នាតតូចបំផុត សិប្បកម្ម។ល។ និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទទួលបានមូលធន និងទីផ្សារ។<br>• ធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌនិយ័តកម្ម ព្រមទាំងលទ្ធភាពក្នុងការទទួលបានបច្ចេកវិទ្យាសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម និង ពង្រីកកិច្ចគាំទ្រហិរញ្ញវត្ថុដើម្បីលើកកម្ពស់សមាហរណកម្មរបស់ពួកគេ ទៅក្នុងខ្សែសង្វាក់តម្លៃសកល។ |

<table>
<tr><td></td><td>• បន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងទីផ្សារ ជាពិសេសនៅក្នុងតំបន់ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។<br>• ពង្រឹងសហគមន៍កសិករប្រើបាស្រ់ទឹកសំដៅធានានូវការប្រើប្រាស់ទឹកប្រកបដោយសមធម៌ និងនិរន្តរភាព<br>• ស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្រ្ត អាងស្តុកទឹក អណ្តូងពង្រីកផ្ទៃដីស្រោចស្រពសម្រាប់វិស័យកសិកម្ម<br>• រក្សាស្តារស្ទឹង ព្រែក ទន្លេ បឹងធម្មជាតិសំដៅកាត់បន្ថយគ្រោះទឹកជំនន់និងភាពរាំងស្ងួត</td></tr>
<tr><td colspan="2"><u>គោលបំណងទី២</u> ៖ធ្វើឱ្យមានភាពប្រសើរឡើងនូវការប្រើប្រាស់ និង ការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ដល់ការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋកម្ពុជា។</td></tr>
<tr><th>អាទិភាពកម្មវិធី</th><th>សកម្មភាពអាទិភាព ( សកម្មភាពសំខាន់ៗ និងឧបករណ៍ )</th></tr>
<tr><td>ពង្រីកសេវាកម្មជាក់លាក់ សម្រាប់អាហារូបត្ថម្ភ និងការអប់រំអំពីអាហារូបត្ថម្ភ</td><td>• ធានាឱ្យមាននូវការគ្របដណ្តប់កាន់តែប្រសើរចំពោះការថែទាំ និងការផ្តល់ប្រឹក្សា ចាំបាច់នានាអំពីបញ្ហាអាហារូបត្ថម្ភក្នុងអំឡុងពេល ១.០០០ថ្ងៃដំបូង ចាប់ពីពេលមានផ្ទៃពោះរហូតដល់កុមារមានអាយុ២ឆ្នាំ នៅឯមណ្ឌលសុខភាព ( ការពិនិត្យផ្ទៃពោះ មុនសម្រាល ការសម្រាល ការថែទាំក្រោយសម្រាល ការតាមដាន និងការលើកកម្ពស់ការលូតលាស់របស់កុមារ ការថែទាំព្យាបាលកង្វះអាហារូបត្ថម្ភស្រួចស្រាវ )<br>• អនុវត្តយុទ្ធនាការផ្សព្វផ្សាយចម្រុះដើម្បីផ្លាស់ប្តូរឥរិយាបថការអនុវត្តន៍ ទៅលើបញ្ហាអាហារូបត្ថម្ភសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា ( បន្តកិច្ចខិតខំទៅលើការឆាប់ បំបៅដោះកូន និងការបំបៅដោះកូនតែមួយមុខគត់ , បង្កើនកិច្ចខិតខំដើម្បីលើកកម្ពស់ការបន្តបំបៅដោះកូនរហូតដល់អាយុ២ឆ្នាំ , បង្កើនកិច្ចខិតខំក្នុងការផ្តល់អាហារបន្ថែមសមស្របជូនដល់កុមារអាយុចន្លោះពី ៦-២៣ខែ ផ្តល់ព័ត៌មានអំពីគ្រោះថ្នាក់នៃការប្រើប្រាស់ និងការចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត... )។<br>• ត្រួតពិនិត្យទៅលើការប្រើប្រាស់ និងការចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត និង បង្កើតឱ្យមាននូវគណៈកម្មការឃ្លាំមើលមួយ ដើម្បីជួយដល់ការអនុវត្តន៍អនុក្រឹត្យ លេខ១៣៣ និងធ្វើនិយ័តកម្មទៅលើមូលដ្ឋានសុខភាពឯកជន ដើម្បីបង្ការការប្រើប្រាស់ទឹកដោះសិប្ប-និម្មិត និងពន្លឿនការអនុវត្តន៍អនុក្រឹត្យនេះតាមរយៈក្រសួងពាក់ព័ន្ធ</td></tr>
</table>

| | |
|---|---|
| | • ដើម្បីអភិវឌ្ឍន៍ និងអនុវត្តផែនការពង្រីក និងធានាឱ្យមាននូវការផ្គត់ផ្គង់ទៀងទាត់ នូវម្សៅមីក្រូសារជាតិចម្រុះបន្ថែម សម្រាប់កុមារអាយុចន្លោះពី ៦-២៣ខែ(IFA និង MNP) និងអភិវឌ្ឍថ្នាំគ្រាប់ផ្សេងទៀត (រួមទាំងត្រៀមលក្ខណៈក្នុងការប្រើអាហារបន្ថែម)។<br>• លើកកម្ពស់សមត្ថភាពមនុស្ស ទាក់ទងទៅនឹងអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាល និងវិស័យដទៃទៀត។ |
| **ធ្វើឱ្យប្រសើរឡើងនូវការ ផ្គត់ផ្គង់ទឹក និងការអនុវត្តន៍ អនាម័យនៅក្នុងមូលដ្ឋាន** | • អនុវត្តយុទ្ធនាការផ្លាស់ប្តូរការប្រព្រឹត្ត និងទំនាក់ទំនង ដោយភ្ជាប់កម្មវិធី WASH ទៅនឹងអាហារូបត្ថម្ភមាតា និងកុមារ។<br>• ធ្វើសមាហរណកម្មផែនការវិនិយោគ និងផែនការយុទ្ធសាស្ត្រជាតិស្តីពី WASH ជាមួយកម្មវិធីជាតិអាហារូបត្ថម្ភមាតា និងកុមារ។<br>• ពង្រឹងការគ្រប់គ្រងតាមសហគមន៍ទៅលើកម្មវិធី WASH។ |
| **ពង្រីកការបញ្ចូល មីក្រូសារជាតិ នៅក្នុងចំណីអាហារ** | • លើកកម្ពស់ការប្រើប្រាស់អាហារដែលបានបញ្ចូលមីក្រូជីវជាតិ។<br>• អភិវឌ្ឍន៍គោលនយោបាយ គោលការណ៍ណែនាំបច្ចេកទេស និងនិយ័តកម្ម ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ/ការធានាគុណភាពរបស់ផលិតផលដែលបានបញ្ចូលមីក្រូសារជាតិ។<br>• ពង្រីក និងកំណត់ជាកាតព្វកិច្ចចំពោះការបញ្ចូលជាតិដែកទៅក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ ផលិតក្នុងស្រុក និងការនាំចូល។<br>• ពង្រីក និងកំណត់ជាកាតព្វកិច្ចចំពោះការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល ជាសកល ផលិតក្នុងស្រុក និងការនាំចូល។<br>• ពង្រីកការបញ្ចូលមីក្រូជីវជាតិ ទៅក្នុងប្រភេទចំណីអាហារមូលដ្ឋានដទៃទៀតដែលមានផលិតក្នុងស្រុក ឧទាហរណ៍ ដូចជា អង្ករ មី នំស្រួយ និងប្រេងឆា។ល។<br>• អភិវឌ្ឍន៍ផលិតផលអាហារបន្ថែម ដែលត្រូវបានផលិតបញ្ចូលមីក្រូសារជាតិនៅក្នុងផលិតផល និងអាហារបំប៉ន។<br>• ពង្រីក និង ពង្រឹងការផ្សព្វផ្សាយអំពីចំណីអាហារដែលបញ្ចូលមីក្រូសារជាតិឱ្យបានទូលំទូលាយ។<br>• ពង្រឹងការអនុវត្តខ្លឹមសារអនុក្រឹត្យលេខ៦៩អនក្រ.បកស្តីពីការគ្រប់គ្រង ការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដឱ្យមានប្រសិទ្ធភាព។<br>• រៀបចំលិខិតបទដ្ឋាន គតិយុត្ត ដើម្បីគ្រប់គ្រងចំណីអាហារដែលបញ្ចូលមីក្រូសារជាតិ ទាំងផលិតក្នុងស្រុក និងការនាំចូល។<br>• បង្កើតឱ្យមានគោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស លិខិតបទដ្ឋានច្បាប់ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឱ្យបានទូលំទូលាយ និងជំរុញការអនុវត្តខ្លឹមសារច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់ឱ្យមានប្រសិទ្ធភាព។ |

| | |
|---|---|
| | • ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារផ្សេងៗទៀត ដែលសមស្រប និងធានាបាននូវគុណភាពសុវត្ថិភាពនិងបរិមាណគ្រប់គ្រាន់តាមតម្រូវការ។<br>• ជំរុញការដាក់បញ្ចូលកម្រិតឬបរិមាណមីក្រូសារជាតិនីមួយៗទៅក្នុងបញ្ជីស្តង់ដាជាតិ។<br>• តម្រូវការចាំបាច់ នូវការវិភាគទិន្នន័យស្តីពីការបរិភោគ ចំណីអាហារតាមប្រភេទនីមួយៗ<br>• ជំរុញឱ្យមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់ អាហារបញ្ចូលមីក្រូសារជាតិឱ្យបានទូលំទូលាយ ។ |
| **លើកកម្ពស់ការមានស្បៀង និងការប្រើប្រាស់ស្បៀងអាហារប្រកប ដោយអាហារូបត្ថម្ភ និងមានសុវត្ថិភាព នៅកម្រិតគ្រួសារ** | • លើកកម្ពស់ការយល់ដឹងអំពីតម្លៃអាហារូបត្ថម្ភរបស់ផលិតផលកសិកម្មក្នុងស្រុក និង បញ្ច្រាបអំពីបញ្ហាអាហារូបត្ថម្ភទៅក្នុងការផ្សព្វផ្សាយអំពីកសិកម្ម។<br>• ពង្រីកកម្មវិធីដែលលើកកម្ពស់ដល់ការផលិតស្បៀងផ្សេងៗគ្នា ការរក្សាទុក និង ការកែច្នៃនៅកម្រិតគ្រួសារ សហគមន៍ និងសាលារៀន ព្រមទាំងភ្ជាប់ទំនាក់ទំនងកម្មវិធីទាំងនេះទៅនឹងវិស័យសុខភាព។<br>• ពង្រឹងការអនុវត្តន៍ច្បាប់និងនិយ័តកម្មនានាដើម្បីលើកកម្ពស់ផលិតកម្មកសិកម្ម និង អាហារូបត្ថម្ភ ដើម្បីឱ្យសុខភាព និងបរិស្ថានកាន់តែមានភាពល្អប្រសើរ និងធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពចំណីអាហារ (រួមទាំងអនាម័យ និងហ្វីតូ-អនាម័យស្តង់ដារ) និងបង្កើនការយល់ដឹងជា សាធារណៈពីម្ហូបអាហារដែលមានសុវត្ថិភាព។ |
| **ប្រើប្រាស់ឧបករណ៍គាំពារសង្គម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ** | • ធានាឱ្យមាននូវការសម្របសម្រួលជិតស្និទ្ធរវាងកម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ (CCT) និងវិធានការណ៍គាំពារសង្គមដទៃទៀត ដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ ជាមួយNNSនិងអន្តរាគមន៍អាហារូបត្ថម្ភតាមសហគមន៍ដែលនឹងមាននៅពេលអនាគត។<br>• កាត់បន្ថយឧបសគ្គហិរញ្ញវត្ថុដែលរាំងស្ទះដល់ការថែទាំអាហារូបត្ថម្ភនៅ មណ្ឌលសុខភាព តាមរយៈការពង្រីកមូលនិធិសមធម៌សុខភាព (HEFs) និងការគ្របដណ្តប់ទៅលើរាល់សេវា និងការថែទាំអាហារូបត្ថម្ភទាំងអស់។<br>• ភ្ជាប់ទំនាក់ទំនងកម្មវិធីសំណង់សាធារណៈ (PWP) ដើម្បីធ្វើឱ្យការប្រើប្រាស់ទឹក និងអនាម័យ កាន់តែមានភាពប្រសើរឡើង។<br>• បង្កើនការយល់ដឹងពីអាហារូបត្ថម្ភនៃសំណាញ់សុវត្ថិភាពសង្គម ដែលមានស្រាប់ ឧទាហរណ៍ការផ្តល់អាហារនៅតាមសាលារៀន។ |

| រៀបចំ និងអនុវត្តសាកល្បងនូវកម្មវិធីសមាហរណកម្មអាហារូបត្ថម្ភដោយមានការចូលរួមពីសហគមន៍ (CBNP) សម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានអនុវត្តតាមរយៈអាជ្ញាធរមូលដ្ឋាន។ | |
|---|---|
| <u>គោលបំណងទី៣</u> ៖ការធ្វើឱ្យប្រសើរឡើងប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងវិបត្តិនានា ដើម្បីបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង សម្រាប់គ្រួសារដែលមានបញ្ហា សន្តិសុខស្បៀង។ | |
| អាទិភាពកម្មវិធី | សកម្មភាពអាទិភាព (សកម្មភាពសំខាន់ៗ និងឧបករណ៍) |
| **ពង្រីកសន្តិសុខស្បៀង ទាក់ទងឧបករណ៍ គាំពារសង្គម** | • អនុវត្តសាកល្បង និងពង្រីកកម្មវិធីសំណង់សាធារណៈមួយនៅកម្រិតថ្នាក់ជាតិ ដើម្បីលើកកម្ពស់ឱកាសការងារដែលអាចព្យាករណ៍ទុកជាមុនបាន សម្រាប់ជនក្រីក្រនៅក្នុងតំបន់ និងឃុំដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ជាពិសេសនៅរដូវដែលពុំមានភាពមមាញឹកនៅក្នុងវិស័យកសិកម្ម និងផ្តល់ការគាំទ្រជីវភាព និងការបង្កើតប្រាក់ចំណូលសម្រាប់ជនដែលងាយរងគ្រោះបំផុត។<br>• រៀបចំផែនការយថាភាព និងពង្រីកការងារពលកម្មក្នុងអំឡុងពេលមានវិបត្តិ និង ភ្ជាប់ទំនាក់ទំនងកម្មវិធីសំណង់សាធារណៈ ទៅនឹងការត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ព្រមទាំងផែនការបន្ស៊ាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។<br>• ពង្រីកនិងបង្កើនភាពជាម្ចាស់របស់រដ្ឋាភិបាលទៅលើសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់ដូចជា ការផ្តល់អាហារូបករណ៍សម្រាប់ជនក្រីក្រ (បឋមសិក្សា និងមធ្យមសិក្សា) ការផ្តល់អាហារនៅតាមសាលារៀន (មុនបឋមសិក្សា និងបឋមសិក្សា)។<br>• អនុវត្ត និងពង្រីកការអនុវត្តន៍សាកល្បងកម្មវិធីផ្ទេរសាច់មានល័ក្ខខ័ណ្ឌ (ដូចមានគូសបញ្ជាក់នៅក្នុង NSPS) ដើម្បីធ្វើឱ្យការទទួលបានស្បៀងអាហាររបស់គ្រួសារក្រីក្រមានភាពរលូន និងលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតា។<br>• លើកកម្ពស់ការសម្របសម្រួលរបស់កម្មវិធីសំណាញ់សុវត្ថិភាពសង្គម ដែលកំណត់ គោលដៅទៅលើគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ជាមួយវិស័យនានា និង ពង្រីកការអនុវត្តន៍សាកល្បង ដើម្បីលើកកម្ពស់សមាហរណកម្មនៃកម្មវិធីគាំពារសង្គមសំដៅជំរុញឱ្យមានសន្តិសុខស្បៀងនៅកម្រិតមូលដ្ឋាន។ |

| | |
|---|---|
| **ធ្វើឱ្យប្រសើរឡើងនូវការត្រៀមលក្ខណៈទប់ទល់ និងកាត់បន្ថយគ្រោះមហន្តរាយ ព្រមទាំងលើកកម្ពស់ភាពធន់ទ្រាំរបស់គ្រួសារ ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ** | • អភិវឌ្ឍន៍សមត្ថភាពសម្រាប់ការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបញ្ចូលបញ្ហាទាំងនេះទៅក្នុងយុទ្ធសាស្ត្រតាមវិស័យ និងផែនការតំបន់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុទៅលើសន្តិសុខស្បៀងរបស់គ្រួសារ។<br>• ពង្រឹងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាទៅនឹងវិបត្តិស្បៀងអាហារ (ធានាឱ្យមាននូវការផ្គត់ផ្គង់ស្បៀង និងជំនួយដទៃទៀត) ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលដើម្បីឆ្លើយតបចំពោះគ្រោះអាសន្ននានា រវាងស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍នានា។<br>• សម្រួល និងធ្វើសមាហរណកម្មព័ត៌មានដែលមានស្រាប់ ប្រព័ន្ធបែងចែកចំណាត់ថ្នាក់ និងឧបករណ៍ជូនដំណឹងជាមុន ព្រមទាំងការប៉ាន់ប្រមាណទៅលើផលប៉ះពាល់នៃគ្រោះមហន្តរាយ។<br>• កសាង និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើស្បៀងបម្រុងជាតិ (និងគ្រាប់ ពូជ) ដើម្បីផ្តល់ការផ្គត់ផ្គង់ស្បៀងអាហារ និងគ្រាប់ពូជឱ្យបានទាន់ពេលវេលា ជូនដល់គ្រួសារដែលទទួលរងផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ ឬ វិបត្តិសេដ្ឋកិច្ច និងដើម្បីទប់ទល់ទៅនឹងការកើនឡើងនៃតម្លៃស្បៀងអាហារ។<br>• ពង្រឹងសមត្ថភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានស្តីពីអាកាសធាតុ គ្រោះធម្មជាតិដែលបណ្តាលមកពីអាកាសធាតុឱ្យបានទាន់ពេលវេលាដើម្បីកសិករមានលទ្ធភាព និងពេលវេលាត្រៀមបង្ការ និងធ្វើការសម្រេចចិត្តក្នុងការដាំដុះរបស់គាត់។ |

## ៦. គោលបំណង និងសកម្មភាពអាទិភាពរបស់យុទ្ធសាស្រ្តជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨

ការសម្រេចបាននូវគោលបំណងនីមួយៗ ក្នុងចំណោមគោលបំណងទាំងនេះ ទាមទារឱ្យមានកម្មវិធីនិយ័តកម្ម និង ការកែលម្អសេវាកម្មនៅក្នុងវិស័យនានា ឱ្យកាន់តែមានភាពប្រសើរជាងមុន។ បើទោះបីជាចន្លោះប្រហោងដែលមានស្រាប់ ក្នុងការដោះស្រាយបញ្ហាអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងត្រូវដោះស្រាយដោយកម្មវិធីថ្មីៗក៏ដោយ ការពង្រីកអន្តរាគមន៍មានស្រាប់ដែលមានមូលដ្ឋានផ្អែកលើភស្តុតាង គឺជាការផ្តោតយកចិត្តទុកដាក់ចម្បងនៃយុទ្ធសាស្រ្តនេះ។ កម្មវិធីជាច្រើនក្នុងចំណោមកម្មវិធីទាំងនេះ ត្រូវបានអនុវត្តដោយដៃគូអភិវឌ្ឍន៍នានា ដោយប្រើប្រាស់អភិក្រមដែលមានមូលដ្ឋានផ្អែកលើគម្រោង និងពុំមានការសម្របសម្រួលច្រើននៅក្នុងនិងរវាងវិស័យនានាឡើយ។ ការចោទសួរសំនួរអំពីនិរន្តរភាពនៃកម្មវិធីជាច្រើនក្នុងចំណោមកម្មវិធីទាំងនេះ រមែងតែអាស្រ័យលើថ្លៃចំណាយប្រតិបត្តិការមានកម្រិតខ្ពស់។ នៅក្នុងការពង្រីកអន្តរាគមន៍ទាំងនេះរាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំបង្កើតយន្តការដែលមានសង្គតភាព ដើម្បីទទួលបានហិរញ្ញប្បទានគាំទ្ររយៈពេលមធ្យម គំរូនៃការអនុវត្តន៍ និងការកំណត់គោលដៅ ព្រមទាំងតំបន់គ្របដណ្តប់នៃកម្មវិធីទាំងនេះឱ្យប្រសើរបំផុត។

សម្រាប់គោលបំណងនីមួយៗ ក្នុងចំណោមគោលបំណងទាំង៣ខាងក្រោមនេះ ការវិភាគស្ថានភាពជាក់លាក់តាមវិស័យដោយសង្ខេបអំពីមូលហេតុនៃកង្វះអាហារូបត្ថម្ភនិងអសន្តិសុខស្បៀងត្រូវបានបញ្ចូលជាមូលហេតុឬសគល់មួយ ដើម្បីកំណត់សកម្មភាពអាទិភាព សំដៅធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាពលរដ្ឋកម្ពុជា។

### ៦.១. គោលបំណងទី១ ៖ បង្កើនការមានស្បៀង និងការទទួលបានស្បៀង

បង្កើនការមានស្បៀង និង ការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វ ដែលកាន់តែមានភាពចម្រុះ និងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើ ប្រកបដោយនិរន្តរភាព ព្រមទាំងពីការងារដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។

គោលបំណងនេះ ផ្តោតយកចិត្តទុកដាក់ទៅលើការលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ នៅក្នុងប្រទេសកម្ពុជា។ គោលបំណងនេះ បានធ្វើឱ្យសមាហរណកម្មទិដ្ឋភាពមួយចំនួនដែលទាក់ទងទៅនឹងការមានស្បៀង និងការទទួលបានស្បៀងនៅក្នុងវិស័យជាច្រើន ដូចជា កសិកម្ម ជលផល និងព្រៃឈើ ធនធានទឹក ដីធ្លី និងការងារ និងការបង្កើតប្រាក់ចំណូល។

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាជាង ៨០% យ៉ាងហោចណាស់ពឹងផ្អែកមួយផ្នែកទៅលើវិស័យកសិកម្ម ហើយគ្រួសារភាគច្រើនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង គឺជាគ្រួសារកសិករខ្នាតតូចដែលរស់នៅតំបន់ជនបទ។ ជាញឹកញាប់ ពួកគេទទួលបានសេចក្តីត្រូវការស្បៀងអាហារ

របស់ពួកគេ តាមរយៈការរួមបញ្ចូលគ្នានូវសកម្មភាពមួយចំនួនដូចជា៖ ការធ្វើដំណាំកសិផល ការចិញ្ចឹមសត្វ និងការប្រមូលអនុផលព្រៃឈើ និងជលផលដែលជាធនធានរួម សម្រាប់ស្បៀងអាហាររបស់ពួកគេ។ ពួកគេក៏ស្វែងរកចំណូលជាសាច់ប្រាក់ពីសកម្មភាពទាំងនេះផងដែរ សម្រាប់ទិញស្បៀងអាហារ ដែលពួកគេមិនអាចផលិតបានដោយខ្លួនឯង ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការមូលដ្ឋាន ក្នុងការទិញស្បៀងអាហារដទៃទៀត។ បើទោះបីជាសកម្មភាពទាំងនេះ គឺជាប្រភពដ៏សំខាន់ដើម្បីទទួលបានស្បៀងអាហារ និងប្រាក់ចំណូលក៏ដោយ ប៉ុន្តែ ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅតំបន់ជនបទប្រឈមទៅនឹងផលិតភាពដែលមានកម្រិតទាប និងហានិភ័យខ្ពស់នៅក្នុងកិច្ចខិតខំផលិតស្បៀងអាហាររបស់ពួកគេ និងការប្រមូលអនុផលព្រៃឈើ និងធនធានជលផល [៥៣]។ ពិពិធភាពកសិផលនៅមានកម្រិតនៅឡើយ អាស្រ័យដោយមួយភាគធំពឹងផ្អែកទៅលើផលិតកម្មស្រូវតាមយថាផល ផ្អែកលើទឹកភ្លៀង ដែលផ្តល់ប្រាក់ចំណូលតែក្នុងរយៈពេលណាមួយប៉ុណ្ណោះក្នុងមួយឆ្នាំ។

បើទោះបីជាប្រជាពលរដ្ឋកម្ពុជាជាង ៨០% រស់នៅតំបន់ជនបទក៏ដោយ ប្រជាពលរដ្ឋជនបទប្រមាណ២០%ពុំមានដីធ្លីឡើយនិង២៥%ទៀតមានដីតិចជាង០,៥ហិកតា(កម្រិតដែលប៉ាន់ប្រមាណសម្រាប់ផលិតស្បៀងឱ្យបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ដោយខ្លួនឯង)។ ជាក់ស្តែង ការមានស្បៀងដែលទទួលបានពីការផលិតដោយខ្លួនឯង កំពុងមានភាពរួមតូច អាស្រ័យដោយជាង ៤០% នៃស្បៀងអាហារដែលទទួលទាននៅតំបន់ជនបទ គឺទទួលបានពីការទិញ។ ការធ្វើប្រពលវប្បកម្ម និងពិពិធកម្មប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច ដើម្បីទទួលបានស្បៀងអាហារផ្ទាល់ខ្លួនសម្រាប់ទទួលទាន និងការបង្កើតឱ្យមាននូវលទ្ធភាពក្នុងការទទួលបានស្បៀងអាហារ តាមរយៈប្រាក់ចំណូល (ពីផលិតកម្មកសិកម្មក្នុងគោលបំណងយកទៅលក់នៅឯទីផ្សារ និង ពីការអភិវឌ្ឍន៍ប្រភពប្រាក់ចំណូលដែលទទួលបានពីសកម្មភាពមិនមែនកសិកម្ម) សុទ្ធសឹងតែមានសារៈសំខាន់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងគ្រួសារ និងលើកកម្ពស់ការធន់ទ្រាំរបស់ប្រជាពលរដ្ឋជនបទ ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដើម្បីទប់ទល់ទៅនឹងវិបត្តិសេដ្ឋកិច្ច និងវិបត្តិអាកាសធាតុ។

សម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ឬ វិស័យសេដ្ឋកិច្ចទំនើប ជាពិសេសគឺសហគ្រាសវិស័យកាត់ដេរធំៗ ឧស្សាហកម្មសំណង់ និងទេសចរណ៍ និង (ក្នុងកម្រិត តិចតួច) វិស័យសេវាកម្ម និងកែច្នៃផលិតផលកសិកម្ម សុទ្ធសឹងតែជាប្រភពប្រាក់ចំណូលសំខាន់ៗ សម្រាប់ស្ត្រីក្រីក្រ ដែលភាគច្រើនរស់នៅតំបន់ជនបទជាង ៣០០.០០០ នាក់។ បើទោះជាដូច្នេះក្តី សម្រាប់ ៨៥% នៃកម្លាំងការងាររបស់កម្ពុជា វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសខ្នាតតូចបំផុត នៅតែជាប្រភពចំណូលមួយដ៏សំខាន់ដើម្បីជានានិរន្តរភាពនៃជីវភាពរស់នៅរបស់គ្រួសារ។

ការពឹងផ្អែកយ៉ាងខ្លាំងទៅលើការទិញស្បៀងអាហារ (គ្រួសារជនបទភាគច្រើន គឺជាអ្នកទិញស្បៀងអាហារសុទ្ធសាធ) និង កម្រិតភាគរយខ្ពស់នៃចំណាយសរុបរបស់គ្រួសារទៅលើការទិញ

---

[៥៣] ៨០% នៃផ្ទៃដីដាំដុះកសិកម្មរបស់ប្រទេស ពឹងផ្អែកទៅលើទឹកភ្លៀង ក្រោមរបបទឹកភ្លៀងក្នុងរដូវវស្សាដែលមិនទៀងទាត់។ ដីដែលមានជីជាតិមិនសូវល្អ ក៏បណ្តាលឱ្យផលិតកម្មកសិផលដំណាំស្រូវមានកម្រិតផងដែរ នៅក្នុងផ្ទៃដីកសិកម្មក្នុងប្រទេសចំនួន ៥០%។

សៀ្បងអាហារ ធ្វើឱ្យគ្រួសារដែលចូលរួមនៅក្នុងវិស័យកសិកម្មនៅតំបន់ជនបទកាន់តែមានភាពងាយរងគ្រោះខ្លាំងឡើង ទៅនឹងអស្ថេរភាពនៃតម្លៃស្បៀងអាហារ[៥៤]។ ពិពិធកម្មនៃប្រភពប្រាក់ចំណូល [៥៥] ព្រមទាំងការភ្ជាប់ទំនាក់ទំនងដ៏រឹងមាំរវាងតំបន់ទីក្រុង និងតំបន់ជនបទ ធ្វើឱ្យគ្រួសារកម្ពុជាកាន់តែមានសន្តិសុខស្បៀងឡើងជាលំដាប់ និងធន់ទ្រាំទៅនឹងវិបត្តិសេដ្ឋកិច្ច និងវិបត្តិអាកាសធាតុ។ គោលបំណងទី១ នៃ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** ផ្តោតយកចិត្តទុកដាក់ទៅលើវិស័យចំនួន៤ ដូចខាងក្រោម៖

១. ការធ្វើប្រពលវប្បកម្ម ពិពិធកម្ម និងសមាហរណកម្មទីផ្សារចំពោះប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច។

២. ការបែងចែកដីធ្លី និងការផ្តល់ប្លង់ដីជូនដល់ជនក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

៣. ការលើកកម្ពស់លទ្ធភាព ក្នុងការទទួលបាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជលផល និងព្រៃឈើដែលជាទ្រព្យសម្បត្តិរួម សម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

៤. បង្កើនការទទួលបានប្រាក់ចំណូលដោយបង្កើនឱកាសការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសម្រាប់ជនក្រីក្រ និង ជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

### ៦.១.១. លើកកម្ពស់ពិពិធកម្ម និងសមាហរណកម្មទីផ្សារនៃការធ្វើកសិកម្ម របស់កសិករខ្នាតតូច

ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុង GDP នៅតែបន្តមានស្ថេរភាពនៅក្នុងទសវត្សរ៍ចុងក្រោយនេះ (២៧,៥% ក្នុងឆ្នាំ២០១២) ប៉ុន្តែ អត្រាកំណើនរបស់វិស័យនេះបានមានការប្រែប្រួលនៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១២ ដោយសារល័ក្ខខ័ណ្ឌអាកាសធាតុ ក្នុងនោះ អត្រាកំណើនមានចន្លោះពី ៥,៧% (២០០៨) និង ៣,៣% (២០១១) និងស្ថិតនៅកម្រិត ៤,៣% ក្នុងឆ្នាំ២០១២។ ភាគរយនៃអ្នកធ្វើការងារក្នុងវិស័យកសិកម្មក្នុងចំណោមកម្លាំងពលកម្មសរុប នៅតែមានកម្រិតខ្ពស់(៦២%ក្នុងឆ្នាំ២០១១) ប៉ុន្តែ អត្រានេះបានធ្លាក់ចុះយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលដូចគ្នាទៅនឹងប្រទេសមានប្រាក់ចំណូលទាបភាគច្រើន ដែលមានអត្រាកំណើនខ្ពស់។ ផលិតកម្មកសិកម្មបានរួមចំណែក ៥៤,៨% ក្នុងGDP របស់វិស័យកសិកម្ម បន្ទាប់មកគឺវិស័យជលផល ដែលបានរួមចំណែក ២៥,៤% ផលិតកម្មបសុសត្វ ចំនួន ១៤,១% និងព្រៃឈើចំនួន ៥,៧%។

[៥៤] ក្នុងចំណោមគ្រួសារជនបទចំនួនពីរប្រភេទ ដែលក្រីក្រជាងគេ ក្នុងឆ្នាំ២០០៩ ភាគរយក្នុងតម្លៃជាសាច់ប្រាក់នៃស្បៀងអាហារដែលផលិតនៅឯផ្ទះ មានចំនួនចន្លោះពី ៣៣%-៣៦% ហើយភាគរយក្នុងតម្លៃជាសាច់ប្រាក់នៃស្បៀងអាហារដែលបានទិញមានចំនួន ៦៤%-៦៧%។

[៥៥] នៅក្នុងបរិបទនេះ វាមានសារៈសំខាន់ដែលប្រភពប្រាក់ចំណូលនៅកម្រិតគ្រួសារធានាបានផងដែរនូវលំហូរប្រាក់ចំណូលដែលចេះតែបន្តមាននៅក្នុងឆ្នាំនីមួយៗ។

## រូបភាពទី៣១ ៖ ការផលិតស្រូវ និងទិន្នផល ឆ្នាំ២០០០-២០១២




| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នផលតោន/ហិកតា | 2,12 | 2,07 | 1,92 | 2,1 | 1,98 | 2,48 | 2,49 | 2,62 | 2,75 | 2,84 | 2,97 | 3,17 | 3,11 |

ប្រភព ៖ MAFF, របាយការណ៍ប្រចាំឆ្នាំ២០១២/២០១៣

ផ្អែកលើការបន្តកិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើប្រពលវប្បកម្ម និងលើកកម្ពស់ផលិតកម្ម និងទីផ្សារ ផលិតកម្មស្រូវបានបន្តកើនឡើង និងធ្វើឱ្យប្រទេសកម្ពុជា មិនត្រឹមតែផលិតអង្ករបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងស្រុក ចាប់តាំងពីឆ្នាំ១៩៩៨ ប៉ុណ្ណោះទេ ប៉ុន្តែ បានក្លាយជាប្រទេសនាំចេញអង្ករមួយ ដ៏សំខាន់នៅក្នុងតំបន់។ ក្នុងឆ្នាំ២០១២/២០១៣ ការផលិតស្រូវ(ស្រូវវស្សា និងស្រូវប្រាំង) មានចំនួនប្រមាណ៩,២៩លានតោន ដោយទទួលបានទិន្នផលជាមធ្យមប្រមាណ ៣,១២ តោនក្នុងមួយហិកតា។ ប្រទេសកម្ពុជា ផលិតបានអតិរេកផលស្រូវចំនួន ៤,៧៣ លានតោន ដែលស្មើនឹងអង្ករប្រមាណ ៣ លានតោន។ កំណើនផលិតកម្មត្រូវបានកំណត់ដោយកំណើននៃផ្ទៃដីប្រមូលផល និងកំណើនទិន្នផល។

ដោយសារតែកំណើនប្រជាជន ផ្ទៃដីដាំដុះនឹងមានចំនួនកាន់តែតិចទៅៗ ហើយការបង្កើនផលិតកម្មស្រូវបន្ថែមទៀត ត្រូវពឹងផ្អែកជាចម្បងទៅលើផលិតភាពដែលមានកម្រិតខ្ពស់ជាងនេះ។ បើទោះជាដូច្នេះក្តី នៅតែមានសក្តានុពល ក្នុងការបង្កើនផលិតកម្ម អាស្រ័យដោយទិន្នផលស្រូវបច្ចុប្បន្នមានចំនួនត្រឹម ៣,១១៧ តោន/ហិកតា ដែលចំនួននេះ នៅមានកម្រិតទាបជាងខ្លាំង បើធៀបទៅនឹងទិន្នផលរបស់ប្រទេសជិតខាងមួយចំនួន។ ដូច្នេះ ការបន្តលើកកម្ពស់បន្ថែមទៀតនូវផលិតភាពស្រូវវស្សា និងការពង្រីកផលិតកម្មស្រូវដោយប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ គឺជាអាទិភាព ដូចមានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រកសិកម្មនិងទឹក និងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ។ ការបង្កើនទិន្នផលតាមរយៈការកែលម្អបច្ចេកទេសធ្វើស្រែ ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទទួលបានគ្រាប់ពូជនិងជីប្រកបដោយគុណភាព ការលើកកម្ពស់សមត្ថភាពម៉ាស៊ីនកិនស្រូវ និងសមត្ថភាពក្នុងការរក្សាទុក ព្រមទាំងការធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងតាមរយៈបទដ្ឋានគុណភាពដែលអនុញ្ញាតឱ្យអង្កររបស់កម្ពុជាអាចទទួលបានទីផ្សារនាំចេញក្នុងតម្លៃខ្ពស់សុទ្ធសឹងតែជាវិស័យចម្បងៗសម្រាប់ការអភិវឌ្ឍន៍។

តាមរយៈទស្សនៈវិស័យសន្តិសុខស្បៀងកម្រិតគ្រួសារ ការកំណត់គោលដៅជាក់លាក់ទៅលើកសិករខ្នាតតូចដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀងនៅក្នុងតំបន់អសន្តិសុខស្បៀង គឺមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានធាតុចូលកសិកម្មប្រកបដោយគុណភាពខ្ពស់ និងបច្ចេកវិទ្យាសមស្រប[៥៦] ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពឃ្លាំងរក្សាផលិតផល និង បណ្តាញទីផ្សារ[៥៧] ដើម្បីឱ្យកសិករអាចទទួលបានប្រយោជន៍ជាអតិបរមាពីការអនុវត្តន៍គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ ការរៀបចំ កសិករខ្នាតតូចជាសមាគមកសិករ ព្រមទាំងការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ទំនាក់ទំនងរវាងកសិករ និងវិស័យឯកជន ឧទាហរណ៍ដូចជា៖ តាមរយៈការផ្តល់សេវាផ្សព្វផ្សាយនៅនឹងកន្លែង និងការរៀបចំឱ្យមាននូវការធ្វើកសិកម្មតាមកិច្ចសន្យា សុទ្ធសឹងតែមានភាពចាំបាច់នៅក្នុងបរិបទនេះ។ ការធ្វើឱ្យប្រសើរឡើងនូវផលិតភាពស្រូវ រមែងតែងជាបច្ច័យមួយសម្រាប់កសិករយថាផល ក្នុងការចូលរួមនៅក្នុងការដាំដុះប្រភេទកសិផលដទៃទៀត ដែលមានតម្លៃខ្ពស់ជាងនៅលើចំណែកណាមួយនៃផ្ទៃដីដ៏តូចរបស់ពួកគេ។

ជារួម ផ្ទៃដីដាំដុះបានកើនឡើងគួរឱ្យកត់សម្គាល់រហូតដល់ ៩៤៧,១៣៤ ហិកតា ឬ ប្រមាណ ២៤,៧% នៃផ្ទៃដីប្រមូលផលសរុប នៅក្នុងខែកញ្ញា ឆ្នាំ២០១២ ហើយរាជរដ្ឋាភិបាលកម្ពុជាបានធ្វើការវិនិយោគគួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ក្នុងការកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្រ្ត[៥៨]។ បើទោះជាដូច្នេះក្តី រាជរដ្ឋាភិបាលនៅតែត្រូវការពង្រីកបន្ថែមទៀតនូវប្រព័ន្ធធារាសាស្រ្ត និងកែលម្អការគ្រប់គ្រងធនធានទឹក តាមរយៈការបង្កើត និងការពង្រឹងសមាគមអ្នកប្រើប្រាស់ទឹក[៥៩] ជាពិសេស គឺសម្រាប់កសិករក្រីក្រដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង នៅក្នុងតំបន់ដែលប្រឈមទៅនឹងគ្រោះរាំងស្ងួត[៦០] ដើម្បីកាត់បន្ថយការពឹងផ្អែករបស់ពួកគេទៅលើទឹកភ្លៀង និងពង្រឹងភាពធន់ទ្រាំរបស់ពួកគេទៅនឹងគ្រោះមហន្តរាយធម្មជាតិ ព្រមទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

---

[៥៦] ក្រៅពីជីគីមី និងប្រភេទគ្រាប់ពូជដែលមានលក្ខណៈប្រសើរជាងមុន ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI)ដែលត្រូវបានលើកកម្ពស់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អស់រយៈពេលជាច្រើនឆ្នាំ ការប្រើប្រាស់ធាតុចូលសរីរាងដែលមាននៅក្នុងមូលដ្ឋាន (លាកសត្វ ជីកំប៉ុស្តិ៍) និងសមាហរណកម្មការគ្រប់គ្រងទៅលើសត្វល្អិតចង្រៃ បានបង្ហាញថាមានភាពជោគជ័យ អាស្រ័យដោយនេះជាយុទ្ធសាស្ត្រដែលប្រើប្រាស់ធាតុចូលកសិកម្មតិច ដើម្បីលើកកម្ពស់ផលិតភាពរបស់កសិករខ្នាតតូច ក្នុងលក្ខណៈមួយប្រកបដោយនិរន្តរភាព។

[៥៧] គ្រួសារភាគច្រើនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង លក់ផលិតផលស្រូវភាគច្រើនរបស់ពួកគេក្នុងតម្លៃទាបក្រោយពេលប្រមូលផល ដើម្បីទិញអង្ករនៅពេលបន្តិចទៀតក្នុងឆ្នាំដដែលពីទីផ្សារ ក្នុងតម្លៃខ្ពស់ជាងមុនច្រើន នៅពេលដែលអស់ស្បៀងបម្រុង។ ធនាគារស្រូវ នៅក្នុងសហគមន៍ ព្រមទាំងការរៀបចំធ្វើកសិកម្មតាមកិច្ចសន្យា អាចជួយបង្កើនប្រាក់ចំណូលពីការធ្វើស្រែ។

[៥៨] រហូតមកទល់នឹងពេលថ្មីៗនេះ ក្រសួងធនធានទឹក និងឧត្តុនិយម បានផ្តោតយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើការងារប្រព័ន្ធធារាសាស្ត្រ ហើយឥឡូវនេះ ក្រសួងគាំទ្រដល់ប្រព័ន្ធធារាសាស្ត្រគ្រប់ជ្រុងជ្រោយ (រហូតដល់ប្រឡាយទឹកធំៗ) និងអន្តរាគមន៍បូមទឹក ដើម្បីធានាឱ្យមានលំហូរទឹកជាទៀងទាត់។ ប្រព័ន្ធខ្នាតតូច និងមធ្យមមានលក្ខណៈស្របទៅនឹងសេចក្តីត្រូវការធារាសាស្ត្ររបស់កសិករដែលជួបប្រទះ បញ្ហាអសន្តិសុខស្បៀង និងរមែងតែងមានភាពសមស្របជាងបើនិយាយអំពីកត្តាសេដ្ឋកិច្ច។

[៥៩] សហគមន៍កសិករអ្នកប្រើប្រាស់ទឹកចំនួន ៩២២ ត្រូវបានបង្កើត គិតត្រឹមខែកញ្ញា ឆ្នាំ២០១២។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១២/២០១៣។

[៦០] ការផ្តល់អាទិភាពទៅលើប្រព័ន្ធធារាសាស្ត្រសម្រាប់កសិផលរដូវវស្សា និង ប្រព័ន្ធធារាសាស្ត្របន្ថែមនៅក្នុងតំបន់អសន្តិសុខស្បៀងដែលធ្វើការដាំដុះកសិផលរដូវវស្សាតែមួយដងក្នុងមួយឆ្នាំ។

ព្រមជាមួយនឹងការប្រមូលផលស្រូវ មានកសិករខ្នាតតូច កាន់តែច្រើនឡើងបានចូលរួមនៅក្នុងការផលិតកសិផល សម្រាប់លក់យកប្រាក់ ជាពិសេសនៅតំបន់ខ្ពង់រាបដែលដីមានជីជាតិល្អ[៦១]។ បន្ថែមពីនេះទៀត ផលិតកម្មបសុសត្វ ក៏មានសក្តានុពលយ៉ាងសម្បើមសម្រាប់ធ្វើការពង្រីកផងដែរ ប៉ុន្តែផលិតកម្មបសុសត្វ នៅជួបប្រទះឧបសគ្គភាគច្រើន បណ្តាលមកពីសេវាផ្សព្វផ្សាយ និង សេវាបសុព្យាបាលនៅមានកម្រិត ហើយបណ្តាញទីផ្សារនៅមានភាពទន់ខ្សោយ។

**ពិពិធកម្មនៃការធ្វើកសិកម្មរបស់កសិករខ្នាតតូច និងការធ្វើសមាហរណកម្មទីផ្សារឱ្យបានកាន់តែប្រសើរ** មានភាពចាំបាច់ណាស់ ដើម្បីលើកកម្ពស់ការមានស្បៀងប្រកបដោយអាហារូបត្ថម្ភសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ និងដើម្បីធ្វើឱ្យគ្រួសារកសិករកាន់តែមានភាពធន់ទ្រាំទៅនឹងវិបត្តិអាកាសធាតុ និងវិបត្តិសេដ្ឋកិច្ច។ ប្រព័ន្ធផលិតកម្មកសិកម្មចម្រុះខ្នាតតូចបានបង្ហាញឱ្យឃើញថាមានផលិតភាពខ្ពស់។ ដូចមានគូសបញ្ជាក់ នៅក្នុងកម្មវិធីគាំទ្រសន្តិសុខស្បៀងរបស់ យុទ្ធសាស្ត្រកសិកម្មនិងទឹក ការលើកកម្ពស់សាកវប្បកម្ម ផលិតកម្មបសុសត្វខ្នាតតូច និងវារីវប្បកម្ម ការលើកកម្ពស់ការកែច្នៃចំណីអាហារ ព្រមទាំងការកាត់បន្ថយការខាតបង់ក្រោយពេលប្រមូលផល តាមរយៈការធ្វើឱ្យប្រសើរឡើង នូវឃ្លាំងរក្សាទុកនៅឯកម្រិតកសិដ្ឋាន ឬ ស្រែចម្ការសុទ្ធសឹងតែជាវិធានការអាទិភាព។ ជាពិសេស ការប្រើប្រាស់ធាតុចូលកសិកម្មប្រកបដោយគុណភាព និងការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាទៅលើបច្ចេកទេសដាំដុះ និងបច្ចេកទេសចិញ្ចឹមសត្វ[៦២] ត្រូវបន្តលើកកម្ពស់ ដើម្បីជំរុញផលិតភាពនៃប្រព័ន្ធធ្វើកសិកម្មចម្រុះរបស់កសិករខ្នាតតូច។

រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមាននូវដំណោះស្រាយសមស្របទៅតាមបញ្ហាកង្វល់ចម្បងៗ និងសេចក្តីត្រូវការជាក់លាក់ដែលទាក់ទងទៅនឹងបរិយាកាសផ្នែកកសិបរិស្ថាន និងសង្គមសេដ្ឋកិច្ច (ការបែងចែកតំបន់) និងពាក់ព័ន្ធនឹងការវិនិយោគលើការស្រាវជ្រាវកសិ-អេកូឡូស៊ីដែលកើនឡើង។ ការដែលកសិករខ្នាតតូច មានលទ្ធភាពកាន់តែប្រសើរ ក្នុងការទទួលបានមីក្រូហិរញ្ញវត្ថុ និងការរៀបចំជាសមាគម ឬ សហករ ព្រមជាមួយនឹងខ្សែសង្វាក់តម្លៃប្រកបដោយសក្តានុពល ដែលនាំឱ្យកសិករមានលទ្ធភាពកាន់តែប្រសើរជាងមុន ក្នុងការទទួលបានព័ត៌មានទីផ្សារ នឹងជួយជានាឱ្យមានការភ្ជាប់ទំនាក់ទំនងទីផ្សារកាន់តែប្រសើរសម្រាប់ផលិតផលរបស់ពួកគេ។ ការភ្ជាប់ទំនាក់ទំនងអ្នកផលិតខ្នាតតូចទៅនឹងខ្សែសង្វាក់ទីផ្សារកសិកម្ម តាមរយៈការរៀបចំធ្វើកសិកម្មតាមកិច្ចសន្យា នឹងក្លាយជាបញ្ហាប្រឈមជាក់លាក់មួយសម្រាប់អនាគតដ៏ខ្លីខាងមុខ ក្នុងការបង្កើនប្រាក់ចំណូលរបស់កសិករ និងធ្វើឱ្យការផលិតសម្រាប់យកទៅលក់នៅឯទីផ្សារមិនសូវមានការប្រឈមខ្ពស់។ ស្ត្រីដើរតួនាទីសំខាន់

---

៦១ ក្រៅពីស្រូវ កសិករខ្នាតតូចភាគច្រើនបានចូលរួមធ្វើការដាំដុះដំណាំពោត ដំឡូង សណ្តែកសៀង និង សណ្តែកបាយ។ ជាពិសេស ផ្ទៃដីដាំដុះសម្រាប់ដំណាំដំឡូងបានមានការកើនឡើងពី២៥.៧៤០ហិកតាក្នុងឆ្នាំ២០០៣ រហូតដល់៣៦១.៨៥៤ ហិកតា ក្នុងឆ្នាំ២០១២។

៦២ ដូចមានគូសបញ្ជាក់នៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រស្តីពីបសុសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ២០១១-២០២០ ការដែលកសិករចិញ្ចឹមសត្វពាហនៈមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានបច្ចេកវិទ្យា និងសេវាកម្មផលិតកម្ម និង បសុព្យាបាល ព្រមទាំងប្រព័ន្ធអប់រំ/បណ្តុះបណ្តាលកសិករឱ្យក្លាយជាបសុពេទ្យដោយអង្គការមិនមែនរដ្ឋាភិបាល មានសារៈសំខាន់ខ្លាំងណាស់។

កាន់តែច្រើនឡើង[៦៣] នៅក្នុងវិស័យកសិកម្មរបស់ប្រទេសកម្ពុជា ដូច្នេះ ទម្ងន់ការងាររបស់ពួកគេត្រូវការកាត់បន្ថយ ហើយលទ្ធភាពក្នុងការទទួលបានធនធាន (ឥណទាន ការបណ្តុះបណ្តាល) និងប្រាក់ចំណូលរបស់ពួកគេ ត្រូវបង្កើនដើម្បីពង្រីកផលប៉ះពាល់នៃកម្មវិធីប្រពលវប្បកម្ម និង ពិពិធកម្មកសិកម្មឱ្យបានជាអតិបរមាទៅលើសន្តិសុខស្បៀងរបស់គ្រួសារ។

**សកម្មភាពអាទិភាពនៅក្រោមអាទិភាពកម្មវិធីទី១ នៃគោលបំណងទី១ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការធ្វើប្រពលវប្បកម្ម ពិពិធកម្ម និងសមាហរណកម្មទីផ្សារចំពោះប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច រួមមាន ៖**

១.១ លើកកម្ពស់លទ្ធភាពរបស់កសិករដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ឱ្យទទួលបានបច្ចេកទេសសមស្រប អាចយកទៅអនុវត្តបាន ហើយមានតម្លៃទាប អាចយកមកធ្វើការកែសម្រួលបាន និង អាចចម្លងយកទៅប្រើប្រាស់នៅកន្លែងដទៃទៀត សម្រាប់ដំណាំស្រូវ និងកសិផលដទៃទៀត វារីវប្បកម្ម ផលិតកម្មបសុសត្វ និងបន្លែខ្នាតតូច ព្រមទាំងការរក្សាទុក និងការកែច្នៃកសិផល។

១.២ លើកកម្ពស់លទ្ធភាពរបស់កសិករដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដើម្បីទទួលបានប្រព័ន្ធធារាសាស្ត្រខ្នាតតូច ជាពិសេសនៅក្នុងតំបន់ដែលប្រឈមទៅនឹងគ្រោះរាំងស្ងួត។

១.៣ ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់សមស្របចំពោះធាតុចូលកសិកម្មប្រកបដោយគុណភាព សម្រាប់កសិករខ្នាតតូចដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

១.៤ លើកកម្ពស់លទ្ធភាពក្នុងការទទួលបានឥណទាន និងការសន្សំប្រាក់សម្រាប់កសិករខ្នាតតូច (គម្រោងមីក្រូហិរញ្ញវត្ថុ)។

១.៥ លើកកម្ពស់យន្តការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូច ឱ្យបានកាន់តែប្រសើរទៅនឹងទីផ្សារ (សមាគមកសិករ/សហករណ៍ ការធ្វើកសិកម្មតាមកិច្ចសន្យា ព័ត៌មានទីផ្សារ) និងអភិវឌ្ឍន៍ឱ្យមាននូវខ្សែសង្វាក់តម្លៃដែលជាប្រយោជន៍ដល់កសិករ។

១.៦ លើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗក្នុងផលិតកម្មដំណាំស្បៀង ជាពិសេសបច្ចេកទេសមុន និងក្រោយប្រមូលផលដំណាំក្នុងបរិបទនៃកង្វះកម្លាំងពលកម្ម កសិកម្មដែលឈានទៅរកកំណើនការងារប្រើប្រាស់គ្រឿងយន្តកសិកម្មគ្រប់ប្រភេទសម្រាប់កសិករខ្នាតតូច

អន្តរាគមន៍ដើម្បីធ្វើប្រពលវប្បកម្ម និងពិពិធកម្មកសិកម្មខ្នាតតូចនៅក្នុងប្រទេសកម្ពុជា ពុំមែនជាអន្តរាគមន៍ថ្មីឡើយ ប៉ុន្តែ បច្ចុប្បន្នអន្តរាគមន៍ទាំងនោះ កំពុងត្រូវបានអនុវត្តតាមរយៈគម្រោង និងកម្មវិធីតូចធំជាច្រើននៅក្នុងវិស័យកសិកម្ម និងប្រតិបត្តិការសង្គ្រោះបន្ទាន់លើបញ្ហាសន្តិសុខស្បៀង។ ច្បាប់ និងនិយ័តកម្មសំខាន់ៗមួយចំនួន ឧទាហរណ៍ដូចជា៖ និយ័តកម្មស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យា ត្រូវបានគូសបញ្ជាក់ និងទទួលបានការអនុម័តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បើទោះជាដូច្នេះក្តី ក៏នៅមានតម្រូវការជាក់លាក់ក្នុងការ ៖

[៦៣] គ្រួសារជាច្រើនក្នុងចំនួនគួរឱ្យកត់សម្គាល់មានស្ត្រីជាមេគ្រួសារ ដោយសារតែបុរសបានធ្វើចំណាកស្រុកទៅកាន់តំបន់ទីក្រុង និងតំបន់ដទៃទៀត។

- ពង្រីកកម្មវិធីទាំងនេះ និង ធានាឱ្យមានការអនុវត្តន៍តាមរយៈអភិក្រមផ្អែកលើកម្មវិធីមួយ ដែលមានការសម្របសម្រួលកាន់តែប្រសើរ[៦៤]។
- ពង្រឹងការប្រាស្រ័យទាក់ទងរវាងវិស័យផ្សេងៗគ្នានៅកន្លែងដែលចាំបាច់ (ឧទាហរណ៍ វិស័យកសិកម្ម និង អាហារូបត្ថម្ភ)។
- បង្កើតគោលនយោបាយ និងនិយ័តកម្ម ដែលបង្កលក្ខណៈឱ្យមាននូវការផលិត និងការធ្វើទីផ្សារសម្រាប់កសិករខ្នាតតូច ព្រមទាំងគាំទ្រដល់ការភ្ជាប់ទំនាក់ទំនងរបស់ពួកគេទៅនឹងអ្នកផ្ដល់សេវាវិស័យឯកជន។
- ធ្វើឱ្យប្រសើរឡើងនូវទិសដៅនៃកម្មវិធី សំដៅឆ្ពោះទៅរកតំបន់អសន្តិសុខស្បៀង និងគ្រួសារកសិករ ដោយពិចារណាអំពីទេយ្យទាន និងឧបសគ្គផ្អែកធនធានជាក់លាក់របស់ពួកគេ។
- ត្រួតពិនិត្យឱ្យបានដិតដល់ទៅលើលទ្ធផលនៃកម្មវិធីទាំងនេះ ទាក់ទងទៅនឹងសន្តិសុខស្បៀងរបស់គ្រួសារ។

### ៦.១.២. លើកកម្ពស់ការបែងចែកដី និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីជូនដល់គ្រួសារក្រីក្រ

ការធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងស្ថេរភាពកម្មសិទ្ធិដីធ្លីកសិកម្ម គឺជាល័ក្ខខ័ណ្ឌដ៏សំខាន់ ក្នុងការគាំទ្រដល់ការវិនិយោគទៅលើវិស័យកសិកម្ម និងដើម្បីការពារជីវភាពរស់នៅរបស់ជនក្រីក្រនិងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីជូនកសិករសម្រេចបាននូវវឌ្ឍនភាពមួយចំនួនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ហើយមកដល់ដំណាច់ឆ្នាំ២០១៣ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញប័ណ្ណកម្មសិទ្ធិដីជូនដល់កសិករចំនួន៤០%នៅក្នុងក្របខ័ណ្ឌនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងលក្ខណៈជាប្រព័ន្ធ។ ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ក៏ទទួលបានប្រយោជន៍ពីកម្មវិធីសម្បទានដីសង្គមកិច្ចនាពេលថ្មីៗនេះដែរ។ ចាប់ពីខែឧសភា២០១២មក រាជរដ្ឋាភិបាលកម្ពុជាបានពន្លឿន និងធ្វើការពង្រីកគួរឱ្យកត់សម្គាល់ចំពោះការបែងចែកដីធ្លីជូនដល់ជនក្រីក្រ ដោយផ្អែកលើបទបញ្ជាលេខ០០១ របស់រាជរដ្ឋាភិបាលស្ដីពីគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដោយបាននិងកំពុងកាត់ដីសម្បទានព្រៃ និងដីសម្បទានសេដ្ឋកិច្ច និងដីព្រៃមានដីកាដកហូតប្រមាណ ១,៨ លានហិកតាចែកជូនប្រជាពលរដ្ឋជាង ៤៩០,០០០គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់ដាំដុះជាក់ស្ដែង ដើម្បីឲ្យមានភាពស្របច្បាប់ ដោយធានាឱ្យមានប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីធ្វើការអភិវឌ្ឍន៍ដីរបស់ពួកគេឱ្យមានប្រសិទ្ធភាព ដោះស្រាយវិវាទដីធ្លីដែលកំពុងកើតមាន និងរក្សាស្ថេរភាពបរិស្ថាននៃធនធានធម្មជាតិ។

ការបែងចែកដីធ្លី គឺជាជំហានមួយដ៏ចម្បង ក្នុងការលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ។ រាជរដ្ឋាភិបាល ត្រូវបន្ត និងពង្រឹងទៅលើការបែងចែកដីកសិកម្ម។ បន្ថែមពីនេះទៀត ការធ្វើស្រែចម្ការ

[៦៤] កម្មវិធីគាំទ្រសន្តិសុខស្បៀងរបស់ SAWបានផ្ដល់ជាព័ត៌មានសម្រាប់ការរៀបចំកម្មវិធីមួយចំនួនដែលមានវិសាលភាពធំធេងនេះ និងផ្ដោតលើប្រពលវប្បកម្ម និងពិពិធកម្មប្រព័ន្ធកសិកម្មរបស់កសិករខ្នាតតូច ព្រមទាំងអាចប្រើប្រាស់ជាវេទិកាមួយដើម្បីពង្រីក និងលើកកម្ពស់ការសម្របសម្រួលអន្តរាគមន៍ ដើម្បីពង្រឹងជីវភាពរស់នៅរបស់គ្រួសារជនបទដែលជួបប្រទះបញ្ហាសន្តិសុខស្បៀង តាមរយៈអភិក្រម ផ្អែកលើកម្មវិធីដែលមានការសម្របសម្រួលប្រសើរជាងនេះ។

ទៅលើផ្ទៃដីទាំងនេះ ត្រូវភ្ជាប់ទំនាក់ទំនងទៅនឹងសេវាគាំទ្រវិស័យកសិកម្ម។ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចនៅក្នុងតំបន់តាំងទីលំនៅថ្មីទាំងនេះ គឺជាល័ក្ខខ័ណ្ឌតម្រូវមួយទៀតដើម្បីកសាងជីវភាពរស់នៅប្រកបដោយនិរន្តរភាព។ កន្លងមក មានសហគមន៍ ជនជាតិដើមភាគតិចមួយចំនួនតូចប៉ុណ្ណោះ បានទទួលកម្មសិទ្ធិដីសមូហភាពលើដីធ្លីនិងកម្មសិទ្ធិដីរួម ស្របតាមច្បាប់ភូមិបាលឆ្នាំ២០១១ ដែលចំណុចនេះ ត្រូវលើកកម្ពស់ ដើម្បីជំរុញឱ្យមានការអភិវឌ្ឍន៍សហគមន៍ប្រកបដោយនិរន្តរភាព ដែលបច្ចុប្បន្ន សហគមន៍ទាំងនេះមាន ប្រេវ៉ាឡង់ភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភយ៉ាងខ្ពស់។

**សកម្មភាពអាទិភាពក្រោមអាទិភាពកម្មវិធីទី២ នៃគោលបំណងទី១ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការបែងចែកដីធ្លី និងការផ្តល់ប្លង់ដីជូនដល់ជនក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង រួមមាន ៖**

២.១ ពង្រីកការបែងចែកដីសង្គមកិច្ចជូនដល់ជនក្រីក្រ និង ជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

២.២ ជំរុញការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

២.៣ ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់កសិករក្រីក្រដែលទទួលបានប័ណ្ណកម្មសិទ្ធិដី ក្នុងការទទួលបានសេវាគាំទ្រពីវិស័យកសិកម្ម និងទីផ្សារ។

២.៤ ទប់ស្កាត់ការធ្វើចំណាកស្រុកពីតំបន់មួយទៅតំបន់មួយ ដែលនាំឱ្យប្រជាជនជួបប្រទះបញ្ហាប្រឈមជាច្រើន ក្នុងនោះរួមមានបញ្ហាប្រឈមនឹងការទទួលបានកម្មសិទ្ធិស្របច្បាប់លើការប្រើប្រាស់ដីធ្លី។

២.៥ លើកកម្ពស់ការគ្រប់គ្រង ប្រើប្រាស់ និងការអភិរក្សធនធានដីកសិកម្មសំដៅធានាឱ្យមានកំណើនផលិតភាព និងនិរន្តរភាពនៃផលិតកម្មស្បៀងក្នុងប្រទេស។

### ៦.១.៣. ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់ធនធានជលផល និងព្រៃឈើ ប្រកបដោយនិរន្តរភាព

ប្រាក់ចំណូលដែលទទួលបានពីធនធានទ្រព្យសម្បត្តិរួម ទាក់ទងទៅនឹងព្រៃឈើ និងជលផលគឺជាប្រភពមួយ ដែលមានភាពពាក់ព័ន្ធទៅនឹងជីវភាពរបស់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ហើយជាពិសេស បានជួយដល់ពួកគេក្នុងការដោះស្រាយស្ថានភាពអន្តរកាលនៃអសន្តិសុខស្បៀង ដែលបណ្តាលមកពីវិបត្តិអាកាសធាតុឬវិបត្តិសង្គមសេដ្ឋកិច្ច។ ត្រីផ្តល់នូវប្រូតេអ៊ីនចំនួន ៣៧% នៃប្រូតេអ៊ីនសរុប , ៨១,៥% នៃការទទួលទានប្រូតេអ៊ីនពីសត្វ និង ៣៧% នៃការទទួលទានជាតិដែកសរុប[៦៥] នៅក្នុងអាហាររបស់កម្ពុជា ព្រមទាំងផ្តល់នូវប្រភពវីតាមីន និងមីក្រូសារជាតិមួយដ៏សំខាន់។ ត្រីទឹកសាបសរុប ដែលនេសាទបាននៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បានកើនឡើង

[៦៥] រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/IFREDI :ភាពងាយរងគ្រោះផ្នែកស្បៀង និងអាហារូបត្ថម្ភចំពោះ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំក្នុងប្រទេសកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១២។

គួរឱ្យកត់សម្គាល់រហូតដល់ ៥០៩.០០០ តោន ក្នុងឆ្នាំ២០១២។ ទិន្នផលត្រីសមុទ្រ និង វារីវប្បកម្ម ក៏កំពុងតែមានការរីកចម្រើន និងសម្រេចបានផលិតកម្មសរុបចំនួន ៩៩.០០០ តោន ចំពោះទិន្នផលត្រីសមុទ្រ និង ៧៤.០០០ តោន ចំពោះទិន្នផលវារីវប្បកម្ម ក្នុងឆ្នាំ២០១២[៦៦]។

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលប់ឡូត៍នេសាទដែលបានផ្តល់ឱ្យឯកជនក្នុងឆ្នាំ២០១១ បានធ្វើឱ្យមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ចំពោះលទ្ធភាពរបស់ជនដែលជួបប្រទះបញ្ហាអសន្តិ សុខស្បៀង ក្នុងការទទួលបានធនធានទ្រព្យសម្បត្តិរួមនេះ ប៉ុន្តែ ការនេសាទហួសប្រមាណ និងការ អនុវត្តន៍នេសាទដែលបង្កឱ្យមាននូវគ្រោះថ្នាក់ នៅតែបន្តជាបញ្ហា។ បញ្ហាប្រឈមធំបំផុតសម្រាប់ជលផលទឹកសាប គឺត្រូវគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេសាបឱ្យមាននិរន្តរភាព។ ការបន្តលើក កម្ពស់ប្រព័ន្ធសហគមន៍នេសាទ[៦៧] ពិពិធកម្មជីវភាពរស់នៅដើម្បីកាត់បន្ថយសម្ពាធទៅលើការផ្គត់ផ្គង់ ព្រមទាំងកិច្ចការពារប្រព័ន្ធអេកូឡូស៊ីនៅតំបន់ដីសើម សុទ្ធសឹងតែជាជំហានសំខាន់ៗក្នុងការធានា និរន្តរភាពប្រភព ប្រូតេអ៊ីនដ៏សំខាន់នេះ ព្រមទាំងប្រាក់ចំណូលសម្រាប់ជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។ ដើម្បីឱ្យស្របទៅតាមសេចក្តីត្រូវការដែលកំពុងតែមានការកើនឡើងពីកំណើនប្រជាជន រាជរដ្ឋាភិបាលត្រូវបន្តលើកកម្ពស់បន្ថែមទៀតទៅលើផលិតកម្មត្រីតាមវាលស្រែ វារីវប្បកម្ម និងការកែច្នៃត្រីក្រោយពេលប្រមូលផល។ បញ្ហាប្រឈមជាក់លាក់មួយ គឺជាការគំរាមកំហែងពីគម្រោងទំនប់វារីអគ្គិសនីទន្លេមេគង្គ ទៅលើការបំលាស់ទីរបស់ត្រី ការចាប់ត្រី និងជីវភាពរស់នៅរបស់ជនក្រីក្រ។ ដូច្នេះ ប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលទទួលបានពីទំនប់វារីអគ្គិសនី ត្រូវថ្លឹងថ្លែងដោយប្រុងប្រយ័ត្ន ដោយធ្វើការប្រៀបធៀបទៅនឹងផលប៉ះពាល់អវិជ្ជមានជាសក្តានុពលរបស់វា[៦៨]។ សកម្មភាពទាំងនេះ ស្របទៅនឹងក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តស្តីពីជលផល ២០១០-២០១៩ ដែលរៀបរាប់លម្អិតអំពីវិធានការលើកកម្ពស់ផលិតភាព និងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។

**ធនធានព្រៃឈើ** គឺជាប្រភពបន្ថែមមួយនៃស្បៀងអាហារ និងប្រាក់ចំណូលសម្រាប់គ្រួសារជនបទដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ក្នុងនោះរួមមានការប្រមូលជ័រឈើ និងអនុផលព្រៃឈើដទៃទៀត ព្រមទាំងអុស ជាពិសេស នៅក្នុងរយៈពេលក្រោយ គ្រោះរាំងស្ងួត និងទឹកជំនន់បានបំផ្លាញកសិផល។ សម្រាប់ប្រព័ន្ធផលិតកម្មកសិកម្មរបស់ជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបព្រៃស្ពុក គឺជាចំណែកមួយដ៏សំខាន់នៃជីវភាពរស់នៅរបស់ពួកគេ ដែលទទួលរងការគំរាមកំហែងពីការហ៊ុំព័ទ្ធពីព្រៃរួម និងភាពវិចវិលធ្ងន់ធ្ងរ ព្រមទាំងការទាញប្រយោជន៍ ហួសប្រមាណទៅលើព្រៃទាំងនោះ។ គម្របព្រៃឈើនៅក្នុងប្រទេសកម្ពុជា បានធ្លាក់ចុះជាលំដាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺបានធ្លាក់ចុះពី ៦១,១៥% ក្នុងឆ្នាំ២០០២ មកត្រឹម ៥៧,៥៩% ក្នុងឆ្នាំ២០១០ បើទោះបីជា

---

[៦៦] របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១២/២០១៣។

[៦៧] សរុបមក មានសហគមន៍ជលផលចំនួន ៥១៦ ត្រូវបានបង្កើត ក្នុងនោះសហគមន៍ចំនួន ៣២៨ ត្រូវបានចុះបញ្ជីជាផ្លូវការក្នុងឆ្នាំ២០១២ - របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១២/២០១៣។

[៦៨] សូមមើលរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/IFREDI ខែវិច្ឆិកា ឆ្នាំ២០១២។ យោងតាមការសិក្សានេះ ទំនប់វារីអគ្គិសនីខ្នាតធំដែលគេគ្រោងអនុវត្តក្នុងប្រទេសកម្ពុជា អាចនាំឱ្យមានការធ្លាក់ចុះនូវធនធានត្រីទឹកសាប និងធនធានសត្វ ក្នុងទឹកដទៃទៀត ចន្លោះពី ៣៥.០០០ តោន ទៅ ១៨២.០០០ តោន។

រដ្ឋាភិបាលបានប្តេជ្ញាអភិរក្សព្រៃឈើ តាមរយៈការកំណត់ព្រំប្រទល់ "តំបន់ការពារ "[៦៩]កិច្ចសហការគ្រប់គ្រងដោយសហគមន៍[៧០] និងការដាំដុះព្រៃឈើឡើងវិញក៏ដោយ។ ដើម្បីថែរក្សាព្រៃឈើ រាជរដ្ឋាភិបាលត្រូវធ្វើការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាពជាងនេះ ទៅលើការកាប់បំផ្លាញព្រៃឈើខុសច្បាប់ និងការទន្ទ្រានដីព្រៃ តាមរយៈសម្បទានដីសេដ្ឋកិច្ច។ ការកាត់បន្ថយការបំភាយឧស្ម័នពីការបំផ្លាញព្រៃឈើ (REED) និងយន្តការអភិវឌ្ឍន៍ស្អាត (CDM) អាចជួយបង្កើតឱ្យមាននូវការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីការពារគម្របព្រៃឈើប្រកបដោយប្រសិទ្ធភាព និងបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន។ ក្នុងនោះ ក៏មានសក្តានុពលថ្មី ក្នុងការបញ្ចូលផលិតផលព្រៃឈើទៅក្នុងប្រព័ន្ធកសិរុក្ខកម្មផងដែរ។

**សកម្មភាពអាទិភាពក្រោមអាទិភាពកម្មវិធីទី៣ នៃគោលបំណងទី១ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការលើកកម្ពស់លទ្ធភាព ក្នុងការទទួលបាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជលផល និងព្រៃឈើដែលជាទ្រព្យសម្បត្តិរួម សម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង រួមមាន ៖**

៣.១ បន្តលើកកម្ពស់វារីវប្បកម្ម និងការចិញ្ចឹមត្រីតាមវាលស្រែ ដើម្បីកាត់បន្ថយសម្ពាធទៅលើត្រីទឹកសាបធម្មជាតិ។

៣.២ ពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ ឱ្យមាននិរន្តរភាព ដើម្បីលើកកម្ពស់ការទទួលទានស្បៀងអាហារប្រកបដោយគុណភាព និងការទទួលបានប្រាក់ចំណូលសម្រាប់គ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

៣.៣ លើកកម្ពស់ទំនាក់ទំនងរវាងទីផ្សារទេសចរណ៍នៅក្នុងតំបន់ទីក្រុង និងអ្នកភូមិដែលអាស្រ័យផលព្រៃឈើ ជាមួយនឹងសហគ្រាសខ្នាតតូច និងសិប្បកម្ម។

៣.៤ ធានាឱ្យសហគមន៍ជនជាតិដើមភាគតិចមានលទ្ធភាពទទួលបានធនធានទ្រព្យសម្បត្តិរួម និង លើកកម្ពស់ការប្រើប្រាស់ដីតាមសហគមន៍ និងប្រព័ន្ធកសិរុក្ខកម្ម ព្រមទាំងកម្មវិធី REED និង CDM។

៣.៥ រក្សាតុល្យភាពរវាងប្រយោជន៍សេដ្ឋកិច្ច និងថ្លៃចំណាយផ្នែកសង្គម និងបរិស្ថានរបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ (វារីអគ្គិសនី) ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ទៅលើធនធានទ្រព្យសម្បត្តិរួម។

៣.៦ ទប់ស្កាត់ការញុះញង់ពីមជ្ឈដ្ឋានខាងក្រៅដែលតែងតែលើកទឹកចិត្តនិងជំរុញឱ្យប្រជាជនបន្តចូលកាប់ទន្ទ្រានរានយកដីព្រៃរបស់រដ្ឋធ្វើជាកម្មសិទ្ធិឯកជនខុសច្បាប់ ជាពិសេសការកាប់ទន្ទ្រាននៅក្នុងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ។

---

[៦៩] ប្រព័ន្ធការពារបច្ចុប្បន្នរួមមានតំបន់ការងារចំនួន២៣ ដែលមានផ្ទៃដីសរុប ៣,១លានហិកតា ដែលផ្ទៃដីនេះ មានចំនួនប្រមាណ ១៨% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា ព្រមទាំងមានតំបន់ការពាររបស់សហគមន៍ចំនួន ១១០ផងដែរ (ឆ្នាំ២០១២)។

[៧០] សហគមន៍ព្រៃឈើ (FC) បានកើនឡើងពី ២៦៤ក្នុងឆ្នាំ២០០៧ ទៅ ៤៥៣ ក្នុងឆ្នាំ២០១២ ដោយផ្ទៃដីព្រៃដែលគ្រប់គ្រងដោយសហគមន៍បានកើនឡើងពី ១៧៩.០២១ ហិកតា ក្នុងឆ្នាំ២០០៧ ទៅ ៣៩៩.៨៧៩ ហិកតា ក្នុងឆ្នាំ២០១២ - របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១២/២០១៣។

ការធ្វើឱ្យប្រសើរឡើងនូវ " អភិបាលកិច្ចសន្តិសុខស្បៀង " មានសារៈសំខាន់ជាពិសេសនៅក្នុងប្រទេសកម្ពុជា ទាក់ទងទៅនឹងការទទួលបាននិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជលផល និងព្រៃឈើ ដែលជាទ្រព្យសម្បត្តិរួម។ ការកសាងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងក្នុងរដ្ឋាភិបាល និងក្នុងវិស័យឯកជន ព្រមទាំងការពង្រឹងច្បាប់ និងនិយ័តកម្មជាធរមានគឺជាការចាំបាច់។

### ៦.១.៤. លើកកម្ពស់ឱកាសការងារ និងឱកាសទទួលបានប្រាក់ចំណូលសម្រាប់ជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង

ដូចមានគូសបញ្ជាក់នៅក្នុងជំពូកទី២ សូម្បីតែនៅតំបន់ជនបទក៏ដោយ ក៏ការទទួលទានស្បៀងអាហាររបស់ប្រជាពលរដ្ឋកម្ពុជា ភាគច្រើន គឺមានកម្រិតមួយសមស្រប ( ៤៣% ក្នុងឆ្នាំ ២០០៩ ) ផ្អែកទៅលើការទិញស្បៀង។ ដូច្នេះ ការកើនឡើងនៃឱកាសក្នុងការបង្កើតប្រាក់ចំណូលគ្រួសារតាមរយៈការងារទទួលបានប្រាក់កម្រៃ ព្រមទាំងការរក្សាតម្លៃស្បៀងអាហារឱ្យមានស្ថេរភាព មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់គ្រួសារ ក្នុងការទទួលបានស្បៀងអាហារទាំងនៅតំបន់ទីក្រុង និងជនបទ។

តាមការប៉ាន់ស្មានកម្លាំងពលកម្មរបស់កម្ពុជាប្រមាណ ១៥% ប៉ុណ្ណោះ នៃកម្លាំងពលកម្មសរុប ទទួលបានប្រាក់ចំណូលពីការងារដែលផ្តល់កម្រៃទៀងទាត់ ភាគច្រើននៅក្នុងឧស្សាហកម្មកាត់ដេរ ទេសចរណ៍ សំណង់ និង សេវាកម្ម។ ការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ គឺជាប្រភពដ៏សំខាន់ដើម្បីទទួលបានប្រាក់ចំណូលនៅក្នុងតំបន់ទីក្រុង ប៉ុន្តែ ការផ្ញើរប្រាក់ក៏មានសារៈសំខាន់ដូចគ្នាផងដែរ ដើម្បីធានានិរន្តរភាពនៃជីវភាពរស់នៅរបស់គ្រួសារជនបទក្រីក្រជាច្រើន។ ប្រាក់បៀវត្សរ៍បទដ្ឋានការងារ ( និងការអនុវត្តន៍បទដ្ឋានទាំងនោះ ) ព្រមទាំងគម្រោងសន្តិសុខសង្គមមូលដ្ឋាន នៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ បានមានភាពប្រសើរឡើងក្នុងរយៈពេល២ឆ្នាំចុងក្រោយ។ តួលេខការងារបានកើនឡើងគួរឱ្យកត់សម្គាល់ បន្ទាប់ពីមានភាពធូរស្រាលឡើងវិញពីវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨/២០០៩។ បើទោះជាដូច្នេះក្តី វិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលផ្តោតតែនៅជុំវិញរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលតាមតំបន់មួយចំនួនតូចនៅមានកម្រិតនៅឡើយ និងបង្ហាញឱ្យឃើញនូវពិពិធភាពតិចតួច ដែលធ្វើឱ្យវិស័យនេះងាយរងគ្រោះទៅនឹងវិបត្តិសេដ្ឋកិច្ចសកល។ ការរៀបចំឱ្យមាននូវកសិដ្ឋាន និងសហគ្រាសកសិធុរកិច្ចដែលមានភាពប្រកួតប្រជែងជាងនេះ មានសារៈសំខាន់ក្នុងការស្រូបយកកម្លាំងពលកម្មនៅតំបន់ជនបទដែលកំពុងមានការកើនឡើង និងបង្កើតការងារ ព្រមទាំងប្រាក់ចំណូលសម្រាប់ជនក្រីក្រ ដែលរស់នៅតំបន់ជនបទ។

សម្រាប់គ្រួសារដែលរស់នៅតំបន់ទីក្រុង និងតំបន់ជនបទជាច្រើន ការងារពលកម្មទទួលបានប្រាក់កម្រៃមិនជាប់លាប់នៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាប្រភពចំណូលមួយដ៏ចម្បងរបស់ពួកគេ។ ជាញឹកញាប់ សម្រាប់គ្រួសារក្រីក្រគ្មានដីធ្លីដែលរស់នៅតំបន់ទីក្រុង និងតំបន់ជនបទ ប្រាក់ចំណូលនេះ រមែងតែងជាប្រភពតែមួយគត់ សម្រាប់ទិញស្បៀងអាហារ។ ការងារពលកម្មមិនជាប់លាប់នៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតំបន់ជនបទ ភាគច្រើនមានទំនាក់ទំនងទៅនឹង

ផលិតកម្មកសិកម្ម ការសាងសង់លំនៅដ្ឋាន និង វិស័យសេវាកម្ម ដូចជាៈ ការដឹកជញ្ជូន និងការកែច្នៃកសិផល។ ការងារទទួលបានប្រាក់កម្រៃមិនជាប់លាប់ អាចទាក់ទងទៅនឹងការធ្វើចំណាកស្រុករយៈពេលខ្លី ពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ឬ ពីតំបន់ជនបទទៅតំបន់ទីក្រុង ហើយក៏រាប់បញ្ចូលផងដែរនូវការធ្វើចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសគឺទៅប្រទេសថៃ និងប្រទេសវៀតណាម[៧១]។ ប្រាក់កម្រៃប្រចាំថ្ងៃ សម្រាប់ការងារគ្មានជំនាញនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធមានកម្រិតទាប ប្រមាណ ១៦.០០០ រៀល ក្នុងមួយថ្ងៃ យ៉ាងណាមិញ តួលេខនេះ បង្ហាញឱ្យឃើញនូវភាពរីកចម្រើនមួយកម្រិតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសនៅតំបន់ជនបទ (សូមមើលជំពូកទី២)។ សកម្មភាពការងារទទួលបានប្រាក់កម្រៃមិនជាប់លាប់នៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធភាគច្រើនពុំមានការធ្វើនិយ័តកម្ម ហើយពលករពុំមានឧបាស្រ័យណាមួយចំពោះផ្លូវច្បាប់ ទាក់ទងទៅនឹងកិច្ចសន្យាការងារលក្ខខ័ណ្ឌការងារ ឬ សិទ្ធិកម្មករនិយោជិតឡើយ។ ពួកគេមានលទ្ធភាពតិចតួចក្នុងការធ្វើឱ្យប្រសើរឡើងនូវជំនាញរបស់ពួកគេ និងពុំមានកិច្ចគាំទ្រណាមួយក្នុងរយៈពេលដែលពួកគេគ្មានការងារធ្វើឡើយ។ ស្ត្រី និងបុរស ដែលចូលរួមនៅក្នុងការងារទទួលបានប្រាក់កម្រៃមិនជាក់លាក់ ប្រឈមទៅនឹងគុណវិបត្តិមួយចំនួន ទាក់ទងទៅនឹងបញ្ហា យេនឌ័រ រាប់បញ្ចូលការផ្តល់ប្រាក់កម្រៃក្នុងកម្រិតទាបជាង និងការចល័តមានកម្រិត។ ពលកម្មកុមារបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[៧២] ប៉ុន្តែ រាជរដ្ឋាភិបាលត្រូវការឱ្យមានកិច្ចខិតខំបន្ថែមទៀតដើម្បីលុបបំបាត់ទាំងស្រុង យ៉ាងហោចណាស់ទៅលើទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ តួនាទីនៃការងារទទួលបានប្រាក់កម្រៃមិនជាប់លាប់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតភាពកសិកម្ម ត្រូវយកមកធ្វើការពិចារណា ឱ្យបានកាន់តែច្រើនជាងនេះ នៅក្នុងការរៀបចំផែនការអន្តរាគមន៍។ កិច្ចសហការរវាងក្រសួង-ស្ថាប័ននានា (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងក្រសួងពាណិជ្ជកម្ម)ត្រូវពង្រឹងបន្ថែមដើម្បីលើកកម្ពស់ការងារនៅតំបន់ជនបទ។

ការកើនឡើងនៃនគរូបនីយកម្ម និង**ការផ្សារភ្ជាប់ទំនាក់ទំនងរវាងសហគមន៍ជនបទ និងមជ្ឈមណ្ឌលកំណើនសេដ្ឋកិច្ចនៅតំបន់ទីក្រុង**ក្នុងប្រទេសកម្ពុជា អាចពង្រីកឱកាសសម្រាប់គ្រួសារដែលជួបប្រទះអសន្តិសុខស្បៀង ទាំងនៅក្នុងតំបន់ទីក្រុង និងជនបទ។ កន្លងមក ការភ្ជាប់ទំនាក់ទំនងរវាងតំបន់ទីក្រុង និងតំបន់ជនបទ បានផ្តល់នូវវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មនានា និងស្បៀងអាហារជូនដល់ប្រជាជនដែលរស់នៅតំបន់ទីក្រុង ពន្ធសម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍ សំណាញ់សុវត្ថិភាពក្នុងអំឡុងពេលមានវិបត្តិ និងបង្កើនសមធម៌យេនឌ័រ។ ការធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងការលើកកម្ពស់ការធ្វើពាណិជ្ជកម្មទៅលើវិស័យកសិកម្ម និងចិញ្ចឹមសត្វ បានបង្កើនតម្រូវការកម្លាំង

---

[៧១] ការធ្វើចំណាកស្រុករយៈពេលខ្លី និងការធ្វើចំណាកស្រុកតាមរដូវកាល រមែងតែងតែជាធាតុផ្សំមួយដ៏សំខាន់នៃយុទ្ធសាស្ត្រសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់គ្រួសារខ្មែរដែលរស់នៅតំបន់ជនបទ ហើយមានសារៈសំខាន់ជាពិសេស ក្នុងការដោះស្រាយទៅនឹងបញ្ហា ព្រមទាំងវិបត្តិនានា ប៉ុន្តែក៏មានហានិភ័យ និងផលវិបាកអវិជ្ជមានដែលប្រកបដោយសក្តានុពលផងដែរ (ដូចជាភាពខ្សត់ខ្សោយនៃប្រជាជនវ័យក្មេងដែលមានថាមពល និងលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងតំបន់ជនបទ)។ ជាមធ្យមការផ្ញើរប្រាក់ពីការងារចំណាកស្រុកមានចំនួនប្រមាណ២៣ដុល្លាសហរដ្ឋអាមេរិកក្នុងមួយខែសម្រាប់ជនចំណាកស្រុកមួយនាក់ ក្នុងនោះ ចំនួនប្រាក់ដែលបានផ្ញើរមានកម្រិតខ្ពស់ជាង សម្រាប់ជនចំណាកស្រុកដែលមកធ្វើការនៅរាជធានីភ្នំពេញ និងជនចំណាកស្រុកដែលទៅធ្វើការនៅ ឯបរទេស។ សូមមើលរបាយការណ៍របស់ក្រសួងផែនការ ខែធ្នូ ឆ្នាំ២០១២។

[៧២] ពលកម្មកុមារ បើធៀបទៅនឹងសមាមាត្រនៃចំនួនកុមារសរុប បានមានការធ្លាក់ចុះពី ២០,៩% ក្នុងឆ្នាំ២០០៩ មក ១៣,៨% ក្នុងឆ្នាំ២០១១។ សូមមើលរបាយការណ៍របស់ក្រសួងផែនការ ខែធ្នូ ឆ្នាំ២០១២។

ពលកម្មដែលទទួលបានប្រាក់កម្រៃមិនជាប់លាប់នៅក្នុងវិស័យទាំងនេះ[៧៣]ហើយទីបំផុត សហគមន៍ជនបទនឹងទទួលបានប្រយោជន៍ពីភាពប្រសើរឡើងនៃលទ្ធភាពក្នុងការទទួលបានទីផ្សារ និងសេវាសង្គម។

គ្រឹះស្ថានធុរកិច្ច និងគ្រឹះស្ថានឧស្សាហកម្មសរុបចំនួន ៨៩.៥៨០ ដែលក្នុងនោះ គ្រឹះស្ថានចំនួន ២០% មានមូលដ្ឋាននៅក្នុងរាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា នៅចន្លោះខែមករា ឆ្នាំ២០០៩ និង ខែមីនា ឆ្នាំ២០១០ ដែលភាគច្រើន (៨៦,១%) គឺជាគ្រឹះស្ថានខ្នាតតូចបំផុតដែលមានកម្មករចន្លោះពី ១-២ នាក់ ប៉ុណ្ណោះ[៧៤]។ ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម (SME) កំពុងជួបប្រទះបញ្ហាប្រឈមជាច្រើន ទាក់ទង ទៅនឹងក្របខ័ណ្ឌច្បាប់ និង និយ័តកម្ម ការទទួលបានហិរញ្ញប្បទានគាំទ្រ ការទទួលបានបច្ចេកវិទ្យា និង សមាហរណកម្មនៃសហគ្រាសទាំងនោះ ទៅក្នុងខ្សែសង្វាក់តម្លៃសកល។

កង្វះជំនាញនៅក្នុងប្រទេសកម្ពុជា បង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតំបន់ទីក្រុង និងតំបន់ជនបទ។ ការអភិវឌ្ឍន៍ជំនាញ នឹងជួយដល់ពិពិធកម្មវិស័យកសិកម្ម និងបង្កើនតម្លៃបន្ថែមនៅកម្រិតកសិដ្ឋាន ឬ ស្រែចម្ការ ព្រមទាំងដំណាក់កាលបន្តបន្ទាប់ទៀត នៃខ្សែសង្វាក់តម្លៃ។ ការងារនឹងនាំឱ្យមានការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិកាន់តែប្រកបដោយនិរន្តរភាព និងបង្កើតឱ្យមាននូវការផ្ទេរកម្លាំងពលកម្មពីវិស័យកសិកម្ម ទៅវិស័យឧស្សាហកម្ម និងសេវាកម្ម ដោយទទួលបានផលតបស្នងត្រឡប់មកវិញខ្ពស់ជាងមុន។ រាជរដ្ឋាភិបាលត្រូវលើកកម្ពស់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលមានលក្ខណៈទូទៅ និងជាក់លាក់ ដើម្បីបង្កើតឱកាសការងារប្រកបដោយនិរន្តរភាពនៅតំបន់ជនបទ និងតំបន់ទីក្រុង។ ក្នុងឆ្នាំ២០០៩ ដើម្បីឆ្លើយតបទៅនឹងវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលបានផ្តួចផ្តើមឲ្យមានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លីមួយចំនួន ដើម្បីបង្កើនជំនាញរបស់និយោជិត និងធ្វើឱ្យប្រសើរឡើងនូវឱកាសការងារសម្រាប់យុវជន។ បើទោះជាដូច្នេះក្តី វិសាលភាពនៃការផ្តួចផ្តើមទាំងនេះនៅមានកម្រិតតូច ហើយការកំណត់គោលដៅទៅលើយុវជន ជាពិសេស យុវជននៃគ្រួសារក្រីក្រ ដើម្បីស្របទៅនឹងសេចក្តីត្រូវការរបស់ទីផ្សារការងារ នៅតែបន្តជាបញ្ហាប្រឈមមួយ។

ការបង្កើតឱកាសការងារ និងប្រាក់ចំណូលនៅតំបន់ជនបទ ក៏ត្រូវការឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធ ប្រសើរជាងមុនផងដែរ។ បើទោះបីជាមានការសម្រេចបាននូវវឌ្ឍនភាពមួយចំនួននៅក្នុងរយៈពេលប៉ុន្មានថ្មីៗនេះ ទាក់ទងទៅនឹងការសាងសង់ និងការស្តារផ្លូវថ្នល់ជនបទឡើងវិញ ក៏ដោយ ក៏បណ្តាញផ្លូវថ្នល់នៅក្នុងប្រទេសនៅមានកម្រិត ជាពិសេស ទាក់ទងទៅនឹងផ្លូវលំជនបទដែលភ្ជាប់ពីភូមិទៅនឹងបណ្តាញផ្លូវថ្នល់សំខាន់ៗ។ ការមានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសេវាដឹកជញ្ជូនមិនគ្រប់គ្រាន់ នាំឱ្យថ្លៃដឹកជញ្ជូនផលិតផល និងថ្លៃធ្វើដំណើរ របស់ប្រជាជនមានតម្លៃខ្ពស់ និងជាពិសេស បណ្តាលឱ្យប៉ះពាល់ដល់គ្រួសារក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដែលរស់

[៧៣] បើទោះជាដូច្នេះក្តី ការស្រូបយកកម្លាំងការងារពីសម្បទានដីសេដ្ឋកិច្ច (ELC) នៅមានកម្រិតនៅឡើយ រហូតមកទល់នឹងពេលនេះ។

[៧៤] សូមមើលរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ទៅលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ក្រសួងផែនការ ឆ្នាំ២០១១។

នៅតំបន់ដាច់ស្រយាល។ ប្រាក់ចំណេញដែលទទួលបានពីការធ្វើពាណិជ្ជកម្ម រមែងតែងមានកម្រិតទាបសម្រាប់គ្រួសារដែលរស់នៅតំបន់ជនបទ ក្នុងនោះមួយផ្នែកគឺបណ្តាលមកពី **ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ** ដែលមិនសូវមានការអភិវឌ្ឍន៍ (ឧទាហរណ៍. គ្មានអគារផ្សារ គ្មានទីកន្លែងធំទូលាយ សម្រាប់រក្សាផលិតផលក្នុងបរិមាណច្រើន គ្មានកន្លែងត្រជាក់សម្រាប់រក្សាផលិតផល គ្មានការផ្គត់ផ្គង់ទឹក-ភ្លើងនៅក្នុងទីផ្សារ) ហើយលទ្ធភាពក្នុងការទទួលបានព័ត៌មានអំពីទីផ្សារនៅមានកម្រិតទាប។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី៤ នៃគោលបំណងទី១ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការបង្កើនប្រាក់ចំណូលដោយបង្កើនឱកាសការងារ នៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ រួមមាន ៖**

៤.១ លើកកម្ពស់ការបណ្តុះបណ្តាលបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនក្រីក្រ និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង នៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ដើម្បីបង្កើនជំនាញ និងលទ្ធភាពក្នុងការទទួលបានការងារ។

៤.២ លើកកម្ពស់ជំនាញការងារដែលចាំបាច់សម្រាប់សហគ្រាសកែច្នៃកសិកម្ម សម្បទានកសិសេដ្ឋកិច្ច និងកិច្ចសន្យាកសិធុរកិច្ច សម្រាប់បង្កើតឱកាសការងារ និងបង្កើនប្រាក់ចំណូលសម្រាប់ គ្រួសារជនបទដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

៤.៣ លើកកម្ពស់កិច្ចគាំពារសង្គមនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធជាពិសេសសម្រាប់ស្ត្រី

៤.៤ លើកកម្ពស់ (ជាពិសេស) សហគ្រិនជាស្ត្រីដែលចូលរួមនៅក្នុងសហគ្រាសខ្នាតតូច សិប្បកម្ម។ល។និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទទួលបានទុននិងទីផ្សារ។

៤.៥ ធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌនិយ័តកម្ម ព្រមទាំងលទ្ធភាពក្នុងការទទួលបានបច្ចេកវិទ្យា សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម និងពង្រីកកិច្ចគាំទ្រហិរញ្ញវត្ថុដើម្បីលើកកម្ពស់សមាហរណកម្មរបស់ពួកគេទៅក្នុងខ្សែសង្វាក់តម្លៃសកល។

៤.៦ បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងទីផ្សារ ជាពិសេសនៅក្នុងតំបន់ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង និងបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំជួយពង្រីក និងថែរក្សា បណ្តាញផ្លូវលំជនបទនៅក្នុងសហគមន៍ ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

ដើម្បីឱ្យឱកាសការងារថ្មីៗ និងការបង្កើនប្រាក់ចំណូលគ្រួសារ ធ្វើឱ្យលទ្ធភាពក្នុងការទិញស្បៀងអាហារ និងការទទួលទានស្បៀងអាហាររបស់គ្រួសារមានភាពប្រសើរឡើង ចាំបាច់ត្រូវមានការអភិវឌ្ឍន៍ប្រកបដោយភាពវិជ្ជមានមួយ ទៅលើល័ក្ខខ័ណ្ឌនៃប្រាក់កម្រៃការងារ (សម្រាប់ការងារគ្មានជំនាញ) ធៀបទៅនឹងតម្លៃស្បៀងអាហារ។ បើទោះបីជាភាគច្រើន តម្លៃស្បៀងអាហារចម្បងៗមានលំនាំទៅតាមទីផ្សារសកលក៏ដោយ ប៉ុន្តែ ការបន្តលើកកម្ពស់គោលនយោបាយដែលមានស្រាប់សំដៅបង្កើនការផ្គត់ផ្គង់ស្បៀងនៅក្នុងប្រទេស (អង្ករ និង ស្បៀងអាហារសំខាន់ៗដទៃទៀត) ព្រមទាំងការពង្រឹងសំណាញ់សុវត្ថិភាពសង្គម ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃការកើនឡើងនូវតម្លៃស្បៀងអាហារ នៅតែបន្តមានភាពចាំបាច់។

## ៦.២. គោលចំណងទី២ ៖ ការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និង ការបឺតស្រូបស្បៀងអាហារ

ធ្វើឱ្យមានភាពប្រសើរឡើងនូវការប្រើប្រាស់ និង ការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ដល់ការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋកម្ពុជា។

បើទោះបីជា មានកំណើនសេដ្ឋកិច្ច ការកាត់បន្ថយអត្រាភាពក្រីក្រ និងភាពរីកចម្រើននៃសូចនាករសុខភាពសំខាន់ៗគួរឱ្យកត់សម្គាល់ ដូចជា ការធ្លាក់ចុះនូវអត្រាមរណៈ របស់កុមារអាយុក្រោម៥ឆ្នាំ និងអត្រាមរណៈរបស់មាតាក៏ដោយ ក៏ប្រទេសកម្ពុជា នៅបន្តជាប្រទេសមួយក្នុងចំណោមប្រទេសនានានៅក្នុងតំបន់ ដែលមានប្រេវ៉ាឡង់ខ្ពស់បំផុតចំពោះបញ្ហាកង្វះអាហារូបត្ថម្ភកុមារ និងមាតា។ CDHS ឆ្នាំ២០១០ បានបង្ហាញឱ្យដឹងថា កុមារចំនួន៤០% មានភាពក្រេះក្រិន ២៨% មិនគ្រប់ទម្ងន់ និង១១%ស្គមស្គាំង។កន្លងមកពុំមានភាពរីកចម្រើនចំពោះសូចនាករមនុស្សសាស្ត្រទាំង៣នេះឡើយ ចាប់តាំងពីឆ្នាំ២០០៥ ហើយបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ កាន់តែមានភាពធ្ងន់ធ្ងរឡើង។ CDHS ឆ្នាំ២០១០ ក៏បានបង្ហាញឱ្យដឹងផងដែរថា ៥៥% នៃកុមារអាយុក្រោម៥ឆ្នាំ និង ៥៣% នៃស្ត្រីមានផ្ទៃពោះមានភាពស្លេកស្លាំង និងស្ត្រីក្នុងវ័យបន្តពូជជិត ២០% មានសន្ទស្សន៍ម៉ាស់រាងកាយទាប ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើទម្ងន់ និងការលូតលាស់នៅដំណាក់បឋមរបស់កូនពួកគេ (សូមមើលជំពូក ២.៣)។

កង្វះអាហារូបត្ថម្ភ ក្នុងអំឡុងពេលដែលកុមារនៅតូច មិនត្រឹមតែបង្កឱ្យមានផលប៉ះពាល់ទៅលើសុខភាពរបស់កុមារ និងបណ្តាលឱ្យកុមារស្លាប់ប៉ុណ្ណោះទេ ប៉ុន្តែ នាំឱ្យមានផលវិបាកចំពោះជីវិតរស់នៅរបស់កុមារនោះអស់មួយជីវិត។ កង្វះអាហារូបត្ថម្ភនាំឱ្យការអភិវឌ្ឍន៍បញ្ញាញាណ និងលទ្ធផលអប់រំមានភាពទន់ខ្សោយ ដែលនាំឱ្យមានការរាំងស្ទះយ៉ាងធ្ងន់ធ្ងរចំពោះការកសាងមូលធនមនុស្ស ផលិតភាព និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសមួយ។ ការសិក្សាថ្មីមួយ ដែលបានធ្វើឡើងក្រោមការត្រួតពិនិត្យរបស់ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានប៉ាន់ប្រមាណថាប្រទេសកម្ពុជាបាត់បង់ប្រាក់ជាង៤០០លានដុល្លារសហរដ្ឋអាមេរិក ក្នុងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ទាក់ទងទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភក្នុងវដ្តជីវិត និងឱនភាពមីក្រូសារជាតិតែម៉្យាង បានក្លាយជាបន្ទុករបស់រដ្ឋដ៏ធំ ដែលត្រូវចំណាយជាង ២០០ លានដុល្លារសហរដ្ឋអាមេរិកដុល្លារក្នុងមួយឆ្នាំលើបញ្ហាទាំងនេះ [៧៥]។ ផ្ទុយគ្នាទៅនឹងថ្លៃចំណាយសេដ្ឋកិច្ច ដែលមានកម្រិតខ្ពស់នៃអាហារូបត្ថម្ភកុមារ ការវិនិយោគទៅលើអាហារូបត្ថម្ភ ផ្តល់នូវផលតបស្នងផ្នែកសង្គម និងសេដ្ឋកិច្ចក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ នៅកម្រិតសកល ប្រយោជន៍មូលដ្ឋាននៃផលធៀបថ្លៃចំណាយ វិនិយោគទៅលើអាហារូបត្ថម្ភកុមារ គឺ ១៥,៨ ធៀបនឹង១ ដែលនេះ គឺជាតួលេខមួយដែលមានកម្រិតខ្ពស់យ៉ាងខ្លាំងបើធៀបទៅនឹងការវិនិយោគអភិវឌ្ឍន៍ដទៃទៀត [៧៦]។

---

[៧៥] អង្គការ UNICEF, ផលវិបាកនៃកង្វះអាហារូបត្ថម្ភនៅប្រទេសកម្ពុជា វិច្ឆិកា២០១៣។

[៧៦] សូមមើលផែនទីបង្ហាញផ្លូវសម្រាប់ពង្រីកការងារអាហារូបត្ថម្ភ (SUN) ខែកញ្ញា ឆ្នាំ២០១០។

**កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ** ក៏បណ្តាលឱ្យមានផលប៉ះពាល់ពីជំនាន់មួយ ទៅជំនាន់មួយទៀតផងដែរ (កង្វះអាហារូបត្ថម្ភមាតា នាំឱ្យកូនមានបញ្ហាកង្វះអាហារូបត្ថម្ភ) ហើយការវិនិយោគទៅលើអាហារូបត្ថម្ភកុមារតូច ជាពិសេសកុមារី [៧៧] មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការបំផ្លាញចោលនូវវដ្តដ៏អាក្រក់នេះ។ បញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ និងផលវិបាកអវិជ្ជមានរយៈពេលវែង អាចនឹងកែលម្អឱ្យប្រសើរឡើង។ បើទោះជាដូច្នេះក្តី ច្រកមួយដ៏សំខាន់ ដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាពគឺនៅក្នុងអំឡុងពេល១.០០០ថ្ងៃដំបូងចាប់ពីពេលដែលស្ត្រីចាប់ផ្តើមមានផ្ទៃពោះរហូតដល់ពេលដែលកុមារអាយុបាន២ឆ្នាំ។

**អត្រាកង្វះអាហារូបត្ថម្ភកុមារ និងមាតា មានកម្រិតខ្ពស់បំផុតក្នុងចំណោមជនក្រីក្រ**។ បើទោះជាដូច្នេះក្តី កង្វះអាហារូបត្ថម្ភបង្កឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងប្រទេសកម្ពុជា។ កុមារម្នាក់ក្នុងចំណោមកុមារ៥នាក់ នៅក្នុងក្រុមប្រជាជនដែលមានទ្រព្យសម្បត្តិច្រើន មានបញ្ហាមិនគ្រប់ទម្ងន់ ហើយស្ត្រីម្នាក់ក្នុងចំណោមស្ត្រី៣នាក់ នៅក្នុងចំណោមក្រុមប្រជាជនដែលមានទ្រព្យសម្បត្តិច្រើនមានភាពស្លេកស្លាំង (CDHS2010)។ស្ថិតិទាំងនេះផ្តល់នូវភស្តុតាងដែលបង្ហាញឱ្យឃើញថាកំណើនសេដ្ឋកិច្ចរឹងមាំ និងការកាត់បន្ថយភាពក្រីក្រតែម៉្យាង មិនគ្រប់គ្រាន់ឡើយក្នុងការលុបបំបាត់បញ្ហាកង្វះអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា និងអាហារូបត្ថម្ភជាក់លាក់ និងតម្រូវឱ្យមានកម្មវិធីយល់ដឹងពីអាហារូបត្ថម្ភ ។

ការវិភាគទៅលើទិន្នន័យ CDHS 2010 បង្ហាញឱ្យឃើញថាអត្រាកង្វះអាហារូបត្ថម្ភមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងរយៈពេល២ឆ្នាំដំបូងនៃជីវិតរបស់កុមារ ហើយអាយុចន្លោះពី ៦-២៣ខែ គឺជារយៈពេលដ៏សំខាន់ ដែលកុមារអាចប្រឈមទៅនឹងភាពក្រេះក្រិន និងមិនគ្រប់ទម្ងន់។ ការធ្លាក់ចុះនៃកំណើន កង្វះអាហារូបត្ថម្ភ ភាគច្រើនត្រូវបានប្រកាសឲ្យដឹង ចាប់ពីកុមារអាយុ៦ខែ នៅពេលដែលការផ្តល់អាហារបន្ថែមត្រូវបានធ្វើជាទំលាប់។ ការឆាប់បំបៅដោះកូន និងការបំបៅដោះកូនតែមួយមុខគត់ ក្នុងរយៈពេលទសវត្សរ៍ចុងក្រោយនេះ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែ ដើម្បីទទួលបានភាពរីកចម្រើនលើសពីនេះទៀត រដ្ឋាភិបាលត្រូវធ្វើការដោះស្រាយចំពោះការអនុវត្តន៍ចិញ្ចឹមកុមារទាំងឡាយណាដែលពុំមានភាពសមស្រប និងកង្វះការទទួលបាននូវអាហារបន្ថែមមានជីវជាតិ និងតម្លៃសមរម្យ។ គម្លាតរវាងកង្វះអាហារូបត្ថម្ភកុមារនៅតំបន់ជនបទ និង តំបន់ទីក្រុង កំពុងមានការកើនឡើង។ មួយផ្នែកនៃបញ្ហានេះ ទំនងជាបណ្តាលមកពីលទ្ធភាពក្នុងការទទួលបានទឹកស្អាត និងបង្គន់អនាម័យ នៅតំបន់ទីក្រុងមានភាពប្រសើរជាងនៅជនបទ។ បើទោះជាដូច្នេះក្តី កង្វះទឹកស្អាតអនាម័យសមស្រប និងកង្វះខាតអនាម័យ នៅតែបន្តជាឧបសគ្គដ៏ចម្បង ដែលរាំងស្ទះដល់ការធ្វើឱ្យប្រសើរឡើង នូវអាហារូបត្ថម្ភកុមារក្នុងតំបន់ជនបទ។

មានការយល់ដឹងល្អប្រសើរនៅកម្រិតសកល អំពីឧបសគ្គដែលរាំងស្ទះដល់ការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងការបឺតស្រូបស្បៀងអាហារ ហើយសកម្មភាពអាទិភាពមួយចំនួន ដែលផ្អែកលើភស្តុតាងត្រូវបានរៀបចំឡើងជាស្រេច ដើម្បីដោះស្រាយឧបសគ្គទាំងនោះ។ បញ្ហាប្រឈមចម្បងៗនៅត្រង់ចំណុចនេះ គឺត្រូវចងក្រងអន្តរាគមន៍អាទិភាពដែលមានការពាក់ព័ន្ធទៅនឹងវិស័យជាច្រើន

[៧៧] ម្តាយដែលគ្មានការអប់រំ ទំនងនឹងមានកូនដែលខ្វះអាហារូបត្ថម្ភច្រើន។

ដើម្បីកំណត់អំពីគំរូនៃការអនុវត្តន៍ និងដើម្បីផ្តល់មូលនិធិឱ្យបានគ្រប់គ្រាន់សម្រាប់ការវិនិយោគ និងការអភិវឌ្ឍសមត្ថភាព ដើម្បីឱ្យកញ្ចប់អន្តរាគមន៍ អាចត្រូវបានយកមកអនុវត្តឱ្យបានទូលំទូលាយ។

ការលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតាក្នុងប្រទេសកម្ពុជា ត្រូវបានសង្កត់បញ្ជាក់ជាថ្មីឡើងវិញថា៖ ជាអាទិភាពខ្ពស់មួយនៃការអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជា នៅក្នុងសិក្ខាសាលាជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទ អាហារូបត្ថម្ភកុមារ និងមាតា ដែលរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងខែឧសភា ឆ្នាំ២០១២។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីផែនទីចង្អុលទិសសម្រាប់សកម្មភាព និងផ្តល់អនុសាសន៍សំខាន់ៗ សម្រាប់អនុវត្តន៍បន្ត ដែលជំរុញឱ្យមានការរៀបចំ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**[៧៨] នេះឡើង។

គោលបំណងទី២ នៃ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ផ្តោតយកចិត្តទុកដាក់ជាចម្បងទៅលើការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ។ គោលបំណងនេះ ផ្តោតសំខាន់ទៅលើ "ច្រកក្នុងការទទួលបានឱកាស" ក្នុងអំឡុងពេលមានផ្ទៃពោះ និងរយៈពេល២ឆ្នាំដំបូងនៅពេលដែលកង្វះអាហារូបត្ថម្ភកុមារបង្កនូវគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត ហើយការវិនិយោគ ផ្តល់នូវផលតបស្នងផ្នែកសង្គម និងសេដ្ឋកិច្ចមកវិញបានខ្ពស់បំផុត។ គោលបំណងនេះមានវិស័យអន្តរាគមន៍អាទិភាពចំនួន៥។ បន្ថែមពីនេះទៀត កម្មវិធីអាហារូបត្ថម្ភដែលមានការចូលរួមពីសហគមន៍[៧៩] នឹងត្រូវរៀបចំឡើងព្រមទាំងយកមកអនុវត្តសាកល្បងជាឧបករណ៍ដើម្បីលើកកម្ពស់ការសម្របសម្រួល និងសមាហរណកម្មសកម្មភាពនៅថ្នាក់មូលដ្ឋាន។

ដើម្បីលើកកម្ពស់កម្មវិធីអាហារូបត្ថម្ភ ចាំបាច់ត្រូវផ្តល់សិទ្ធិសម្រេចដល់ស្ត្រី មិនត្រឹមតែតាមរយៈអន្តរាគមន៍ ដើម្បីការពារសុខុមាលភាពផ្នែកអាហារូបត្ថម្ភ និងសុខភាពរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែត្រូវបង្កើនស្ថានភាពសង្គមសេដ្ឋកិច្ច និងលទ្ធភាពរបស់ពួកគេ ក្នុងការគ្រប់គ្រងពេលវេលា និងធនធាន ព្រមទាំងលើកកម្ពស់សិទ្ធិអំណាច ក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ពួកគេ ទាក់ទងទៅនឹងការបែងចែកស្បៀងអាហារក្នុងគ្រួសារ និងចំណាយសម្រាប់ការថែទាំសុខភាព [៨០]។ អាស្រ័យដោយអាហារូបត្ថម្ភគឺជាបញ្ហាដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា រាជរដ្ឋាភិបាលនឹងបង្កើតយន្តការមួយចំនួន ដើម្បីពង្រឹងការសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងលើកកម្ពស់ការធ្វើសមាហរណកម្មឱ្យបានប្រសើរជាងនេះបន្ថែមទៀត ចំពោះការងាររៀបចំផែនការ និង ការត្រួតពិនិត្យ។

---

[៧៨] សូមមើលរបាយការណ៍សិក្ខាសាលាថ្នាក់ជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទអាហារូបត្ថម្ភកុមារ និងមាតា ដែលប្រព្រឹត្តិធ្វើឡើងនៅថ្ងៃទី ២១-២២ ខែឧសភា ឆ្នាំ២០១២ ក្នុងរាជធានីភ្នំពេញ។

[៧៩] កម្មវិធីតាមសហគមន៍ដែលផ្តោតយកចិត្តទុកដាក់លើបញ្ហាអាហារូបត្ថម្ភ អាចដោះស្រាយមូលហេតុជាច្រើនដែលបណ្តាលឱ្យមានបញ្ហាអាហារូបត្ថម្ភ តាមរយៈការពាំនាំកម្រងសេវាកម្មមួយចំនួនទៅក្នុងសហគមន៍ទាំងមូល។ ការពង្រឹងកិច្ចសហការក្នុងចំណោមតួអង្គសំខាន់ៗ (ក្រសួងតាមវិស័យ ដៃគូអភិវឌ្ឍន៍ ព្រមទាំងវិស័យឯកជន) នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានបង្ហាញឱ្យឃើញថាជាមាគ៌ាមួយ ប្រកបដោយជោគជ័យនៅក្នុងប្រទេសជាច្រើនក្នុងការដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាព។

[៨០] គំហើញពីការស្រាវជ្រាវអន្តរជាតិបានផ្តល់ភស្តុតាងជាក់ស្តែងទូលំទូលាយថា មានទំនាក់ទំនងដោយផ្ទាល់មួយរវាងស្ថានភាពស្ត្រី និងការថែទាំសម្រាប់ស្ត្រី និងកូន ហើយការផ្តល់ភាពអង់អាចដល់ស្ត្រី នាំឱ្យទទួលបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតគ្រួសារកាន់តែប្រសើរ។

## រូបភាពទី៣២៖ វិស័យអាទិភាពសម្រាប់គោលបំណងទី២




វិស័យនីមួយៗក្នុងចំណោមវិស័យអាទិភាពទាំងនេះ នឹងមានរៀបរាប់លម្អិតដោយមានកម្រងសកម្មភាពអាទិភាពមួយចំនួនដែលត្រូវអនុវត្តឲ្យបានមុនឆ្នាំ២០១៨។

### ៦.២.១. ពង្រីកសេវា និងការអប់រំអំពីអាហារូបត្ថម្ភ

ចំណុចអាទិភាពដែលត្រូវយកចិត្តទុកដាក់ចំពោះស្ត្រី និងកូនរបស់ពួកគេ គឺក្នុងរយៈពេល ១.០០០ថ្ងៃដំបូង (ការថែទាំបន្តក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល ក្រោយសម្រាល ពេលទារកនៅតូចរហូតដល់កុមារមានអាយុ២ឆ្នាំ) នឹងត្រូវបង្កើនតាមរយៈការពង្រឹងយន្តការសម្រាលកូនដែលមានស្រាប់ និងការធ្វើឱ្យប្រសើរឡើង នូវគុណភាពនៃការថែទាំអាហារូបត្ថម្ភ និងការផ្តល់ប្រឹក្សានៅក្នុងប្រព័ន្ធ សុខាភិបាល។ យុទ្ធសាស្ត្របន្ថែមមួយចំនួនដូចជា៖ ការផ្ទេរសាច់ប្រាក់ជូនដល់ជនក្រីក្រ ដើម្បីសម្រួលដល់តម្រូវការថែទាំមុនពេលសម្រាល និងក្រោយពេលសម្រាល ការផ្ទេរស្បៀងអាហារដល់ប្រជាជនក្រីក្រ ដើម្បីលើកកម្ពស់ការទទួលបានអាហារបន្ថែមដែលមានជីវជាតិ និងការតាមដាន និងការលើកកម្ពស់ការលូតលាស់របស់កុមារ រហូតដល់អាយុ២ឆ្នាំ និងយុទ្ធនាការអប់រំ អំពីអាហារូបត្ថម្ភនឹងត្រូវយកមកអនុវត្ត។

**ជំងឺស្លេកស្លាំងនៅក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ** គឺជាមូលហេតុឬសគល់មួយ បណ្តាលឱ្យមានមរណភាពមាតា និងទារកកើតមិនគ្រប់ទម្ងន់ បានធ្លាក់ចុះតែបន្តិចបន្តួចប៉ុណ្ណោះពី ៤៦,៦% ក្នុងឆ្នាំ២០០៥មកត្រឹម ៤៤,១%ក្នុងឆ្នាំ២០១០ (CDHS 2005, 2010)។ មួយផ្នែកធំនៃភាពស្លេកសាំង គឺទាក់ទងទៅនឹងកង្វះជាតិដែក ត្រូវដោះស្រាយ មុនពេលមានផ្ទៃពោះ ជាពិសេសតាមរយៈការពង្រីកការបញ្ចូលជាតិដែកទៅក្នុងទឹកត្រី និងទឹកស៊ីអ៊ីវ ព្រមទាំងការផ្តល់គ្រាប់ថ្នាំជាតិដែកបន្ថែមរៀងរាល់សប្តាហ៍ អាហារមានគុណភាពប្រូតេអ៊ីន និង ការផ្តល់អាហារថាមពលសម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន។ បច្ចុប្បន្ន សេចក្តីត្រូវការផ្នែកសុខភាពរបស់ស្ត្រីក្នុងវ័យបន្តពូជ មិនទាន់ត្រូវបានគ្របដណ្តប់ក្នុងលក្ខណៈជាប្រព័ន្ធ តាមរយៈសេវាដែលមានស្រាប់ របស់ប្រព័ន្ធសុខាភិបាលនៅឡើយ ហើយត្រូវកំណត់រកជនបង្គោលមួយឱ្យបានសមស្រប។

**ការផ្តួចផ្តើមបំបៅដោះកូននិងការបំបៅដោះកូនតែមួយមុខគត់មានសារៈសំខាន់ខ្លាំងណាស់** អាស្រ័យដោយទឹកដោះម្តាយរួមមានរាល់សារជាតិទាំងអស់ដែលទារកត្រូវការ ក្នុងរយៈពេល៦ខែដំបូងនៃជីវិតរបស់ពួកកុមារ។ **អង្គបដិបក្ខប្រាណ**នៅក្នុងទឹកដោះម្តាយ ជួយការពារទារកពីការឆ្លងរោគ ហើយការបំបៅដោះជួយឱ្យកុមារគេចផុតពីការបង្កភាពកខ្វក់ និងការឆ្លងរោគពីទឹកគ្មានសុវត្ថិភាព និងដបដែលកខ្វក់។ ការកើនឡើងនៃការបំបៅដោះកូនតែមួយមុខគត់ពី ៦០% ទៅ ៧៤% និងការឆាប់បំបៅដោះកូនពី ៣៥% ទៅ ៦៦% នៅចន្លោះឆ្នាំ២០០៥ និងឆ្នាំ២០១០ (CDHS) បានរួមចំណែកកាត់បន្ថយអត្រាស្លាប់របស់ទារក និងកុមារអាយុក្រោម៥ឆ្នាំ នៅក្នុងប្រទេសកម្ពុជា[៨១]។ សមិទ្ធផលនេះឆ្លុះបញ្ចាំងអំពីកិច្ចខិតខំរបស់កម្មវិធីជាតិអាហារូបត្ថម្ភ និងដៃគូអភិវឌ្ឍន៍ក្នុងការផ្លាស់ប្តូរការប្រព្រឹត្តតាមរយៈការធ្វើឱ្យប្រសើរឡើង នូវការថែទាំរបស់ឆ្មបនិងយុទ្ធនាការផ្សព្វផ្សាយ ព្រមទាំងការអប់រំសហគមន៍។ យ៉ាងណាមិញ យោងទៅតាមCDHS2010 ការធានាឱ្យមាននិរន្តរភាពនិងធ្វើឱ្យប្រសើរឡើងនូវសមិទ្ធផលទាំងនេះ បង្ហាញឱ្យដឹងថាមានការធ្លាក់ចុះនៃការបន្តបំបៅដោះកូនក្រោយរយៈពេល៦ខែ និងមានការកើនឡើងយ៉ាងខ្លាំងចំពោះការចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត ជាពិសេសនៅតំបន់ទីក្រុង។ មានកុមារចំនួន៤៣% ប៉ុណ្ណោះ ដែលនៅទទួលការបំបៅដោះម្តាយ នៅចន្លោះអាយុ ២០-២៣ខែ។ និន្នាការទាំងនេះ មានទំនាក់ទំនងទៅនឹងការផ្សព្វផ្សាយអំពីម្សៅទឹកដោះសិប្បនិម្មិតពីសំណាក់វេជ្ជបណ្ឌិត ឆ្មប និងគិលានុបដ្ឋាយិកាជាពិសេសនៅតាមគ្លីនិកឯកជន ការបន្តផ្សាយពាណិជ្ជកម្មអំពីទឹកដោះសិប្បនិម្មិតសម្រាប់កុមារ អាយុក្រោម២ឆ្នាំ ពីក្រុមហ៊ុនម្សៅទឹកដោះសិប្បនិម្មិតដែលផ្ទុយទៅនឹងអនុក្រឹត្យលេខ១៣៣ ព្រមទាំងកង្វះការយល់ដឹងអំពី សារៈសំខាន់នៃការបន្តបំបៅដោះកូនយ៉ាងហោចណាស់រហូតដល់ពួកគេមានអាយុ២ឆ្នាំ ដើម្បីឱ្យកុមារមានសុខភាពល្អ ព្រមទាំងទទួលបានអាហារូបត្ថម្ភ និងការអភិវឌ្ឍន៍ប្រសើរបំផុត។

**ការផ្តល់អាហារបន្ថែមសមស្របដល់ទារកនិងកុមារតូច** ដែលមានអាហារូបត្ថម្ភខ្ពស់ និងអាហារដែលមានថាមពលខ្ពស់ ពុំមែនទទួលរងការរាំងស្ទះដោយសារតែកង្វះលទ្ធភាពក្នុងការទទួលបានអាហារនេះឡើយ ប៉ុន្តែ ក៏ត្រូវការ ឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តផងដែរ។ ការវិភាគទិន្នន័យ CDHS 2010 បង្ហាញឱ្យដឹងថាកង្វះអាហារូបត្ថម្ភ មានការកើនឡើងយ៉ាងខ្លាំងនៅចន្លោះអាយុពី ៦-២៣ខែ ដែលនេះគឺជាដំណាក់កាលដ៏សំខាន់ដែលបណ្តាលឱ្យកុមារមានភាពក្រេះក្រិន និង មិនគ្រប់ទម្ងន់។ CDHS 2010 ក៏បង្ហាញឱ្យដឹងផងដែរថា កុមារចំនួន ៧៦% មិនបានទទួលអាហារសមស្របដែលអាចទទួលយកបានក្នុងកម្រិតអប្បបរមាឡើយ។ ដូច្នេះ ការអនុវត្តន៍ផ្តល់អាហារបន្ថែមដែលមិនសមស្របនឹងត្រូវដោះស្រាយតាមរយៈការកែលម្អទៅលើការថែទាំ និង ការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភនៅមូលដ្ឋានសុខភាពយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងសកម្មភាពអាហារូបត្ថម្ភតាមសហគមន៍ពហុវិស័យ ដើម្បីជំរុញឱ្យមានភាពប្រសើរឡើងទៅលើអាហារូបត្ថម្ភរបស់កុមារ នៅក្នុងប្រទេសកម្ពុជាសម្រាប់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ វិធានការបន្ថែមទៀតគឺជាការចាំបាច់ដូចជាការផ្ទេរសាច់ប្រាក់និង / ឬស្បៀងអាហារ។

[៨១] ការឆាប់បំបៅដោះកូន និងការបំបៅដោះកូនតែមួយមុខគត់ក៏ជាមូលហេតុចម្បងដែលធ្វើឱ្យអត្រាកង្វះអាហារូបត្ថម្ភ ក្នុងចំណោមទារកមានកម្រិតទាបគួរឱ្យកត់សម្គាល់ផងដែរ (អត្រាកង្វះអាហារូបត្ថម្ភមានការកើនឡើងនៅពេលដែលឈប់មានការបំបៅដោះកូន និងចាប់ផ្តើមការផ្តល់អាហារបន្ថែមមិនសមស្រប)។

យោងតាម CDHS 2010 បានឱ្យដឹងថា ២,៥% នៃកុមារអាយុក្រោម៥ឆ្នាំ រងគ្រោះពីបញ្ហាកង្វះអាហារូបត្ថម្ភ ស្រួចស្រាវធ្ងន់ធ្ងរ (SAM = ទម្ងន់ធៀបនឹងកម្ពស់ % ក្រោម -3SD) និង៨,៤% នៃកុមារអាយុក្រោម ៥ ឆ្នាំ ជួបបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរកម្រិតមធ្យម (MAM = ទម្ងន់ធៀបនឹងកម្ពស់% ក្រោម-2SD និងលើ -3SD) ។ ហើយភាគច្រើននៃកុមារកង្វះអាហារូបត្ថម្ភទាំងនេះ ខ្វះការថែទាំ និងការព្យាបាលឱ្យបានគ្រប់គ្រាន់។ រដ្ឋាភិបាលបានរៀបចំគោលការណ៍ណែនាំជាតិ និងមេរៀនបណ្តុះបណ្តាលសម្រាប់ការព្យាបាលបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ។ បើទោះជាដូច្នេះក្តី មានតែ១% ប៉ុណ្ណោះ នៃ ៦៦,០០០ ទៅ ៨៣,០០០ ករណីកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរដែលតាមការប៉ាន់ប្រមាណថាមានចំនួន ១១៧.០០០ ករណី កំពុងទទួលបានការព្យាបាលសមស្រប។ ដូច្នេះ ការធ្វើឱ្យប្រសើរឡើងនូវការកំណត់អត្តសញ្ញាណបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរនៅកម្រិតមណ្ឌលសុខភាព និងសហគមន៍ ព្រមជាមួយនឹងការពង្រីកការព្យាបាល បញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរទៅកាន់យ៉ាងហោចណាស់មន្ទីរពេទ្យមួយ នៅក្នុងខេត្តនីមួយៗ គឺជាអាទិភាពសម្រាប់អនាគត។

កង្វះមីក្រូសារជាតិ[៨២] រួមចំណែកឱ្យមាននូវកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំនិងស្ត្រីក្នុងវ័យបន្តពូជព្រមទាំងអត្រាឈឺនិងអត្រាស្លាប់របស់កុមារនិងមាតាដែលមានកម្រិតខ្ពស់។ ការផ្តល់វីតាមីនAបន្ថែម ជូនដល់កុមារអាយុចន្លោះពី ៦-៥៩ខែ ព្រមជាមួយនឹងការទម្លាក់ព្រូនបានមានការកើនឡើងយ៉ាងខ្លាំង។ យោង តាម CDHS 2010 កុមារចំនួន ៧១% នៅក្នុងក្រុមអាយុនេះបានទទួលវីតាមីន A បន្ថែម បើធៀបទៅនឹងឆ្នាំ ២០០៥ គឺមានចំនួនត្រឹមតែ៣៥%ប៉ុណ្ណោះ។ បើទោះជាដូច្នេះក្តី ភាពស្លេកស្លាំងដោយសារកង្វះជាតិដែកក្នុងចំណោមស្ត្រី និងកុមារ នៅតែបន្តជាបញ្ហាសុខភាពសាធារណៈមួយដ៏ធ្ងន់ធ្ងរ[៨៣] ជាមួយនឹងអត្រា ៤៤% នៅក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ ៥៣% ក្នុងចំណោមស្ត្រីមានផ្ទៃពោះ និង ៥៥% ក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ (CDHS 2010)។ ការគ្របដណ្តប់នៃការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក និងអាស៊ីតហ្វូលិក សម្រាប់ស្ត្រីមានផ្ទៃពោះ បានមានការកើនឡើងក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ដោយបច្ចុប្បន្ន មានស្ត្រីចំនួន ៥៧% កំពុងទទួលបាន និងប្រើប្រាស់គ្រាប់ថ្នាំចំនួន ៩០គ្រាប់ ក្នុងអំឡុងពេលមានផ្ទៃពោះ ទៅតាមការណែនាំ ហើយការផ្តល់គ្រាប់ថ្នាំ ជាតិដែកនិងអាស៊ីតហ្វូលិក ក្រោយពេលសម្រាល បានគ្របដណ្តប់ប្រមាណពាក់កណ្តាលនៃក្រុមប្រជាជនគោលដៅ។ យ៉ាងណាមិញ ដើម្បីធ្វើឱ្យអត្រាភាពស្លេកស្លាំងមានការធ្លាក់ចុះ នៅក្នុងចំណោមក្រុមប្រជាជនដែលមានភាពស្លេកស្លាំងធ្ងន់ធ្ងរ អនុសាសន៍អន្តរជាតិ បានអំពាវនាវឱ្យប្រើប្រាស់គ្រាប់ថ្នាំជាតិដែកនិងអាស៊ីតហ្វូលិចបន្ថែម រយៈពេល១៨០ថ្ងៃ ក្នុងអំឡុងពេលមានផ្ទៃពោះ និងរយៈពេល៣ខែបន្ថែមទៀតក្រោយសម្រាល។ ប្រេវ៉ាឡង់នៃភាពស្លេកស្លាំងក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ បានធ្លាក់ចុះតែបន្តិចប៉ុណ្ណោះពី ៦២,៩% ក្នុងឆ្នាំ២០០៥ មកត្រឹម ៥៥,១% ក្នុងឆ្នាំ២០១០ អាស្រ័យដោយពុំទាន់មានអន្តរាគមន៍ទូលំទូលាយនៅឡើយ។ ការថែទាំ និងការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ នៅតាមមណ្ឌលសុខភាព នៅមានកម្រិតនៅឡើយ ដោយឡែកការផ្តល់ម្សៅមីក្រូសារជាតិចម្រុះសម្រាប់កុមារបានគ្របដណ្តប់ប្រមាណ ១០% ប៉ុណ្ណោះ ហើយការបញ្ចូលជាតិដែក ទៅក្នុងប្រភេទចំណីអាហារសំខាន់ៗ កំពុងស្ថិតនៅដំណាក់កាលបឋមនៃការពង្រីកសកម្មភាពនេះ។

[៨២] កង្វះមីក្រូសារជាតិទាំងនេះ ភាគច្រើនរួមមាន បញ្ហាកង្វះជាតិអ៊ីយ៉ូដ (IDD) បញ្ហាកង្វះវីតាមីន A (VAD) និងភាពស្លេកស្លាំងដែលបណ្តាលមកពីកង្វះជាតិដែក (IDA)។ បញ្ហាកង្វះមីក្រូសារជាតិអាចដោះស្រាយបានតាមរយៈ ក) ការផ្តល់ជីវជាតិបន្ថែម ខ) ការបញ្ចូលមីក្រូសារជាតិ ទៅក្នុងចំណីអាហារ និង គ) អភិក្រមដែលមានមូលដ្ឋានផ្អែកលើចំណីអាហារ។

[៨៣] អត្រាភាពស្លេកស្លាំងដែលមានកម្រិតស្មើ ឬ លើស ៤០% ត្រូវបានចាត់ទុកថាជាបញ្ហាសុខភាពសាធារណៈធ្ងន់ធ្ងរមួយ។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី១ នៃគោលបំណងទី២ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការពង្រីកសេវា និងការអប់រំអំពីអាហារូបត្ថម្ភ រួមមាន[៨៤]៖**

១.១ ធានាឱ្យមាននូវការគ្របដណ្តប់កាន់តែប្រសើរចំពោះការថែទាំ និងការផ្តល់ប្រឹក្សាចាំបាច់នានាអំពីបញ្ហាអាហារូបត្ថម្ភក្នុងអំឡុងពេល ១.០០០ថ្ងៃដំបូង ចាប់ពីពេលមានផ្ទៃពោះរហូតដល់កុមារមានអាយុ២ឆ្នាំ នៅឯមណ្ឌលសុខភាព (ការពិនិត្យផ្ទៃពោះមុនសម្រាល ការសម្រាល ការថែទាំក្រោយសម្រាល ការតាមដាន និងការលើកកម្ពស់ការលូតលាស់របស់កុមារអាយុក្រោម២ឆ្នាំ ការថែទាំព្យាបាលកង្វះអាហារូបត្ថម្ភស្រួចស្រាវ និងបញ្ហាអាហារូបត្ថម្ភ ក្នុងលក្ខណៈជាផ្នែកមួយនៃសមាហរណកម្មទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ (IMCI) (ក្រសួងសុខាភិបាល/កម្មវិធីជាតិអាហារូបត្ថម្ភ) [៨៥]។

១.២ អនុវត្តយុទ្ធនាការផ្សព្វផ្សាយចម្រុះដើម្បីផ្លាស់ប្តូរឥរិយាបថ ការអនុវត្តន៍និងទម្លាប់ ចំពោះបញ្ហាអាហារូបត្ថម្ភសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា (បន្តកិច្ចខិតខំទៅលើការឆាប់បំបៅដោះកូន និងការបំបៅដោះកូនតែមួយមុខគត់, បង្កើនកិច្ចខិតខំដើម្បីលើកកម្ពស់ការបន្តបំបៅដោះកូនរហូតដល់អាយុ២ឆ្នាំ, បង្កើនកិច្ចខិតខំក្នុងការផ្តល់អាហារបន្ថែមសមស្របជូនដល់កុមារអាយុចន្លោះពី ៦-២៣ខែ ផ្តល់ព័ត៌មានអំពីគ្រោះថ្នាក់នៃការចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត ព្រមទាំងសារៈសំខាន់នៃទឹកមានសុវត្ថិភាព និងអនាម័យ ដើម្បីឱ្យអាហារូបត្ថម្ភកាន់តែមានភាពប្រសើរឡើង(ក្រសួងសុខាភិបាល/កម្មវិធីជាតិអាហារូបត្ថម្ភ ក្រសួងព័ត៌មាន)។

១.៣ ត្រួតពិនិត្យឱ្យបានដិតដល់ទៅលើការកើនឡើងនៃនិន្នាការប្រើប្រាស់ និង ចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត និងបង្កើតឱ្យមាននូវគណៈកម្មការឃ្លាំមើលមួយ ដើម្បីជួយដល់ការអនុវត្តន៍អនុក្រឹត្យ លេខ១៣៣ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារតូចដើម្បីទប់ស្កាត់ការប្រើប្រាស់ទឹកដោះសិប្បនិម្មិត និងពន្លឿនការអនុវត្តន៍អនុក្រឹត្យនេះ តាមរយៈក្រសួងពាក់ព័ន្ធ (កម្មវិធីជាតិអាហារូបត្ថម្ភ/ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងព័ត៌មាន) នឹងធ្វើនិយ័តកម្មទៅលើមូលដ្ឋានសុខភាពរបស់វិស័យឯកជន។

១.៤ ដើម្បីអភិវឌ្ឍន៍ និង អនុវត្តផែនការពង្រីក និងធានាឱ្យមាននូវការផ្គត់ផ្គង់ទៀងទាត់នូវម៉ៃក្រូមីក្រូសារជាតិចម្រុះ សម្រាប់កុមារអាយុចន្លោះពី ៦-២៣ខែ (ក្រសួងសុខាភិបាល/កម្មវិធីជាតិអាហារូបត្ថម្ភ)។

១.៥ ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំបច្ចុប្បន្ននៅលើថ្នាំគ្រាប់មីក្រូសារជាតិ យោងតាមសេចក្តីណែនាំអន្តរជាតិ។

---

[៨៤] កម្មវិធីជាតិអាហារូបត្ថម្ភ (NNP) របស់ក្រសួងសុខាភិបាល កំពុងរៀបចំបង្កើតផែនការសកម្មភាព និងផែនការវិនិយោគអាទិភាពមួយទៅលើបញ្ហាអាហារូបត្ថម្ភ ដែលគូសបញ្ជាក់លម្អិតជាងនេះបន្ថែមទៀត អំពីអាទិភាពដែលទាក់ទងទៅនឹងវិស័យសុខាភិបាល ដែលមានសង្ខេបនៅក្នុងយុទ្ធសាស្ត្រនេះ។

[៨៥] ដើម្បីពិចារណាឱ្យកាន់តែមានភាពជាក់លាក់នៅក្នុងបរិបទនេះ ៖ ការលើកកម្ពស់កំណើនទម្ងន់នៅពេលមានផ្ទៃពោះ, ការកែលម្អគុណភាពចំពោះការឆាប់ផ្តល់ការថែទាំមុនសម្រាល និងភាពអនុលោមទៅតាមការផ្តល់ IFAបន្ថែមប្រចាំថ្ងៃ, ពង្រីកការផ្តល់ IFA បន្ថែមប្រចាំសប្តាហ៍សម្រាប់ស្ត្រីក្រីក្រ, ការព្យាបាលជំងឺពករូសដោយគ្រាប់ថ្នាំជាតិស័ង្កសី តាមរយៈការចែកចាយក្នុងអំឡុងពេលនៃសកម្មភាពចុះផ្ទាល់តាមមូលដ្ឋានដោយបុគ្គលិកមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិនៅក្នុងសហគមន៍, ការធ្វើឱ្យប្រសើរឡើងនូវការកំណត់អត្តសញ្ញាណបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរនៅមណ្ឌលសុខភាព និងសហគមន៍ ព្រមទាំងពង្រីកការព្យាបាលទៅដល់គ្រប់មន្ទីរពេទ្យ ទាំងអស់។

១.៦ ពង្រីកគោលដៅផ្តល់អាហារបន្ថែមសម្រាប់ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងកុមារអាយុ ៦-២៣ ខែនៅក្នុងគ្រួសារក្រីក្រ និងងាយរងគ្រោះ។
១.៧ បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងដើម្បីលើកកំពស់ការយល់ដឹងនិងការលើកឡើងបញ្ហា និងផលវិបាកនៃការលើសអាហារូបត្ថម្ភនៅកម្ពុជា។
១.៨ បង្កើនសមត្ថភាពធនធានមនុស្សសម្រាប់បញ្ហាអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាល និងវិស័យដទៃទៀត។

ក្រៅពីសកម្មភាពអាទិភាពទាំងនេះ រាជរដ្ឋាភិបាលត្រូវបង្កើនសមត្ថភាពធនធានមនុស្សសម្រាប់បញ្ហាអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាល និងវិស័យដទៃទៀត តាមរយៈកម្មវិធីថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រអាហារូបត្ថម្ភដែលទើបត្រូវបានបង្កើតថ្មី ព្រមទាំងការរៀបចំមេរៀនអាហារូបត្ថម្ភសម្រាប់បញ្ចូលទៅក្នុងកម្មវិធីសិក្សាផ្សេងៗគ្នា។ រាជរដ្ឋាភិបាលនឹងបន្តធ្វើការត្រួតពិនិត្យបន្ថែមទៀតទៅលើការបង្កើតវិទ្យាស្ថានជាតិអាហារូបត្ថម្ភកម្ពុជា ក្នុងលក្ខណៈជាអង្គភាពមជ្ឈឹមមួយសម្រាប់ការស្រាវជ្រាវដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ ការរៀបចំកម្មវិធីការត្រួតពិនិត្យ និងការអភិវឌ្ឍន៍សមត្ថភាព (ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ)។

កង្វះអាហារូបត្ថម្ភកុមារ និងមាតា មានទំនាក់ទំនងទៅនឹងកម្រិតនៃការអប់រំរបស់ឪពុកម្តាយ និងជាពិសេស គឺ ម្តាយ(សូមមើលជំពូកទី២)។ ភាពប្រសើរឡើងនៃការអប់រំចំណេះដឹងទូទៅ ធ្វើដំណើរស្របគ្នាទៅនឹងភាពប្រសើរឡើងនៃអាហារូបត្ថម្ភរបស់ស្ត្រី ព្រមទាំងផលប៉ះពាល់ទៅលើការថែទាំកុមារ ការអនុវត្តន៍ចិញ្ចឹមកូន ការប្រព្រឹត្តស្វែងរកការថែទាំសុខភាព និងការអនុវត្តន៍អនាម័យ។ ភាពរីកចម្រើននៃលទ្ធផលអប់រំ ជាពិសេស ចំពោះកុមារី គឺជាល័ក្ខខ័ណ្ឌមួយដ៏សំខាន់ក្នុងការលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតាជាបន្តបន្ទាប់។

បន្ថែមពីនេះទៀត ការបញ្ចូលទិដ្ឋភាពផ្នែកអាហារូបត្ថម្ភ និងអនាម័យទៅក្នុងកម្មវិធីសិក្សានៅឯសាលារៀន និងការផ្តោតយុទ្ធនាការអាហារូបត្ថម្ភទៅលើកុមារនៅតាមសាលារៀន នឹងជួយធ្វើឱ្យមានភាពប្រសើរឡើងនូវចំណេះដឹង និងការអនុវត្តន៍ពាក់ព័ន្ធ។ សកម្មភាពដែលមានការសម្របសម្រួលរវាងវិស័យសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា មានសារៈសំខាន់ខ្លាំងណាស់ក្នុងការងារនេះ។

### ៦.២.២. ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពក្នុងមូលដ្ឋាន និងការអនុវត្តអនាម័យ

កង្វះលទ្ធភាពក្នុងការទទួលបានទឹកមានសុវត្ថិភាព និងជាពិសេសគឺអនាម័យ ព្រមទាំងការអនុវត្តន៍អនាម័យមិនបានល្អប្រសើរ ធ្វើឱ្យមានការកើនឡើងនូវប្រេវ៉ាឡង់នៃជំងឺរាគរូស និងប៉ារ៉ាសិត ដែលបណ្តាលឱ្យបាត់បង់អាហារូបត្ថម្ភ ហើយការស្រូបយកជីវជាតិពីចំណីអាហារមានការធ្លាក់ចុះ។ ជំងឺរាគរូស ក៏ជាមូលហេតុមួយដ៏ចម្បងនៃមរណភាពកុមារ និងកង្វះអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជាផងដែរ។នៅក្នុងប្រទេសកម្ពុជាប្រជាពលរដ្ឋចំនួន៦៦%បន្ទោបង់ពាសវាលពាសកាល ហើយមានគ្រួសារត្រឹមតែ ៥៣% ប៉ុណ្ណោះ មានលទ្ធភាពទទួល បានទឹកដោយការដឹកជញ្ជូនយកមកប្រើប្រាស់នៅក្នុងរដូវប្រាំង។ ប្រមាណជា ២៥% នៃការស្លាប់របស់កុមារត្រូវបានសន្មត់ថាមកពីជំងឺ

រាគរូស និងការវិភាគកម្រិតមធ្យមទៅលើទិន្នន័យ CDHS 2010 បានបង្ហាញឱ្យដឹងថា កុមារទំនងនឹងមានភាពគ្រេះគ្រិន ឬ មិនគ្រប់ទម្ងន់ ប្រសិនបើការបន្ទោបង់ពាសវាលពាសកាល នៅតែបន្តជាការអនុវត្តន៍ទូទៅ។ តាមការប៉ាន់ប្រមាណ ការខាតបង់ផ្នែកសេដ្ឋកិច្ចប្រចាំឆ្នាំ ដែលបណ្តាលមកពីកង្វះអនាម័យនៅក្នុងប្រទេសកម្ពុជា មានកម្រិតខ្ពស់ខ្លាំង (៤៤៨លានដុល្លាសហរដ្ឋអាមេរិក) ដូច្នេះរាជរដ្ឋាភិបាលត្រូវបង្កើនការអនុវត្តន៍ អនាម័យមូលដ្ឋានក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់[៨៦]។

ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់ប្រជាពលរដ្ឋនៅទីជនបទ ក្នុងការទទួលបានទឹកមានសុវត្ថិភាព និងអនាម័យ (តាមរយៈការបង្កើនការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ព្រមទាំងការលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ទឹកឱ្យបានសមស្រប និងការអនុវត្តន៍អនាម័យ) គឺជាអាទិភាពអន្តរាគមន៍មួយ ដ៏ខ្ពស់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ**។ យុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ (RWSSHS 2010-2025) ត្រូវបានក្រសួងអភិវឌ្ឍន៍ជនបទអនុម័តក្នុងឆ្នាំ២០១១។ ការបង្កើតឱ្យមានតម្រូវការអនាម័យ និងការអនុវត្តន៍អនាម័យប្រសើរជាងមុន ការគាំទ្រដល់វិស័យឯកជនក្នុងការផ្តល់សេវាអនាម័យ ការធ្វើវិមជ្ឈការនៃការផ្តល់សេវាកម្ម និងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ព្រមទាំងការលើកកម្ពស់ប្រតិបត្តិការតាមសហគមន៍ និងការថែទាំ សុទ្ធសឹងតែជាគោលការណ៍ណែនាំនៃយុទ្ធសាស្ត្រនេះ។ ដើម្បីបង្កើតការរួមកម្លាំងគ្នា ការអនុវត្តន៍យុទ្ធសាស្ត្រនេះ ត្រូវមានទំនាក់ទំនងប្រសើរជាងនេះ ទៅនឹងអន្តរាគមន៍អាហារូបត្ថម្ភកុមារ និងមាតាដែលមានកន្លងមក និង អន្តរាគមន៍ដែលនឹងមាននៅពេលអនាគត ជាពិសេស គឺកម្មវិធីអាហារូបត្ថម្ភសមាហរណកម្មតាមសហគមន៍។ ការបញ្ចូលបញ្ហាអនាម័យទៅក្នុងកម្មវិធីសំណង់សាធារណៈ ព្រមទាំងការផ្តល់បង្គន់ក្នុងលក្ខណៈឧបត្ថម្ភធនជូនដល់ជនក្រីក្របំផុត នឹងជួយបង្កើនការគ្របដណ្តប់អនាម័យនៅតំបន់ជនបទ។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី២ នៃគោលបំណងទី២ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពក្នុងមូលដ្ឋាន និងការអនុវត្តន៍អនាម័យ រួមមាន ៖**

២.១ បញ្ចូលនូវទិដ្ឋភាពទាំងអស់ ដែលទាក់ទងទៅនឹងទឹកមានសុវត្ថិភាព និងអនាម័យ (WASH) ទៅក្នុងរាល់កម្មវិធីអាហារូបត្ថម្ភមាតា និងកុមារ និងជាពិសេសនៅក្នុងកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ (ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍)។

២.២ ផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពអប់រំ និងអនុវត្តយុទ្ធនាការ BCCតាមរយៈការភ្ជាប់ទំនាក់ទំនងកម្មវិធី WASH ទៅនឹងកម្មវិធីអាហារូបត្ថម្ភមាតា និងកុមារ (ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា)។

២.៣ ធ្វើសមាហរណកម្មផែនការវិនិយោគ និង ផែនការយុទ្ធសាស្ត្រជាតិស្តីពី WASH ជាមួយកម្មវិធីជាតិអាហារូបត្ថម្ភមាតា និងកុមារ។

២.៤ ពង្រឹងការគ្រប់គ្រងទៅលើការផ្គត់ផ្គង់ទឹកមានសុវត្ថិភាព និងអនាម័យតាមសហគមន៍ នៅកម្រិតថ្នាក់ភូមិទាក់ទងទៅនឹងប្រតិបត្តិការ និងការថែទាំបរិក្ខាដែលមានស្រាប់ (ក្រសួងអភិវឌ្ឍន៍ជនបទ និង អាជ្ញាធរមូលដ្ឋាន)។

[៨៦] យុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកជនបទ និងអនាម័យ ២០១១-២០១៥ ក្រសួងអភិវឌ្ឍន៍ជនបទ ខែធ្នូ ឆ្នាំ២០១២។

### ៦.២.៣. ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ

ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារសំខាន់ៗ ត្រូវបានបង្ហាញនៅកម្រិតអន្តរជាតិថា៖ ជាដំណោះស្រាយមួយ ក្នុងចំណោមដំណោះស្រាយនានា មានប្រសិទ្ធភាពសេដ្ឋកិច្ច និងមាននិរន្តរភាពខ្ពស់បំផុត ក្នុងការបង្ការបញ្ហាកង្វះមីក្រូសារជាតិ។ ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជាមួយនឹងការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិលជាសកលកាលពីជាង ១០ឆ្នាំមុន ហើយចាប់តាំងពីឆ្នាំ២០០៣ មក អនុក្រឹត្យស្តីពីការគ្រប់គ្រង ការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ តម្រូវឱ្យរាល់អំបិលទាំងអស់ ទាំងអំបិលផលិតក្នុងស្រុកនិងអំបិលនាំចូល ត្រូវបញ្ចូលជាតិអ៊ីយ៉ូដ។ ការអនុវត្តន៍អនុក្រឹត្យនេះ បានទទួលជោគជ័យល្អប្រសើរ អាស្រ័យដោយក្នុងឆ្នាំ២០១០ មានគ្រួសារចំនួន ៨៣% ប្រើប្រាស់អំបិលអ៊ីយ៉ូដ បើធៀបទៅនឹងឆ្នាំ២០០៥ មានចំនួន ៧២.៥% និងឆ្នាំ២០០០ មានចំនួនត្រឹមតែ ១៤% ប៉ុណ្ណោះ ដែលអនុវត្តដោយអនុគណៈកម្មការជាតិលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ **អជលកអ** (NSCIDD)។ ក្នុងឆ្នាំ២០០៥ អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ **អជមអ** (NSCFF) ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ **កជអជ** (NCN) នៃក្រសួងផែនការដើម្បីអភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយរួមមួយ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារដោយមានកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន។ ជំហានត្រៀមលក្ខណៈដើម្បីបង្កើតគោលនយោបាយជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ (ការវិភាគទៅលើការទទួលទានស្បៀងអាហារ ការចងក្រងទិន្នន័យជីវគីមី) គឺជាជំហានដែលត្រូវបាន បន្តអនុវត្ត ហើយគោលការណ៍ណែនាំ សម្រាប់បញ្ចូលមីក្រូសារជាតិទៅក្នុងប្រភេទចំណីអាហារ មូលដ្ឋានផ្សេងៗគ្នាត្រូវបានបង្កើតឡើង ដូចជា៖ អំបិលអ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក ប្រេងឆាអង្ករ...។ល។

ផ្អែកលើជំនួយឥតសំណងរយៈពេល៥ឆ្នាំ ដែលទទួលបានពី GAIN (2011-2015) អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ នៃក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិក្រសួងផែនការ ដោយមានការគាំទ្រពី សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (RACHA) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយ កំពុងពង្រីកផលិតកម្ម និងរកទីផ្សារទឹកត្រី និងទឹកស៊ីអ៊ីវដែលមានបញ្ចូលជាតិដែក[៨៧]។ អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៃក្រសួងផែនការគ្រោងកំណត់គោលដៅទៅលើសិប្បកម្មផលិតទឹកត្រីចំនួន៨០ក្នុងចំណោមសិប្បកម្មចំនួន៨៤ ដែលបានចុះបញ្ជីក្នុងប្រទេសកម្ពុជា នៅចុងបញ្ចប់នៃកម្មវិធីនេះ។ ការផលិតប្រេងឆាដោយមានបញ្ចូលវីតាមីន A កំពុងស្ថិត ក្រោមដំណើរការសិក្សាស្វែងរកសិប្បកម្ម រោងចក្រ ផលិតប្រេងឆា។ អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍ ដូចជា WFP, PATH និង IRD កំពុងសហការគ្នានៅក្នុងគម្រោងបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ។ ស្បៀងអាហារដែលមានបញ្ចូលមីក្រូសារជាតិ (ប្រេងបន្លែបញ្ចូលមីក្រូសារជាតិ អំបិលអ៊ីយ៉ូដ អាហារបញ្ចូលមីក្រូសារជាតិច្រើនមុខ) ក៏កំពុងត្រូវបាន WFP និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ប្រើប្រាស់នៅក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន និងកម្មវិធីកំណត់គោលដៅចែកស្បៀងសម្រាប់កុមារអាយុក្រោម២ឆ្នាំ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូននៅក្នុងខេត្តជាច្រើន។ អង្គការ GRET បានផលិត និងបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារបន្ថែមសម្រាប់ការធ្វើទីផ្សារសង្គម។ គំនិតផ្តួចផ្តើមផ្សេងទៀត ដើម្បីផលិតអាហារបន្ថែមដែលបញ្ចូលមីក្រូសារជាតិ នៅក្នុងស្រុក រួមមាន៖ ក្រុមហ៊ុនWinFood និងក្រុមហ៊ុន So! Nutritious ។

[៨៧] នៅចន្លោះឆ្នាំ២០០៧ និងខែមេសា ឆ្នាំ២០១១ ទឹកត្រីចំនួន ៤៦៩.២០០លីត្រ និងទឹកស៊ីអ៊ីវ ចំនួន ១៨១.០០០ លីត្រ ត្រូវបានបញ្ចូល មីក្រូជីវជាតិ។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី៣ នៃគោលបំណងទី២ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ រួមមាន ៖**

៣.១ អភិវឌ្ឍន៍គោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស (បទដ្ឋានជាតិស្តីពីការបញ្ចូលមីក្រូសារជាតិ) និងនិយ័តកម្មពាក់ព័ន្ធ ស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ ព្រមទាំងលើកកម្ពស់ការអនុវត្តន៍ និងប្រសិទ្ធភាពនៃនិយ័តកម្មដែលមានស្រាប់ (ក្រសួងផែនការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម)។

៣.២ ពង្រីកការបញ្ចូលជាតិដែកទៅក្នុងទឹកត្រី និងទឹកស៊ីអ៊ីវ ព្រមទាំងរៀបចំនិងអនុវត្តបទប្បញ្ញត្តិដែលកំណត់ថាជាកាតព្វកិច្ចចំពោះការបញ្ចូលជាតិដែក ទៅក្នុងទឹកត្រី និងទឹកស៊ីអ៊ីវ ចំពោះផលិតផលនាំចូល និងសិប្បកម្មក្នុងស្រុក(ក្រសួងផែនការ អង្គការមិនមែន រដ្ឋាភិបាល និងវិស័យឯកជន) ។

៣.៣ រៀបចំលិខិតបទដ្ឋានគតិយុត្តិ ដើម្បីគ្រប់គ្រងចំណីអាហារដែលបញ្ចូលមីក្រូសារជាតិទាំងផលិតក្នុងស្រុក និងការនាំចូល។ ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងប្រភេទស្បៀងអាហារសមស្របដទៃទៀត ព្រមទាំងធានាគុណភាព សុវត្ថិភាព និងបរិមាណសមស្របដែលមនុស្សម្នាក់ៗត្រូវការ (ក្រសួងផែនការ និងវិស័យឯកជន)[៨៨]។

៣.៤ ធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ និង ការធានាគុណភាពផលិតផលដែលត្រូវបានបញ្ចូលមីក្រូសារជាតិ(អំបិលអ៊ីយ៉ូដ ទឹកត្រី និងទឹកស៊ីអ៊ីវដែលបានបញ្ចូលជាតិដែក អនុវត្តធ្វើការវិភាគបន្ថែមទៅលើការទទួលទានស្បៀងអាហារ និងកង្វះមីក្រូសារជាតិ។

៣.៥ ពង្រឹងការអនុវត្តខ្លឹមសារអនុក្រឹត្យលេខ៦៩អនបក ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដឱ្យមានប្រសិទ្ធភាព។

៣.៦ ពង្រីកការបញ្ចូលជាតិដែកនៅក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ និងរៀបចំនិងអនុវត្តច្បាប់ដើម្បីធ្វើឱ្យការបញ្ចូលជាតិដែកនៅក្នុងទឹកត្រី និងទឹកស៊ីអ៊ីវជាល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការ នាំចូលនិងផលិតផលក្នុងស្រុក (NSCFF/NCN/ក្រសួងផែនការ)។

៣.៧ ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងផលិតផលសមស្របដទៃទៀត (ដូចជាអង្ករនិងប្រេងឆា) និងធានានូវគុណភាព សុវត្ថិភាព និងបរិមាណសមស្របតាមតម្រូវការ (NSCFF/ក្រសួងផែនការនិងវិស័យឯកជន)។

៣.៨ បន្តអភិវឌ្ឍនិងជំរុញផលិតផលអាហារបំប៉នក្នុងស្រុកដែលបញ្ចូលមីក្រូសារជាតិ និងអាហារបន្ថែមតាមរយៈវិស័យឯកជន (មិនរួមបញ្ចូលម្សៅទឹកគោសិប្បនិម្មិតនិងឧស្សាហកម្មដែលការក្លែងបន្លំកូដ) (NSCFF/ អង្គការមិនមែនរដ្ឋាភិបាល)។

[៨៨] នៅក្នុងបរិបទនេះការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករនិងប្រភេទអាហារដទៃទៀតដែលប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កំណត់គោលដៅទៅលើការចែកចាយស្បៀង ព្រមទាំងការបញ្ចូលមីក្រសារជាតិទៅក្នុងស្បៀងបម្រុងជាតិ នឹងត្រូវយកមក ធ្វើការពិចារណា។

### ៦.២.៤. បង្កើនការមានស្បៀង និងការប្រើប្រាស់ស្បៀងឱ្យបានសមស្របនៅកម្រិតគ្រួសារ

កម្មវិធីលើកកម្ពស់ការមានស្បៀងដែលពោរពេញទៅដោយអាហារូបត្ថម្ភ និងមានសុវត្ថិភាពនៅកម្រិតគ្រួសារ តាមរយៈការលើកកម្ពស់ប្រព័ន្ធផលិតស្បៀងអាហាររបស់កសិករខ្នាតតូច (ការបញ្ចូលសួនបន្លែនិងចម្ការផ្លែឈើ ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងវារីវប្បកម្ម) ព្រមទាំងការលើកកម្ពស់ចំណេះដឹងអំពីអាហារូបត្ថម្ភនៅក្នុងសហគមន៍ ដើម្បីប្រើប្រាស់ និងរៀបចំស្បៀងអាហារដែលមាននៅក្នុងមូលដ្ឋានប្រកបដោយអាហារូបត្ថម្ភ ត្រូវបានអនុវត្តជាច្រើនឆ្នាំមកហើយ តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ព្រមទាំង បានបង្ហាញឱ្យឃើញអំពីប្រសិទ្ធភាព។ អន្តរាគមន៍ទាំងនេះ ត្រូវពង្រីកបន្ថែម និងត្រូវមានការសម្របសម្រួលប្រសើរជាងមុន រវាងវិស័យនានា (កសិកម្ម និងសុខាភិបាល) ហើយត្រូវលើកកម្ពស់ចំណេះដឹងអំពីអាហារូបត្ថម្ភកុមារ និងមាតា ក្នុងចំណោមអ្នកផ្តល់សេវាកសិកម្ម ដើម្បីបង្កើនផលប៉ះពាល់។ អភិក្រមដែលមានមូលដ្ឋានផ្អែកលើស្បៀង ដើម្បីធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ នឹងត្រូវយកមកធ្វើការពិចារណាថាជាធាតុផ្សំមួយដ៏សំខាន់នៅក្នុងកម្មវិធី អាហារូបត្ថម្ភតាមសហគមន៍ សមាហរណកម្មចម្រុះវិស័យ ដែលត្រូវបានអនុវត្តតាមរយៈអាជ្ញាធរមូលដ្ឋាន។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី៤ នៃគោលបំណងទី២ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ បង្កើនការមានស្បៀង និងការប្រើប្រាស់ស្បៀងដែលពោរពេញទៅដោយអាហារូបត្ថម្ភ នៅកម្រិតគ្រួសារ រួមមាន ៖**

៤.១ លើកកម្ពស់ការយល់ដឹងអំពីតម្លៃអាហារូបត្ថម្ភដែលមាននៅក្នុងផលិតផលកសិកម្មក្នុងស្រុកជូនដល់សហគមន៍ និងបញ្ជ្រាបបញ្ហាអាហារូបត្ថម្ភទៅក្នុងការផ្សព្វផ្សាយកសិកម្ម។

៤.២ ពង្រីកកម្មវិធីដែលលើកកម្ពស់ប្រព័ន្ធផលិតកម្មចម្រុះ ការរក្សាទុក ការកែច្នៃនៅក្នុងកម្រិតគ្រួសារ សហគមន៍ និងសាលារៀន ព្រមទាំងភ្ជាប់ទំនាក់ទំនងកម្មវិធីទាំងនេះ ទៅនឹងវិស័យសុខាភិបាល (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្មវិធីជាតិអាហារូបត្ថម្ភនៃក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា)។

៤.៣ ពង្រឹងការអនុវត្តន៍ច្បាប់ និងនិយ័តកម្មនានា ដើម្បីលើកកម្ពស់ផលិតកម្មកសិកម្ម និងអាហារូបត្ថម្ភ ដើម្បីឱ្យសុខភាព និងបរិស្ថានកាន់តែមានភាពល្អប្រសើរ(សុវត្ថិភាពចំណីអាហារ) រួមទាំងអនាម័យ និងបទដ្ឋានហ្វីតូ-អនាម័យ និងបង្កើនការយល់ដឹងជាសាធារណៈអំពីសុវត្ថិភាពចំណីអាហារ។

### ៦.២.៥. ការប្រើប្រាស់ឧបករណ៍គាំពារសង្គមដើម្បីលើកកម្ពស់អាហារូបត្ថម្ភ

ការលើកកម្ពស់មូលធនមនុស្សតាមរយៈការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារនិងមាតា ត្រូវបានដោះស្រាយ ដោយផ្ទាល់នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។ ភាពក្រីក្រកំពុងបង្កឱ្យមានផលប៉ះពាល់ទៅលើកង្វះអាហារូបត្ថម្ភកុមារ ដូច្នេះ កម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ (CCT) ដែលសម្រួលដល់ការទទួលទាន និងតម្រូវការ

អាហារូបត្ថម្ភ ព្រមទាំងសេវាសុខភាព និងអនាម័យ ត្រូវបានកំណត់អាទិភាពថាជាសកម្មភាពថ្មីមួយ នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។ កម្មវិធីសាកល្បងមួយ ដែលកំណត់គោលដៅទៅលើកុមារតូច ស្ត្រីមានផ្ទៃពោះ និងម្តាយកំពុងបំបៅដោះកូន នៅតំបន់ជនបទនៃស្រុកចំនួន២ ត្រូវបានរៀបចំ ដើម្បីអនុវត្ត ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងផ្សេងៗគ្នា តាមរយៈរដ្ឋាភិបាលមូលដ្ឋាន។ បទពិសោធន៍ដែលទទួលបានពីប្រទេសដទៃទៀត បង្ហាញឱ្យឃើញថា ប្រសិនបើកម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌត្រូវបានរៀបចំកំណត់គោលដៅ និងភ្ជាប់ទំនាក់ទំនងបានល្អទៅនឹងសេវាអាហារូបត្ថម្ភ និងសេវាសុខភាព អាចធ្វើឱ្យប្រសើរឡើងនូវលទ្ធផលអាហារូបត្ថម្ភ។ បន្ថែមពីនេះទៀត កម្មវិធី និងអន្តរាគមន៍ដទៃទៀត ដែលត្រូវបានគូសបញ្ជាក់ នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ដូចជាៈ មូលនិធិសមធម៌សុខភាព (HEF) កម្មវិធីសំណង់ សាធារណៈ និងការកំណត់គោលដៅចែកចាយស្បៀងអាហារ ដែលមានបញ្ចូលមីក្រូសារជាតិ មានទំនាក់ទំនងដោយផ្ទាល់ ឬ ប្រយោលទៅនឹងលទ្ធផលអាហារូបត្ថម្ភ។ ដូច្នេះ ទាមទារឱ្យមានការសម្របសម្រួលឱ្យបានជិតដល់ ចំពោះការអនុវត្តន៍កម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ ជាមួយសកម្មភាពអាហារូបត្ថម្ភតាមសហគមន៍ដទៃទៀត ដែលមានគូសបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី៥ នៃគោលបំណងទី២ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺការភ្ជាប់ទំនាក់ទំនងឧបករណ៍គាំពារសង្គមទៅនឹងអាហារូបត្ថម្ភ រួមមាន ៖**

៥.១ សម្របសម្រួលកម្មវិធីគាំពារសង្គមដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ ជាមួយវេទិកាអាហារូបត្ថម្ភ ជាតិ(យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងផែនការវិនិយោគអាហារូបត្ថម្ភ)។

៥.២ កាត់បន្ថយរបាំងហិរញ្ញវត្ថុ ដែលរាំងស្ទះដល់ការថែទាំអាហារូបត្ថម្ភនៅមណ្ឌលសុខភាព តាមរយៈការពង្រីកមូលនិធិសមធម៌សុខភាព (HEFs) និងការគ្របដណ្តប់ទៅលើរាល់សេវា និងការថែទាំអាហារូបត្ថម្ភទាំងអស់ ក្រោមមូលនិធិសមធម៌សុខភាព។

៥.៣ ភ្ជាប់ទំនាក់ទំនងកម្មវិធីសំណង់សាធារណៈ(PWP)ដើម្បីធ្វើឱ្យទឹកមានសុវត្ថិភាព និងអនាម័យកាន់តែមានភាពប្រសើរឡើង។

៥.៤ បង្កើនអាហារូបត្ថម្ភតាមរយៈបណ្តាញសុវត្ថិភាពសង្គមដែលមានស្រាប់ ដូចជាការផ្តល់អាហារតាមសាលារៀន និងការរៀបចំចងក្រងបញ្ជីក្រុមអាហារដែលសម្បូរអាហារូបត្ថម្ភ សម្រាប់ការអន្តរាគមន៍ទៅគោលដៅទាំងឡាយ។

### ៦.២.៦. អភិវឌ្ឍន៍ និងអនុវត្តន៍កម្មវិធីអាហារូបត្ថម្ភតាមសហគមន៍

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងសិក្ខាសាលាជាតិស្តីពីអាហារូបត្ថម្ភ ដែលប្រារព្ធធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១២ ការអនុវត្តន៍សាកល្បង និង ការអនុវត្តន៍ជាផ្លូវការចំពោះកម្មវិធីអាហារូបត្ថម្ភ ដោយមានការចូលរួមពី

សហគមន៍និងតាមរយៈសកម្មភាពនិងការចូលរួមរបស់អាជ្ញាធរមូលដ្ឋានគឺជាឧបករណ៍មួយដ៏សំខាន់ ដើម្បីលើកកម្ពស់ការប្រើប្រាស់ និងការបឺតស្រូបស្បៀងអាហារឱ្យបានសមស្រប ដើម្បីធ្វើឱ្យអាហារូបត្ថម្ភមានភាពប្រសើរនៅក្នុងប្រទេសកម្ពុជា។

បទពិសោធពីប្រទេសដទៃទៀតបង្ហាញឱ្យឃើញថា ដើម្បីឱ្យកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ទទួលបានជោគជ័យ ចាំបាច់ត្រូវមានការប្តេជ្ញាចិត្តពីកម្រិតថ្នាក់ជាតិ និង សមាហរណកម្មល្អប្រសើរនៅកម្រិតមូលដ្ឋាន ព្រមជាមួយនឹងការធ្វើចលនាសហគមន៍ឱ្យបានគ្រប់គ្រាន់។ បន្ថែមពីនេះទៀត ការត្រួតពិនិត្យ និងវាយតម្លៃឱ្យបានដិតដល់នៃការអនុវត្តសិក្សាស្រាវជ្រាវ និងការកសាងសមត្ថភាពសុទ្ធសឹងតែត្រូវបានបង្ហាញឱ្យឃើញថា ជាល័ក្ខខ័ណ្ឌតម្រូវបន្ថែមទៀត ដើម្បីគាំទ្រឱ្យកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ទទួលបានជោគជ័យ។ បទពិសោធន៍ដែលទទួលបានពីមូលនិធិ MDG - កម្មវិធីរួមស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភកុមារ និង ការអនុវត្តន៍សាកល្បងជាច្រើនទៅលើគម្រោងដែលមានស្រាប់ និងគម្រោងដែលនឹងមាននៅពេលអនាគត ចំពោះអាហារូបត្ថម្ភតាមសហគមន៍ នឹងត្រូវយកមកប្រើប្រាស់ដើម្បីរៀបចំកិច្ចអន្តរាគមន៍។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទមានអាណត្តិការងារធានាការសម្របសម្រួលទូទៅ និងបង្កើតរចនាសម្ព័ន្ធសមស្រប សម្រាប់កម្មវិធីអាហារូបត្ថម្ភតាមសហគមន៍នៅក្នុងប្រទេសកម្ពុជា។ តួនាទី និងមុខងាររបស់ស្ថាប័នពាក់ព័ន្ធ នឹងត្រូវបានកំណត់ ព្រមទាំងផ្តល់នូវធនធានគ្រប់គ្រាន់។ ប្រព័ន្ធតាមដានអាហាររូបត្ថម្ភមួយនឹងត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យផលប៉ះពាល់ទៀងទាត់នៃការអន្តរាគមន៍និងសមត្ថភាពរបស់ស្រុកដែលបានពង្រីក [៨៩]។ ការអនុវត្តន៍សាកល្បងកម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌដែលផ្តោតយកចិត្តទុកដាក់ទៅលើស្ត្រីមានផ្ទៃពោះ ម្តាយដែលកំពុងបំបៅដោះកូន និងកុមារតូច និងដែលត្រូវបានអនុវត្តនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា នឹងមានទំនាក់ទំនងជិតស្និទ្ធជាមួយកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍។

ការសម្រេចបាននូវគោលដៅសម្រាប់គោលបំណងទី២នៃ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ**ទាមទារឱ្យមានកម្រងសកម្មភាពអាហារូបត្ថម្ភជាក់លាក់មួយ ព្រមទាំងការអភិវឌ្ឍន៍ដែលផ្តោតយកចិត្តទុកដាក់ទៅលើអាហារូបត្ថម្ភ នៅក្នុងវិស័យផ្សេងៗគ្នា។ ដូច្នេះ ការសម្របសម្រួលដ៏រឹងមាំ គឺជាគន្លឹះមួយ ដើម្បីទទួលបានជោគជ័យ។ ការរៀបចំស្ថាប័នអនុវត្តសម្រាប់គោលបំណងនេះ ត្រូវបានគូសបញ្ជាក់នៅក្នុងជំពូកទី៧ នៃ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ**។ យោងតាមអនុសាសន៍ដែលទទួលបានពីសិក្ខាសាលាថ្នាក់ជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដែលប្រារព្ធធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលចាំបាច់ត្រូវធានាថា បញ្ហាអាហារូបត្ថម្ភត្រូវបានឆ្លុះបញ្ចាំង និងរៀបចំថវិកាឱ្យបានគ្រប់គ្រាន់នៅក្នុងគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក៏នឹងសម្របសម្រួលដល់ការរៀបចំក្របខ័ណ្ឌផែនការ និង ក្របខ័ណ្ឌវិនិយោគរួមគ្នាមួយសម្រាប់បញ្ហាអាហារូបត្ថម្ភ( សកម្មភាពអាហារូបត្ថម្ភ

[៨៩] តាមដានអាហាររូបត្ថម្ភលើប្រសិទ្ធិភាពនៃការចំណាយអាចត្រូវបានបង្កើតឡើងតាមរយៈការកម្មវិធីត្រួតពិនិត្យកំណើន ដែលផ្សារភ្ជាប់ទៅនឹងចាក់ថ្នាំបង្ការរោគ។

និងផែនការវិនិយោគនៅក្នុងវិស័យជាច្រើនផ្សេងៗគ្នា) ដើម្បីបន្តដាក់ឱ្យដំណើរការនូវអាទិភាពសម្រាប់ការងារអាហារូបត្ថម្ភ ដែលមានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រនេះ និងធានាឱ្យមានការផ្តល់ហិរញ្ញប្បទានគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ តាមរយៈអភិក្រមដែលមានមូលដ្ឋានផ្អែកលើកម្មវិធី។

## ៦.៣. គោលបំណងទី៣ ៖ ការបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង

**ធ្វើឱ្យប្រសើរឡើងប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងវិបត្តិនានា ដើម្បីបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង សម្រាប់គ្រួសារដែលមានបញ្ហាសន្តិសុខស្បៀង។**

គ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់ និងគ្រោះរាំងស្ងួត) វិបត្តិសេដ្ឋកិច្ចសង្គម(ដូចជា ការកើនឡើងនូវតម្លៃស្បៀងអាហារភ្លាមៗ) ឬ វិបត្តិបុគ្គល (ភាពគ្មានការងារធ្វើ ឬ មានជំងឺ) អាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង[៩០] សម្រាប់គ្រួសារក្រីក្រ និងរមែងតែងជំរុញឱ្យមានយុទ្ធសាស្ត្រ [៩១] សម្រាប់ដោះស្រាយហានិភ័យ និងវិបត្តិនានា ដែលអាចធ្វើឱ្យគ្រួសារជួបប្រទះបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ។

រូបភាពទី៣៣ ៖ ស្ថេរភាពនៃសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ- យុទ្ធសាស្ត្រអន្តរាគមន៍ដើម្បីកាត់បន្ថយហានិភ័យ




[៩០] ការផ្គត់ផ្គង់ស្បៀងនៅក្នុងបរិបទនេះ សំដៅចំពោះការមានស្បៀង ការទទួលបានស្បៀង និងការប្រើប្រាស់/ការបឺតស្រូបស្បៀង។

[៩១] ការអង្កេតដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃវិបត្តិតម្លៃស្បៀងអាហារលើកចុងក្រោយ បានបង្ហាញឱ្យឃើញថា គ្រួសារចំនួន ៩៨% បានជំពាក់បំណុលថ្មី ហើយគ្រួសារប្រមាណ ៥០% បានរាយការណ៍ឱ្យដឹងថាពួកគេកាត់បន្ថយការទទួលទានស្បៀងក្នុងលក្ខណៈជាវិធីដោះស្រាយបញ្ហាបែបអវិជ្ជមាន(សូមមើលរបាយការណ៍របស់CDRIអំពីផលប៉ះពាល់នៃតម្លៃស្បៀងអាហារខ្ពស់នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨)។ អត្រាការប្រាក់ខ្ពស់ពីអ្នកចងការប្រាក់ រមែងតែងបណ្តាលឱ្យមានការលក់ដីនិងបាត់បង់ទ្រព្យសម្បត្តិសម្រាប់ផលិតស្បៀងអាហារ ព្រមទាំងជួបប្រទះបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ។

### ៦.៣.១. ពង្រីកសំណាញ់សុវត្ថិភាពសង្គមលើផ្នែកសន្តិសុខស្បៀង

ការកំណត់គោលដៅសង្គហទានសង្គម ដើរតួនាទីកាន់តែសំខាន់[៩២] ក្នុងការបង្កលក្ខណៈឱ្យគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ធានាបានស្ថេរភាពក្នុងការទទួលបានស្បៀងអាហារ។ គម្រោងសង្គហទានសង្គមទាំងនេះ ផ្តោតគោលដៅទៅលើគ្រួសារអសន្តិសុខស្បៀងរ៉ាំរ៉ៃ ឬ បណ្តោះអាសន្ន (តាមរដូវកាល) ក្នុងពេលធម្មតា និងអាចត្រូវបានរៀបចំ ឬ ពង្រីកបន្ថែមក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ បានបង្កើតឱ្យមាននូវយុទ្ធសាស្ត្រមួយសម្រាប់សំណាញ់សុវត្ថិភាពសង្គមដែលមានភាពគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈជាប្រព័ន្ធសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដែលត្រូវបានផ្តល់អនុសាសន៍ជាសកម្មភាពអាទិភាពនៅក្នុង SFFSN 2008-2013។ **យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា** ត្រូវបានអនុម័តក្នុងខែមីនា ឆ្នាំ២០១១ ហើយគោលការណ៍ណែនាំ និងនីតិវិធី សម្រាប់សម្របសម្រួលអនុវត្ត និងត្រួតពិនិត្យយុទ្ធសាស្ត្រ និងផែនការដើម្បីលើកកម្ពស់សមត្ថភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ត្រូវបានគូសបញ្ជាក់នាពេលថ្មីៗនេះ (ជំពូកទី៣)។ រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០០៨ ព្រមជាមួយនឹងការពង្រីកទៅលើការអភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសង្គម ការធ្វើសុខដុមនីយកម្ម និងការកំណត់គោលដៅ។ អន្តរាគមន៍សំណាញ់សុវត្ថិភាពសង្គមប្រកបដោយជោគជ័យ ដូចជា៖ មូលនិធិសមធម៌សុខភាព ការផ្តល់អាហារនៅតាមសាលារៀន កម្មវិធីស្បៀងពលកម្មនិងសាច់ប្រាក់ពលកម្ម និង ការកំណត់គោលដៅអន្តរាគមន៍ សម្រាប់ក្រុមងាយរងគ្រោះជាក់លាក់ត្រូវបានពង្រីក។ បច្ចុប្បន្ន អន្តរាគមន៍ថ្មីៗ ដូចជា៖ ការផ្ទេរសាច់ប្រាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ ឬ គម្រោងសំណង់សាធារណៈ កំពុងត្រូវបានរៀបចំនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម។ ការកំណត់គោលដៅនៃគម្រោងសង្គហទានសង្គម ក៏បានមានភាពប្រសើរឡើងផងដែរ ជាពិសេស តាមរយៈការបង្កើនការគ្របដណ្តប់នៃប្រព័ន្ធជាតិស្តីពីការកំណត់អត្តសញ្ញាណកម្ម គ្រួសារក្រីក្រ (ID Poor) របស់ក្រសួងផែនការដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ (មើលជំពូកទី៧)។

កម្មវិធីស្បៀងពលកម្ម/សាច់ប្រាក់ពលកម្ម គឺជាឧបករណ៍ដែលប្រើប្រាស់ញឹកញាប់នៅក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយបញ្ហាអសន្តិសុខស្បៀងតាមរដូវកាល ឬ ផ្តល់ស្បៀងអាហារក្រោយពេលគ្រោះមហន្តរាយ ដើម្បីសម្រួលដល់ស្ថានភាពសន្តិសុខស្បៀងឱ្យមានភាពធូរស្រាលឡើងវិញ។ កម្មវិធីទាំងនេះ បម្រើឱ្យគោលបំណងចំនួន២ស្របពេលតែមួយ ៖ សម្រួលដល់ការទទួលទានស្បៀងអាហាររបស់គ្រួសារ តាមរយៈការបង្កើតប្រាក់ចំណូលបន្ថែម និងធ្វើឱ្យប្រសើរឡើងនូវទ្រព្យសម្បត្តិសម្រាប់ផលិតស្បៀង តាមរយៈការបង្កើន ឬការថែរក្សាហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ដោយប្រើប្រាស់

[៩២] នៅពេលដែលមានការអភិវឌ្ឍន៍សេដ្ឋកិច្ចជារួម សំណាញ់សុវត្ថិភាពសង្គមបែបប្រពៃណី (គ្រួសារ មិត្តភក្តិ និងសហគមន៍) កាន់តែមានភាពខ្សោយទៅៗ។

កម្លាំងការងារពលកម្មសន្ទឹកសន្ទាប់។ កម្មវិធីសាច់ប្រាក់ពលកម្ម[៩៣] ត្រូវបានអនុវត្តអស់រយៈពេលជាច្រើនឆ្នាំនៅពេលដែលមានភាពចាំបាច់ ហើយនាពេលថ្មីៗនេះ ត្រូវបានពង្រីក បន្ថែមនៅក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការស្បៀងអាហារសង្គ្រោះបន្ទាន់ ក្រោយពេលមានវិបត្តិតម្លៃស្បៀងអាហារ និងវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨/២០០៩[៩៤]។ ដើម្បីដោះស្រាយភាពគ្មានការងារធ្វើដែលកើតឡើងដដែលៗ ជាទៀងទាត់ (តាមរដូវកាល) នៅតំបន់ជនបទ ព្រមទាំងផ្តល់ប្រាក់ចំណូលទៀងទាត់សម្រាប់គ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ  រាជរដ្ឋាភិបាលត្រូវផ្តល់ឱកាសការងារដែលអាចព្យាករណ៍ទុកជាមុនបានឱ្យច្រើន និងទូលំទូលាយជាងនេះ បន្ថែមទៀត ដោយផ្តោតយកចិត្តទុកដាក់ទៅលើការថែទាំផ្លូវលំជនបទសំខាន់ៗ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ការស្តារហេដ្ឋារចនាសម្ព័ន្ធនៅក្នុងភូមិ និងការងារដែលទាក់ទងទៅនឹងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ (ការដាំព្រៃឈើឡើងវិញ ។ល។)[៩៥]។ កម្មវិធីសំណង់សាធារណៈនៅកម្រិតថ្នាក់ជាតិ ត្រូវមានទំនាក់ទំនងទៅនឹងផែនការយថាភាពសម្រាប់ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ដើម្បីពង្រីកការគ្របដណ្តប់របស់កម្មវិធីនេះ នៅពេលមានវិបត្តិ។ នៅក្នុង**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា** បានគូសបញ្ជាក់អំពីធាតុផ្សំសំខាន់ៗសម្រាប់កម្មវិធីសំណង់សាធារណៈមួយដែលមានភាពសុខដុមនីយកម្មនៅកម្រិតថ្នាក់ជាតិ ព្រមទាំងមានការពិគ្រោះយោបល់រវាងតួអង្គពាក់ព័ន្ធនានា។ រាជរដ្ឋាភិបាលបានរៀបចំឱ្យមាននូវអភិក្រមដែលមានមូលដ្ឋានផ្អែកលើកម្មវិធីមួយ ដើម្បីផ្តល់មូលនិធិគាំទ្រ និងអនុវត្តកម្មវិធីសំណង់សាធារណៈ ដែលមានវិសាលភាពកាន់តែធំជាងមុន ដោយផ្អែកលើគោលការណ៍ណែនាំដែលបានឯកភាពគ្នា[៩៦]។

នៅក្នុងប្រទេសកម្ពុជា ការចំណាយទៅលើបញ្ហាសុខភាពដែលគ្មានការគ្រោងទុក នាំឱ្យមានការជំពាក់បំណុល និងការបាត់បង់ទ្រព្យសម្បត្តិសម្រាប់ផលិតស្បៀងអាហារ ហើយកត្តានេះ រមែងតែងតែជាមូលហេតុមួយដ៏ចម្បង ដែលធ្វើឱ្យគ្រួសារក្រីក្រជួបប្រទះបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ។ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំមូលនិធិសមធម៌សុខភាពប្រកបដោយជោគជ័យ ព្រមទាំងបានអនុវត្តសាកល្បងនូវគម្រោងធានារ៉ាប់រងសុខភាពតាមសហគមន៍ (CBHI)។

៩៣ ក្នុងរយៈពេលប៉ុន្មានចុងក្រោយនេះ  មានការផ្លាស់ប្តូរនិន្នាការមួយយ៉ាងច្បាស់លាស់ពីស្បៀងអាហារទៅជាសាច់ប្រាក់អាស្រ័យ ដោយមានស្បៀងអាហារនៅក្នុងមូលដ្ឋានទូទាំងប្រទេសកម្ពុជា ហើយជាទូទៅ ប្រសិទ្ធភាពនៃការផ្ទេរប្រាក់របស់កម្មវិធីដែលមាន មូលដ្ឋានផ្អែកលើសាច់ប្រាក់ រមែងតែងមានកម្រិតខ្ពស់ជាង។

៩៤ គម្រោង EFAP-AFបានមើលឃើញជាមុននូវសកម្មភាពសាច់ប្រាក់ពលកម្មទ្រង់ទ្រាយធំ (៥,៥លានដុល្លា ចន្លោះពី ២០១៣-២០១៥) ដោយផ្តោតលើការស្តារផ្លូវថ្នល់ និងទំនប់ ព្រមទាំងប្រព័ន្ធធារាសាស្ត្រ ដើម្បីជាប្រយោជន៍ដល់ក្រុមប្រជាជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដោយផ្តល់អាទិភាពជូនដល់គ្រួសារក្រីក្រកម្រិត១និងកម្រិត២គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងគ្រួសារដែលគ្មានដីធ្លី ។

៩៥ កម្មវិធីសំណង់សាធារណៈមួយដែលអនុវត្តក្នុងរយៈពេលវែង នឹងមានថ្លៃចំណាយខ្ពស់ដែលថ្លៃចំណាយទាំងនោះ មិនទាក់ទងទៅនឹងប្រាក់កម្រៃ ដើម្បីធានានិរន្តរភាពនៃទ្រព្យសម្បត្តិរូបវន្ត និងទ្រព្យសម្បត្តិសង្គម ដែលបានបង្កើតឡើង ព្រមទាំងទាមទារឱ្យមានប្រព័ន្ធថែទាំតាមសហគមន៍ ទៅលើហេដ្ឋារចនាសម្ព័ន្ធដែលបានបង្កើតឡើង។

៩៦ កម្មវិធីបង្កើតទ្រព្យធន និងឧបត្ថម្ភជីវភាពរស់នៅដល់សហគមន៍ (PALS) ត្រូវបានរៀបចំឡើង និងផ្សព្វផ្សាយនៅក្នុងឆ្នាំ២០១៣ ដោយអង្គការស្បៀងអាហារពិភពលោក ហើយកម្មវិធីសំណង់សាធារណៈមួយនៅកម្រិតថ្នាក់ជាតិ អាចធ្វើការពង្រឹងបន្ថែមដោយផ្អែកលើបទពិសោធន៍ទទួលបានពីកម្មវិធីនេះ។

ឥឡូវនេះ មូលនិធិសមធម៌សុខភាពកំពុងស្ថិតនៅលើមាគ៌ា សំដៅឆ្ពោះទៅសម្រេចឱ្យបាននូវការគ្របដណ្តប់ទូទាំងប្រទេស[៩៧]។ បើទោះ ជាដូច្នេះក្តី រាជរដ្ឋាភិបាលនៅតែត្រូវការសម្រួលកញ្ចប់តាវកលិក (រាប់បញ្ចូលថ្លៃចំណាយសម្រាប់ការដឹកជញ្ជូននៅពេលមានគ្រោះអាសន្ន។ល។) និងធានាថាមូលនិធិសមធម៌សុខភាពគ្របដណ្តប់បានពេញលេញ ចំពោះសេវាដែលទាក់ទងទៅនឹងអាហារូបត្ថម្ភកុមារ និងមាតា។

**សំណាញ់សុវត្ថិភាពដែលមានមូលដ្ឋានផ្អែកលើសាច់ប្រាក់ និងស្បៀង សម្រាប់គ្រួសារ និងក្រុមជួបប្រទះបញ្ហាអសន្តិសុខស្បៀង** ដែលពុំមានលទ្ធភាពក្នុងការធ្វើការងារត្រូវបានអនុវត្តជាច្រើនឆ្នាំមកហើយ ដើម្បីធានាស្ថេរភាពនៃការទទួលបានស្បៀងអាហាររបស់ពួកគេ និងលើកកម្ពស់អាហារូបត្ថម្ភ (កម្មវិធីផ្តល់អាហារនៅតាមសាលារៀននិងអាហារដែលបញ្ចូលមីក្រូសារជាតិសម្រាប់យកមកផ្ទះ ការចែកស្បៀងដែលបញ្ចូលមីក្រូសារជាតិដោយឥតគិតថ្លៃ ឬ ក្នុងតម្លៃឧបត្ថម្ភធន ការចែកស្បៀងអាហារបន្ថែមជូនដល់កុមារតូច និងស្ត្រីមានផ្ទៃពោះ ព្រមទាំងម្តាយកំពុងបំបៅដោះកូន និងក្រុមងាយរងគ្រោះជាក់លាក់មួយចំនួន)។ អាស្រ័យដោយវត្តមាននៃវិបត្តិតម្លៃស្បៀងអាហារលើកចុងក្រោយ កម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ (CCT) ត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅក្នុងស្រុកចំនួន២ ដើម្បីលើកកម្ពស់ការទទួលទានស្បៀងអាហារ សម្រាប់គ្រួសារក្រីក្រដែលមានកូនតូច ស្ត្រីមានផ្ទៃពោះ និងម្តាយកំពុងបំបៅដោះកូន ព្រមទាំងសម្រួលដល់តម្រូវការសេវាអាហារូបត្ថម្ភ។ បន្ថែមពីនេះទៀត ធាតុចូលកសិកម្មឥតគិតថ្លៃ ឬ ក្នុងតម្លៃឧបត្ថម្ភធន ត្រូវបានផ្តល់ជូនទៅឱ្យគ្រួសារកសិករខ្នាតតូចដែលក្រីក្រតាមរយៈកម្មវិធីផ្សេងៗគ្នា ដើម្បីជួយដល់ពួកគេក្នុងការលើកកម្ពស់ផលិតកម្មស្បៀងអាហារនៅពេលមានវិបត្តិសេដ្ឋកិច្ច ឬ វិបត្តិអាកាសធាតុ។

សកម្មភាពជាច្រើនដែលត្រូវបានគូសបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា** ផ្តល់ការលើកកម្ពស់ដោយផ្ទាល់ ចំពោះស្ថេរភាពនៃការទទួលបានស្បៀងអាហារ និងភាពធន់ទ្រាំនៃគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដើម្បីឱ្យពួកគេអាចធ្វើការដោះស្រាយបានកាន់តែប្រសើរចំពោះហានិភ័យនិងវិបត្តិនានា។លើកលែងតែករណីមួយចំនួនតូចប៉ុណ្ណោះ បច្ចុប្បន្ន សំណាញ់សុវត្ថិភាពផ្អែកសន្តិសុខស្បៀងភាគច្រើនមានលក្ខណៈបណ្តោះអាសន្ន ឬជាអន្តរាគមន៍មានមូលដ្ឋានផ្អែកលើគម្រោង ដែលត្រូវអភិវឌ្ឍន៍ឱ្យក្លាយទៅជាកម្មវិធីរយៈពេលវែងរបស់រដ្ឋាភិបាលទាំងស្រុង និងពង្រីកបន្ថែម ដើម្បីគ្របដណ្តប់ឱ្យបានទូលំទូលាយ។ **យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា** គូសបញ្ជាក់អំពីមាគ៌ាមួយ ដើម្បីធ្វើសមាហរណកម្មឱ្យបានកាន់តែប្រសើរចំពោះការអភិវឌ្ឍន៍ និងការអនុវត្តន៍កម្មវិធីសំណាញ់សុវត្ថិភាពសង្គមនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងលើកកម្ពស់ភាពជា

---

[៩៧] គិតត្រឹមខែសីហា ឆ្នាំ២០១១ មានស្រុកប្រតិបត្តិ (ODs) ចំនួន ៥៨ ដែលស្ថិតក្រោមការគ្របដណ្តប់របស់មូលនិធិសមធម៌សុខភាព ដោយមានតែស្រុកប្រតិបត្តិចំនួន១៩ប៉ុណ្ណោះ ដែលពុំមានមូលនិធិសមធម៌សុខភាព ហើយមានប្រជាជនក្រីក្រប្រមាណ ៧៩% ត្រូវបានគ្របដណ្តប់ដោយមូលនិធិសមធម៌សុខភាព។ ការពង្រីកឱ្យបានទូទាំងប្រទេស និងសមាហរណកម្មនៃគម្រោងមូលនិធិសមធម៌សុខភាពដែលមានស្រាប់ សម្រាប់ជនក្រីក្រ គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយគិតត្រឹមឆ្នាំ ២០១៥ រាជរដ្ឋាភិបាលគួរអាចសម្រេចបាននូវការគ្របដណ្តប់ទូទាំងប្រទេសនៃមូលនិធិសមធម៌សុខភាព (សូមមើល ៖ ផែនការពង្រីក និងទិសដៅនិរន្តរភាពនៅពេលអនាគត សម្រាប់ការគ្របដណ្តប់ទូទាំងប្រទេសនៃ SHPសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០១១ របស់ក្រសួងសុខាភិបាល)។

ម្ចាស់របស់រដ្ឋាភិបាល[៩៨]។ ការទាញប្រយោជន៍ពីការរួមកម្លាំងគ្នា រវាងកម្មវិធីសំណាញ់សុវត្ថិភាពសង្គម និងការភ្ជាប់ទំនាក់ទំនងកម្មវិធីទាំងនេះ ទៅនឹងអន្តរាគមន៍វិស័យបំពេញបន្ថែម មានសារៈសំខាន់ខ្លាំងណាស់។ អន្តរាគមន៍ ដែលត្រូវពង្រីកបន្ថែម ក្រោមគោលបំណងទី៣ នៃ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ**មានលក្ខណៈស្របគ្នាទៅនឹងអន្តរាគមន៍ និងកម្មវិធីដែលបានគូសបញ្ជាក់រួចទៅហើយនៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម។ ការសម្របសម្រួលជិតស្និទ្ធរវាង **យុទ្ធសាស្ត្រជាតិគាំពារសង្គម** និង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ទាក់ទងទៅនឹងការអភិវឌ្ឍន៍កម្មវិធី (និងការរៀបចំស្ថាប័នសម្រាប់អនុវត្ត) មានសារៈសំខាន់ ក្នុងការធ្វើឱ្យការរួមគ្នារវាងយុទ្ធសាស្ត្រទាំងពីរដែលមានលក្ខណៈប្រទាក់ក្រឡាគ្នានេះ មានភាពប្រសើរបំផុត។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី១ នៃគោលបំណងទី៣ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ ការពង្រីកសំណាញ់សុវត្ថិភាពសង្គមលើផ្នែកសន្តិសុខស្បៀង រួមមាន ៖**

១.១ អនុវត្តសាកល្បង និងពង្រីកកម្មវិធីសំណង់សាធារណៈមួយនៅកម្រិតថ្នាក់ជាតិ (ដូចមានគូសបញ្ជាក់នៅក្នុងNSPS) ដើម្បីលើកកម្ពស់ឱកាសការងារដែលអាចព្យាករណ៍ទុកជាមុនបាន សម្រាប់ជនក្រីក្រនៅក្នុងតំបន់ និងឃុំដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ជាពិសេស នៅរដូវដែលពុំមានភាពមមាញឹកនៅក្នុងវិស័យកសិកម្ម។

១.២ រៀបចំផែនការយថាភាព ដើម្បីពង្រីកការងារពលកម្មក្នុងអំឡុងពេលមានវិបត្តិ (ភ្ជាប់ទៅនឹងការត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ព្រមទាំងផែនការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

១.៣ អនុវត្ត និងពង្រីកការអនុវត្តន៍សាកល្បងកម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ (ដូចមានគូសបញ្ជាក់នៅក្នុងNSPS)ដើម្បីធ្វើឱ្យការទទួលបានស្បៀងអាហាររបស់គ្រួសារក្រីក្រ មានភាពរលូន និងលើកកម្ពស់អាហារូបត្ថម្ភកុមារ និងមាតា។

១.៤ បន្ត និងពង្រីក ការផ្តល់អាហារនៅតាមសាលារៀន នៅក្នុងតំបន់ក្រីក្រនិងអសន្តិសុខស្បៀង និងផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រ។

១.៥ ធានាឱ្យមានការសម្របសម្រួលជិតដល់ និង សមាហរណកម្មកម្មវិធីសំណាញ់សុវត្ថិភាពសង្គម ដែលផ្តោតគោលដៅទៅលើគ្រួសារ និងកម្មវិធីអសន្តិសុខស្បៀង (រវាងវិស័យយុទ្ធសាស្ត្រ និងផែនការអន្តរវិស័យនានា នៅកម្រិតថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន) ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពក្នុងមូលដ្ឋាន។

### ៦.៣.២. ធ្វើឱ្យប្រសើរឡើងនូវភាពបន្សាំរបស់គ្រួសារទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានគ្រោះមហន្តរាយដែលបណ្តាលមកពីកត្តាអាកាសធាតុធំៗចំនួន២ បានវាយប្រហារ ជាពិសេសទៅលើជនក្រីក្រ និងជនងាយរងគ្រោះក្នុងនោះ រួមមានព្យុះ

[៩៨] តាមរយៈការលើកកម្ពស់ការសម្របសម្រួលក្នុងចំណោមក្រសួងទទួលបន្ទុកការងារអនុវត្ត និងការធ្វើសមាហរណកម្មកាន់តែប្រសើរជាងមុនចំពោះការអភិវឌ្ឍន៍ និងការអនុវត្តន៍សំណាញ់សុវត្ថិភាពនៅថ្នាក់ក្រោមជាតិ។ នៅក្នុងបរិបទនេះ "ការអនុវត្តន៍សាកល្បងទៅលើសមាហរណកម្មកិច្ចគាំពារសង្គមសម្រាប់សន្តិសុខស្បៀង" (ISPP) ត្រូវបានផ្តួចផ្តើមធ្វើឡើងនាពេលថ្មីៗនេះនៅក្នុងស្រុកចំនួន២ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍។ការកសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់នៅកម្រិតថ្នាក់ស្រុក និងថ្នាក់ឃុំ មានសារៈសំខាន់ខ្លាំងណាស់នៅក្នុងបរិបទនេះ។

កេតសាណា ដែលបានកើតឡើង ក្នុងខែកញ្ញា ឆ្នាំ២០០៩ និងទឹកជំនន់ ក្នុងខែកញ្ញានិងតុលា ឆ្នាំ២០១១ ដោយបានបង្កផលប៉ះពាល់ទៅលើគ្រួសារ ចំនួន ៣៣១.៧៦៥គ្រួសារ (មនុស្សជាង ១,៥លាននាក់) នៅក្នុងខេត្តចំនួន១៨ ក្នុងចំណោមខេត្តចំនួន២៤ ក្នុងប្រទេសកម្ពុជា ព្រមទាំងបាន បំផ្លាញផលស្រូវសរុបប្រមាណ ៩,៤%។ នៅឆ្នាំ២០១៣ ទឹកជំនន់បានប៉ះពាល់ដល់ប្រជាជនចំនួន ៣៧៧,៣៥៤គ្រួសារនៅក្នុង២១ខេត្តនិងបានបំផ្លាញប្រហែល៥ភាគរយនៃផ្ទៃដីដាំដុះស្រូវរដូវវស្សា។ ការប៉ាន់ប្រមាណពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ដោយសារទឹកជំនន់នេះ មានចំនួនប្រមាណ ១% នៃ GDP។ បន្ថែមពីលើទឹកជំនន់នេះ ទឹកភ្លៀង ខុសប្រក្រតី និងការអូសបន្លាយនៃភាពរាំងស្ងួតនៅក្នុង តំបន់មួយចំនួន បានបង្កឱ្យមានផលប៉ះពាល់ទៅលើផលិតកម្មកសិកម្មដំណាំស្រូវ ដែលពឹងផ្អែកទៅ លើទឹកភ្លៀង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ [៩៩]។

បើទោះបីជាទឹកជំនន់នាពេលថ្មីៗនេះ មានភាពធ្ងន់ធ្ងរក៏ដោយ ការប្រឈមជារួមរបស់ ប្រទេសកម្ពុជា ទៅនឹងគ្រោះមហន្តរាយធម្មជាតិ នៅមានកម្រិតមធ្យមនៅឡើយ បើធៀបទៅនឹង ប្រទេសដទៃទៀតនៅក្នុងតំបន់។ បើទោះជាដូច្នេះក្តី សមត្ថភាពរបស់ប្រជាជន និងស្ថាប័នក្នុងការ ដោះស្រាយទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ និងការសម្របខ្លួនទៅនឹងឥទ្ធិពលនៃការប្រែប្រួល អាកាសធាតុនៅមានកម្រិតទាប [១០០] ដូច្នេះប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដែលងាយ រងគ្រោះបំផុតនៅក្នុងតំបន់ [១០១]។

**រូបភាពទី៣៤ ៖ តំបន់ស្រូវវស្សា ដែលបំផ្លាញដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ២០០១-២០១១**




ប្រភព ៖ MAFF

99 គ្រោះរាំងស្ងួតមិនបណ្តាលឱ្យមនុស្សស្លាប់ឡើយ ប៉ុន្តែវាមានសក្តានុពលក្នុងការបង្កផលប៉ះពាល់ទៅលើមនុស្សមួយចំនួនធំ និងរមែងតែងមានផលប៉ះពាល់អវិជ្ជមានរយៈពេលវែងទៅលើជីវភាពរស់នៅរបស់ជនក្រីក្រជាងគ្រោះទឹកជំនន់។ ទឹកជំនន់ក៏មានផលប៉ះពាល់វិជ្ជមានទៅលើជីវភាពរស់នៅដែលផ្អែកលើកសិកម្មផងដែរ (ការកើនឡើងនៃសំណើមដី/ជីជាតិ ប្រយោជន៍ផ្នែកអេកូឡូស៊ីសម្រាប់វិស័យជលផល)។

100 ភាពងាយរងគ្រោះខ្ពស់របស់ប្រទេសកម្ពុជា ទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ មិនសូវបណ្តាលមកពីការប្រឈមខ្ពស់ឡើយ ប៉ុន្តែភាគច្រើនគឺបណ្តាលមកពីភាពរសើបដែលមានកម្រិតខ្ពស់ (ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ) និង សមត្ថភាពបន្សាំនៅមានកម្រិត៖ សេដ្ឋកិច្ចរបស់កម្ពុជាមិនសូវមានភាពចម្រុះឡើយ ប្រជាជនភាគច្រើនរស់នៅតំបន់ជនបទ និងពឹងអាស្រ័យយ៉ាងខ្លាំងទៅលើការធ្វើស្រែដោយទឹកភ្លៀង ហើយមនុស្សជាច្រើនពឹងផ្អែកទៅលើធនធានទ្រព្យសម្បត្តិរួមដែលមានការថយចុះដោយសារតែការប្រើប្រាស់គ្មាននិរន្តរភាព។ ភាពក្រីក្រនៅតែមានភាពទូលំទូលាយ ហើយការអប់រំនៅមានកម្រិតទាប និងសំណាញ់សុវត្ថិភាពសង្គម នៅមានចន្លោះប្រហោងនៅឡើយ។

101 សូមមើលមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) កម្មវិធីសេដ្ឋកិច្ច និងបរិស្ថានសម្រាប់អាស៊ីអាគ្នេយ៍ (EEPSEA) ឆ្នាំ២០០៩ ការកំណត់ផែនទីអំពីភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់តំបន់អាស៊ីអាគ្នេយ៍។

ការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យកំដៅមានការកើនឡើងប៉ះពាល់ទៅលើគំរូរបបទឹកភ្លៀងក្នុងប្រទេសកម្ពុជា និងនាំឱ្យមានការធ្លាក់ចុះជាបន្តបន្ទាប់នូវផលិតភាពកសិកម្ម ទិន្នផលត្រី ព្រមទាំងមានការកើនឡើងនូវជំងឺដែលបណ្តាលមកពីទឹកជំនន់។ បន្ថែមពីនេះទៀត ភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃគ្រោះរាំងស្ងួតនិងទឹកជំនន់[១០២] ទំនងនឹងមានការកើនឡើងផងដែរ។ គ្រោះមហន្តរាយធម្មជាតិទាំងពីរនេះ នឹង បណ្តាលឱ្យមានផលប៉ះពាល់ជាក់លាក់ទៅលើគ្រួសារក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ព្រមទាំងអាចធ្វើឱ្យចំនួនគ្រួសារក្រីក្រ និងគ្រួសារដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង មានការកើនឡើងជាបន្តបន្ទាប់ ព្រោះការដាំដំណាំជួបបញ្ហាគ្រោះរាំងស្ងួត និងទឹកជំនន់ តម្រូវឱ្យមានយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាបែបអវិជ្ជមានទាំងនេះ។

ដូច្នេះ ការប្រែប្រួលអាកាសធាតុ គឺជាកត្តារយៈពេលវែងមួយដែលបណ្តាលឱ្យមានអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា[១០៣] ហើយដូចគ្នានេះដែរ អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភក្នុងកម្រិតមួយខ្ពស់ ធ្វើឱ្យប្រទេសកាន់តែងាយរងគ្រោះទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ សកម្មភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងសន្តិសុខស្បៀងគ្រួសារប្រកបដោយនិរន្តរភាព ដូចមានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រនេះ(ក្រោមគោលបំណងទី១)មានលក្ខណៈដូចគ្នាក្នុងកម្រិតមួយជាក់លាក់។ យុទ្ធសាស្ត្របន្សាំ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសន្តិសុខស្បៀង ព្រមទាំងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ រួមមាន៖ វិធានការនៅក្នុងវិស័យកសិកម្ម (ការពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធប្រមូល និងរក្សាទឹក ការទទួលបានប្រភេទពូជកសិផល និងបច្ចេកទេសដាំដុះ ដែលធន់ទៅនឹងអាកាសធាតុ ប្រព័ន្ធធ្វើកសិកម្ម និងទ្រទ្រង់ជីវភាពរស់នៅដែលមានភាពចម្រុះជាងមុន) វិស័យសុខាភិបាល (ពង្រឹងការត្រួតពិនិត្យទៅលើជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម និងលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានទឹកសុវត្ថិភាព និងអនាម័យ) អន្តរាគមន៍គាំពារសង្គម (ការធានារ៉ាប់រងទៅលើកសិផល[១០៤] ការកំណត់ទិសដៅកម្មវិធីសំណង់សាធារណៈ សំដៅឆ្ពោះទៅរកសកម្មភាពដែលពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជា៖ ការដាំដុះព្រៃឈើឡើងវិញ និងប្រព័ន្ធធារាសាស្ត្រ) ព្រមទាំងការលើកកម្ពស់ការគ្រប់គ្រងធនធានជលផល និងព្រៃឈើតាមសហគមន៍ប្រកបដោយនិរន្តរភាព។

---

102 ការប្រែប្រួលអាកាសធាតុ ទំនងនឹងនាំឱ្យមានគ្រោះរាំងស្ងួតកាន់តែញឹកញាប់ជាងមុន/រដូវប្រាំងកាន់តែអូសបន្លាយ រដូវវស្សាមាន ភាពយឺតយ៉ាវ ជាមួយនឹងការទទួលបានទឹកភ្លៀងយ៉ាងគំហុក និងទឹកជំនន់ ហើយលំហូរទឹកទន្លេនៅរដូវប្រាំងមានការធ្លាក់ចុះ និង លំហូរទឹកទន្លេនៅរដូវវស្សាមានការកើនឡើង។

103 គំរូនៃសន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់អាស៊ីអាគ្នេយ៍ដែលធ្វើឡើងដោយ IFPRI បាននាំឱ្យមានសេចក្តី សន្និដ្ឋានថាការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យមានការធ្លាក់ចុះនូវការមានស្បៀងអាហារ និងធ្វើឱ្យមានការកើនឡើងនូវកង្វះអាហា រូបត្ថម្ភកុមារ។ សូមមើល CRI/CARD/IFPRIសន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុរហូតដល់ឆ្នាំ២០៥០ ៖ ប្រទេសកម្ពុជា - ឯកសារ ពិភាក្សាអំពីគោលនយោបាយ ខែមីនា ឆ្នាំ២០១១។

104 ក្រៅពីសំណាញ់សុវត្ថិភាពសង្គម ដូចជាការផ្ទេរស្បៀង និងការផ្ទេរសាច់ប្រាក់ និងឧបត្ថម្ភធនធាតុចូលកសិកម្ម ដែលផ្តល់ជូនដោយវិស័យឯកជន(និងសន្ទស្សន៍អាកាសធាតុ)គម្រោងធានារ៉ាប់រងទៅលើបរាជ័យនៃការប្រមូលផលឬការខាតបង់សត្វពាហនៈ អាចដើរតួនាទីឱ្យបានកាន់តែច្រើនជាងនេះទៀតនៅក្នុងប្រទេសកម្ពុជា ដើម្បីទប់ទល់ទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយដែលបណ្តាល មកពីអាកាសធាតុ។

ក្រៅពីគ្រោះធម្មជាតិ ស្ថេរភាពនៃលទ្ធភាពរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងការទទួលបានស្បៀងអាហារ បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីឥទ្ធិពលនៃវិបត្តិតម្លៃស្បៀងអាហារ និងវិបត្តិសេដ្ឋកិច្ចសកលលោក ក្នុងឆ្នាំ២០០៨ និងឆ្នាំ២០០៩ ដែលនាំឱ្យមានការបាត់បង់ការងារ និងប្រាក់ចំណូលក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ គ្រោះមហន្តរាយទាំងពីរនេះ បានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើលទ្ធភាពរបស់គ្រួសារក្រីក្រក្នុងការទិញស្បៀងអាហារ និងប៉ះពាល់ដល់អាហាររូបត្ថម្ភ សុខភាព និងការអប់រំរបស់កុមារ (សូមមើលជំពូកទី២)។ វិធានការ គោលនយោបាយរយៈពេលខ្លី និងរយៈពេលមធ្យមប្រកបដោយប្រសិទ្ធភាព ត្រូវបានយកមកអនុវត្តក្នុងលក្ខណៈជាការឆ្លើយតបមួយ ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំយុទ្ធសាស្ត្ររយៈពេលវែង (NSPS) ព្រមទាំងបានផ្តួចផ្តើមយន្តការសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការត្រៀមលក្ខណៈទប់ទល់ និង ឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ ក្នុងចំណោមសកម្មភាពដទៃទៀត ប្រព័ន្ធស្បៀងបម្រុងជាតិមួយ កំពុងត្រូវបានកសាងនៅក្នុងប្រទេសកម្ពុជា។ ការរក្សាទុកជារូបវន្តនូវស្បៀង (និងគ្រាប់ពូជ) នឹងគ្របដណ្តប់ទៅលើសេចក្តីត្រូវការបឋមក្រោយពេលគ្រោះអាសន្ន ហើយនឹងមានការបំពេញបន្ថែមពីថវិកាបម្រុង (សាច់ប្រាក់) ដើម្បីធ្វើឱ្យថ្លៃចំណាយប្រតិបត្តិការមានកម្រិតទាប[១០៥]។ អនុក្រឹត្យមួយ ដែលគូសបញ្ជាក់អំពីតួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័ននានា ដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងស្បៀងបម្រុង (គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិរបស់គណៈកម្មាធិការនេះ ក្រុមហ៊ុន Green trade, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ , កាកបាទក្រហមកម្ពុជា វិស័យឯកជន និង ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ)។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានអាណត្តិការងារទទួលខុសត្រូវចំពោះការត្រៀមលក្ខណៈទប់ទល់ និងឆ្លើយតបទៅនឹងគ្រោះអាសន្ន ក្នុងករណីមានគ្រោះមហន្តរាយធម្មជាតិ។ កាកបាទក្រហមកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន និងអង្គការសហប្រជាជាតិ ផ្តល់ជំនួយភ្លាមៗ ក្នុងស្ថានភាពគ្រោះអាសន្ន (ការចែកស្បៀង ការផ្តល់ទីជម្រក សម្លៀកបំពាក់ និងឱសថ) ដោយឡែក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានកិច្ចគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីចែកធាតុចូលកសិកម្មនៅពេលដែលមានភាពធូរស្រាលឡើងវិញ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ (គណៈកម្មាធិការ ខេត្ត ស្រុក និងជាពិសេស គឺគណៈកម្មាធិការឃុំគ្រប់គ្រងគ្រោះមហន្តរាយ) ត្រូវការឱ្យមានកិច្ចគាំទ្រ និងការកសាងសមត្ថភាព ដើម្បីបំពេញមុខងាររបស់ពួកគេឱ្យមានប្រសិទ្ធភាព។ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយមានសារៈសំខាន់ក្នុងការបន្ថយផលប៉ះពាល់នៃគ្រោះធម្មជាតិ ហើយផែនការយុទ្ធសាស្ត្រមួយ ស្តីពីការកាត់បន្ថយ

[១០៥] នៅក្នុងគម្រោង EFAP រាជរដ្ឋាភិបាលបានស្នើឱ្យរៀបចំស្បៀងបម្រុងមួយ ដែលស្មើនឹងអង្ករចំនួន ១៦.០០០ តោន ដែលអាចគ្របដណ្តប់ ទៅលើសេចក្តីត្រូវការស្បៀងអាហារបានពេញលេញសម្រាប់ប្រជាជនចំនួន ១០% ក្នុងរយៈពេលមួយខែ។ រាជរដ្ឋាភិបាលគ្រោងរក្សាស្បៀង បម្រុងជាលក្ខណៈរូបវន្តចំនួន ១០.០០០ តោន (៧.០០០ តោន រក្សាដោយក្រុមហ៊ុន Green tradeនិង ៣.០០០ តោនទៀត រក្សាដោយឈ្មួញ ឯកជន) និងប្រាក់បម្រុងសម្រាប់ទិញអង្ករចំនួន ៦.០០០ តោន ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គួរមានគ្រាប់ពូជ ស្រូវចំនួន ១.១០០ តោន និងគ្រាប់ពូជបន្លែ ព្រមទាំងគ្រាប់ពូជសម្រាប់កសិផលដទៃទៀត ចំនួន ៥០ តោន សម្រាប់បំពេញបន្ថែមទៅលើ អង្ករបម្រុង។

ហានិភ័យនៃគ្រោះមហន្តរាយ ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួងផែនការ ក្នុងឆ្នាំ២០០៨ ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ព្រមទាំងបញ្ចូលទស្សនៈ វិស័យអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងគោលនយោបាយ និងផែនការដទៃទៀត។ កិច្ចខិតខំក្នុងការភ្ជាប់ការត្រៀមលក្ខណៈទប់ទល់ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅនឹងការផ្តួចផ្តើម និងការធ្វើផែនការអភិវឌ្ឍន៍រយៈពេលវែង ព្រមទាំងការលើកកម្ពស់ការសម្របសម្រួលរវាងបណ្តាអ្នកពាក់ព័ន្ធទាំងអស់ មានសារៈសំខាន់ក្នុងការធ្វើឱ្យមានវឌ្ឍនភាពចំពោះការត្រៀមលក្ខណៈទប់ទល់ និងកាត់បន្ថយគ្រោះមហន្តរាយ។

រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តទាំងស្រុងចំពោះកិច្ចខិតខំសកល ក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនិងបានរៀបចំកម្មវិធីជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ព្រមទាំងបង្កើតគណៈកម្មាធិការជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NCCC)។ បច្ចុប្បន្នក្រសួងបរិស្ថានកំពុងដឹកនាំការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCSP) ដែលផែនការនេះ នឹងកំណត់អំពីមាគ៌ាសម្រាប់ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទូទាំងគ្រប់វិស័យពាក់ព័ន្ធទាំងអស់។

ព័ត៌មានគួរឱ្យជឿជាក់បាន (ការផ្តល់ដំណឹងជាមុន) អំពីហានិភ័យដែលនឹងកើតមានចំពោះលទ្ធភាពក្នុងការទទួលបានស្បៀងអាហារ និងអាហារូបត្ថម្ភ ព្រមទាំងព័ត៌មានអំពីផលប៉ះពាល់នៃវិបត្តិអាកាសធាតុ វិបត្តិសេដ្ឋកិច្ច ឬ ការឆ្លងរាលដាលនៃជម្ងឺ សុទ្ធសឹងតែមានសារៈសំខាន់ សម្រាប់រៀបចំឱ្យមាននូវការឆ្លើយតបឱ្យបានគ្រប់គ្រាន់ទាន់ពេលវេលា។ដូចមានគូសបញ្ជាក់រួចមកហើយនៅក្នុងជំពូកទី៣ ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាព គួរឱ្យកត់សម្គាល់ ទាក់ទងទៅនឹងការគ្រប់គ្រងព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ បើទោះជាដូច្នេះក្តី រាជរដ្ឋាភិបាលគួរតែពង្រឹងសមត្ថភាពគ្រប់គ្រងលើប្រព័ន្ធ និងឧបករណ៍ដែលមានស្រាប់ ព្រមទាំងលើកកម្ពស់ភាពជាម្ចាស់ទៅលើប្រព័ន្ធ និងឧបករណ៍ទាំងនោះ។ រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានបែបផែនជាផ្លូវការចំពោះការប្រើប្រាស់ប្រព័ន្ធ និងឧបករណ៍ទាំងនោះសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត ក្នុងករណីមានគ្រោះមហន្តរាយនិងវិបត្តិនានា(សូមមើលជំពូកទី៧)។

**សកម្មភាពអាទិភាព ក្រោមអាទិភាពកម្មវិធីទី២ នៃគោលបំណងទី៣ របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺ ការធ្វើឱ្យប្រសើរឡើងនូវការត្រៀមលក្ខណៈទប់ទល់ និងកាត់បន្ថយគ្រោះមហន្តរាយ ព្រមទាំងលើកកម្ពស់ភាពធន់ទ្រាំរបស់គ្រួសារទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរួមមាន ៖**

២.១ អភិវឌ្ឍន៍សមត្ថភាពសម្រាប់ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និង ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបញ្ចូលបញ្ហាទាំងនេះទៅក្នុងយុទ្ធសាស្ត្រតាមវិស័យនិងផែនការតំបន់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុទៅលើសន្តិសុខស្បៀងរបស់គ្រួសារ[១០៦]។

២.២ ពង្រឹងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ទៅនឹងវិបត្តិស្បៀងអាហារ (ធានាឱ្យមាននូវការផ្គត់ផ្គង់ស្បៀង និងជំនួយដទៃទៀត[១០៧]) ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃការឆ្លើយតបចំពោះគ្រោះអាសន្ន រវាងក្រសួង-ស្ថាប័នពាក់ពន្ធ័ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា។

២.៣ លើកកំពស់ការធន់ទ្រាំរបស់សហគមន៍ ទៅនឹងគ្រោះមហន្តរាយ និងវិបត្តិសេដ្ឋកិច្ច ដោយពង្រីកគណនីសន្សំនិងឥណទានដោយមានការចូលរួមពីសហគមន៍(ធនាគារស្រូវ និងឥណទាន) ប្រព័ន្ធស្រោចស្រពខ្នាតតូចនិងគម្រោងបន្សាំការប្រែប្រួលអាកាសធាតុរបស់សហគមន៍។

២.៤ សម្រួល និងធ្វើសមាហរណកម្មព័ត៌មានដែលមានស្រាប់ ប្រព័ន្ធបែងចែកចំណាត់ថ្នាក់ និងឧបករណ៍ជូនដំណឹងជាមុនព្រមទាំងការប៉ាន់ប្រមាណទៅលើផលប៉ះពាល់នៃគ្រោះមហន្តរាយ។

២.៥ បង្កើននិងគ្រប់គ្រងឱ្យមានប្រសិទ្ធភាពស្បៀងបំរុងជាតិ(គ្រាប់ពូជ) ដើម្បីផ្តល់ស្បៀងនិងគ្រាប់ពូជទាន់ពេលវេលា ជូនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច និងការកើនឡើងតម្លៃស្បៀង។

២.៦ ថែរក្សា និងស្តារប្រឡាយ ទន្លេនិងបឹងធម្មជាតិ សម្រាប់កាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត។

[១០៦] កិច្ចខិតខំកសាងសមត្ថភាពនៅក្នុងន័យនេះ ត្រូវបានគូសបញ្ជាក់នៅក្នុង SNAP ហើយគេត្រូវធ្វើសមាហរណកម្មរវាង CCCSP និង NSFSN ។

[១០៧] កញ្ចប់ជំនួយគ្រប់ជ្រុងជ្រោយ រួមមានស្បៀងអាហារ ទឹក និងអនាម័យ ការផ្គត់ផ្គង់ឱសថ សម្លៀកបំពាក់ ទីជម្រក ដែលត្រូវបានផ្តល់ជូនក្នុងលក្ខណៈជាការផ្តល់ជំនួយសង្គ្រោះភ្លាមៗ ព្រមទាំងការផ្តល់ធាតុចូលកសិកម្មក្នុងអំឡុងពេលដែលមានធូរស្រាលឡើងវិញ។

## ៧. ការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា គឺជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនានា និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ**បន្ថែមតម្លៃតាមរយៈការផ្តល់នូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយដើម្បីជួយដល់បណ្តាក្រសួង-ស្ថាប័ននានា និងអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងអនុវត្តអន្តរាគមន៍អាទិភាព ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងលក្ខណៈមួយប្រកបដោយប្រសិទ្ធភាព និងមានភាពសក្តិសិទ្ធិ។ រចនាសម្ព័ន្ធ ប្រព័ន្ធ និងគោលគំនិតសម្រាប់ការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន ការកំណត់គោលដៅ និងការអភិវឌ្ឍន៍សមត្ថភាព សុទ្ធសឹងតែជាបញ្ហាដែលមានលក្ខណៈប្រទាក់ក្រឡាគ្នានៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានរួចទៅហើយ ក្នុងប្រទេសកម្ពុជា (សូមមើលជំពូកទី៣)។ ផ្អែកលើគំហើញដែលទទួលបានពីការត្រួតពិនិត្យឡើងវិញទៅលើក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជំពូកនេះគូសបញ្ជាក់អំពីគោលការណ៍ណែនាំ និងសកម្មភាពអាទិភាពដើម្បីធ្វើឱ្យប្រសើរឡើងនិងបន្តអភិវឌ្ឍន៍ការរៀបចំស្ថាប័នទាំងនេះទាក់ទងទៅនឹង ៖

- ការសម្របសម្រួល និងការឃ្លាំមើលទៅលើគោលនយោបាយសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការត្រួតពិនិត្យ និងវាយតម្លៃទៅលើយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ និងកម្មវិធីរបស់យុទ្ធសាស្ត្រនេះ។
- ការបង្កើតអង្គភាពទទួលបន្ទុកសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ,ក្រសួងសុខាភិបាល, ក្រសួងអភិវឌ្ឍន៍ជនបទ...។
- ការគ្រប់គ្រងចំណេះដឹង និងព័ត៌មាន ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ។
- ការជ្រើសរើសអ្នកទទួលផល និងការកំណត់គោលដៅអន្តរាគមន៍លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការកសាងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៧.១. ការសម្របសម្រួល និងការឃ្លាំមើលទៅលើគោលនយោបាយសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ការសម្របសម្រួល រួមមានការត្រួតពិនិត្យទៀងទាត់ និងការលើកកម្ពស់កិច្ចខិតខំប្រកបដោយសុខដុមនីយកម្ម រវាងកម្មវិធី និងអន្តរាគមន៍ផ្សេងៗគ្នា ដើម្បីជៀសវាងភាពត្រួតស៊ីគ្នានៅតាមតំបន់ភូមិសាស្ត្រនានា ឬ ចន្លោះប្រហោងនៅក្នុងការគ្របដណ្តប់អ្នកទទួលផល ការធ្វើសុខដុមនីយកម្មទៅលើនីតិវិធីកំណត់គោលដៅ និងនីតិវិធីអនុវត្ត ព្រមទាំងស្វែងរកការគាំទ្រសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងប្រើប្រាស់មូលនិធិឱ្យបានប្រសើរបំផុត។ ដូចមានគូសបញ្ជាក់នៅក្នុងជំពូកទី៣ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាភារកិច្ចមួយមានលក្ខណៈប្រទាក់ក្រឡាគ្នា និងទាមទារឱ្យមាន

ការសម្របសម្រួល និងកិច្ចសហការប្រកបដោយប្រសិទ្ធភាពពីស្ថាប័នរដ្ឋាភិបាលជាច្រើន ព្រមទាំងកិច្ចសន្ទនាសកម្មជាមួយអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ យោងតាមព្រះរាជក្រឹត្យ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានអាណត្តិការងារសម្រួលដល់ការសម្របសម្រួលឱ្យមានប្រសិទ្ធភាព សម្របសម្រួលសេចក្តីណែនាំគោលនយោបាយ ការត្រួតពិនិត្យ និងការគ្រប់គ្រងព័ត៌មាន ទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ អាណត្តិការងាររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ ក្នុងនាមជាអង្គភាពឃ្លាំមើលជារួមទៅលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងសិក្ខាសាលាជាតិ លើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលបានប្រារព្ធធ្វើឡើងក្នុងខែឧសភាឆ្នាំ២០១២។ ថ្មីៗនេះ អង្គភាពសម្របសម្រួលវិស័យគាំពារសង្គម ត្រូវបានបញ្ចូលជាមួយនឹងក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅជា**ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ក្រោមការដឹកនាំដោយប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បង្កើតចំណុចរួម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និងត្រួតពិនិត្យគោលនយោបាយ សម្រាប់បញ្ហាដ៏សំខាន់ និងមានលក្ខណៈប្រទាក់ក្រឡាយ៉ាងស្និតរមួតនៅកម្ពុជា។

<u>សកម្មភាពទី១</u>៖ ពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងនាមជាស្ថាប័ន ផ្តល់សេចក្តីណែនាំគោលនយោបាយ និងលើកកម្ពស់ការសម្របសម្រួល និងសមាហរណកម្មការងារដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងចំណោមក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងរៀបចំឱ្យមានកិច្ចប្រជុំជាទៀងទាត់កម្រិតខ្ពស់ ដែលមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសម្រេចចិត្តអំពីគោលការណ៍ណែនាំ សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងធានាថា៖ បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានយកមកធ្វើការឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) និងយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធ។បុគ្គលិកនៃនាយកដ្ឋានផែនការរបស់ក្រសួងពាក់ព័ន្ធ នឹងត្រូវបានតែងតាំងជាជនបង្គោលសម្រាប់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅកម្រិតប្រតិបត្តិ ហើយសមត្ថភាពរបស់ពួកគេក៏នឹងត្រូវបានពង្រឹងផងដែរ។ ការធ្វើការងារទៅលើបញ្ហាដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ក្រោមអាណត្តិការងាររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ (ឧទាហរណ៏. កិច្ចគាំពារសង្គម និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ) នឹងត្រូវបានធ្វើសមាហរណកម្មប្រសើរជាងនេះ ដើម្បីបង្កើតឱ្យមាននូវការរួមកម្លាំងគ្នា ព្រមទាំងប្រើប្រាស់ឱ្យអស់លទ្ធភាពចំពោះធនធានផ្ទាល់ខ្លួនតិចតួច ដែលមាននៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

**ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងផែនការជាសហប្រធាន ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៤ ដើម្បីជំរុញទៅលើកិច្ចសន្ទនាជាផ្លូវការ រវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ទៅលើប្រធាន

បទដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ព្រមទាំងធានាឱ្យមានការដាក់បញ្ចូល និងការធ្វើសុខដុមនីយកម្ម ចំពោះអន្តរាគមន៍នានា។ ក្រុមការងារបច្ចេកទេសជួបប្រជុំគ្នាជាទៀងទាត់ ហើយលេខាធិការដ្ឋានមួយនៃក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានបង្កើតឡើងនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីសម្របសម្រួលការងារនេះ។ យ៉ាងណាមិញ គម្រោង និងកម្មវិធីធំៗ កាលពីអតីតកាល រមែងតែងត្រូវបានរៀបចំឡើង ដោយរំលងក្រុមការងារបច្ចេកទេសនេះ។ ដើម្បីធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពទៅលើអន្តរាគមន៍ជាអាទិភាព ដែលមានគូសបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** រាជរដ្ឋាភិបាល ត្រូវធ្វើឱ្យរចនាសម្ព័ន្ធនេះ មានភាពរស់រវើកឡើងវិញ ពង្រឹង និងប្រើប្រាស់ឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងលក្ខណៈជាវេទិកាមួយសម្រាប់កិច្ចសន្ទនារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

<u>សកម្មភាពទី២</u> ៖ ពង្រឹងក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភដើម្បីសម្របសម្រួលគម្រោង និងកម្មវិធីឱ្យមានប្រសិទ្ធភាព ដោយផ្អែកលើអាទិភាពដែលត្រូវបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ទូទាំងវិស័យនានា និងលើកកម្ពស់ការធ្វើសុខដុមនីយកម្ម និងការតម្រឹមកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍន៍សម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា។

**ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** នឹងចូលរួមដើម្បីរៀបចំ និងសម្របសម្រួលសកម្មភាពអាទិភាព ដែលមានគូសបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** និង (ក្នុងករណីសមស្រប) អភិវឌ្ឍន៍នូវអភិក្រមដែលមានមូលដ្ឋានផ្អែកលើកម្មវិធី ព្រមទាំងផែនការសកម្មភាព និងផែនការវិនិយោគទូទាំងវិស័យនានា។ សកម្មភាពបែបនេះ នឹងពង្រឹងទៅលើការធ្វើសមាហរណកម្ម និងការធ្វើសុខដុមនីយកម្មនៃអន្តរាគមន៍នានា ព្រមទាំងកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការ (ឧទាហរណ៍សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ និង មាតា)។

ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវធានាឱ្យមានការចូលរួមទៀងទាត់នៅក្នុង**ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** តាមរយៈការចាត់តាំងតំណាងក្នុងកម្រិតឋានានុក្រមសមស្រប ដែលមានអាណត្តិការងារផ្តល់សេចក្តីរាយការណ៍ជាផ្លូវការអំពីសកម្មភាពតាមវិស័យ និង ពិនិត្យតាមដានទៅលើលទ្ធផលពិភាក្សារបស់ ក្រុមការងារបច្ចេកទេសនេះនៅក្នុងក្រសួង-ស្ថាប័នរបស់ពួកគេ។ លេខាធិការដ្ឋានរបស់**ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងត្រូវបានពង្រឹងដើម្បីសម្របសម្រួលការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ព្រមទាំងចូលរួមឱ្យបានសកម្មនៅក្នុងក្រុមការងារបច្ចេកទេសរបស់វិស័យពាក់ព័ន្ធ និងរចនាសម្ព័ន្ធសម្របសម្រួលដទៃទៀតដែលពាក់ព័ន្ធទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីធានាឱ្យមានការភ្ជាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព សម្រាប់អនុវត្ត **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ** និងបង្កើតឱ្យមាននូវការរួមកម្លាំងគ្នា។ នៅក្នុងបរិបទនេះ ការសម្របសម្រួលរបស់ **យុទ្ធសាស្ត្រជាតិ**

**ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** និង (ដែលយុទ្ធសាស្រ្តទាំង២នេះ មានលក្ខណៈប្រទាក់ក្រឡាគ្នា ក្រោមការឃ្លាំមើលជារួម របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ) នឹងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយរចនាសម្ព័ន្ធសម្របសម្រួលដែលមានស្រាប់ នឹងត្រូវបានធ្វើសមាហរណកម្មកាន់តែប្រសើរ ដើម្បីប្រើប្រាស់ធនធានមនុស្សដែលកំពុងខ្សត់ខ្សោយឱ្យមានប្រសិទ្ធភាព និង ជៀសវាងកិច្ចខិតខំត្រួតស៊ីគ្នា ។ ក្នុងការសម្របសម្រួលរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ការតាមដាននិងត្រួតពិនិត្យ និងការគ្រប់គ្រងព័ត៌មាន ទាក់ទងទៅនឹង **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** និង **យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះនៅកម្ពុជា** យុទ្ធសាស្រ្តប្រទាក់ក្រឡាទាំងពីរនេះ ស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងត្រូវបានផ្សារភ្ជាប់យ៉ាងស្អិតរមួត ដើម្បីការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព។

ការវាយតម្លៃរបស់ **ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នឹងត្រូវបានអនុវត្តនៅចុងឆ្នាំ ២០១៤ ដើម្បីពិនិត្យឡើងវិញនូវតួនាទីនិងមុខងាររបស់ **ក្រុមការងារបច្ចេកទេសគាំពារសង្គមសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** និង លេខាធិការដ្ឋានរបស់ខ្លួន និងដើម្បីបន្តលើកកម្ពស់ប្រសិទ្ធភាព ការសម្របសម្រួល អន្តរក្រសួង នៃក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងវិស័យគាំពារសង្គម និង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ក្នុងឆ្នាំ២០០១ ប្រទេសកម្ពុជា បានជ្រើសរើសមាគ៌ាវិមជ្ឈការ និងវិសហមជ្ឈការ ដោយមានការបោះឆ្នោតឃុំ/សង្កាត់លើកទី១ ក្នុងឆ្នាំ២០០២។ ដោយមានការអនុម័ត "ច្បាប់អង្គការ" [១០៨] ក្នុងឆ្នាំ ២០០៨ និងមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាថ្នាក់ខេត្ត និងថ្នាក់ស្រុក ក្នុងឆ្នាំ២០០៩ វិមជ្ឈការកាន់តែមានភាពរីកចម្រើនបន្ថែមទៀត។ នៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) សមត្ថភាពរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ កំពុងត្រូវបានធ្វើឱ្យមានភាពប្រសើរឡើង ដើម្បីឱ្យពួកគេអាចអនុវត្តតួនាទី ការទទួលខុសត្រូវ និងមុខងាររបស់ពួកគេប្រកបដោយប្រសិទ្ធភាព។ ដើម្បីអនុវត្ត **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ឱ្យបានជោគជ័យ ចាំបាច់ត្រូវមានការចូលរួមពីអាជ្ញាធរថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ។

<u>សកម្មភាពទី៣៖</u> ធានាឱ្យមានការសម្របសម្រួលកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រកបដោយប្រសិទ្ធភាព រវាងនាយកដ្ឋានរបស់ក្រសួង-ស្ថាប័ននានា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន នៅកម្រិតថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។ ក្រុមប្រឹក្សាឃុំ ត្រូវឃ្លាំមើលទៅលើការកំណត់គោលដៅ និងការអន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលជាអន្តរាគមន៍អាទិភាព នៅកម្រិតមូលដ្ឋាន។

[១០៨] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ផ្អែកលើបទពិសោធន៍កន្លងមកដែលទទួលបានពីគម្រោងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ[១០៩] រាជរដ្ឋាភិបាលនឹងរៀបចំឱ្យមាននីតិវិធី និងយន្តការ ដើម្បីបញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឱ្យបានកាន់តែគ្រប់ជ្រុងជ្រោយ ទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋាន និងពង្រឹងរចនាសម្ព័ន្ធ ដែលមានស្រាប់នៅកម្រិតថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ដើម្បីធ្វើការសម្របសម្រួលចំពោះបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ នៅកម្រិតថ្នាក់ខេត្ត គណៈកម្មាធិការសម្របសម្រួលថ្នាក់ខេត្ត នឹងទទួលបានការគាំទ្រ ដើម្បីបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ខេត្ត ព្រមទាំងឃ្លាំមើលទៅលើការអនុវត្តន៍អន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ នៅកម្រិតថ្នាក់ឃុំគណៈកម្មការឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ (គកនក) គឺជាជនបង្គោលសម្រាប់ការអនុវត្តន៍អន្តរាគមន៍សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលមានការចូលរួមពីសហគមន៍ ដូចជាកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍។

ដើម្បីលើកកម្ពស់និរន្តរភាពរយៈពេលវែង កម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភទ្រង់ទ្រាយធំនឹងមានការធ្វើសមាហរណកម្មសមាសធាតុមួយចំនួន ដើម្បីបង្កើនសមត្ថភាពក្នុងមូលដ្ឋាន ក្នុងការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងផែនការអភិវឌ្ឍន៍/វិនិយោគឃុំ (CDP/CIP)។ មូលនិធិក៏នឹងត្រូវបានវិភាជន៍ដោយផ្ទាល់ផងដែរ ជូនដល់ក្រុមប្រឹក្សាឃុំ (CC) សម្រាប់អនុវត្តអន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងមូលដ្ឋាន ដែលជាអន្តរាគមន៍អាទិភាព ដើម្បីធានាឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងជំរុញការលើកទឹកចិត្ត ឱ្យពិចារណាអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងដំណើរការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

កិច្ចគាំទ្រចំពោះវិស័យឯកជនក្នុងការផ្តល់ផលិតផល និងសេវាកម្មប្រកបដោយគុណភាពជូនដល់ខេត្ត ស្រុក និងឃុំ ដើម្បីអនុវត្តគម្រោងរបស់ពួកគេ ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសារៈសំខាន់ខ្លាំងណាស់[១១០]។ ការរៀបចំឱ្យមានភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន នឹងត្រូវបានលើកកម្ពស់ ដើម្បីជំរុញឱ្យមានការផ្តល់សេវាកម្មសមស្រប។

## ៧.២. ការត្រួតពិនិត្យ និងវាយតម្លៃទៅលើយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ការត្រួតពិនិត្យ និងវាយតម្លៃទៅលើ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** ដោយផ្អែកលើលទ្ធផល និងកម្មវិធីដែលអនុវត្ត ក្រោមឆ័ត្រនៃយុទ្ធសាស្ត្រនេះ គឺជាល័ក្ខខ័ណ្ឌតម្រូវ ដ៏សំខាន់ ដើម្បីឱ្យមានកិច្ចសន្ទនាប្រកបដោយប្រសិទ្ធភាពទៅលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា ព្រមទាំងដើម្បីឱ្យមានការអភិវឌ្ឍន៍បន្ថែមទៀតទៅលើ យុទ្ធសាស្ត្រនេះ។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ត្រូវតែអាចសម្របខ្លួនទៅនឹងបរិយាកាស និងសេចក្តីត្រូវការដែលកំពុងមានការប្រែប្រួល ក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីពិចារណាទៅលើមេរៀនបទពិសោធន៍ដែលទទួលបានក្នុងអំឡុងពេលនៃការអនុវត្តន៍។ ប្រព័ន្ធត្រួតពិនិត្យ និងវាយ

[១០៩] ចាប់តាំងពីឆ្នាំ២០០៦ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានអនុវត្តគម្រោងសាកល្បងមួយនៅក្នុងស្រុកជាច្រើន ដើម្បីលើកកម្ពស់ការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋាន និងដើម្បីអភិវឌ្ឍន៍ សមត្ថភាពសម្រាប់ការអនុវត្តន៍ភារកិច្ចនេះ នៅកម្រិតថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។

[១១០] ឧទាហរណ៍ វិស័យឯកជនអាចផ្តល់សេវាប្រឹក្សាយោបល់នៅនឹងកន្លែង ព្រមទាំងដើរតួនាទីនៅក្នុងការធ្វើទីផ្សារសង្គម។

តម្លៃមួយប្រកបដោយប្រសិទ្ធភាព សម្រាប់ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** រួមមាន ៖

(១). ក្របខ័ណ្ឌសូចនាកររួមមួយដែលផ្អែកលើលទ្ធផល
(២). នីតិវិធីសម្រាប់ការប្រមូល និងវិភាគទិន្នន័យ ដែលគូសបញ្ជាក់អំពីការទទួលខុសត្រូវរបស់ភាគីដែលពាក់ព័ន្ធ
(៣). យន្តការសម្រាប់រាយការណ៍អំពីវឌ្ឍនភាព និង សម្រាប់ប្រើប្រាស់ ភស្តុតាងដែលប្រមូលបាន ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងការកែសម្រួលទៅលើ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។

**ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ក្នុងនាមជាក្របខ័ណ្ឌឯកសារយោងមួយ សម្រាប់បញ្ហាបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា មានត្រឹមតែបញ្ជីរាយនាមសូចនាករត្រួតពិនិត្យ និងវាយតម្លៃមួយប៉ុណ្ណោះ ជាមួយនឹងកម្រងសូចនាករមួយនៅកម្រិត គោលដៅ និងគោលបំណង។ ពុំមាននីតិវិធីសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃណាមួយត្រូវបានគូសបញ្ជាក់ឡើយ ដោយឡែក មានតែរបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំមួយប៉ុណ្ណោះ ដែលត្រូវបានផលិតដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅចុងឆ្នាំ២០១០។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** ក្នុងលក្ខណៈជាយុទ្ធសាស្ត្រមួយ ដែលមានមូលដ្ឋានផ្អែកលើសកម្មភាព ទាមទារឱ្យមានការត្រួតពិនិត្យ និងវាយតម្លៃដិតដល់ ដើម្បីតាមដានទៅលើវឌ្ឍនភាព និងផ្តល់ព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។ គោលការណ៍សម្រាប់រៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ដែលមានមូលដ្ឋានផ្អែកលើលទ្ធផល ត្រូវបានគូសបញ្ជាក់នៅក្នុងជំពូកនេះ ហើយក្របខ័ណ្ឌ សូចនាករបឋមមួយមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១។ បើទោះជាដូច្នេះក្តី ចាំបាច់ត្រូវការឱ្យមានសកម្មភាពបន្ថែមទៀតនៅក្នុងរយៈពេលមួយឆ្នាំដំបូងនៃការអនុវត្តន៍**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ដើម្បីធ្វើការប្រចាប់បញ្ចូលគ្នានូវក្របខ័ណ្ឌសូចនាករ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ។

<u>សកម្មភាពទី៤៖</u> កែសម្រួលនិងធ្វើការច្របាច់បញ្ចូលគ្នានូវក្របខ័ណ្ឌសូចនាករយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភដោយផ្អែកលើកម្រងសូចនាករមួយ និងគោលដៅជាក់ស្តែងដែលស្របទៅនឹងយុទ្ធសាស្ត្រ និងផែនការតាមវិស័យពាក់ព័ន្ធដែលមានស្រាប់។

គោលការណ៍ខាងក្រោម នឹងត្រូវបានយកមកអនុវត្ត ក្នុងអំឡុងពេលនៃការត្រួតពិនិត្យឡើងវិញ និង ការច្របាច់បញ្ចូលគ្នានូវក្របខ័ណ្ឌសូចនាករ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ៖

- ធ្វើការតម្រឹមក្របខ័ណ្ឌសូចនាករយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភទាំងស្រុង ទៅនឹងសូចនាកររបស់ NSDP ២០១៤-២០១៨ ព្រមទាំងក្របខ័ណ្ឌសូចនាករពីយុទ្ធសាស្ត្រ និងផែនការជាតិដទៃទៀត។
- ធ្វើឱ្យប្រសើរឡើងនូវឋានានុក្រម និងសង្គតភាពសមស្របនៃក្របខ័ណ្ឌសូចនាករ និង ធានាថា

អាចធ្វើការផ្ទៀងផ្ទាត់ទៅលើគោលដៅជាប្រចាំ ដោយផ្អែកលើទិន្នន័យពីការអង្កេត និងទិន្នន័យរដ្ឋបាលដែលមាន។

- រៀបចំបង្កើតសូចនាករអន្តរការីមួយចំនួន ដើម្បីតាមដានទៅលើសមិទ្ធផល ទាក់ទងទៅនឹងសកម្មភាពអាទិភាពក្រោមគោលបំណងនីមួយៗរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ រាជរដ្ឋាភិបាលចាំបាច់ត្រូវការឱ្យមាននូវសូចនាករបែបនេះ ដើម្បីតាមដានទៅលើវឌ្ឍនភាពប្រចាំឆ្នាំ ក្នុងគោលបំណងអនុញ្ញាតឱ្យមានសកម្មភាពកែតម្រូវទាន់ពេលវេលា[១១១]។
- ការភ្ជាប់ទំនាក់ទំនងសូចនាករអន្តរការី ទៅនឹងសូចនាករលទ្ធផលកម្រិតខ្ពស់ តាមរយៈការបង្កើត "ខ្សែសង្វាក់នៃផលប៉ះពាល់" ដែលមានសង្គតភាពចាប់ពីធាតុចេញរហូតដល់លទ្ធផល ព្រមទាំងកម្រិតនៃផលប៉ះពាល់ ដើម្បីលើកកម្ពស់ការត្រួតពិនិត្យផ្អែកលើលទ្ធផល នៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ធ្វើការប្រេបាច់បញ្ចូលគ្នានូវសូចនាករអំពីដំណើរការ ដើម្បីពិនិត្យតាមដានទៅលើសមិទ្ធផលទាក់ទងទៅនឹងគោលនយោបាយនិងបរិយាកាសស្ថាប័ននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ឧទាហរណ៍. ការវាស់ស្ទង់ទៅលើវឌ្ឍនភាព ទាក់ទងទៅនឹងការរៀបចំស្ថាប័ន ដែលត្រូវបានគូសបញ្ជាក់នៅក្នុងជំពូកនេះ)។

<u>សកម្មភាពទី៥ ៖</u> បង្កើតនីតិវិធីត្រួតពិនិត្យ និងវាយតម្លៃ និងយន្តការផ្តល់របាយការណ៍សមស្រប ដើម្បីធានាឱ្យការអនុវត្តន៍យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រកបដោយប្រសិទ្ធភាព និងដើម្បីផ្តល់មតិយោបល់ត្រឡប់ផ្អែកលើភស្តុតាង ក្នុងគោលបំណងអភិវឌ្ឍន៍កម្មវិធី និងអន្តរាគមន៍បន្ថែមទៀត។

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីតួនាទី និងមុខងារសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃព្រមទាំងនីតិវិធីចំពោះវិធីប្រើប្រាស់ព័ត៌មានឱ្យបានប្រសើរបំផុត ដើម្បីសម្របសម្រួលឱ្យមានការកែតម្រូវយុទ្ធសាស្ត្រជាប្រចាំ។ ការរៀបចំខាងក្រោម នឹងត្រូវបានយកមកអនុវត្ត ដើម្បីអភិវឌ្ឍន៍ឱ្យមាននូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃមួយប្រកបដោយប្រសិទ្ធភាព ៖

- ការត្រួតពិនិត្យទៅលើអន្តរាគមន៍និងកម្មវិធីជាក់លាក់នឹងត្រូវធ្វើឡើងដោយទីភ្នាក់ងារអនុវត្ត (ក្រសួង)។ ទីភ្នាក់ងារទាំងនោះ នឹងធ្វើការពិនិត្យតាមដានទៅលើសកម្មភាព ធាតុចេញ និងលទ្ធផលនៅក្នុងវិស័យទទួលខុសត្រូវដោយឡែកពីគ្នារបស់ពួកគេ ដោយផ្អែកលើស្ថិតិរដ្ឋបាល ហើយពួកគេនឹងវាយការណ៍អំពីព័ត៌មាននេះ ជាទៀងទាត់ ជូនដល់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។
- តួនាទីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ គឺត្រូវធ្វើការពិនិត្យតាមដាន

[១១១] សម្រាប់សូចនាករដែលមានការបំបែកក្នុងកម្រិតមួយខ្ពស់ទៅតាមផលប៉ះពាល់ និងលទ្ធផលព័ត៌មានសម្រាប់សូចនាករទាំងនេះ រមែងតែងមានរៀងរាល់៥ឆ្នាំ ឬ ៩ឆ្នាំម្តង ហើយគេត្រូវតាមដានទៅលើដំណើរវឌ្ឍនភាពដោយប្រើប្រាស់សូចនាករ ដែលផ្តោតយកចិត្តទុកដាក់ទៅលើដំណើរការនៃការផ្តល់សេវា។

ជាមួយក្រសួងតាមវិស័យ ដើម្បីចងក្រង និងធ្វើសមាហរណកម្មរបាយការណ៍តាមវិស័យ ព្រមទាំងប៉ាន់ប្រមាណទៅលើផលប៉ះពាល់ជារួម ទៅលើគោលដៅ និងគោលបំណងរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងបង្កើតរបាយការណ៍ត្រួតពិនិត្យ និង វាយតម្លៃប្រចាំឆ្នាំមួយ សម្រាប់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីសង្ខេបអំពីវឌ្ឍនភាពដែលសម្រេចបាន។

- នៅក្នុងសិក្ខាសាលាបូកសរុបការងារប្រចាំឆ្នាំរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តាមរយៈលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ អ្នកពាក់ព័ន្ធទាំងអស់ពិភាក្សាអំពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ ដើម្បីកំណត់អំពីការកែសម្រួលនានាដែលចាំបាច់ ទៅលើការអនុវត្តន៍សកម្មភាពអាទិភាព និងអន្តរាគមន៍នៃយុទ្ធសាស្ត្រនេះ។ សេចក្តីសន្និដ្ឋាននឹងត្រូវបានផ្តល់ជូនទៅអ្នកបង្កើតគោលនយោបាយ អ្នកអនុវត្តនិងដៃគូអភិវឌ្ឍន៍នៅក្នុងក្របខ័ណ្ឌនៃដំណើរការវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ដើម្បីជះឥទ្ធិពលទៅលើការរៀបចំផែនការជាទូទៅសម្រាប់អន្តរាគមន៍នានា ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងការវិភាជន៍ធនធាននៅពេលអនាគត។
- ការត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឯករាជ្យមួយ ទៅលើយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងត្រូវបានធ្វើឡើងនៅចុងឆ្នាំ២០១៦ ដើម្បីគាំទ្រដល់កិច្ចសន្ទនាមួយដែលទទួលបានព័ត៌មានកាន់តែប្រសើរអំពីលទ្ធផលជារួម និងជំរុញឱ្យមានការអភិវឌ្ឍន៍បន្ថែមទៀតទៅលើយុទ្ធសាស្ត្រនេះ។
- ការអនុវត្តន៍កម្មវិធី នឹងត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើអភិក្រមត្រួតពិនិត្យ និងវាយតម្លៃបែបចូលរួម (ការពិគ្រោះយោបល់ជាមួយអ្នកទទួលផលអំពីការរៀបចំ និងលទ្ធផលដែលទទួលបានពីការអនុវត្តន៍កម្មវិធី) ហើយក្រុមប្រឹក្សាឃុំនឹងទទួលបានការគាំទ្រ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលត្រូវបានអនុវត្តនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/ផែនការវិនិយោគឃុំរបស់ពួកគេ។
- បន្ថែមពីនេះទៀត ការត្រួតពិនិត្យទៅលើដំណើរការហិរញ្ញវត្ថុ និងការវិភាគទៅលើថ្លៃចំណាយ និងផលចំណេញរបស់កម្មវិធី និងអន្តរាគមន៍ជាក់លាក់ នឹងត្រូវធ្វើឡើងដើម្បីគ្រប់គ្រងហានិភ័យនៃការសន្យាជានា ព្រមទាំងបង្កើនប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃអន្តរាគមន៍ឱ្យបានជាអតិបរមា។

ដើម្បីសម្របសម្រួលឱ្យមានឥទ្ធិពលទៅលើការរៀបចំផែនការពង្រីក និងការគ្របដណ្តប់នៃអន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលជាអន្តរាគមន៍អាទិភាព ដូចមានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងបង្កើតសារពើភ័ណ្ឌបច្ចុប្បន្នភាពមួយអំពីកម្មវិធីកំពុងដំណើរការដែលពាក់ព័ន្ធទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្តល់ព័ត៌មានមូលដ្ឋានទាក់ទងទៅនឹងការគ្របដណ្តប់នៃ

តំបន់ភូមិសាស្ត្រ ប្រភេទ និងចំនួនអ្នកទទួលផល កាលវិភាគ -ពេលវេលា និងថវិកា ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីជួយឱ្យមានការយល់ដឹងអំពីចន្លោះប្រហោង និងភាពត្រួតស៊ីគ្នា [១១២]។

ទិន្នន័យមូលដ្ឋាន និងការគ្រប់គ្រងទិន្នន័យមូលដ្ឋាន សម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និង គាំពារសង្គម នឹងត្រូវបានធ្វើសមាហរណកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និង បញ្ចៀសការត្រួតស៊ីគ្នា។

ដើម្បីធានាថា **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បន្តស្ថិតនៅជាឯកសារយោងមួយដែលត្រូវបានប្រើប្រាស់ ដើម្បីកែសម្រួល ទៅលើការអនុវត្តន៍ និងអាទិភាពដោយយោងទៅតាមបទពិសោធន៍ យុទ្ធសាស្ត្រនេះ ទាមទារឱ្យការត្រួតពិនិត្យ និងវាយតម្លៃផ្តល់ព័ត៌មាន អំពីការកែសម្រួលទៅលើការអនុវត្តន៍ជារៀងរាល់ឆ្នាំ។ តារាងខាងក្រោមគូសបញ្ជាក់អំពីជំហានសម្រាប់ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នៅក្នុងវដ្តប្រចាំឆ្នាំមួយ។

<u>រូបភាពទី៣៥</u> ៖ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ-ការត្រួតពិនិត្យ និងវាយតម្លៃ និងអភិក្រមផែនការពង្រីក




## ៧.៣. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសារៈសំខាន់ក្នុងការលើកកម្ពស់ការសម្របសម្រួល និងការត្រួតពិនិត្យ និងវាយតម្លៃទៅលើ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។ ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានបានកាន់តែល្អ នឹងធ្វើឱ្យការភ្ជាប់ទំនាក់ទំនង និងលំហូរព័ត៌មាន រវាងអ្នកពាក់ព័ន្ធ ទាំងអស់កាន់តែមានភាពប្រសើរឡើង។ ព័ត៌មានអំពីស្ថានភាព និងនិន្នាការបច្ចុប្បន្ននៃសន្តិសុខស្បៀង

[១១២] បញ្ជីរាយនាមអំពីកម្មវិធី និងគម្រោងខ្នាតធំដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា ត្រូវបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធ២ នៃយុទ្ធសាស្ត្រនេះ។ បើទោះជាដូច្នេះក្តី បញ្ជីរាយនាមនេះ ត្រូវបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យមួយ ព្រមទាំងត្រូវធ្វើបច្ចុប្បន្នភាពឱ្យបានញឹកញាប់។

និងអាហារូបត្ថម្ភនវានុវត្តន៍ និងមេរៀនបទពិសោធន៍ ព្រមទាំងសមត្ថភាពក្នុងការបង្កើត និងផ្ទេរចំណេះដឹង និងព័ត៌មាន សុទ្ធសឹងតែមានសារៈសំខាន់ ដើម្បីរៀបចំអន្តរាគមន៍ រយៈពេលខ្លី និងរយៈពេលវែងសមស្រប និងប្រកបដោយប្រសិទ្ធភាព សំដៅលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា។

ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលទសវត្សរ៍ចុងក្រោយនេះ។ ផ្អែកលើអនុសាសន៍ដែលទទួលបានពីសិក្ខាសាលាជាតិស្តីពីការគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងឆ្នាំ២០០៦ FSNIMTF ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងលក្ខណៈជាអនុរចនាសម្ព័ន្ធនៃក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីសម្របសម្រួល និងអភិវឌ្ឍន៍ បណ្តាញព័ត៌មានសមាហរណកម្មមួយ ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា។ ក្រុមវិភាគទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភមួយ (FSNDAT) ដែលរួមមានសមាសភាពចូលរួមពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងផែនការ ក្រសួងសុខាភិបាល និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចវិភាគទៅលើស្ថានភាពសន្តិសុខស្បៀងឱ្យបានទៀងទាត់ ដោយផ្អែកលើព័ត៌មានដែលទទួលបានពីស្ថានីយព្យាករណ៍អាកាសធាតុ ស្ថិតិរដ្ឋបាល និងទិន្នន័យថ្មីៗដែលទទួលបានពីការអង្កេតថ្នាក់ជាតិ។ ព្រឹត្តិបត្រព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រចាំត្រីមាសមួយដែលផ្តល់ទិដ្ឋភាពទូទៅជាប្រចាំ អំពីនិន្នាការ និងការគំរាមកំហែងថ្មីៗទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា ត្រូវបានផលិតឡើងដើម្បីចែករំលែកព័ត៌មាន និងផ្តល់ព័ត៌មាន សម្រាប់ការរៀបចំគោលនយោបាយ និងអន្តរាគមន៍នានា ព្រមទាំងឆ្លើយតបទៅនឹងវិបត្តិ [១១៣]។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSNIS) នៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានក្លាយជាច្រកស្វែងរកប្រភពព័ត៌មានតាមអ៊ិនធឺណែតនៅកម្រិតថ្នាក់ជាតិ សម្រាប់ព័ត៌មានទាំងឡាយណាដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា ហើយប្រព័ន្ធនេះ កំពុងផ្តល់ព័ត៌មានដែលត្រូវបានធ្វើបច្ចុប្បន្នភាពញឹកញាប់អំពីព្រឹត្តិការណ៍នានាដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងរួមមានមូលដ្ឋានទិន្នន័យរបស់ឯកសារ និងគម្រោងមួយចំនួន ដែលសុទ្ធសឹងតែមានសារៈប្រយោជន៍។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់វេទិកាជាតិសន្តិសុខស្បៀង ដែលរៀបចំឡើងជាទៀងទាត់ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកម្ម និងជនបទ ចាប់តាំងពីឆ្នាំ២០០៣ ព័ត៌មាន និងទិន្នន័យថ្មីៗអំពីស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងបទពិសោធន៍ និងមេរៀននានា ដែលទទួលបានពីកម្មវិធី ដែលកំពុងអនុវត្ត និងអភិក្រមដែលប្រកបដោយភាពច្នៃប្រឌិត ត្រូវបានចែករំលែក និងពិភាក្សាក្នុងចំណោមក្រសួងតាមវិស័យ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ វេទិកាប្រព្រឹត្តឡើងជារៀងរាល់ត្រីមាស នៅទីស្តីការគណៈរដ្ឋមន្ត្រីនឹងត្រូវបានពង្រីកដើម្បីគ្របដណ្តប់ទៅលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការគាំពារសង្គម។

[១១៣] ព្រឹត្តិបត្រព័ត៌មានត្រូវបានរៀបចំឡើងជាភាសាអង់គ្លេស និងភាសាខ្មែរ ហើយរហូតមកទល់នឹងខែមិថុនា ឆ្នាំ២០១៣ មានព្រឹត្តិបត្រ ចំនួន ១០ច្បាប់ ត្រូវបានផលិត។

បន្ថែមពីនេះទៀត ប្រព័ន្ធ ឬ ឧបករណ៍ផ្សេងៗគ្នា ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានដៃគូអភិវឌ្ឍន៍បង្កើតឡើង ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងតាមវិស័យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការវិភាគ និងការកំណត់ផែនទីព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងត្រូវបានយកមកប្រើប្រាស់សម្រាប់រៀបចំកម្មវិធី ឬ ធ្វើការកំណត់គោលដៅ ៖

- **ផែនទីសន្តិសុខស្បៀងនៅកម្ពុជា** បានផ្តល់ការវិភាគស្ថានភាពមួយនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា ហើយផែនទីនេះត្រូវបានអភិវឌ្ឍន៍ និងធ្វើបច្ចុប្បន្នភាពដោយអង្គការស្បៀងអាហារពិភពលោក (WFP) ក្រោមកិច្ចសហប្រតិបត្តិការជាមួយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងត្រូវបានបញ្ចូលនៅក្នុងវិបសាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- អង្គការ FAO និង WFP ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងពាក់ព័ន្ធ កំពុងរៀបចំប្រើប្រាស់**សមាហរណកម្មការបែងចែកចំណាត់ថ្នាក់ដំណាក់កាលសន្តិសុខស្បៀង(IPC)**ជាឧបករណ៍បទដ្ឋានមួយសម្រាប់ការវិភាគទិន្នន័យមធ្យម និងការបែងចែកចំណាត់ថ្នាក់ស្ថានភាពសន្តិសុខស្បៀង ទៅតាមកម្រិតនៃភាពធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា [១១៤]។
- វិទ្យាស្ថានជាតិស្ថិតិ ដោយមានការគាំទ្រពីអង្គការស្បៀងអាហារពិភពលោក បានធ្វើបច្ចុប្បន្នភាពទៅលើ**ការប៉ាន់ប្រមាណភាពក្រីក្រ និង កង្វះអាហារូបត្ថម្ភកុមារនៅតាមតំបន់តូចៗ** ដោយប្រើប្រាស់ការអង្កេត(CDHS,CSES)និងជំរឿនប្រជាជន។ការសិក្សានេះបានផ្តល់ព័ត៌មានអំពីភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភ នៅកម្រិតមូលដ្ឋាន និងអាចយកមកប្រើប្រាស់សម្រាប់ការកំណត់គោលដៅតាមតំបន់។
- **មូលដ្ឋានទិន្នន័យឃុំ និងមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ ត្រូវបានអភិវឌ្ឍន៍បន្ថែមទៀត**។ មូលដ្ឋានទិន្នន័យទាំងនេះ រួមមានកម្រងសូចនាករពាក់ព័ន្ធអំពីទ្រព្យសម្បត្តិគ្រួសារ ការមាន និងការទទួលបានសេវានានា ព្រមទាំងការផ្លាស់ប្តូរការប្រព្រឹត្ត [១១៥]។
- ក្នុងឆ្នាំ២០១០និងឆ្នាំ២០១១ ដោយមានកិច្ចគាំទ្រពីអង្គការ FAO វិទ្យាស្ថានជាតិស្ថិតិបានធ្វើ**ការវិភាគមួយទៅលើការទទួលទានស្បៀងអាហារ** ដោយផ្អែកលើទិន្នន័យ CSES 2009 ហើយការវិភាគនេះ បានបង្ហាញអំពីនិន្នាការនៅក្នុងការទទួលទានស្បៀងអាហារតាមគ្រួសារចាប់តាំងពី CSES 2004 [១១៦]។

---

[១១៤] ការអនុវត្តន៍សាកល្បងមួយទៅលើ IPCត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជា នៅឆ្នាំ២០០៧ ហើយបច្ចុប្បន្ន សមត្ថភាពក្នុងការអនុវត្តន៍អភិក្រមសម្រាប់បញ្ហាអសន្តិសុខស្បៀងស្រួចស្រាវ និងរ៉ាំរ៉ៃ កំពុងត្រូវបានអភិវឌ្ឍន៍។

[១១៥] បន្ថែមពីនេះទៀត ការសម្របសម្រួលចំពោះបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតថ្នាក់ខេត្ត និងការបញ្ជ្រាបអំពីបញ្ហាដែលមានលក្ខណៈប្រទាក់ក្រឡាគ្នានេះ ទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋាន អាចទទួលបានប្រយោជន៍ពីការប្រើប្រាស់ប្រភពទាំងនេះឱ្យបានទៀងទាត់ ដើម្បីកំណត់អំពីសេចក្តីត្រូវការ និង តាមដានទៅលើដំណើរវឌ្ឍនភាពសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅថ្នាក់ក្រោមជាតិ។

[១១៦] វិទ្យាស្ថានជាតិស្ថិតិ របាយការណ៍វិភាគនិន្នាការសន្តិសុខស្បៀង CSES ២០០៤ និង ២០០៩ ខែតុលា ឆ្នាំ២០១០។ គេនៅតែត្រូវការឱ្យមានការធ្វើសមាហរណកម្មនៃការវិភាគទៅលើការទទួលទានស្បៀងអាហារ សម្រាប់ប្រើប្រាស់ជានីតិវិធីមួយជាប្រចាំ នៅក្នុងការវិភាគ CSESដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងដើម្បីបង្កើតឱ្យមាននូវការយល់ដឹង និងការទទួលយកនូវឧបករណ៍នេះកាន់តែច្រើនជាងនេះបន្ថែមទៀតនៅក្នុងប្រទេសកម្ពុជា។

- ការអង្កេត និងការងារវិភាគទៅលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតគ្រួសារ ត្រូវបានធ្វើឡើងដោយ អង្គការសង្គមស៊ីវិល និងអង្គការស្រាវជ្រាវមួយចំនួន ដូចជា CDRI។

បើទោះបីជាមានសមិទ្ធផលសម្រេចបានគួរឱ្យកត់សម្គាល់ក្នុងការគ្រប់គ្រងចំណេះដឹង និងព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា ក្នុងទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏រាជរដ្ឋាភិបាល នៅតែត្រូវធ្វើការកែលម្អបន្ថែមទៀតទៅលើសង្គតភាពនៃប្រព័ន្ធ និងការងារវិភាគសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និរន្តរភាព និងការប្រើប្រាស់ព័ត៌មានក្នុងលក្ខណៈជាប្រព័ន្ធ ដោយអ្នកធ្វើសេចក្តីសម្រេចចិត្តសម្រាប់រៀបចំអន្តរាគមន៍និងការកែសម្រួលទៅលើគោលនយោបាយ ព្រមទាំងកម្មវិធីនានា។

<u>សកម្មភាពទី៦ ៖</u> ពង្រឹងសមាហរណកម្ម និងការធ្វើសុខដុមនីយកម្មនៃការគ្រប់គ្រងចំណេះដឹង និងព័ត៌មានអំពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជាតាមរយៈការពង្រឹងទំនាក់ទំនងរវាងប្រព័ន្ធ អភិក្រម និងផលិតផលផ្សេងៗគ្នា ដើម្បីបង្ហាញអំពីព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានសង្គតភាព និងត្រូវបានច្របាច់បញ្ចូលគ្នា ជូនដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត។

ការឯកភាពរវាងបណ្តាក្រសួង-ស្ថាប័ននានា និងរចនាសម្ព័ន្ធសម្របសម្រួលការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មាន (ពីស្ថិតិរដ្ឋបាល) និងវប្បធម៌នៃការចែករំលែកព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងចំណោមស្ថាប័ននានា នឹងត្រូវបានលើកកម្ពស់។ ការផ្តួចផ្តើមពីដៃគូអភិវឌ្ឍន៍ ទាក់ទងទៅនឹងព័ត៌មានសន្តិសុខស្បៀង និង អាហារូបត្ថម្ភនឹងទទួលបានការសម្របសម្រួលកាន់តែប្រសើរជាងនេះ ជាមួយក្រុមការងារបច្ចេកទេសគាំពារសង្គមសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងក្រុមការងារអន្តរក្រសួងទទួលបន្ទុកការគ្រប់គ្រងព័ត៌មាន ដើម្បីឱ្យក្លាយជាចំណុចចាប់ផ្តើមមួយ សម្រាប់កិច្ចគាំទ្រចំពោះរាល់គម្រោងទាំងអស់ដែលនឹងមាននៅពេលអនាគត។ ផែនការរយៈពេលមធ្យមមួយដែលគូសបញ្ជាក់អំពីអាទិភាព នឹងត្រូវអភិវឌ្ឍន៍ឡើង ដើម្បីជួយ ធ្វើការបន្សុីកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍន៍នៅក្នុងការងារនេះ។ តួនាទី និងមុខងាររបស់ស្ថាប័នផ្សេងៗគ្នា ដែលពាក់ព័ន្ធនៅក្នុងការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការធ្វើសេចក្តីសម្រេចចិត្ត នឹងត្រូវលើកយកមកធ្វើការពិភាក្សាបន្ថែមទៀត ដើម្បីឱ្យមានការឯកភាពគ្នា [១១៧]។

<u>សកម្មភាពទី៧ ៖</u> ពង្រឹងសមត្ថភាពក្នុងការវិភាគទិន្នន័យដែលទាក់ទងទៅនឹងគាំពារសង្គមសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការធ្វើបទបង្ហាញនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងពាក់ព័ន្ធតាមវិស័យ ព្រមទាំងផ្តល់នូវធនធានដែល អាចព្យាករណ៍ទុកជាមុនបានសម្រាប់ភារកិច្ចនេះ ដើម្បីលើកកម្ពស់និរន្តរភាព។

---

[១១៧] គម្រោង EFAP បានស្នើនៅក្នុងរបាយការណ៍ឱ្យមានការរៀបចំប្រព័ន្ធគ្រប់ជ្រុងជ្រោយមួយសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ ព្រមជាមួយនឹងការជូនដំណឹងជាមុន ទាក់ទងទៅនឹងបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយកំណត់អំពីតួនាទី និងមុខងារ។ បើទោះជាដូច្នេះក្តី សំណើនេះមិនដែលបានទទួលការឯកភាពជាផ្លូវការឡើយ។

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** នឹងដើរតួនាទីកាន់តែសកម្ម នៅក្នុងការវិភាគទិន្នន័យ និងការតាមដាន ជាមួយអ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យ។ សម្រាប់បញ្ហានេះ ក្រុមស្នូលតូចមួយសម្រាប់ធ្វើការវិភាគនិងបង្ហាញព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងត្រូវបានបង្កើតឡើងនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងទទួលបានការលើកកម្ពស់សមត្ថភាពផងដែរ[១១៨]។ សមត្ថភាពសម្រាប់ការគ្រប់គ្រង និង វិភាគទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងបណ្តាក្រសួងពាក់ព័ន្ធ ជាពិសេស គឺក្រុមវិភាគទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនឹងត្រូវបានអភិវឌ្ឍន៍បន្ថែមទៀត តាមរយៈការបណ្តុះបណ្តាល និងការអនុវត្តន៍ការងារផ្ទាល់ [១១៩]។ បន្ថែមពីនេះទៀត ជនបង្គោលថ្នាក់ខេត្តសម្រាប់ទទួលបន្ទុកការងារគ្រប់គ្រងចំណេះដឹង និងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងត្រូវបានកំណត់អត្តសញ្ញាណនិងផ្តល់ការបណ្តុះបណ្តាល។ អាស្រ័យដោយប្រព័ន្ធព័ត៌មាន និងផលិតផលព័ត៌មានមួយចំនួន ដូចជា៖ ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាសអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពឹងផ្អែកទៅលើមូលនិធិដៃគូអភិវឌ្ឍន៍តាមគម្រោង ដូច្នេះ និរន្តរភាពរយៈពេលវែងនៃប្រព័ន្ធ និង ផលិតផលព័ត៌មានទាំងនេះ ត្រូវធានានៅក្នុងក្របខ័ណ្ឌនៃផែនការវិនិយោគសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

សកម្មភាពទី៨ ៖ លើកកម្ពស់ការប្រើប្រាស់ផលិតផលព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់រៀបចំផែនការ និងធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីធ្វើឱ្យប្រសើរឡើង នូវការផ្សព្វផ្សាយព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រាជរដ្ឋាភិបាល ត្រូវលើកកម្ពស់បន្ថែមទៀត នូវការប្រើប្រាស់ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងលក្ខណៈជាឧបករណ៍សម្រាប់ធ្វើការបង្ហាញមួយដ៏សំខាន់ និងពង្រឹងសមត្ថភាពរបស់ក្រុមដែលទទួលបន្ទុកការងាររ៉ុបសាយ[១២០]។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងរៀបចំឱ្យមានការផ្សព្វផ្សាយជាទៀងទាត់នូវព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស អំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជូនដល់អ្នកពាក់ព័ន្ធទាំងអស់ដែលធ្វើការងារនៅក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងប្រទេសកម្ពុជា នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងទម្រង់ជាឯកសារបោះពុម្ព និងតាមរយៈអ៊ីម៉ែល។

---

១១៨ គេត្រូវការឱ្យមាននូវការប៉ាន់ប្រមាណបន្ថែមទៀត ដើម្បីសម្រេចថាតើក្រុមការងារប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានស្រាប់នៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ អាចអនុវត្តការងារនេះបានដែរឬទេ ឬ តម្រូវឱ្យមានការពង្រឹងបន្ថែម។

១១៩ ចន្លោះប្រហោងផ្នែកសមត្ថភាពសម្រាប់ការវិភាគ និងការត្រួតពិនិត្យទៅលើទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ អាចបំពេញតាមរយៈការផ្តួចផ្តើមបណ្តោះអាសន្នពីគម្រោងមួយចំនួនប៉ុណ្ណោះ ប៉ុន្តែបញ្ហានេះ ក៏ត្រូវកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ធនធានមនុស្ស រយៈពេលវែងរបស់ស្ថាប័នដោយឡែកពីគ្នាផងដែរ។

១២០ ការគ្រប់គ្រងមាតិកា តាមរយៈក្រុមការងារប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង ត្រូវមានលក្ខណៈប្រតិសកម្មជាងនេះ ដើម្បីធានាថារាល់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានរក្សាទុកទាន់ពេលវេលានៅក្នុងរ៉ុបសាយ។ អ្នកប្រើប្រាស់ប្រកបដោយសក្តានុពល នឹងត្រូវបានជូនដំណឹងជាទៀងទាត់ អំពីមាតិកាសំខាន់ថ្មីៗតាមរយៈសារអេឡិចត្រូនិក ដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងបន្តធ្វើការកែសម្រួលទៅលើផ្នែកមួយចំនួននៅក្នុងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ អំពីការគ្រប់គ្រងព័ត៌មាន និងទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីប្រើប្រាស់ជាវេទិកាមួយសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃទៅលើ NSFSឱ្យបានកាន់តែប្រសើរ។

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** នឹងបន្តរៀបចំ និងលើកកម្ពស់ការប្រើប្រាស់ទិន្នន័យព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការបង្ហាញព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស ឬ លទ្ធផលអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលទទួលបានពីលំហាត់ IPC នៅក្នុងកិច្ចប្រជុំរបស់វេទិកាជាតិសន្តិសុខស្បៀង និងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស ដើម្បីពិភាក្សា។ រាជរដ្ឋាភិបាលត្រូវអភិវឌ្ឍន៍ឱ្យមាននូវអភិក្រមដែលមានលក្ខណៈផ្លូវការជាងនេះ អំពីការប្រើប្រាស់ព័ត៌មានដែលមាន (ព្រឹត្តិបត្រព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ , IPC ។ល។) ដើម្បីរៀបចំវិធានការឆ្លើយតបទៅនឹងគ្រោះអាសន្ន ក្នុងករណីមានវិបត្តិនៅពេលអនាគត ឬ វិបត្តិស្រួចស្រាវណាមួយ [១២១]។

## ៧.៤. ការអភិវឌ្ឍន៍សមត្ថភាព

ការអនុវត្តន៍**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ប្រកបដោយជោគជ័យ ទាមទារឱ្យមានការពង្រឹងសមត្ថភាពស្ថាប័ននៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (រាប់បញ្ចូលធនធាន និងចំណេះដឹងបច្ចេកទេស) ដើម្បីបន្តអភិវឌ្ឍន៍ ពង្រីក សម្របសម្រួល និងត្រួតពិនិត្យទៅលើសកម្មភាពអាទិភាព ដែលមានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រទូទាំងវិស័យនានា។

សមត្ថភាពក្នុងការវិភាគស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងធ្វើការរៀបចំកំណត់គោលដៅត្រួតពិនិត្យ និងកែសម្រួលកម្មវិធី និងអន្តរាគមន៍ ត្រូវបានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងក្រសួងពាក់ព័ន្ធ ធ្វើការអភិវឌ្ឍន៍រួចទៅហើយក្នុងរយៈពេល៧ឆ្នាំកន្លងមកនេះ។ ក្រុមគ្រូបង្គោលថ្នាក់ជាតិ មួយសម្រាប់ផ្តល់ការបណ្តុះបណ្តាលអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរួមមានសមាសភាពគ្រូបណ្តុះបណ្តាលមកពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ និងរៀបចំជាផ្លូវការក្នុងឆ្នាំ២០១១។ លំហាត់បណ្តុះបណ្តាលជាច្រើនអំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ត្រូវបានអនុវត្តនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការកសាងសមត្ថភាពនៅកម្រិតថ្នាក់ក្រោមជាតិ ក្នុងគោលបំណងបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋាន បានចាប់ផ្តើមនៅខេត្តតាកែវ ហើយថ្មីៗនេះ ត្រូវបានពង្រីកទៅកាន់ខេត្តចំនួន៤បន្ថែមទៀត។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងលំហាត់បណ្តុះបណ្តាលសម្រាប់បុគ្គលិកថ្នាក់ខេត្ត និងថ្នាក់ស្រុក អំពីបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងបានជួយដល់ក្រុមប្រឹក្សាឃុំមួយចំនួន ដែលត្រូវបានជ្រើសរើសឱ្យធ្វើការបញ្ចូលបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យបានកាន់តែប្រសើរ ទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋានរបស់ពួកគេ (ផែនការអភិវឌ្ឍន៍ឃុំនិង ផែនការវិនិយោគឃុំ)។

---

[១២១] គោលបំណងបឋមនៃព្រឹត្តិបត្រព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺដើម្បីបង្ហាញពីនិន្នាការសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ព្រមទាំងផ្តល់ព័ត៌មាន "ជូនដំណឹងជាមុន" អំពីវិបត្តិនានា។ បើទោះជាដូច្នេះក្តី ការចេញផ្សាយរៀងរាល់ត្រីមាស អាចពុំគ្រប់គ្រាន់ឡើយ នៅមានគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ឬ មានការកើនឡើងភ្លាមៗនូវតម្លៃស្បៀងអាហារ ដែលទាមទារឱ្យមានការផ្តល់ព័ត៌មានញឹកញាប់ជាងនេះ (និងមានការបំបែកប្រភេទព័ត៌មានឱ្យបានកាន់តែច្រើនជាងនេះ) ដើម្បីជាព័ត៌មានសម្រាប់ផ្តល់ការឆ្លើយតបនៅពេលមានគ្រោះអាសន្ន។

សកម្មភាពទី៩៖ កែសម្រួលឡើងវិញទៅលើកម្មវិធីបណ្តុះបណ្តាលអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្អែកលើការប៉ាន់ប្រមាណទៅលើផលប៉ះពាល់ និងការពង្រីកការបណ្តុះបណ្តាលនៅកម្រិតថ្នាក់ក្រោមជាតិ តាមរយៈប្រព័ន្ធបណ្តុះបណ្តាលបន្ត។

គ្រូបង្គោលថ្នាក់ជាតិនៃក្រុមគ្រូបង្គោល ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មិនអាចធ្វើការគ្របដណ្តប់គ្រប់ខេត្តទាំងអស់បានឡើយ ដូច្នេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តម្រូវឱ្យមានការរៀបចំអតិក្រមមួយដែលមានភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចខ្ពស់បំផុត ក្នុងការពង្រីកការផ្សព្វផ្សាយ និងការកសាងសមត្ថភាពសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅកម្រិតថ្នាក់ក្រោមជាតិ។ គំរូនៃការបណ្តុះបណ្តាល "បន្ត "ដោយប្រើប្រាស់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្គោលនឹងត្រូវបានយកមកប្រើប្រាស់នៅកម្រិតថ្នាក់ក្រោមជាតិ ហើយលំហាត់បណ្តុះបណ្តាលអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នឹងត្រូវពង្រីកទៅកាន់ខេត្តដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀងខ្ពស់បំផុតឱ្យបានត្រឹមឆ្នាំ២០១៨។ កម្មវិធីបណ្តុះបណ្តាលអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នាពេលបច្ចុប្បន្ន ត្រូវធ្វើការកែសម្រួលឡើងវិញ ដោយផ្អែកលើការប៉ាន់ប្រមាណផលប៉ះពាល់នៃការកសាងសមត្ថភាព។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងរៀបចំអតិក្រមមួយដែលមានលក្ខណៈជាប្រព័ន្ធប្រសើរជាងនេះ ដើម្បីតាមដានទៅលើការផ្ទេរ ចំណេះដឹង និងវាយតម្លៃផលប៉ះពាល់នៃការអភិវឌ្ឍន៍សមត្ថភាព សម្រាប់បញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋាន និងការបណ្តុះបណ្តាលនឹងផ្តោតបន្ថែមទៀតទៅលើការគ្រប់គ្រងវដ្តគម្រោង ដើម្បីអនុញ្ញាតឱ្យអ្នករៀបចំនៅមូលដ្ឋានបង្កើត និងអនុវត្ត និងត្រួតពិនិត្យគម្រោងដែលទាក់ទងនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

សកម្មភាពទី១០ ៖ ភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតថ្នាក់ក្រោមជាតិ ទៅនឹងសមាសធាតុផ្នែកកសាងសមត្ថភាពដែលមានស្រាប់នៅក្នុងបរិបទនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ព្រមទាំងសកម្មភាពផ្សេងៗទៀត ដែលបានមើលឃើញទុកជាមុននៅក្នុងបរិបទនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជានិងកម្មវិធីជាតិដទៃទៀត។

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** ដោយមានការពិភាក្សាជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងអភិវឌ្ឍន៍អតិក្រមមួយដែលមានភាពសក្តិសិទ្ធិ និង មានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច ដើម្បីពង្រីកការផ្សព្វផ្សាយ និងការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតថ្នាក់ក្រោមជាតិ ព្រមទាំងលើកកម្ពស់ការធ្វើសមាហរណកម្មនៃការកសាងសមត្ថភាព សម្រាប់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ (កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍

តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ)។ការបញ្ចូលមាតិកានៃកម្មវិធីសិក្សាអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងកម្មវិធីសិក្សាស្នូលរបស់ក្រុមប្រឹក្សាឃុំ ព្រមទាំងការភ្ជាប់ទំនាក់ទំនង ការកសាងសមត្ថភាពផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាមួយលំហាត់បណ្តុះបណ្តាលអំពីបញ្ហាដទៃទៀតដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា គឺជាវិធីដើម្បីធ្វើឱ្យមានភាពប្រសើរឡើង ចំពោះនិរន្តរភាព និងពង្រីកការបញ្ជ្រាបបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅក្នុងដំណើរការរៀបចំផែនការក្នុងមូលដ្ឋាន។

សមត្ថភាពដែលអាជ្ញាធរមូលដ្ឋានត្រូវមាន ដើម្បីអនុវត្តកម្មវិធីនានា ក្រោមយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានលក្ខណៈស្រដៀងគ្នា។ **យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា**និង**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** សុទ្ធសឹងតែ ស្ថិតក្រោមការសម្របសម្រួលរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ហើយមេរៀនបណ្តុះបណ្តាល និងលំហាត់នានា នឹងត្រូវបានយកមកធ្វើការច្របាច់បញ្ចូលគ្នា ដើម្បីសម្រេចឱ្យបាននូវការរួបរួមកម្លាំងគ្នា និងជៀសវាងកិច្ចខិតខំស្ទួនគ្នា។

<u>សកម្មភាពទី១១ ៖</u> រៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ធនធានមនុស្សដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីលើកកម្ពស់សមត្ថភាពជារួមសម្រាប់ការងារសម្របសម្រួលលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងការឃ្លាំមើលគោលនយោបាយនៅកម្រិតថ្នាក់ជាតិ។

ដើម្បីធានាឱ្យការត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងចំណេះដឹងនិងព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងការអនុវត្តន៍**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**មានប្រសិទ្ធភាព និងមានការសម្របសម្រួលល្អ ចាំបាច់ត្រូវពង្រឹងសមត្ថភាពនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងស្ថាប័នដែលមានអាណត្តិការងារឃ្លាំមើលទៅលើគោលនយោបាយសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងទទួលបានធនធានមនុស្សគ្រប់គ្រាន់ ដើម្បីធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពចំពោះការអនុវត្តន៍ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក៏នឹងបង្កើតផែនការអភិវឌ្ឍន៍ធនធានមនុស្ស រយៈពេលវែងមួយ ដើម្បីបង្កើនសមត្ថភាពអង្គភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភបន្ថែមទៀត នៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។ ដូច្នេះ ដៃគូអភិវឌ្ឍន៍អាចធ្វើការដាក់បញ្ចូលកិច្ចគាំទ្ររបស់ពួកគេ សម្រាប់ការអភិវឌ្ឍន៍សមត្ថភាពផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងលក្ខណៈមួយដែលមានការសម្របសម្រួលប្រសើរជាងមុន និងមិនពឹងផ្អែកទៅលើគម្រោង។ ជនបង្គោលដែលទទួលបន្ទុកការងារសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ នៅក្នុងក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងបានទទួលការគ្របដណ្តប់ស្មើភាពគ្នាក្រោមផែនការនេះ។

## ៧.៥. ការជ្រើសរើសនិងការកំណត់គោលដៅអ្នកទទួលផល

យន្តការកំណត់គោលដៅសមស្រប មានសារៈសំខាន់ខ្លាំងណាស់ ចំពោះការអនុវត្តន៍កម្មវិធី និងអន្តរាគមន៍ ដែលត្រូវបានគូសបញ្ជាក់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ប្រកបដោយភាពសក្តិសិទ្ធិ និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។ រាជរដ្ឋាភិបាលនឹងពិនិត្យទៅលើកម្រងអភិក្រមមួយចំនួន ដើម្បីជ្រើសរើសអ្នកទទួលផលសម្រាប់អន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងគោលបំណងកាត់បន្ថយអសន្តិសុខស្បៀងរ៉ាំរ៉ៃ ឬ អសន្តិសុខស្បៀងស្រួចស្រាវ។ យោងតាមការអន្តរាគមន៍នេះ រាជរដ្ឋាភិបាលផ្តោតទៅលើស្វ័យកំណត់គោលដៅ ការកំណត់គោលដៅទៅតាមប្រភេទ ការកំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រ ឬ ការកំណត់គោលដៅទៅតាមគ្រួសារ ឬ ការច្របាច់បញ្ចូលគ្នានូវគោលការណ៍នៃការកំណត់គោលដៅទាំងនេះ។

ការកំណត់គោលដៅគ្រួសារដើម្បីកាត់បន្ថយភាពក្រីក្រ បានមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ជាពិសេសតាមរយៈការបង្កើនការគ្របដណ្តប់នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID Poor) នៅកម្រិតថ្នាក់ជាតិរបស់ក្រសួងផែនការ។ បញ្ជីរាយនាមគ្រួសារក្រីក្រ ដែលបង្ហាញអំពីស្ថានភាពក្រីក្ររបស់ពួកគេ មានផ្តល់ជូនចំពោះប្រជាពលរដ្ឋកម្ពុជាស្ទើរគ្រប់រូបដែលរស់នៅតំបន់ជនបទ [១២២] ហើយទិន្នន័យនេះ នឹងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ [១២៣]។ ដោយមានការអនុម័តទៅលើអនុក្រឹត្យដោយឡែកពីគ្នាមួយចំនួន ការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាប្រភពទិន្នន័យបឋមសម្រាប់កំណត់គោលដៅគ្រួសារ បានក្លាយជាកាតព្វកិច្ច ដែលតម្រូវឱ្យអនុវត្តតាមយ៉ាងដូច្នេះ ក្នុងឆ្នាំ២០១០។ ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់កំណត់គោលដៅអ្នកទទួលផលពីមូលនិធិសមធម៌សុខភាព ព្រមទាំងត្រូវបានប្រើប្រាស់ដើម្បីកំណត់គោលដៅចែកស្បៀងអាហារដោយឥតគិតថ្លៃ ការផ្ទេរធាតុចូលកសិកម្ម និងគម្រោងស្បៀងពលកម្មនិងសាច់ប្រាក់ពលកម្ម នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីឆ្លើយតបទៅនឹងគ្រោះអាសន្នចំពោះបញ្ហាសន្តិសុខស្បៀង(EFAP,EU-FF,EFAP2) បើទោះជាដូច្នេះក្តី បច្ចុប្បន្ន អត្តសញ្ញាណកម្មគ្រួសារក្រីក្រមិនទាន់បានគ្របដណ្តប់ទៅលើតំបន់ទីក្រុងនៅឡើយ ហើយគេត្រូវការបញ្ចូលបន្ថែម និងដកចេញចំពោះគ្រួសារមួយចំនួន។ និរន្តរភាពហិរញ្ញវត្ថុរយៈពេលវែងនៃប្រព័ន្ធកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅតែត្រូវការឱ្យមានការធានាតាមរយៈការផ្តល់មូលនិធិគាំទ្រពីថវិកាជាតិ ព្រមទាំងថវិកាពីដៃគូអភិវឌ្ឍន៍។បញ្ជីរាយនាមអត្តសញ្ញាណកម្មគ្រួសារក្រីក្រកម្រិត១និងកម្រិត២នឹងត្រូវយកមកប្រើប្រាស់នៅក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**ជាឧបករណ៍ចម្បង សម្រាប់កំណត់គោលដៅគ្រួសារនៃអន្តរាគមន៍សំណាញ់សុវត្ថិភាពដែលផ្តោតលើបញ្ហាសន្តិសុខស្បៀង និងអន្តរាគមន៍ឆ្លើយតបបន្ទាន់។

---

[១២២] លើកលែងតែផ្នែកខ្លះនៃខេត្តកំពង់ចាម និងតំបន់មួយចំនួនដែលស្ថិតនៅជាយរាជធានីភ្នំពេញ។

[១២៣] ចាប់ផ្តើម (នៅឆ្នាំ២០១២) ជាមួយនឹងជុំទី៦ ការអនុវត្តន៍កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នឹងវដ្តរយៈពេល៣ឆ្នាំ។ ខេត្តចំនួន៨ នឹងត្រូវបានគ្របដណ្តប់ក្នុងឆ្នាំនីមួយៗ ដើម្បីឱ្យមានព័ត៌មានបច្ចុប្បន្នភាពសម្រាប់ខេត្តនីមួយៗ រៀងរាល់រយៈពេល៣ឆ្នាំ។

ការកំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រ ផ្តល់អាទិភាពចំពោះតំបន់ (ខេត្ត ស្រុក និងឃុំ/ភូមិ) ដែលមានអត្រាកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀងខ្ពស់ និង/ឬ តំបន់ដែលមានប្រជាពលរដ្ឋជួបប្រទះបញ្ហាអសន្តិសុខស្បៀងច្រើន។ សម្រាប់ការកំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រ គេអាចប្រើប្រាស់ផែនទី កង្វះអាហារូបត្ថម្ភ និងភាពក្រីក្រ ដោយផ្អែកលើការប៉ាន់ប្រមាណទៅតាមតំបន់តូចៗ ដែលទទួលបានពីទិន្នន័យ ជំរឿនឆ្នាំ២០០៨ CAS 2008 CSES 2009 និងទិន្នន័យជំរឿនឆ្នាំ២០១០ [១២៤]។ បន្ថែមពីនេះទៀត ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលបង្ហាញអំពីភាពក្រីក្រនៅកម្រិតផ្សេងៗគ្នា ព្រមទាំងព័ត៌មានពីមូលដ្ឋានទិន្នន័យឃុំ [១២៥] អាចត្រូវបានយកមក ធ្វើការពិគ្រោះសម្រាប់គោលបំណងកំណត់គោលដៅ។ការអនុវត្តន៍IPCដែលជាឧបករណ៍ប្រកបដោយបទដ្ឋានមួយសម្រាប់ធ្វើការវិភាគទិន្នន័យកម្រិតមធ្យម និងបែងចែកចំណាត់ថ្នាក់ស្ថានភាពសន្តិសុខស្បៀង ទៅតាមកម្រិតភាពធ្ងន់ធ្ងរ អាចផ្តល់ការណែនាំសម្រាប់ការកំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រ ហើយនឹងអាចត្រូវបាន បញ្ចូលទៅក្នុងព្រឹត្តិបត្រព័ត៌មានអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការធ្វើសមាហរណកម្ម និងការអនុវត្តន៍ត្រីកោណវិធាននៃឧបករណ៍កំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នា ព្រមទាំងការធ្វើឱ្យប្រសើរឡើង នូវកម្រិតនៃការសម្របសម្រួលរបស់អន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយ ផ្អែកលើព័ត៌មានក្នុងតំបន់នីមួយៗ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីសម្រេចឱ្យបាននូវការគ្របដណ្តប់ទៅលើតំបន់ និងប្រជាពលរដ្ឋដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ឱ្យបានសមស្រប និងមានគុណភាព។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**នឹងអនុវត្តការកំណត់គោលដៅទៅតាម ប្រភេទ សម្រាប់ក្រុមគោលដៅជាក់លាក់នៃប្រជាពលរដ្ឋដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ជាមួយនឹងអន្តរាគមន៍មួយចំនួន (ដូចជា គ្រួសារដែលមានកូនតូច និងម្តាយមានផ្ទៃពោះ គ្រួសារដែលមានដីកសិកម្ម គ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំផ្លិចបំផ្លាញដោយទឹកជំនន់ ឬគ្រោះរាំងស្ងួត។ល។)។ ជាធម្មតា ក្នុងករណីសមស្រប ការកំណត់គោលដៅទៅតាមប្រភេទ រមែងតែងត្រូវបានច្របាច់បញ្ចូលគ្នា ជាមួយកំណត់គោលដៅភាពក្រីក្រ (បញ្ជីរាយនាមអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។ ព័ត៌មានសម្រាប់យន្តការក្រោយពេលកំណត់អត្តសញ្ញាណកម្ម ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ និងកែសម្រួលទៅលើការកំណត់គោលដៅ គ្រួសារក្រីក្រ អាចរកមើលនៅក្នុងមូលដ្ឋានទិន្នន័យ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និង មូលដ្ឋានទិន្នន័យឃុំ ប៉ុន្តែទាមទារឱ្យមានការប្រមូលទិន្នន័យជាក់លាក់មួយចំនួនដូចជាការអង្កេតទៅលើផលប៉ះពាល់នៃគ្រោះមហន្តរាយផងដែរ។

ស្វ័យកំណត់គោលដៅ គឺជាយន្តការកំណត់គោលដៅមួយ ក្នុងចំណោមយន្តការកំណត់គោលដៅនានា ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់បំផុត ដោយកម្មវិធីត្រូវបានរៀបចំឡើងដើម្បីឱ្យមានតែគ្រួសារដែលមានល័ក្ខខ័ណ្ឌសមស្របប៉ុណ្ណោះ ទើបមានបំណងចង់ចូលរួម។ គោលការណ៍កំណត់គោលដៅនេះ នឹងត្រូវបានយកមកអនុវត្ត សម្រាប់គម្រោងសាច់ប្រាក់ពលកម្ម (កម្មវិធីសំណង់សាធារណៈ) ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន តាមរយៈការកំណត់ប្រាក់កម្រៃទៅតាមអត្រាទីផ្សារ

[១២៤] NIS/WFP, ការប៉ាន់ប្រមាណភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភនៅតាមតំបន់តូចៗក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣។
[១២៥] MoP/WFP, ផែនទីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឆ្នាំ២០១៣។

សម្រាប់ការងារពលកម្មគ្មានជំនាញនៅតំបន់ជនបទ។ បន្ថែមពីនេះទៀត ស្វ័យកំណត់គោលដៅអាចយកមកធ្វើការប្រេបាច់បញ្ចូលគ្នា ជាមួយការកំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រ ឬការកំណត់គោលដៅទៅតាមគ្រួសារតាមរយៈប្រព័ន្ធកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

**<u>សកម្មភាពទី១២</u>៖ ធ្វើឱ្យប្រសើរឡើងនូវការកំណត់គោលដៅអន្តរាគមន៍លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈ៖**

- ការអភិវឌ្ឍន៍នីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់ប្រព័ន្ធមួយដែលមានសង្គតភាព សំដៅកំណត់អត្តសញ្ញាណជនក្រីក្រនៅតំបន់ទីក្រុងនិងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង
- ការធ្វើឱ្យប្រសើរឡើងនូវសុក្រឹត្យភាពនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងបន្តកែលម្អនីតិវិធីអនុវត្តរបស់កម្មវិធីនេះ។
- ការធានាឱ្យមានយន្តការផ្តល់ហិរញ្ញប្បទានរយៈពេលវែងមួយ សម្រាប់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(អនុញ្ញាតឱ្យមានការធ្វើបច្ចុប្បន្នភាពជាទៀងទាត់រៀងរាល់៣ឆ្នាំម្តង ទៅលើបញ្ជីរាយនាមគ្រួសារក្រីក្រ នៅក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។
- ការលើកកម្ពស់សមាហរណកម្ម និងឧបករណ៍កំណត់គោលដៅទៅតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នា ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវកម្រិតនៃការសម្របសម្រួលរបស់អន្តរាគមន៍សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្អែកលើព័ត៌មានក្នុងតំបន់។
- ការអភិវឌ្ឍន៍ IPC ក្នុងលក្ខណៈជាប្រព័ន្ធបែងចែកចំណាត់ថ្នាក់មួយប្រកបដោយសង្គតភាពទៅលើបញ្ហាសន្តិសុខស្បៀង និងបញ្ចូលប្រព័ន្ធនេះ ទៅក្នុងព្រឹត្តិបត្រព័ត៌មានប្រចាំ ត្រីមាសអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

## ៧.៦. ជំហានបន្ត ដើម្បីរៀបចំត្រៀមលក្ខណៈអនុវត្តន៍យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**នឹងត្រូវបានចែករំលែកក្នុងទម្រង់ជាឯកសារបោះពុម្ពនិងឯកសារអេឡិចត្រូនិក[១២៦]ហើយនឹងត្រូវផ្សព្វផ្សាយតាមរយៈវេទិកាថ្នាក់ជាតិនិងតំបន់ និងសិក្ខាសាលាតាមវិស័យនានា។ កិច្ចពិភាក្សានៅកម្រិតថ្នាក់ក្រោមជាតិ នឹងបង្កើតឱ្យមានការយល់ដឹងអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ថាជាបញ្ហាមួយដ៏សំខាន់សម្រាប់លើកកម្ពស់ធនធានមនុស្សនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ព្រមទាំងផ្តោតទៅលើកម្មវិធី និងសកម្មភាពអាទិភាពដែលមានភាពពាក់ព័ន្ធបំផុតសម្រាប់ខេត្តផ្សេងៗគ្នា និងស្រុកដែលត្រូវបានជ្រើសរើស។

ការដាក់ឱ្យយុទ្ធសាស្ត្រនេះ មានដំណើរការតាមរយៈកម្មវិធី និងគម្រោងថ្នាក់ជាតិ ត្រូវមានមូលដ្ឋានផ្អែកលើដំណើរការដែលមានការចូលរួមមួយរបស់ប្រទេស ដែលរៀបចំឡើងដោយ

[១២៦] NSFSNនឹងត្រូវបានដាក់នៅក្នុងវិបសាយរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងវិបសាយរបស់ក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ។ ខិត្តប័ណ្ណមួយដែលរួមមានសារសំខាន់ៗអំពី NFSNSនឹងត្រូវបានផលិត និងចែកចាយនៅកម្រិតថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។ **ក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នឹងជំរុញឱ្យមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងបំពេញ ព្រមទាំងកែសម្រួលទៅលើសារពើភ័ណ្ឌនៃអន្តរាគមន៍ដែលកំពុងអនុវត្ត និងអន្តរាគមន៍ដែលគ្រោងអនុវត្ត ទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ឧបសម្ព័ន្ធ២ នៃយុទ្ធសាស្រ្តនេះ)។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងពិភាក្សាដើម្បីស្វែងរកការឯកភាពជាមួយក្រសួងផ្សេងៗគ្នា ទៅលើជំហានបន្ទាប់ ក្នុងនោះរាប់បញ្ចូលសេចក្តីត្រូវការធនធាន ដើម្បីពង្រីកកម្មវិធីដែលមានស្រាប់ ឬ កម្មវិធីថ្មី ព្រមទាំងអនុវត្តសកម្មភាពអាទិភាព ដូចមានគូសបញ្ជាក់នៅក្នុង **យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភ**។ ស្របពេលជាមួយគ្នានេះដែរ គោលការណ៍ណែនាំសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃ និងការគ្រប់គ្រងព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងជំពូកអំពីការអភិវឌ្ឍន៍សមត្ថភាព នឹងត្រូវបញ្ជាក់ឱ្យបានជាក់លាក់បន្ថែមទៀត ហើយសកម្មភាពនានានឹងត្រូវបានយកមករៀបចំឱ្យមានផែនការសកម្មភាពការងារ និងផែនការថវិកា។

ដូចដែលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ក្នុងអំឡុងពេលនៃសិក្ខាសាលាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលបានប្រព្រឹត្តិទៅក្នុងខែឧសភា ឆ្នាំ២០១២ ផែនការសកម្មភាព និងផែនការវិនិយោគមួយទៅលើបញ្ហាអាហារូបត្ថម្ភ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ និងមាតា នឹងត្រូវរៀបចំនៅដើមឆ្នាំ២០១៤ ទូទាំងវិស័យ ដើម្បីបន្តធ្វើប្រតិបត្តិការចំពោះសកម្មភាពអាទិភាពនានា ដែលត្រូវបានគូសបញ្ជាក់សម្រាប់គោលបំណងទី២ នៃ**យុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**។

## ឧបសម្ព័ន្ធ ១ ៖ ក្របខ័ណ្ឌសូចនាករ NSFSN ២០១៤ - ២០១៨

ក្របខ័ណ្ឌសូចនាករនេះ រៀបរាប់អំពីកម្រងសូចនាករ សម្រាប់គោលដៅយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN) គោលបំណងនីមួយៗ នៃគោលបំណងទាំង៣ របស់យុទ្ធសាស្ត្រនេះ ព្រមទាំងការរៀបចំស្ថាប័ន ដើម្បីអនុវត្តន៍។ សូចនាករត្រូវបានបែងចែកជាក្រុមទៅតាមប្រធានបទវេង និង រៀបរាប់អំពីសូចនាករ លទ្ធផលមុនពេលការផ្លាស់ប្តូរការប្រព្រឹត្ត/ ដំណើរការ និងសូចនាករអំពីការផ្តល់សេវាកម្ម។

ក្របខ័ណ្ឌសូចនាករបឋមនេះ រួមមានសូចនាករជាច្រើនដែលត្រូវបានកំណត់រួចទៅហើយនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (SFFSN) ២០០៨-២០១៣ និងពិចារណាផងដែរ ទៅលើសូចនាករដទៃទៀត ស្តីពីអាហារូបត្ថម្ភដែលស្នើឡើងដោយក្រុមការងារដែលបានផ្តល់ធាតុចូលមួយចំនួន អំពីអាហារូបត្ថម្ភសម្រាប់ NSDP ២០១៤-២០១៨ ព្រមទាំងសូចនាករជាក់លាក់ថ្មីៗមួយចំនួន ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង។ ដូចមានកំណត់ នៅក្នុងជំពូកទី៧នៃ NSFSN ក្របខ័ណ្ឌសូចនាករនេះ ត្រូវធ្វើការពង្រឹងបន្ថែមទៀត ហើយការរៀបចំបង្កើត/ការកំណត់គោលដៅ ត្រូវឱ្យមានភាពស្របគ្នា ទៅនឹងសូចនាករថ្មី របស់NSDP ២០១៤-២០១៨។

| សូចនាករ | ស្រប ទៅនឹង | ប្រភព ទិន្នន័យ | មូលដ្ឋាន ទិន្នន័យ[១២៧] | គោលដៅ ឆ្នាំ២០១៤ | គោលដៅ ឆ្នាំ២០១៥[១២៨] | គោលដៅ ឆ្នាំ២០១៦ | គោលដៅ ឆ្នាំ២០១៧ | គោលដៅ ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|---|---|
| **គោលដៅ៖** *ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សម្គាល់ ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្រប ទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់។* | | | | | | | | |
| សូចនាករទូទៅនៃផលប៉ះពាល់របស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (មនុស្សសាស្ត្រ) | | | | | | | | |
| ភាគរយនៃកុមារដែលមានអាយុ ចន្លោះពី 0-៥៩ខែដែល ក្រេះក្រិន មធ្យម ឬ ធ្ងន់ធ្ងរ (កម្ពស់ធៀបនឹងអាយុ < - 2SD ) | NSDP NNS | CDHS | 39.9 2010 | | 24.5 CMDG | | | 25 |

[១២៧] ទិន្នន័យបឋមភាគច្រើនទទួលបានពី CDHS (២០១០) ឬ CSES (ការអង្កេតធំៗ ឆ្នាំ២០០៩ ឬការអង្កេតបន្តបន្ទាប់ទៀតក្នុងឆ្នាំ២០១១) ឬទទួលបានពី ស្ថិតិ រដ្ឋបាល ឆ្នាំ២០១១ ឬ ឆ្នាំ២០១២។ ជានិច្ចកាល ចំណុចយោងបឋមសម្រាប់ទិន្នន័យ CDHS រមែងសំដៅចំពោះ CDHS ឆ្នាំ២០១០។ សម្រាប់ប្រភព ទិន្នន័យដទៃទៀត ឆ្នាំដែលគេសំដៅយោង ត្រូវបានគូសបញ្ជាក់នៅក្រោមរូបភាព។

[១២៨] សម្រាប់សូចនាករដែលត្រូវបានបញ្ចូលនៅក្នុងតារាងសូចនាករស្នូលរបស់ NSDP ២០០៦-២០១០ គោលដៅនៅក្នុង NSFSN សម្រាប់ឆ្នាំ២០១៥ ត្រូវបាន ដាក់បញ្ចូលឱ្យស្របទៅនឹង NSDP/CMDG។ សម្រាប់សូចនាករមួយចំនួន អាចប្រើប្រាស់គោលដៅពីយុទ្ធសាស្ត្រតាមវិស័យ។ បើទោះជាដូច្នេះក្តី គោលដៅ ភាគច្រើនសម្រាប់ឆ្នាំ២០១៨ (ព្រមទាំងសម្រាប់ឆ្នាំ២០១៤ , ២០១៦ , ២០១៧) ត្រូវរៀបចំឱ្យស្របទៅនឹង NSDP ថ្មី ព្រមទាំងគោលដៅតាមវិស័យ ដោយឡែកពីគ្នា។ សម្រាប់សូចនាករដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ គោលដៅដែលត្រូវបានស្នើឡើងនៅក្នុងធាតុចូលសម្រាប់ NSDP ២០១៤-២០១៨ ត្រូវបានប្រើប្រាស់ជាការចង្អុលទិសសម្រាប់ការពិភាក្សាបន្តទៀត។ សូចនាករដែលបង្ហាញអំពីតម្លៃបឋមមួយ (២០១៣ ឬ មុននេះ) ដែលមានភាពប្រសើរជាង គោលដៅ NSDP/CMDG សម្រាប់ឆ្នាំ២០១៥ រួចទៅហើយនោះ ត្រូវបានកំណត់ពណ៌ក្រហម អាស្រ័យដោយគោលដៅសម្រាប់សូចនាករទាំងនេះ សម្រាប់ឆ្នាំ ២០១៥ ត្រូវពិនិត្យកែសម្រួលឡើងវិញ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ភាគរយនៃកុមារដែលមានអាយុចន្លោះពី ០-៥៩ខែដែល មិនគ្រប់ទម្ងន់មធ្យម ឬ ធ្ងន់ធ្ងរ (ទម្ងន់ធៀបនឹងអាយុ < - 2SD ) | NNS | CDHS | 28.3<br>2010 | | 19.2<br>CMDG | | | 19 |
| ភាគរយនៃកុមារដែលមានអាយុចន្លោះពី ០-៥៩ខែដែល ស្គមស្គាំងមធ្យម ឬ ធ្ងន់ធ្ងរ (ទម្ងន់ធៀបនឹងកម្ពស់ < - 2SD ) | NSDP<br>NNS | CDHS | 10.9<br>2010 | 10 | 10.1<br>CMDG | 9 | 8 | 7 |
| ភាគរយនៃស្ត្រីដែលមានអាយុចន្លោះ ពី ១៥-៤៩ឆ្នាំដែលមាន BMI<18.5kg/sq.meter | NNS | CDHS | 19.1 | | 8<br>CMDG | 8 | 7 | 7 |
| សូចនាករទូទៅនៃផលប៉ះពាល់របស់ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (ការទទួលទានចំណីអាហារ) | | | | | | | | |
| សមាមាត្រនៃចំនួនប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រចំណីអាហារ (%) | NSDP | CSES<br>2011 | 3.8 | <5 | <5 | <5 | <5 | <5 |
| ការទទួលទានអាហារជាមធ្យម/Kcal / ក្នុងមួយនាក់ / ក្នុងមួយថ្ងៃ ក្នុងចំណោមក្រុមប្រជាជន ដែលក្រីក្របំផុត | new | CSES | 1690 | | 1886 | 1944 | 2002 | 2060 |
| **<u>គោលបំណងទី១</u>** ៖ *បង្កើនការមានស្បៀង និងការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វដែលកាន់តែមានភាពចម្រុះនិងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើ ប្រកប ដោយនិរន្តរភាពព្រមទាំងពីការងារដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។* | | | | | | | | |
| សូចនាករអំពីភាពក្រីក្ររបស់គ្រួសារ និង លទ្ធភាពក្នុងការទិញ | | | | | | | | |
| កម្រិតនៃភាពក្រីក្រ - គិតជាភាគរយ%នៃចំនួនប្រជាជនសរុប | NSDP | CSES | 18.8<br>(2013) | 17.8 | 16.8 | 15.8 | 14.8 | 13.8 |
| កម្រិតនៃភាពក្រីក្រគិតជាភាគរយ % នៃប្រជាជនដែល រស់នៅជនបទ | NSDP | CSES | 19.7<br>(2013) | 18.7 | 17.7 | 16.7 | 15.7 | 14.7 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| (%) នៃក្រុមប្រជាជនដែលក្រីក្របំផុត នៅក្នុងការទទួលទានចំណីអាហារ ទូទាំងប្រទេស | NSDP | CSES | 8.98 (2011) | | 10 CMDG | | | |
| អសមភាពក្នុងការទទួលទានចំណីអាហារ (Gini Coefficient) | NSDP | CSES | 0.32 (2013) | 0.32 | 0.32 | 0.31 | 0.31 | 0.30 |
| អត្រានៃអតិផរណាតម្លៃចំណីអាហារ (ភាគរយនៃកំណើនCPI ពីមួយឆ្នាំទៅមួយឆ្នាំ) | new | NIS | 6.2% (2013) | <4 | <4 | <4 | <4 | <4 |
| ប្រាក់កម្រៃពិតប្រាកដរបស់ពលករ គ្មានជំនាញ ToT ធៀបទៅនឹងតម្លៃអង្ករលក់រាយនៅជនបទ (គុណភាពទាបបំផុត) | new | NIS MAFF | 10.7 (2013) | <10 | <10 | <10 | <10 | <10 |
| (%) នៃការងារទទួលបានប្រាក់កម្រៃ របស់ស្ត្រីពីវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម | NSDP | | 44, 56, 30 | | 50, 50, 50 | | | |
| សមាមាត្រនៃចំនួនស្ត្រីដែលបានបញ្ចប់ការអប់រំបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលវែង (គិតជា %) | NSDP | MOLVT | | | | | | |
| សូចនាករ | ស្របទៅនឹង | ប្រភពទិន្នន័យ | មូលដ្ឋានទិន្នន័យ | គោលដៅឆ្នាំ២០១៤ | គោលដៅឆ្នាំ២០១៥ | គោលដៅឆ្នាំ២០១៦ | គោលដៅឆ្នាំ២០១៧ | គោលដៅឆ្នាំ២០១៨ |
| សូចនាករអំពីស្បៀងអាហារដែលមាន (ការផលិត) និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព | | | | | | | | |
| NSDP ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | NSDP | MAFF Report | 3.12 (2012/2013) | 3.15 | 3.10 | 3.21 | 3.23 | 3.25 |
| សន្ទស្សន៍ការដំណាំចម្រុះ ភាគរយនៃផ្ទៃដីដាំដុះសរុប | NSDP | MAFF | 31 | 32 | 35 | 35 | 35 | 35 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អតិរេកផលស្រូវប្រចាំឆ្នាំ គិតជាលានតោន | new | MAFF Report | 4.73 (2012/ 2013) | | | | | |
| គម្របព្រៃឈើ - ភាគរយ នៃផ្ទៃដីសរុប | NSDP | MAFF | 58.4 (2010) | 60 | 60 CMDG | 60 | 60 | 60 |
| ចំនួននៃសហគមន៍ព្រៃឈើ | NSDP | MAFF | 453 | 500 | 520 | 550 | 570 | 600 |
| តំបន់សហគមន៍ការពារ | NSDP | MoEYS | 120 | 130 | 140 | 142 | 145 | 150 |
| មធ្យមភាគនៃត្រីដែល មានសម្រាប់ការ ប្រើប្រាស់ ទូទាំងប្រទេសនៅសល់ យ៉ាងហោចណាស់ ត្រឹមកម្រិតឆ្នាំ២០០៧ (៥២,៤គីឡូក្រាម/ ក្នុងមួយនាក់ /ក្នុង មួយឆ្នាំ) | SPF-FiA | MAFF FiA | 52.4 (2007) | 52.4 | 52.4 | 52.4 | 52.4 | 52.4 |
| ក) ផលិតកម្មត្រីនៅតាម វាលស្រែ និង ខ) ផលិតកម្ម វារីវប្បកម្ម មានការកើន ឡើង ១៥% ជារៀងរាល់ឆ្នាំ ដើម្បីឱ្យឈានដល់ ៥០០.០០០ តោន និង ១៨៥.០០០ តោន ក្នុង មួយឆ្នាំ ត្រឹម ឆ្នាំ២០១៩ | SPF-FiA | MAFF Report | 168,000 tons (2011) | 255,507 | 293,833 | 337,908 | 388,594 | 446,883 |
| ចំនួនឡូតិ៍នៃសាទ សហគមន៍ដែលបាន ចុះបញ្ជី និងធ្វើ ប្រតិបត្តិការប្រកប ដោយ ប្រសិទ្ធភាព | SPF-FiA | MAFF. Report | 300 (2011) | 450 | 465 | 480 | 495 | 510 (2018) |
| សូចនាករដទៃទៀតដែលទាក់ទងទៅនឹងគោលបំណងទី១ | | | | | | | | |
| តំបន់ទទួលរងផលប៉ះពាល់ ដែល ត្រូវបានបោសសំអាត មីន និង យុទ្ធភ័ណ្ឌមិនទាន់ ផ្ទុះ (ha) | NSDP | CMAA | 8,708 (2013) | 9,143 | 9,600 | 10,080 | 10,584 | 11,113 |
| ដីសម្បទានសេដ្ឋកិច្ច ដែលបានចែកជូនទៅឱ្យ ប្រជាជនក្រីក្រ | NSDP | MLMUC | | 35,000 | 37000 | 39000 | 41000 | 43,000 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្លង់ដីដែលបានចែកជូនទៅឱ្យកសិករ - ភាគរយនៃផ្ទៃដីកសិកម្មសរុប(%) | NSDP | MLMUC | 28 (2011) | 52 | 57 | 62 | 66 | 70 |
| ផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិភាគតិច | NSDP | MLMUC | | 18 | 28 | 38 | 48 | 58 |
| ផ្លូវជនបទដែលត្រូវបានស្តារ - គីឡូម៉ែត្រ (ក្នុងចំណោមចម្ងាយផ្លូវសរុបចំនួន ៤០.000 គីឡូម៉ែត្រ) | NSDP | MRD | 22750 | 28,600 | 29,450 | 30,300 | 31,150 | 32,000 |
| **គោលបំណងទី២** ៖ ធ្វើឱ្យមានភាពប្រសើរឡើងនូវការប្រើប្រាស់ និង ការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ដល់ការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។ | | | | | | | | |
| វិស័យសុខាភិបាល - ផលប៉ះពាល់នៃអាហារូបត្ថម្ភ និង សូចនាករអំពីលទ្ធផល | | | | | | | | |
| ភាគរយនៃកុមារអាយុចន្លោះពី ៦-៥៦ខែ ដែលមានបញ្ហាស្លេកស្លាំង | NSDP NNS | CDHS, | 55.1 | 44 | 42 (NNS) | 40 | 38 | 36 |
| ភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលមានបញ្ហាស្លេកស្លាំង | NSDP NNS | CDHS | 44.4 | 38 | 36 | 34 | 32 | 30 |
| ភាគរយនៃស្ត្រីមានផ្ទៃពោះដែលមានបញ្ហាស្លេកស្លាំង | NNS HSP | CDHS | 52.7 | 48 | 46 HSP | 44 | 42 | 40 |
| ភាគរយនៃស្ត្រីដែលលើសទំងន់ (BMI>25kg/sq.meter) | new | CDHS | 6 (2010) | <15 | <15 | <15 | <15 | <15 |
| ភាគរយនៃទារកដែលមានអាយុ 0-៦ខែ ដែលត្រូវបានបំបៅដោះតែមួយមុខគត់ | NNS | CDHS | 73.5 | 77 | 78 | 80 | 83 | 84 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ភាគរយនៃម្តាយដែលចាប់ផ្តើមបំបៅដោះ កូនក្នុងរយៈពេល១ម៉ោងក្រោយសម្រាល | NNS | CDHS HMIS | 65.2 | 70 | 71 | 72 | 73 | 74 |
| ភាគរយនៃកុមារអាយុចន្លោះពី ១២-២៥ខែ ដែលត្រូវបាន បំបៅដោះ | new | CDHS | 83.3 | 85 | 86 | 86 | 87 | 87 |
| ភាគរយនៃកុមារអាយុចន្លោះពី ៦-២៣ខែ ដែលបានទទួលអាហារបន្ថែមក្នុងកម្រិតអប្បបរមា ដែលអាចទទួលយកបាន (ត្រូវបានផ្តល់អាហារបន្ថែម ដោយយោង ទៅតាមការអនុវត្តន៍ IYCF ទាំង៣) | NNS | CDHS | 24 | 32 | 36 | 40 | 44 | 48 |
| វិស័យសុខាភិបាល - សូចនាករនៃសេវាអាហារូបត្ថម្ភ | | | | | | | | |
| ចំនួនកុមារខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរដែលបានទទួលការព្យាបាលគ្រប់ជ្រុងជ្រោយ | new | HMIS | 1550 (NNP 2013) | 2500 | 3000 | 9000 | 15000 | 20000 |
| ភាគរយនៃស្ត្រីមកពិនិត្យផ្ទៃពោះមុន សម្រាល ដែលបានទទួលការផ្តល់ប្រឹក្សា អំពីអាហារូបត្ថម្ភ | NNS | CDHS HMIS | 81.5 | 84 | 86 | 88 | 90 | 92 |
| ភាគរយនៃកុមារ(៦-២៣ខែ) ដែលបានទទួល ម្សៅមីក្រូសារធាតុចម្រុះក្នុងរយៈពេល១ខែចុងក្រោយ | new | CDHS HMIS | 1.7 (2010) | 25 | 30 | 35 | 40 | 45 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំនួនភាគរយនៃស្ត្រីសម្រាលកូនរួច ដែលបានទទួល គ្រាប់ថ្នាំជាតិដែកយ៉ាងហោចណាស់ ៤២គ្រាប់ | NNS | HSI | 79 (2012) | 84 | 85 | 85 | 86 | 87 |
| **សូចនាករដែលទាក់ទងទៅនឹងការបញ្ចូលសារធាតុទៅក្នុងចំណីអាហារ អនាម័យ និងបញ្ហាអាហារូបត្ថម្ភដទៃទៀត** | | | | | | | | |
| ភាគរយនៃគ្រួសារដែលប្រើប្រាស់ទឹកត្រី ឬទឹកស៊ីអ៊ីវដែលមានបញ្ចូលជាតិដែក | new | MoP | 15 | 25 | 35 | 45 | 55 | 65 |
| ភាគរយនៃគ្រួសារដែលប្រើប្រាស់ អំបិលអ៊ីយ៉ូដ | NNS | MoP (CDHS) | 82.7 | | 90 CMDG | 90 | 90 | 90 |
| ភាគរយនៃការប្រើប្រាស់ក្នុងស្រុកប្រចាំឆ្នាំ ដែលផ្គត់ផ្គង់ដោយផលិតកម្មទឹកត្រី និង ទឹកស៊ីអ៊ីវក្នុងស្រុកដែលមានបញ្ចូលជាតិដែក | New | MoP | 15 | 30 | 48 | 50 | 52 | 54 |
| ចំនួននៃប្រភេទអាហារសំខាន់ៗនិង គ្រឿងផ្សំដែលមានបទប្បញ្ញត្តិតម្រូវឱ្យបញ្ចូលសារធាតុបន្ថែមជាកំហិត | New | MoP | 1 | 2 | 2 | 3 | 3 | 3 |
| ការអនុវត្តន៍អនាម័យមូលដ្ឋាន(ភាគរយ នៃប្រជាជនដែលរស់នៅជនបទ) | RWSHS | CDHS | | | 30% CMDG | | | |
| ការទទួលបានការផ្គត់ផ្គង់ទឹកស្អាត (ភាគរយប្រជាជននៅតាមជនបទ) | RWSHS NSDP | MRD | 44.2 (2013) | 46.7 | 50 | 53 | 67 | 67 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការទទួលបានអនាម័យ ដែលមានភាព ប្រសើរជាង មុន (ភាគរយនៃប្រជាជន ដែលរស់នៅជនបទ) | RWSHS NSDP | MRD | 37,5 (2013) | 42 | 46 | 50 | 55 | 60 |
| ការចុះឈ្មោះចូលរៀនៈ អនុវិទ្យាល័យ-កុមារី (%) | NSDP | MoEYS | 57.7 (2013) | 60.3 | 66.5 | 73.1 | 80.4 | 85.9 |
| ***<u>គោលបំណងទី៣៖</u>*** *ការធ្វើឱ្យប្រសើរឡើងប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យនិងវិបត្តិនានា ដើម្បីបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀងសម្រាប់គ្រួសារដែល មានបញ្ហាសន្តិសុខស្បៀង។* | | | | | | | | |
| សន្ទស្សន៍នៃការទទួល រងមហន្តរាយ ហានិភ័យ ខ្ទាតពី ០ ទៅ ១០០ | | | 51 | | | | | |
| សូចនាករនៃយុទ្ធសាស្ត្រ សម្រាប់ឆ្លើយតប | WFP | | | | | | | |
| ចំនួនគ្រួសារក្រីក្រដែល ចូលរួមនៅក្នុងកម្មវិធី សំណង់សាធារណៈ(PWP) | NSPS | CARD | TBD | TBD | TBD | TBD | TBD | TBD |
| គ្រួសារមានកូនតូចៗដែល ទទួលបានប្រយោជន៍ពី CCT | NSPS | CARD | TBD | TBD | TBD | TBD | TBD | TBD |
| ចំនួនគ្រួសារជំពាក់បំណុល (ដែលបណ្តាលមកពីវិបត្តិ ផ្សេងៗគ្នាដែលកើតឡើង ស្របពេលជាមួយគ្នា ឬ វិបត្តិផ្ទាល់ខ្លួន) | new | | TBD | TBD | TBD | TBD | TBD | TBD |
| ចំនួនមនុស្សទទួលរងផល ប៉ះពាល់ពីទឹកជំនន់ ដែល ត្រូវការជំនួយស្បៀង អាហារ [១២៩] | | NCDM | TBD | TBD | TBD | TBD | TBD | TBD |
| ចំនួនមនុស្សទទួលរងផល ប៉ះពាល់ពីគ្រោះរាំងស្ងួត ដែលត្រូវការជំនួយស្បៀង អាហារ | | NCDM | TBD | TBD | TBD | TBD | TBD | TBD |

[១២៩] សូចនាករនេះ និងសូចនាករបន្ទាប់ (ដែលសូចនាករទាំងពីរនេះ ដកស្រង់ចេញពី SFFSN) ត្រូវពិភាក្សាឡើងវិញ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ភាគរយនៃតំបន់កសិកម្មដែលមានប្រព័ន្ធធារាសាស្ត្រ | NSDP | MOWRAM | 1,485,130 | 1,515,130 | 1,545,130 | 1,575,130 | 1,605,130 | 1,635,130 |
| **សូចនាករសម្រាប់តាមដានវឌ្ឍនភាព ទាក់ទងទៅនឹងការរៀបចំស្ថាប័ន (សកម្មភាពជាអាទិភាពត្រូវបានកំណត់នៅក្នុងជំពូកទី៧)** | | | | | | | | |
| សារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយមួយអំពីអន្តរាគមន៍ទាក់ទងទៅនឹង FSNដែលមានស្រាប់ និង ដែលបានគ្រោងទុកត្រូវបានអភិវឌ្ឍន៍ | | CARD | | 06/2014 | | | | |
| ប្រព័ន្ធត្រួតពិនិត្យសម្រាប់ NSFSN (ក្របខ័ណ្ឌ សូចនាករដែលត្រូវបានច្របាច់បញ្ចូលគ្នា នីតិវិធី និងយន្តការផ្តល់របាយការណ៍) ត្រូវបានរៀបចំនិងអនុម័ត | | CARD | | 06/2014 | | | | |
| ផែនការសកម្មភាព និងផែនការវិនិយោគទៅលើ អាហារូបត្ថម្ភមួយទូទាំង វិស័យនានា និងផ្អែកលើ អាទិភាពដែលត្រូវបានកំណត់ក្រោមគោលបំណងទី២ នៃ NSFSN ត្រូវបានរៀបចំ និងអនុម័ត | | CARD | | 12/2014 | | | | |
| កម្មវិធីអាហារូបត្ថម្ភតាមសហគមន៍ត្រូវបានរៀបចំ និងទទួលបានមូលនិធិគាំទ្រ សម្រាប់ការអនុវត្តន៍សាកល្បង | | CARD | | 12/2014 | | | | |
| ឧបករណ៍ និងផលិតផលព័ត៌មានដែលមានស្រាប់អំពី FSN(IPC, ព្រឹត្តប័ត្រ FSN ផែនទី FS ត្រូវបាន ក) ធ្វើសមាហរណកម្ម ប្រសើរជាងមុននិង ខ)ធ្វើប្រតិបត្តិការប្រកបដោយនិរន្តរភាព | | CARD | | a) 2014 | | | b) 2017 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ភាគរយនៃកម្មវិធីនិងគម្រោង ដែលទាក់ទងទៅនឹងFSNធ្វើ ឡើងដោយការសម្របសម្រួល (តាមរយៈ TWG SP&FSN) | CARD | TBD | TBD | TBD | TBD | TBD | TBD |
| ផែនការអភិវឌ្ឍន៍ធនធាន មនុស្សមួយ សម្រាប់ CARD និងជនបង្គោល FSN នៅតាម ក្រសួងពាក់ព័ន្ធ ដើម្បីធ្វើឱ្យ ប្រសើរឡើងនូវសមត្ថភាព ដែលទាក់ទង ទៅនឹង FSN ត្រូវបាន ក) រៀបចំ និង អនុម័តយល់ព្រម និង ខ) ត្រូវបានអនុវត្តន៍ | CARD | | a) 2014 | | | b) 2017 | |
| សមត្ថភាពនៅកម្រិតវិមជ្ឈការ សម្រាប់បញ្ជ្រាបបញ្ហា FSN ទៅ ក្នុងដំណើរការរៀបចំ ផែនការនៅថ្នាក់ ក្រោមជាតិ ត្រូវបានលើកកម្ពស់ តាមរយៈ ក) ការបញ្ចូល ប្រធានបទទៅក្នុងកម្មវិធី បណ្តុះបណ្តាលស្នូលរបស់ NCDD សម្រាប់ក្រុមប្រឹក្សា ឃុំ និង ខ) ការអនុវត្តន៍គោល គំនិតបណ្តុះបណ្តាល ដែលត្រូវ បានពិនិត្យ កែសម្រួលនៅក្នុង ខេត្តទាំង៥ ដែលមានបញ្ហា អសន្តិសុខស្បៀងធ្ងន់ធ្ងរបំផុត | CARD<br>NCDD | | a) 2014 | | | b) 2017 | |
| ភាគរយនៃឃុំដែលបានបញ្ចូល សកម្មភាពទាក់ទង ទៅនឹង FSN (សកម្មភាពអាទិភាពមាន រៀបរាប់ នៅក្នុង NSFSN) នៅក្នុង ផែនការអភិវឌ្ឍន៍ ឃុំរបស់ ពួកគេ | NCDD | TBD | TBD | TBD | TBD | TBD | TBD |
| ភាគរយនៃថវិកាឃុំដែល ចំណាយទៅលើសកម្មភាព ដែលទាក់ទងទៅនឹង FSN | NCDD | TBD | TBD | TBD | TBD | TBD | TBD |

## ឧបសម្ព័ន្ធ២៖ ទិដ្ឋភាពទូទៅអំពីកម្មវិធី និងគម្រោងចម្បងៗដែលទាក់ទងទៅនឹង យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា

| | កម្មវិធី ឬ គម្រោង | ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា | ដៃគូអភិវឌ្ឍន៍ដែលផ្តល់ការគាំទ្រ | ខេត្ត | ការប៉ាន់ប្រមាណអ្នកទទួលផល | ក្របខ័ណ្ឌពេលវេលា | ថវិកា |
|---|---|---|---|---|---|---|---|
| គោលបំណងទី១ ៖ គ្រួសារដែលពុំមានសន្តិសុខស្បៀង បង្កើនការមានស្បៀង និងការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និង ការចិញ្ចឹមសត្វដែលកាន់តែមានភាព ចម្រុះនិង ផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងពីការងារដែលពុំមែនជាការងារកសិកម្ម និងឱកាសក្នុងការទទួលបានប្រាក់ចំណូល។ | | | | | | | |
| ១ | គម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហរិញ្ញប្បទានបន្ថែម | MEF | ADB | បន្ទាយមានជ័យ កំពង់ចាម សៀមរាប កំពង់ធំ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រៃវែង ព្រះវិហារ ស្វាយរៀង តាកែវ | អត្ថសញ្ញាណកម្មគ្រួសារក្រីក្រ ១&២ នៅក្នុងឃុំចំនួន ១០០ | ២០១២-២០១៥ | ២៤.៥លានដុល្លារសហរដ្ឋអាមេរិក |
| ២ | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិករខ្នាតតូច នៅជុំវិញបឹងទន្លេសាប | MAFF | ADB | បន្ទាយមានជ័យ កំពង់ចាម សៀមរាប កំពង់ធំ | កសិករខ្នាតតូច នៅក្នុងឃុំចំនួន ១៩៦ | ២០១០-២០១៥ | ៥.៣លានដុល្លារសហរដ្ឋអាមេរិក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | បង្កើនលទ្ធភាពទទួលបានទីផ្សារសម្រាប់ប្រជាជនក្រីក្រ នៅភាគកណ្តាលនៃប្រទេសកម្ពុជា | MOT | ADB | កំពង់ធំ | គ្រួសារនៅក្នុង១១ភូមិជុំវិញរមណីយដ្ឋានប្រាសាទសំបូរព្រៃគុហ៍ | ២០១២-២០១៤ | ១.៩៦លានដុល្លារសហរដ្ឋអាមេរិក |
| ៤ | កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មលើដំណាំស្រូវដែលមានពូជធន់នឹងបម្រែបម្រួលអាកាសធាតុភាព | MEF, MAFF, MIME, MOWRAM | ADB | បាត់ដំបង កំពង់ធំ ព្រៃវែង | គ្រួសាររស់នៅតំបន់គោលដៅគម្រោងខ្សែសង្វាក់តម្លៃស្រូវអង្ករ | ២០១៣-២០១៨ | ៥៥លានដុល្លារសហរដ្ឋអាមេរិក |
| ៥ | គម្រោងកែលំអផ្លូវជនបទ | MRD | ADB | បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ សៀមរាប ពោធិសាត់ | គ្រួសារដែលរស់នៅតាមបណ្តោយផ្លូវជនបទប្រវែង៥០០គីឡូម៉ែត ដែលបានកែលំអ | 2011-2016 | ៣៥លានដុល្លារសហរដ្ឋអាមេរិក |
| ៦ | គម្រោងពង្រឹងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ - សមាសភាគកម្មវិធីបណ្តុះបណ្តាលជំនាញប្រើប្រាស់ប័ណ្ណទូទាត់ | MLVT | ADB | ទាំង២៣ខេត្ត | ប្រហែល២១០,០០០នាក់នៅតាមសហគមន៍ ក្រៅប្រព័ន្ធចូលរួមវគ្គសិក្សាខ្លីស្តីពីកសិកម្ម | ២០១០-២០១៥ | ២៤.៥លានដុល្លារ សហរដ្ឋ អាមេរិក |
| ៧ | ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងទំនាក់ទំនងទីផ្សារ សម្រាប់កសិករខ្នាតតូចនៅក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ | MAFF, MoWA, MoH | EU | ឧត្តរមានជ័យ និង ព្រះវិហារ | ៧,៥០០ គ្រួសារ | ២០១២-២០១៥ | ៤លានអឺរ៉ូ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | គម្រោងសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មនិងពង្រឹងអំណាចសេដ្ឋកិច្ច (PADEE) | MAFF | IFAD and FAO | កំពត កណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ | ១២,៥០០ គ្រួសារ | ២០១២-២០១៨ | ១.៥លាន ដុល្លារសហរដ្ឋអាមេរិក |
| ៩ | ការប្រយុទ្ធប្រឆាំងអនក្ខរកម្មហិរញ្ញវត្ថុក្នុងចំណោមគ្រួសារក្រីក្រនៅជនបទ | MAFF, MoWA and MoH | EU | ឧត្តរមានជ័យ និង ព្រះវិហារ | ៧,៥០០ គ្រួសារ | ២០១២-២០១៥ | ០.៣លាន ដុល្លារសហរដ្ឋអាមេរិក |
| ១០ | ការពង្រឹងសមត្ថភាពបន្សាំនិងភាពធន់ទ្រាំនៃសហគមន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធជម្រាលទឹកខ្នាតតូច ចំពោះការផ្លាស់ប្តូរនិងការប្រែប្រួលអាកាសធាតុ ដើម្បីសម្រេចបានសន្តិសុខស្បៀងប្រកបដោយ និរន្តរភាពនៅប្រទេសកម្ពុជា | MOE | GEF-LDCF | សៀមរាប កំពង់ធំ ព្រះវិហារ និងរតនគិរី | អ្នកទទួលផល ១០,០០០ នាក់ | ២០១៣-២០១៨ | ៥,៦លាន ដុល្លារសហរដ្ឋអាមេរិក |
| ១១ | លើកកម្ពស់បច្ចេកវិទ្យាសមស្របសម្រាប់កសិករ ខ្នាតតូចដើម្បីបង្កើន សន្តិសុខស្បៀងក្នុងចំណោមជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជានិងប្រទេសឡាវ | MAFF | EU | រតនគិរី | ៨០,០០០ | ២០១២-២០១៥ | ១.៩លាន ដុល្លារសហរដ្ឋអាមេរិក |
| ១២ | ពង្រឹងសំឡេងចូលរួមរបស់អង្គការកសិករនៅក្នុងកិច្ចសន្ទនាគោលនយោបាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | MAFF | EU | រតនគិរី | ៩០០ គ្រួសារ | ២០១៣-២០១៥ | ៦៣៨,៤៥៦ ដុល្លារសហរដ្ឋអាមេរិក |
| ១៣ | រក្សាស្តុបទឹក ដើម្បីរក្សាលំនឹងស្បៀងនិង | MAFF, | EU | ឧត្តរមានជ័យ | ៨០០ គ្រួសារ | ២០១២- | ១.២៨លាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | អាហាររូបត្ថម្ភ | MOWRAM | | | | ២០១៥ | ដុល្លារសហរដ្ឋអាមេរិក |
| ១៤ | វិធីសាស្ត្រថ្មីៗសម្រាប់ទប់ទល់នឹងអសន្តិសុខស្បៀងចំពោះប្រជាជនក្រីក្ររស់នៅទីប្រជុំជន និងតំបន់ក្រីក្រជុំវិញខេត្តសៀមរាប ប្រទេសកម្ពុជា | MAFF | EU | សៀមរាប | ១,៨០០ គ្រួសារ | ២០១១-២០១៥ | ១.៣លាន ដុល្លារសហរដ្ឋអាមេរិក |
| ១៥ | សកម្មភាពប្រកបដោយនិរន្តរភាពប្រយុទ្ធនឹងភាពក្រីក្រ ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភនៅក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ | | EU | ឧត្តរមានជ័យ និង សៀមរាប | ៤,០៩៣ គ្រួសារ | ២០១១-២០១៤ | ១.៨លាន ដុល្លារសហរដ្ឋអាមេរិក |
| ១៦ | កាត់បន្ថយអសន្តិសុខស្បៀងរ៉ាំរ៉ៃ និងភាពងាយរងគ្រោះ ចំពោះវិបត្តិភ័យក្នុងចំណោមកសិករជនជាតិដើមភាគតិចក្រីក្រ និងសហគមន៍របស់ពួកគេនៅក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី | MAFF, MOH | EU | មណ្ឌលគិរី & រតនៈគិរី | អ្នកទទួលផលចំនួន ៥,២២៤នាក់ | ២០១១-២០១៤ | ១.០៥លាន ដុល្លារសហរដ្ឋអាមេរិក |
| ១៧ | លើកកម្ពស់កំណើនរួមនិងនិរន្តរភាពនៅក្នុងវិស័យកសិកម្ម ជលផលនិងការសត្វចិញ្ចឹម | MAFF | EU | ទូទាំងប្រទេស | | ២០១៤-២០១៨ | ២០លានអឺរ៉ូ |
| ១៨ | ការអនុវត្តន៍ផែនការមនុស្សធម៌-សម្រាប់ឆ្លើយតបទៅនឹងខ្យល់ព្យុះ Wutip និងNari | | EU ( ECHO ) | ខេត្តរងផលប៉ះពាល់ | | ២០១៤ | ៣លានអឺរ៉ូ |
| ១៩ | DIPECHO HIP អាស៊ីអាគ្នេយ៍-២០១៤ | | EU ( ECHO ) | មិនបញ្ជាក់ | | ២០១៤-២០១៥ | ០.៥លាន អឺរ៉ូ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **<u>គោលបំណងទី២</u> ៖ ប្រជាពលរដ្ឋកម្ពុជាធ្វើឱ្យមានភាពប្រសើរឡើងចំពោះការប្រើប្រាស់ និងការបឺតស្រូបស្បៀងអាហារ របស់ពួកគេ ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ដល់ការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ច។** | | | | | | | |
| ១ | ការអនុវត្តអនុក្រឹត្យ លេខ១៣៣ ស្តីពីការធ្វើទីផ្សារផលិតផលអាហារបំប៉ន | NNP/NMCHC/ MoH | WHO-UNICEF | ទូទាំងប្រទេស | គ្រប់កុមារទាំងអស់ | ២០១៤-២០១៥ | គ្មាន |
| ២ | ការអភិវឌ្ឍផែនការសកម្មភាពវិនិយោគអាហារូបត្ថម្ភជាតិសម្រាប់ក្រសួងសុខាភិបាល (យោងតាមផែនទីបង្ហាញផ្លូវសម្រាប់អាហារូបត្ថម្ភ២០១៤-២០២០) | NNP/NMCHC/ MoH | UNICEF | ទូទាំងប្រទេស | គ្រប់ប្រជាជនទាំងអស់ ដោយផ្តោតលើកុមារ និងស្ត្រី | ២០១៤-២០១៥ | គ្មាន |
| ៣ | កម្មវិធីសុខភាព និងអាហារូបត្ថម្ភកុមារ និងមាតា (MCHN) ផ្តល់ដែលមានលាយបញ្ចូលមីក្រូសារជាតិដល់កុមារអាយុ ៦-២៣ ខែនិងស្ត្រីមានផ្ទៃពោះ / ស្ត្រីបំបៅដោះកូន (១០០០ ថ្ងៃ) និងការអប់រំសុខភាព និងអាហារូបត្ថម្ភ | MoH | WFP (ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា) | ពោធិ៍សាត់ និងសៀមរាប | កុមារអាយុក្រោម២ឆ្នាំ ចំនួន១១,០០០ នាក់ និងស្ត្រីមានផ្ទៃពោះ/ស្ត្រីបំបៅដោះកូនក្នុងមួយខែ | កក្កដា ២០១១-មិថុនា ២០១៦ | ១.៥លានដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំ |
| ៤ | ការគ្រប់គ្រងបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ - ការព្យាបាលកុមារអាយុ ៦-៥៩ ខែ ដែលបានរកឃើញថាមានបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវកម្រិតមធ្យម តាមរយៈការផ្តល់អាហារដែលបញ្ចូលមីក្រូសារជាតិ | MoH/PHD | WFP | កំពង់ស្ពឺ | កុមារអាយុ ៦ -៥៩ ខែ ចំនួន ៣៥០នាក់ ក្នុងមួយខែ | ធ្នូ ២០១០-មិថុនា ២០១៦ | មើលខាងលើ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យជនបទលើកទី២ | MED | ADB | កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ | ប្រជាជនចំនួន ៣៧៧,០០០ នាក់ មានលទ្ធភាពទទួលបានទឹកមានសុវត្ថិភាព , ២៩០,០០០ នាក់ ទទួលបាន អនាម័យប្រសើរឡើង | ២០១០-២០១៥ | ២១លានដុល្លារសហរដ្ឋអាមេរិក |
| ៦ | គម្រោងត្រួតពិនិត្យជំងឺឆ្លងក្នុងមហាអនុតំបន់ទន្លេមេគង្គលើកទី២ (អន្តរាគមន៍អនាម័យក្រោមសមាសភាគភូមិឃុំស្អាតគំរូ) | MoH | ADB | ភូមិចំនួន ៩០ ក្នុងស្រុកចំនួន ១៨ នៅតាមព្រំដែន | គ្រួសារចំនួន៥,៤០០ : (៦០ ក្នុងមួយភូមិ) មានលទ្ធភាពទទួលបាននូវអនាម័យប្រសើរឡើង | ២០១៤-២០១៥ | គ្មាន |
| ៧ | ការគ្រប់គ្រងបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរនៅកម្រិតមន្ទីរពេទ្យ | NNP/NMCHC/ MoH | UNICEF | មន្ទីរពេទ្យចំនួន ៣៥ នៅក្នុងខេត្តចំនួន២៥ | ពិនិត្យពីបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរគ្រប់កុមារទាំងអស់ | ២០១៤-២០១៨ | គ្មាន |
| ៨ | ពង្រីកការចែកចាយនៃម្សៅមីក្រូសារជាតិចិញ្ចឹមដល់កុមារអាយុចន្លោះពី ៦-២៤ ខែ | NNP/NMCHC/ MoH | UNICEF/HKI/W VC | កម្រិតជាតិ | គ្រប់កុមារទាំងអស់ អាយុចន្លោះ ៦-២៣,៩ ខែ | ២០១៤-២០១៨ | គ្មាន |
| ៩ | អនុវត្តយុទ្ធនាការផ្តល់អាហារដល់ទារកនិងកុមារតូចៗ | NNP/NMCHC/ MoH | UNICEF | កម្រិតជាតិ | គ្រប់កុមារទាំងអស់ អាយុចន្លោះ ៦-២៣,៩ ខែ | ២០១៤-២០១៨ | គ្មាន |
| ១០ | គាំទ្រគំនិតផ្តួចផ្តើមការបញ្ចូលមីក្រូសារជាតិនៅកម្ពុជា | NSCFF/NCIDD /MOP/MOH | RACHA/UNICEF | កម្រិតជាតិ | ប្រជាជនទូទាំងប្រទេស | ២០១៤-២០១៨ | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១ | គាំទ្រគំនិតផ្តួចផ្តើមពង្រីកអាហារូបត្ថម្ភនៅកម្ពុជា | CARD | ទីភ្នាក់ងារ UN | កម្រិតជាតិ | ប្រជាជនទូទាំងប្រទេស | ២០១៤-២០១៨ | គ្មាន |
| ១២ | ការចែកចាយថ្នាំគ្រាប់ជាតិដែកដល់ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូន | MOH | | | | | |
| ១៣ | ការចែកចាយថ្នាំគ្រាប់វីតាមីន A ដល់កុមារអាយុ៦-៥៩ ខែ (២ដងក្នុងមួយឆ្នាំ) | MOH | | | | | |
| ១៤ | ការចែកចាយ Mebendazole ជារៀងរាល់ ៦ ខែសម្រាប់កុមារអាយុ ៦-៥៩ ខែ | MOH | | | | | |
| **<u>គោលបំណងទី៣៖</u> ការធ្វើឱ្យប្រសើរឡើងប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងវិបត្តិនានា ដើម្បីបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង សម្រាប់គ្រួសារដែល មានបញ្ហាសន្តិសុខស្បៀង។** | | | | | | | |
| ១ | កម្មវិធីផ្តល់អាហារតាមសាលារៀននៅសាលាបឋមសិក្សានិងមត្តេយ្យ | MoEYS | WFP | បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប កំពង់ធំ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រៃវែង ព្រះវិហារ ស្ទឹងត្រែង | កុមារចំនួន ៣៩០,០០០ ក្នុង ២០% នៃសាលាបឋមសិក្សានិង មុនបឋមសិក្សាដែលមានទីតាំងស្ថិតនៅជាមួយគ្នា ក្នុងមួយឆ្នាំសិក្សា | កក្កដា ២០១១-មិថុនា ២០១៦ | ១០លានដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | កម្មវិធីអាហារូបករណ៍ (អាហារ ឬសាច់ប្រាក់) សម្រាប់សិស្សក្រីក្រនៅតាមសាលាបឋមសិក្សា | MoEYS | WFP | បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប កំពង់ធំ ឧត្តរមានជ័យ កំពង់ស្ពឺ ព្រៃវែង ព្រះវិហារ ក្រចេះ ស្ទឹងត្រែង ស្វាយរៀង | កុមារចំនួន ៩៦.៥០០ នាក់ (និងគ្រួសាររបស់ពួកគេ) ក្នុង៦២% នៃសាលាបឋមសិក្សាក្នុងមួយឆ្នាំសិក្សា | កក្កដា ២០១១- មិថុនា ២០១៦ | ៩លានដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំ |
| ៣ | កម្មវិធីគាំពារទ្រព្យសម្រាប់ផលិតភាព និងទ្រទ្រង់ជីវភាពរស់នៅ(PALS) | MRD/NCDD /provincial administration | WFP | កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ សៀមរាប កំពង់ធំ ព្រៃវែង ស្វាយរៀង | គ្រួសារមានបញ្ហាអសន្តិសុខស្បៀងនៅតាមជនបទ ចំនួន ១៤,០០០ ក្នុងមួយឆ្នាំ | កក្កដា ២០១១- មិថុនា ២០១៦ | ១.៩លានដុល្លារសហរដ្ឋអាមេរិក |
| ៤ | ជំនួយសង្គ្រោះបន្ទាន់ដើម្បីស្តារជីវភាពរបស់គ្រួសារកសិករងាយរងគ្រោះដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅក្នុងខេត្តបន្ទាយមានជ័យនិងខេត្តបាត់ដំបង | MAFF (GDA) and NCDM | FAO | បន្ទាយមានជ័យ និងបាត់ដំបង | គ្រួសារកសិករ ចំនួន ៧០០០ សម្រាប់ការដាំដុះស្រូវនិង គ្រួសារចំនួន៤៥០០ សម្រាប់ការដាំដុះបន្លែ | ២០១៣- ២០១៤ | ០.៥លានដុល្លារសហរដ្ឋអាមេរិក |